

# កម្រងឯកសារសំណួរ_ចម្លើយ

# ទាក់ទងនឹងរដ្ឋធម្មនុញ្ញ

រៀបចំចងក្រងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

ខែ សីហា ឆ្នាំ២០១១

# អារម្ភកថា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នមួយដែលមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព និងដោះស្រាយវិវាទដែលកើតចេញពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា ។

ក្រៅពីបំពេញការងារនៅក្នុងស្ថាប័ន ក្រុមប្រឹក្សាធម្មនុញ្ញបានចាត់តាំងគណៈប្រតិភូចុះបំពេញបេសកកម្មតាមក្រសួង-ស្ថាប័ន គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ សាលាគរុកោសល្យ សាលារាជធានី និងនៅគ្រប់ខេត្តទាំង ២៣ ជូនមន្ត្រីរាជការ សិស្ស និស្សិត និងប្រជាជនបានចំនួន ៩៦ លើក ដើម្បីផ្សព្វផ្សាយអំពីខ្លឹមសាររដ្ឋធម្មនុញ្ញ និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយចែកសៀវភៅរដ្ឋធម្មនុញ្ញគ្រប់ៗគ្នា ។ នៅគ្រប់ពេលផ្សព្វផ្សាយមួយលើកៗ ក្រុមប្រឹក្សាធម្មនុញ្ញ បានបញ្ចូលក្នុងរបៀបវារៈនូវសំណួរ-ចម្លើយ និងមានអ្នកចូលរួមសរសេរលើកជាសំណួរចម្ងល់បានច្រើននាក់ ហើយម្នាក់ៗបានសួរជាច្រើនចំណុចទៀតផង ។ សំណួរទាំងអស់ដែលបានលើកឡើងត្រូវបាន ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និង សមាជិក សមាជិកា ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្លើយបំភ្លឺ និងពន្យល់យ៉ាងក្បោះក្បាយ ដោយផ្អែកលើមូលដ្ឋានគតិយុត្ត។

ដោយយល់ឃើញខ្លឹមសាររបស់សំណួរ-ចម្លើយទាំងអស់នេះ ជាចំណែកមួយទៀតនៃពុទ្ធិគតិយុត្តទើបអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ប្រមូលចងក្រងដោយរៀបជាលំដាប់ទៅតាមផ្នែក (បុព្វកថា ជំពូកនានា ឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ ...) ញ៉ាំងឱ្យងាយស្រួលក្នុងការអាន ឬស្រាវជ្រាវ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីខ្លឹមសារនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទ ១៩ ខែ សីហា ឆ្នាំ២០១១

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

# មាតិកា

**ទំព័រ**

- ពាក់ព័ន្ធនឹងបុព្វកថា និង ឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ ........ ១
- ពាក់ព័ន្ធនឹងច្បាប់ធម្មនុញ្ញបន្ថែម ........ ២
- ពាក់ព័ន្ធនឹងជំពូកទី ១ : អំពីអធិបតេយ្យ ........ ៣
- ពាក់ព័ន្ធនឹងជំពូកទី ២ : អំពីព្រះមហាក្សត្រ ........ ៥
- ពាក់ព័ន្ធនឹងជំពូកទី ៣ : អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ........ ១៤
- ពាក់ព័ន្ធនឹងជំពូកទី ៤ : អំពីរបបនយោបាយ ........ ១៨
- ពាក់ព័ន្ធនឹងជំពូកទី ៥ : អំពីសេដ្ឋកិច្ច ........ ២១
- ពាក់ព័ន្ធនឹងជំពូកទី ៦ : អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច ........ ២៥
- ពាក់ព័ន្ធនឹងជំពូកទី ៧ : អំពីរដ្ឋសភា ........ ២៧
- ពាក់ព័ន្ធនឹងជំពូកទី ៨ ថ្មី : អំពីព្រឹទ្ធសភា ........ ៣២
- ពាក់ព័ន្ធនឹងជំពូកទី ១០ ថ្មី : អំពីរាជរដ្ឋាភិបាល ........ ៣៥
- ពាក់ព័ន្ធនឹងជំពូកទី ១១ ថ្មី : អំពីអំណាចតុលាការ ........ ៣៧
- ពាក់ព័ន្ធនឹងជំពូកទី ១២ ថ្មី : អំពីក្រុមប្រឹក្សាធម្មនុញ្ញ ........ ៤៣
- ពាក់ព័ន្ធនឹងជំពូកទី ១៣ ថ្មី : អំពីការគ្រប់គ្រងរដ្ឋបាល ........ ៦៧
- ពាក់ព័ន្ធនឹងជំពូកទី ១៤ ថ្មី : អំពីសមាជជាតិ ........ ៦៨
- ពាក់ព័ន្ធនឹងជំពូកទី ១៥ ថ្មី : អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ ........ ៧០
- ពាក់ព័ន្ធនឹងជំពូកទី ១៦ ថ្មី : អំពីអន្តរប្បញ្ញត្តិ ........ ៧៧
- ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ ........ ៧៨

# កម្រង

## សំណួរ-ចម្លើយ

## ក្នុងពេលគណៈប្រតិភូក្រុមប្រឹក្សាធម្មនុញ្ញ ចុះផ្សព្វផ្សាយអំពីខ្លឹមសាររដ្ឋធម្មនុញ្ញ និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នៅតាមក្រសួង គ្រឹះស្ថានសិក្សាសាធារណៈ រាជធានី និង ខេត្ត

## ពាក់ព័ន្ធនឹងបុព្វកថា នៃរដ្ឋធម្មនុញ្ញ

***សំណួរ : តើបុព្វកថានៃរដ្ឋធម្មនុញ្ញ មានអត្ថន័យគតិយុត្តយ៉ាងដូចម្ដេច ?***

ចម្លើយ : បុព្វកថានៃរដ្ឋធម្មនុញ្ញ មិនមែនជាបទប្បញ្ញត្តិ ឬ ជាអត្ថបទច្បាប់ទេ គ្រាន់តែជាការលើកឡើងអំពីប្រវត្តិសាស្ត្រ វប្បធម៌ អរិយធម៌អតីតកាលខ្លះ បញ្ជាក់ហេតុការណ៍ធំៗដែលបានកើតឡើង និង ជាពិសេសចុងក្រោយដៅគោលបំណង ក្នុងឆន្ទៈដ៏មោះមុតរបស់ប្រជារាស្ត្រខ្មែរភាគច្រើន ។ បុព្វកថា គឺជាអត្ថបទប្រមូលផ្ដុំខ្លឹមសារធំៗនៅក្នុងរដ្ឋធម្មនុញ្ញ ។ សៀវភៅរបស់លោក **ម៉ូរីស ហ្គាយ៉ា** (Maurice Gaillard) បានសរសេរថា " បុព្វកថា គ្រាន់តែជាការបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរចង់បានរដ្ឋធម្មនុញ្ញមួយដែលមានខ្លឹមសារដូចតទៅ " ។ ដូច្នេះ បុព្វកថា មានតម្លៃគតិយុត្ត តែតម្លៃគតិយុត្តមិនដូចមាត្រានានានៅក្នុងរដ្ឋធម្មនុញ្ញទេ ។

## ពាក់ព័ន្ធនឹងឧបសម្ព័ន្ធ នៃរដ្ឋធម្មនុញ្ញ

***សំណួរ : នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញបានដាក់ឧបសម្ព័ន្ធមាន ៥ តើឧបសម្ព័ន្ធមានន័យដូចម្ដេច ? ចូរពន្យល់ ?***

ចម្លើយ : ឧបសម្ព័ន្ធ គឺអ្វីដែលគេមិនបានសរសេរក្នុងមាត្រា ហើយគេយោងទៅឧបសម្ព័ន្ធនៅខាងក្រោយវិញ ដោយសារខ្លឹមសារវែង ឧទាហរណ៍ ភ្លេងជាតិ សញ្ញាជាតិ សច្ចាប្រណិធានជាដើម ។

***សំណួរ : តើ "សច្ចាប្រណិធាន" ស៊ីជម្រៅកម្រិតណា ដល់ឆន្ទៈ និង ទស្សនៈបុគ្គល ទើបបុគ្គលក្នុងសង្គមខ្មែរនៅ តែប្រព្រឹត្តិអំពើពុករលួយ ?***

ចម្លើយ : ប្រទេសណាក៏គេស្បថដែរ អ្នកកាន់សាសនាគ្រិស្តក៏ស្បថ អ៊ីស្លាមក៏ស្បថ ហិណ្ឌូក៏ស្បថ ព្រះពុទ្ធសាសនាក៏ស្បថ នេះជាជំនឿ ។

# ពាក់ព័ន្ធនឹងច្បាប់ធម្មនុញ្ញបន្ថែម

***សំណួរ : តើរដ្ឋធម្មនុញ្ញជំនួសមានន័យដូចម្តេច?***

ចម្លើយ : រដ្ឋធម្មនុញ្ញជំនួសមិនមានទេ។ ប្រហែលអ្នកសួរច្រឡំរឿងរដ្ឋធម្មនុញ្ញបន្ថែមទេ។ កាលនោះនៅឆ្នាំ២០០៤ មានការជាប់គាំងនយោបាយ រហូតដល់មានកិច្ចព្រមព្រៀងរវាងគណបក្សនយោបាយដែលឈ្នះឆ្នោតឈានទៅរកការបង្កើតច្បាប់ធម្មនុញ្ញបន្ថែម ដែលសព្វថ្ងៃនេះក្លាយទៅជាច្បាប់រដ្ឋធម្មនុញ្ញពេញលក្ខណៈហើយ ។

***សំណួរ : តើខុសគ្នាត្រង់ណាររវាងមតិភាគច្រើនដោយប្រៀប មាត្រា ១០០ថ្មី និងមតិភាគច្រើនដាច់ខាតនៃមាត្រា ៦ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម ។***

ចម្លើយ : -មតិភាគច្រើន គឺសំឡេងបោះឆ្នោតដែលយកជាបានការទៅតាមករណី ករណីខ្លះច្បាប់តម្រូវថា ទាល់តែមានសំឡេងភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល (**Majorité absolue**) ។ ឧទាហរណ៍ សមាជិកមាន ៥០នាក់ ដើម្បីឱ្យបានសំឡេងជាប់ឆ្នោត ទាល់តែយក ៥០ ចែកនឹង ២ ឬ ពាក់កណ្តាលនៃ ៥០ បូក ១ ។

-មតិភាគច្រើនដោយប្រៀប (**Majorité Simple** ឬ **relative**) គឺមិនគិតចំនួនលើសពីពាក់កណ្តាលនៃសមាជិកទាំងមូលទេ ។ ឧទាហរណ៍ សមាជិកចូលរួមប្រជុំ ៤៥នាក់ អ្នកទី១បាន ២១សំឡេង អ្នកទី២បាន ២០សំឡេង បានន័យថា អ្នកទី១ជាប់ឆ្នោតហើយដោយប្រៀបទៅនឹងចំនួនវត្តមានទាំងអស់។

***សំណួរ : តើរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែមដូចគ្នាឬទេ ? តើច្បាប់ធម្មនុញ្ញបន្ថែម ជាវិសោធនកម្មរដ្ឋធម្មនុញ្ញឬទេ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែម គឺជារដ្ឋធម្មនុញ្ញ ។ ច្បាប់ធម្មនុញ្ញបន្ថែម មិនមែនជាវិសោធនកម្មរដ្ឋធម្មនុញ្ញទេ ។

***សំណួរ : តើការបោះឆ្នោតកញ្ចប់ដែលបង្កើតរដ្ឋាភិបាលអាណត្តិទី៣ បានរំលោភលើរដ្ឋធម្មនុញ្ញ និង លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សដែរឬទេ ?***

ចម្លើយ : សំណួរនេះកើតនៅឆ្នាំ២០០៤ តាមពិតធ្វើនីតិវិធីបោះឆ្នោតបង្កើតក្បាលម៉ាស៊ីនរដ្ឋសភាអាណត្តិទី៣ បោះឆ្នោតផ្តល់សេចក្តីទុកចិត្តរាជរដ្ឋាភិបាលអាណត្តិទី៣ គឺធ្វើទៅតាមច្បាប់ធម្មនុញ្ញបន្ថែមទាំងអស់ ច្បាប់ធម្មនុញ្ញបន្ថែមនេះវាជារដ្ឋធម្មនុញ្ញបន្ថែម។ ដូច្នេះមិនមានរឿងអ្វីទៅរំលោភលើរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនោះទេ ។

***សំណួរ : ហេតុអ្វីបានជាមានច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ?***

ចម្លើយ : នេះគឺចូលដល់រឿងវិបត្តិជាប់គាំងនយោបាយ ក្រោយការបោះឆ្នោតសាកលឆ្នាំ២០០៣ ។វិបត្តិនយោបាយកាលនោះ គឺកើតចេញមកពីភាពមិនទុកចិត្តគ្នាទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ជាមួយនឹងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល ។

# ពាក់ព័ន្ធនឹងជំពូកទី ១
## អំពីអធិបតេយ្យ

***សំណួរ : ហេតុអ្វីបានជាមាត្រា ២ មិនប្រកាសអំពីផ្ទៃក្រឡាពិតប្រាកដរបស់បូរណភាពប្រទេសយើង យើងសង្ឃឹម ថាថ្ងៃក្រោយយើងអាចចំណេញឬទេ បើប្រទេសជិតខាងគេចង់បានឱ្យប្រទេសគេធំទូលាយដែរ ?***

ចម្លើយ : សូមជម្រាបថា មកដល់ថ្ងៃនេះ ម៉ោងនេះ យើងស្រាវជ្រាវមិនទាន់ឃើញថា មានឯកសារផ្លូវការណាមួយដែលថា ផ្ទៃក្រឡាព្រះរាជាណាចក្រកម្ពុជាមានប៉ុន្មានគីឡូម៉ែត្រក្រឡានោះទេ ។ យើងដឹងតាមរយៈសៀវភៅសិក្សា និងសៀវភៅខ្លះទៀត ប៉ុន្តែការសរសេរមិនឯកភាពគ្នាទេ។ ផ្ទៃក្រឡា ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ដែលយើងដឹង គឺដោយសារយើងរៀនអំពីភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលគ្រូគាត់សរសេរ អ្នកដែលសរសេរមុនគេ គឺលោក តាន់ គឹមហួន ប្រធានសភាសម័យសាធារណរដ្ឋខ្មែរ ហើយសួរថា លេខហ្នឹងគាត់បានមកពីណា អត់ដឹងច្បាស់ទេ។ ព្រះករុណាសម្តេចឪ ប្រើក្នុងការបោះពុម្ពផ្សាយសៀវភៅមួយឈ្មោះថា **La Monarchie Cambodgienne et la Croisade Royale pour l`Indépendance** ហើយខ្ញុំមានឯកសារជាលាយលក្ខណ៍អក្សរ លោកសរសេរត្រឹមតែ ១៨១.000 គីឡូម៉ែត្រក្រឡា។ តាមឯកឧត្តម សុខ អាន ប្រាប់ថា ផ្ទៃក្រឡា ១៨១.០៣៥ គីឡូម៉ែត្រក្រឡានេះ បើតាមអ្នកធ្វើព្រំដែនដែលគាត់រកឃើញថា ជាក្រដាសកត់ត្រាមួយសន្លឹករបស់អគ្គទេសាភិបាលឥណ្ឌូចិនសរសេរថា ផ្ទៃក្រឡាប្រទេសកម្ពុជាមាន ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ដល់ទៅរកមើលឯកសារផ្លូវការរបស់បារាំងអត់មាននិយាយទាំងអស់ អ៊ីចឹងលេខនេះមិនទាន់ជាលេខពិតប្រាកដទេ ។ ដល់ពេលធ្វើព្រំដែនហើយ ខាត ឬ ចំណេញ យើងអត់ទាន់ហ៊ាននិយាយទេ គ្រាន់តែសុំធ្វើយ៉ាងណាឱ្យត្រឹមត្រូវតាមផែនទី ជាមួយវៀតណាម គឺផែនទី ១/១០០.000 ជាមួយថៃ គឺផ្អែកលើកិច្ចព្រមព្រៀងឆ្នាំ១៩០៤ សន្ធិសញ្ញាឆ្នាំ១៩០៧ សន្ធិសញ្ញាឆ្នាំ១៩២៥ និងមានសន្ធិសញ្ញាបន្តបន្ទាប់មកទៀត ។

***សំណួរ : ជំពូកទី១ មាត្រា ២ បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានដាច់ខាតក្នុងព្រំដែន របស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.000 ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបាន ទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ ។ បច្ចុប្បន្នសៀមមិនទទួលស្គាល់សន្ធិសញ្ញាអន្តរជាតិ ចុះហត្ថលេខាបារាំង-សៀមលើផែនទីនៅឆ្នាំណា ?***

ចម្លើយ : រឿងសន្ធិសញ្ញាអន្តរជាតិបារាំង-សៀម គឺជាច្បាប់អន្តរជាតិមួយ ទាំងអង្គការសហប្រជាជាតិ ទាំងតុលាការអន្តរជាតិទីក្រុងឡាអេ គេទទួលស្គាល់ ពិសេសកិច្ចព្រមព្រៀងនិងការគូសបន្ទាត់ព្រំដែនឆ្នាំ១៩០៤ និង ១៩០៧ ប៉ុន្តែកិច្ចព្រមព្រៀងហ្នឹងសៀមខ្លួនឯងក៏មានតម្កល់ទុកក្នុងព្រះរាជបណ្ណាល័យ បារាំងគេទុកក្នុងសារមន្ទីររបស់បារាំង សៀមរេទៅណាអត់រួចទេ ព្រោះស្តេចសៀមទទួលស្គាល់បូរណភាពទឹកដី ហើយព្រមបោះបង្គោលជាមួយ

បារាំង ។ រឿងដែលសៀមឈឺចាប់ពីឆ្នាំ១៩០៧មក គឺវាបាត់បង់ខេត្តដែលត្រូវប្រគល់ឱ្យខ្មែរវិញមាន ខេត្តបាត់ដំបង ស៊ីសុផុន សៀមរាប និង ស្ទឹងត្រែង កាលហ្នឹងអត់ទាន់មានខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារទេ គឺជាខេត្តខ្មែរ ដែលស្ថិតនៅខាងជើងខ្សែស្របទី១៥ ទាំងប៉ុន្មានសៀមយល់ព្រមទទួលស្គាល់ថាជាទឹកដីរបស់ខ្មែរ ប៉ុន្តែទឹកដីរបស់ខ្មែរពេលនោះក្រោមឈ្មោះឥណ្ឌូចិនបារាំង ។

***សំណួរៈ** បច្ចុប្បន្នយើងកំពុងតែមានបញ្ហាជាមួយសៀម ដោយកម្ពុជាយកផែនទីឆ្នាំ១៩០៤-១៩០៧ ជាផែនទី ស្របច្បាប់ ដែលផែនទីនេះកើតឡើងរវាងបារាំង-សៀម ដែលត្រូវបានអន្តរជាតិទទួលស្គាល់ ។ ហេតុអ្វីបានជានៅ ក្នុងជំពូកទី១ មាត្រា ២ បានចែងថា បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុង ព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវ បានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ វិញ ?*

ចម្លើយ ៖ សូមជម្រាបថា អ្វីដែលវាច្បាស់លាស់ហើយយើងអត់សរសេរទេ អឺចឹង ព្រំដែនខាងលិច គឺច្បាស់លាស់ហើយ បញ្ហាដែលនៅមិនទាន់ច្បាស់លាស់ គឺព្រំដែនខាងកើត ពេលនោះបារាំងធ្វើម្នាក់ឯង ហើយបារាំងធ្វើផែនទីនេះ គឺងាយស្រួលក្នុងការយកពន្ធ ។ កន្លែងណាដែលមន្ត្រីអាណានិគមប្រមូលពន្ធបានច្រើនបារាំងគេឱ្យរង្វាន់ បើកន្លែងណាប្រមូលពន្ធមិនបានតាមផែនការ បារាំងដកចោល រហូតដល់ដកចៅហ្វាយខេត្តខ្មែរលើកោះត្រល់ដែលមិនព្រមទៅប្រមូលពន្ធ ។ កាលហ្នឹង អគ្គទេសាភិបាលបារាំងឈ្មោះ ប្រេវីយេ បានគូសផែនទីមួយកាត់កោះត្រល់ឱ្យវៀតណាមទៅទារពន្ធ ហើយក្លាយទៅជាកោះមួយសម្បូរធនធានរបស់វៀតណាម ។ អឺចឹងផែនទីខ្នាត ១/១០០.០០០ ហ្នឹង បារាំងជាអ្នកគូស ។

***សំណួរៈ** ជំពូកទី១ មាត្រា៥ ភាសា និង អក្សរ ដែលប្រើជាផ្លូវការ គឺភាសា និង អក្សរខ្មែរ ។ (សួរថា ហេតុអ្វីមិនចែងថា ភាសា និង អក្សរ ដែលប្រើជាផ្លូវការ គឺជាភាសា និង អក្សរកម្ពុជា) ។*

ចម្លើយ ៖ តាមពិតកម្ពុជា និង ខ្មែរ បកស្រាយទៅវាអាចមានន័យល្បៀងគ្នាដែរ ។ យើងប្រើពាក្យខ្មែរ គឺមានន័យថា ជនជាតិយើង គឺជាជនជាតិដែលរលាយសាច់មួយ អ៊ីស្លាមក៏យើងហៅខ្មែរអ៊ីស្លាម ខ្មែរលើ ខ្មែរក្រោមក៏យើងហៅខ្មែរ ។

# ពាក់ព័ន្ធនឹងជំពូកទី ២
# អំពីព្រះមហាក្សត្រ

***សំណួរ : បើច្បាប់ដែលព្រះមហាក្សត្រមិនព្រមឡាយព្រះហស្តលេខា តើច្បាប់នោះអាចយកទៅអនុវត្តបានដែរឬទេ ?***

ចម្លើយ : ឥតមានព្រះហស្តលេខា និង ព្រះរាជលញ្ចកររបស់ព្រះមហាក្សត្រ ធ្វើម្ដេចអាចប្រើបាន ពីព្រោះពាក្យថា ច្បាប់ត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម។ ព្រះមហាក្សត្រព្រះអង្គឡាយព្រះហស្តលេខាលើព្រះរាជក្រម បើព្រះអង្គមិនឡាយផង ធ្វើម៉េចទៅជាច្បាប់បាន ។ ប៉ុន្តែករណីបែបនេះមិនមានទេ ពីព្រោះព្រះមហាក្សត្រកម្ពុជាព្រះអង្គពុំមានព្រះរាជសិទ្ធិវ៉េតូ (veto) ទេ ។

***សំណួរ : ព្រះមហាក្សត្រមិនកាន់អំណាចទេ ចុះហេតុអ្វីឱ្យព្រះមហាក្សត្រធានាសិទ្ធិសេរីភាព និង ឯករាជជូនប្រជាជន ?***

ចម្លើយ : ពីព្រោះព្រះអង្គមានព្រះរាជតួនាទីសំខាន់ ជាពិសេសធ្វើសំណើមកក្រុមប្រឹក្សាធម្មនុញ្ញមួយៗសុទ្ធតែខ្លឹម ព្រោះទាក់ទងនឹងការធានាសិទ្ធិសេរីភាព និង ឯករាជជូនប្រជាជន។

***សំណួរ : តើព្រះមហាក្សត្រមានអំណាចពិតប្រាកដយ៉ាងណា ដើម្បីអាចធានាការគោរពសន្ធិសញ្ញាអន្តរជាតិបាន?***

ចម្លើយ : ចំពោះការធានាការគោរពសន្ធិសញ្ញាអន្តរជាតិ ព្រះអង្គមានព្រះរាជភារកិច្ចឡាយព្រះហស្តលេខាប្រទានសច្ចាប័ន ពីព្រោះព្រះអង្គជាព្រះប្រមុខរដ្ឋ ។ ប៉ុន្តែបើមានចំណុចណាដែលព្រះអង្គសង្ស័យ ទ្រង់អាចធ្វើសំណើមកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីសុំពិនិត្យធម្មនុញ្ញភាពបាន ។

***សំណួរ : តើព្រះមហាក្សត្រអាចបន្ធូរបន្ថយទោស ឬ លើកលែងទោសឱ្យមេដឹកនាំខ្មែរក្រហមបានដែរឬទេក្រោយ ពីការកាត់ទោស ?***

ចម្លើយ : មិនទាន់មានចម្លើយទេ ទាល់តែចាំមើលទាំងអស់គ្នា ។ យើងទាំងអស់គ្នានៅទីនេះប្រហែលទទួលរងគ្រោះពីរបបនោះទាំងអស់គ្នាហើយ ដូច្នេះយើងចាំមើលទាំងអស់គ្នា តើមានអ្វីកើតឡើង ។

***សំណួរ : ហេតុដូចម្ដេចបានជារដ្ឋសភាឆ្នាំ១៩៩៣ នាំគ្នាតែងច្បាប់ចងព្រះមហាក្សត្រឱ្យទ្រង់សោយរាជ្យ ហើយមិន កាន់អំណាច ?***

ចម្លើយ : ចំណុចនេះខ្ញុំសូមជម្រាបថា ពេលដែលសភាធម្មនុញ្ញតាក់តែងរដ្ឋធម្មនុញ្ញពេលនោះ គឺយើងមិនមាននិយាយអំពីថា តើប្រទេសជាតិត្រូវប្រកាន់យករបបគ្រប់គ្រងណាមួយនៅឡើយទេ ទើបគណៈប្រតិភូសភាធម្មនុញ្ញបានទៅគាល់ ព្រះមហាក្សត្រ **នរោត្តម សីហនុ** នៅទីក្រុងព្យុងយ៉ាង សាធារណរដ្ឋប្រជាមា-

និតប្រជាធិបតេយ្យកូរ៉េ ។ ក្នុងនាមរូបខ្ញុំជាសមាជិកបម្រុងនៅពេលនោះ គណៈកម្មការសរសេររដ្ឋធម្មនុញ្ញមិនទាន់មានសរសេរចំណុចស្ដីពីប្រមុខរដ្ឋទេ ដោយចំណុចនេះរង់ចាំបន្ទាប់ពីមានការចូលគាល់ព្រះមហាក្សត្រ ។ យើងទាំងអស់គ្នាពេលនោះចាំតែទទួលព្រះរាជអត្ថបទពីព្រះមហាក្សត្រ ដែលអត្ថបទនោះព្រះអង្គបានរៀបរៀងជាភាសាបារាំងជាស្រេច ទើបរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានចែងពីចំណុចព្រះប្រមុខរដ្ឋនេះឡើង យើងគោរពទៅតាមព្រះរាជតម្រិះរបស់ព្រះអង្គ ។

***សំណួរ : ក្នុងជំពូកទី២ មាត្រា ៧ ចែងថា ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ តែមិនកាន់អំណាចឡើយ... ។ តែនៅក្នុងមាត្រា ២៣ ចែងថាទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ហើយអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។ សំណួរសួរថា ហេតុអ្វីបានជាមាត្រាទាំងពីរចែងថា ទ្រង់មិនកាន់អំណាច តែជាមេបញ្ជាការកំពូល និង អគ្គមេបញ្ជាការបញ្ជាកងយោធពលខេមរភូមិន្ទទាំងមូល ? សូមឯកឧត្តមជួយស្រាយបំភ្លឺ ?***

ចម្លើយ : ទ្រង់គង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ហើយអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ ។ ក្នុងតួនាទីនេះ ដោយសារព្រះមហាក្សត្រមានព្រះរាជតួនាទី និង ភារកិច្ច យោងតាមមាត្រា ៨ នៃរដ្ឋធម្មនុញ្ញ " ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។" ទ្រង់មិនកាន់អំណាច ប៉ុន្តែទ្រង់មានតួនាទីមួយកំពូលចំពោះបូរណភាពទឹកដី ។ មិនកាន់អំណាចផ្នែករដ្ឋបាល ប៉ុន្តែ ទ្រង់ជានិមិត្តរូបឯកភាពជាតិទាំងមូល ។

***សំណួរ : មាត្រា ២៣ តើព្រះមហាក្សត្រ ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទក្នុងពេលណា ?***

ចម្លើយ : ឱ្យតែព្រះអង្គនៅគ្រងរាជសម្បត្តិ គឺព្រះអង្គទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។

***សំណួរ : ក្នុងជំពូកទី២ មាត្រា ៧ ចែងថា ព្រះមហាក្សត្រមិនអាចមានអ្នកណារំលោភបំពានបានឡើយ ។ សួរថា នៅពេលដែលព្រះមហាក្សត្រប្រព្រឹត្តខុសច្បាប់ក្នុងករណីណាមួយ តើមានអំណាចណាមួយដែលអាចដោះស្រាយ បញ្ហានេះ ឬ ក៏ទ្រង់មិនមានទោសកំហុសអ្វីទាំងអស់ ?***

ចម្លើយ : ក្នុងពេលព្រះអង្គទ្រង់គង់ជាព្រះមហាក្សត្រ គឺមិនកាន់អំណាចឡើយ ព្រះអង្គទ្រង់មិនអាចលូកដៃចូលអំណាចណាមួយឡើយ ។ ក្នុងនាមជាព្រះមហាក្សត្រ គឺជាប្រមុខរដ្ឋ ដូចប្រធានាធិបតីបារាំង ដូចប្រធានាធិបតីអាមេរិកដែរ គឺមិនអាចមានជនណាមួយមកស្ដីបន្ទោសតំណាងរដ្ឋបានឡើយ ។

*សំណួរ : យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ពីសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ ប៉ុន្តែបើពិនិត្យមើលលើ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ បានចែងពីសិទ្ធិ នៃព្រះមហាក្សត្រទៅវិញ សូមជួយបកស្រាយ ?*

ចម្លើយ : អំពីព្រះមហាក្សត្រ ក្នុងរដ្ឋធម្មនុញ្ញ មាត្រា ៧ ចែងថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនមានអំណាចឡើយ ។ ដូច្នេះ ទ្រង់គ្មានអំណាចទេ គឺព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ ។ ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ អធិបតេយ្យ និងបូរណភាពទឹកដី ។

*សំណួរ : តាមប្រសាសន៍របស់លោកជំទាវ បានលើកឡើងនូវមាត្រា៨ ក្នុងជំពូកទី២ អំពីព្រះមហាក្សត្រ បានបង្ហាញថា ព្រះមហាក្សត្រជាអ្នកធានារដ្ឋធម្មនុញ្ញ យោងមាត្រានេះ ហេតុអ្វីព្រះមហាក្សត្រជាអ្នកធានានូវរដ្ឋធម្មនុញ្ញ ?*

ចម្លើយ : ភ្ជាប់តាមចំលើយខាងលើ ព្រះមហាក្សត្រ ទ្រង់ធានាការគោរពសិទ្ធិរបស់ពលរដ្ឋ ធានា ឯករាជ អធិបតេយ្យ និងបូរណភាពទឹកដី ។ ដូច្នេះព្រះមហាក្សត្រទ្រង់ធានារដ្ឋធម្មនុញ្ញដែរ ។

*សំណួរ : មាត្រា ១០០ មាត្រា ១៣៤ មាត្រា ១៣៧ ព្រះមហាក្សត្រមានព្រះរាជបុព្វសិទ្ធិតែងតាំង ។ មាត្រា ១០០ តែងតាំងសមាជិកព្រឹទ្ធសភា ០២រូប មាត្រា ១៣៤ថ្មី តែងតាំងព្រះរាជតំណាងរបស់ព្រះអង្គចំនួន ០១រូប និង មាត្រា ១៣៧ថ្មី តែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន ០៣រូប ។ តើព្រះមហាក្សត្រមានព្រះរាជសិទ្ធិ ឡាយព្រះហស្តលេខាបដិសេធចំពោះច្បាប់ដែលបានអនុម័តចប់ដោយរដ្ឋសភា និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ហើយដែរឬទេ ?*

ចម្លើយ : តាមស្មារតីរដ្ឋធម្មនុញ្ញ កាលណានីតិវិធីឆ្លងកាត់សភាទាំងពីរចប់សព្វគ្រប់ហើយ បានដាក់ថ្វាយព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា ព្រះអង្គឡាយព្រះហស្តលេខាហើយ មិនដែលមានការបដិសេធទេ ។ មិនដូចប្រធានាធិបតីសហរដ្ឋអាមេរិកទេ ។ សូមបញ្ជាក់ឱ្យច្បាស់ត្រង់ចំណុចនេះ ។

*សំណួរ : សូមឯកឧត្តម លោកជំទាវ ជួយបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ជាពិសេសកថាខ័ណ្ឌទី២ បានចែងថា ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត ?*

ចម្លើយ : ត្រង់នេះដូចជាច្បាស់លាស់ហើយ មានន័យថា រដ្ឋធម្មនុញ្ញថ្វាយសិទ្ធិដល់ព្រះមហាក្សត្រយើង គឺលោកអាចគ្រងរាជសម្បត្តិរហូតដល់ព្រះអង្គសោយទិវង្គត ច្បាប់គោល គឺអ៊ីចឹង ។ តែមានច្បាប់មួយទៀតស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ក្នុងច្បាប់នោះបានចែងថា ព្រះមហាក្សត្រមានព្រះរាជសិទ្ធិចូលនិវត្តន៍ ច្បាប់បានចែងច្បាស់ហើយ ។

***សំណួរ*** : *មាត្រា ៧ ចែងថា "អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ" ។ តើមានការដាក់ទោសដែរឬទេ បើមានបុគ្គលណាម្នាក់រំលោភបំពានប៉ះពាល់ដល់ព្រះមហាក្សត្រ ? ឧទាហរណ៍ ព្រះមហាក្សត្រព្រះអង្គបានប្រទានគោរម្យងារដល់សម្ដេចទាំងបី រួមមានសម្ដេច **ជា ស៊ីម** សម្ដេច **ហេង សំរិន** និង សម្ដេច **ហ៊ុន សែន** ប៉ុន្តែខ្ញុំតែងសង្កេតឃើញគណបក្សប្រឆាំងតែងប្រើពាក្យហៅសម្ដេចទាំងបីថា "លោក" ។ តើអ្នកទាំងនោះមានទោសដែរឬទេ ? តើរំលោភបំពានដល់ព្រះមហាក្សត្រដែរឬទេ ?*

ចម្លើយ : នៅក្នុងក្រមព្រហ្មទណ្ឌថ្មីបានចែងហើយអំពីទោសទណ្ឌដែលបំពានលើព្រះមហាក្សត្រ ។ អត់មានដាក់ទោសអ្នកហៅសម្ដេចទាំងបីថា "លោក" ទេ ។ នេះជាសិទ្ធិសេរីភាពរបស់គេ ព្រោះយើងមិនទាន់មានច្បាប់ស្តីពីគោរម្យងារទេ ។

***សំណួរ*** : *បើព្រះមហាក្សត្រទ្រង់មិនកាន់អំណាច ហេតុអ្វីបានជាទ្រង់មានអំណាចតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ?*

ចម្លើយ : កុំច្រឡំពាក្យ "អំណាច" ។ អំណាចមួយជាអំណាចនយោបាយ ។ អំណាចតែងតាំងនេះ គឺរដ្ឋធម្មនុញ្ញប្រគល់ថ្វាយព្រះអង្គ ។ អំណាចនយោបាយ សំដៅលើអំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ព្រះមហាក្សត្រមានអំណាច ប៉ុន្តែអំណាចកំណត់ដោយរដ្ឋធម្មនុញ្ញ (ពាក្យបារាំងថា Pouvoiz lié) ។

***សំណួរ*** : *បើយោងតាមមាត្រា ២៦ថ្មី តើព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាដែរឬទេ បើគ្មានការពិនិត្យ ធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញ ?*

ចម្លើយ : ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីអំពីអ្វីមួយ ។ ព្រះមហាក្សត្រ ទ្រង់អាចស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ឬសន្ធិសញ្ញាទាំងឡាយណាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ ។

***សំណួរ*** : *សូមពន្យល់មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ។*

ចម្លើយ : មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ចែងថា "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស ។" តាមធម្មតាស្រុកណាក៏ដោយ គឺប្រមុខរដ្ឋតែងមានសិទ្ធិលើកលែងទោស ឬ បន្ធូរបន្ថយទោស ប៉ុន្តែការលើកលែង ឬ បន្ធូរបន្ថយទោសនេះអនុវត្តតាមច្បាប់ ពុំមែនចេះតែធ្វើបាននោះទេ ។ ជាគោលការណ៍ គឺមេគុកនោះនឹងធ្វើរបាយការណ៍ពីរយៈពេលជាប់ទោស និង ការកែប្រែខ្លួន មុនពេលមានការលើកលែងទោស ឬ បន្ធូរបន្ថយទោសដល់នរណាម្នាក់ ហើយផ្ញើមកថ្នាក់លើតាមឋានានុក្រម មុនពេលថ្វាយដល់ព្រះមហាក្សត្រ ដើម្បីលើកលែង ឬ បន្ធូរបន្ថយទោសនេះ គឺត្រូវមាននីតិវិធីត្រឹមត្រូវស្របតាមច្បាប់ ។

*សំណួរ ៖ មាត្រា ២៧ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និង លើកលែងទោស ។ ប៉ុន្តែហេតុអ្វី បានជាការអនុវត្តជាក់ស្តែង ប្រសិនបើគ្មានការស្នើពីនាយករដ្ឋមន្ត្រី ការលើកលែងទោសមិនអាចប្រព្រឹត្តទៅកើត ។ (នាយករដ្ឋមន្ត្រីធ្លាប់ប្រកាសពីរឿងនេះដែរ ថាបើគ្មានការស្នើពីនាយករដ្ឋមន្ត្រីគឺមិនអាចធ្វើកើត) ។*

ចម្លើយ ៖ នេះជានីតិវិធីនៃការចេញព្រះរាជក្រឹត្យនៃការលើកលែងទោស និង បន្ធូរបន្ថយទោស ។ ទ្រង់គោរពតាមច្បាប់ ។

*សំណួរ ៖ សូមឯកឧត្តមមេត្តាបកស្រាយមាត្រា ២៧ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស ឬ លើកលែងទោស ។ តើការលើកលែងទោសនេះមានករណីពិសេសអ្វីខ្លះ ? (ចំពោះករណីចារបុរសសៀម) ។*

ចម្លើយ ៖ រឿងហ្នឹងមាននីតិវិធីរបស់គេនៅតុលាការផង និង រាជរដ្ឋាភិបាលផង ។

*សំណួរ ៖ នៅមាត្រា ២៧ ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និង លើកលែងទោស សួរថា លើកលែងទោសតែអ្នកនយោបាយ ឬ លើកលែងទោសចំពោះប្រជាពលរដ្ឋក្រីក្រដែរឬទេ ?*

ចម្លើយ ៖ មិនថា អ្នកនយោបាយ ឬ អ្នកក្រីក្រទេ ព្រោះសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។

*សំណួរ ៖ តើនីតិវិធីនៃការសុំបន្ធូរបន្ថយទោសដំណើរការយ៉ាងដូចម្តេច?*

ចម្លើយ ៖ នីតិវិធីនេះ ត្រូវនិយាយចាប់ពីសំណើសុំរបស់ប្រធានពន្ធនាគារ មកក្រសួងយុត្តិធម៌ និងពីក្រសួងយុត្តិធម៌ស្នើទៅនាយករដ្ឋមន្ត្រី បន្ទាប់មកនាយករដ្ឋមន្ត្រីទូលថ្វាយព្រះមហាក្សត្រ ដើម្បីសុំបន្ធូរបន្ថយទោសទៅតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងច្បាប់ ។

*សំណួរ ៖ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជជាតិ អធិបតេយ្យ និង បូរណភាពទឹកដី... ។ តើឱ្យព្រះអង្គធានា យ៉ាងដូចម្តេចទៅបើព្រះអង្គគ្មានព្រះរាជអំណាចផងនោះ ? បើអំណាចស្ថិតនៅក្នុងដៃរបស់រាជរដ្ឋាភិបាល ? បើអ៊ីចឹង វាមិនផ្ទុយនឹងអ្វីដែលរដ្ឋធម្មនុញ្ញបានចែងទៅហើយទេឬ ?*

ចម្លើយ ៖ ហ្នឹងហើយជារបបប្រជាធិបតេយ្យ សេរីពហុបក្ស និង របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ខុសគ្នាពីរបបរាជានិយមផ្តាច់ការ ។ រាជានិយមយើងនេះ មិនខុសគ្នាពីរាជានិយមនៅថៃ ម៉ាឡេស៊ី ជប៉ុន អេស្ប៉ាញ អង់គ្លេសទេ ។

*សំណួរ ៖ ហេតុអ្វីបានជាព្រះមហាក្សត្រ ជាអ្នកធានាឯករាជជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ?*

ចម្លើយ ៖ បញ្ហានេះមានចែងនៅក្នុងមាត្រា ៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រាបន្តបន្ទាប់ ។ តួនាទីរបស់ព្រះអង្គជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ មាត្រា ២៣ នៃរដ្ឋធម្មនុញ្ញ ព្រះអង្គជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ មាត្រា ២៤ថ្មី នៃរដ្ឋធម្មនុញ្ញ ព្រះអង្គទ្រង់គង់ជាព្រះរាជាធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ តែច្បាប់នេះមិនទាន់បានបង្កើតនៅឡើយទេ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ បានទៅធ្វើការសិក្សាដក

ស្រង់បទពិសោធន៍នៅចក្រភពអង់គ្លេស ឃើញថា ព្រះមហាក្សត្រីយានី អេលីហ្សាប៊ែត ក៏មានព្រះរាជតួនាទីស្រដៀងគ្នានេះដែរ ។

***សំណួរ : មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ តើខ្លឹមសារនេះមានន័យត្រឹមណា ?***

ចម្លើយ : ព្រះមហាក្សត្រជាសក្ការៈបុគ្គល ដូច្នេះរដ្ឋធម្មនុញ្ញការពារមិនឱ្យនរណារំលោភបំពានព្រះអង្គបានឡើយ ទោះតាមរូបភាពណាក៏ដោយ ដូចជាតាមសារព័ត៌មានក្តី តាមរលកធាតុអាកាសក្តី តាមលិខិតក្តី ទាំងការជជែកនៅកន្លែងឯកជន ឬ តាមទីសាធារណៈក្តី ។

***សំណួរ : តាមមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ តើមានយន្តការច្បាប់ ឬ បទប្បញ្ញត្តិច្បាប់ណាដែលការពារព្រះកិត្តិនាម ព្រះមហាក្សត្រ ឬ ពង្រឹងមាត្រា ៧ នេះដែរទេ ?***

ចម្លើយ : ព្រះមហាក្សត្រ ជាតួអង្គដែលតំណាងឱ្យរដ្ឋ ដូច្នេះការធ្វើឱ្យប៉ះពាល់ ឬ រំលោភដល់ព្រះមហាក្សត្រមានន័យថា ជាការធ្វើឱ្យប៉ះពាល់ដល់ជាតិយើង ។ ឧទាហរណ៍ នៅខាងសាសនាវិញ សម្តេច ប៉ាប ក្នុងសាសនាគ្រិស្តគឺត្រូវបានគេចាត់ទុកថាជាបុគ្គលខ្ពស់បំផុតដែលមិនអាចរំលោភបាន ។ ម្យ៉ាងវិញទៀត ប្រទេសមួយចំនួនដូចជាប្រធានាធិបតីកូរ៉េខាងត្បូង និង ប្រធានាធិបតីបារាំង លោក ហ្សាក់ ស៊ីរ៉ាក់ នៅពេលដែលបញ្ចប់អាណត្តិជាប្រធានាធិបតី និង ជាប្រមុខរដ្ឋ អាចប្រឈមជាមួយនឹងការចោទប្រកាន់ឱ្យចូលតុលាការ ។ ដោយឡែក ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាវិញ គឺជាព្រះប្រមុខរដ្ឋអស់មួយជីវិត ។

***សំណួរ : ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។ រាល់ការតែងតាំងឥស្សរជនធំៗ ត្រូវមានការឡាយព្រះហស្តលេខាពីព្រះមហាក្សត្រ ។ តើនេះជាអំណាចឬទេ ?***

ចម្លើយ : កាលដែលគេចែងថា "ទ្រង់មិនកាន់អំណាច" មិនមែនមានន័យថា ទ្រង់មិនមានអំណាចនោះទេ ដូចជាករណីព្រះមហាក្សត្រីយ៉ានី អេលីហ្សាប៊ែត នៃចក្រភពអង់គ្លេសដែរ ទ្រង់មិនកាន់អំណាចទេ ដោយទ្រង់ធ្វើការចែករំលែកអំណាចទៅឱ្យស្ថាប័នផ្សេងទៀតកាន់កាប់ មានរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា និង តុលាការ ដើម្បីបំពេញកិច្ចការជំនួសព្រះអង្គ ។ ដូច្នេះក្រៅតែពីអំណាចខាងលើ ដូចជាការតែងតាំងមន្ត្រីជាន់ខ្ពស់ ឬ ឥស្សរជនសំខាន់ៗ អំណាចនេះត្រូវបានគេទុកថ្វាយព្រះមហាក្សត្រ ក្នុងឋានៈព្រះអង្គជាព្រះប្រមុខរដ្ឋ ដូចជាករណីនៅព្រះរាជាណាចក្រកម្ពុជាដែរ ។

***សំណួរ : ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ តើពុំកាន់អំណាចមានន័យ ដូចម្តេច ?***

ចម្លើយ : អំពីព្រះមហាក្សត្រ ក្នុងរដ្ឋធម្មនុញ្ញមាត្រា ៧ ចែងថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនមានអំណាចឡើយ ។ ដូច្នេះ ក្នុងពេលព្រះអង្គទ្រង់គង់ជាព្រះមហាក្សត្រ

គឺមិនកាន់អំណាចឡើយ ទ្រង់គ្មានអំណាចទេ ទ្រង់មិនអាចលូកដៃចូលអំណាចណាមួយឡើយក្នុងនាមជាព្រះមហាក្សត្រ គឺជាព្រះប្រមុខរដ្ឋ ។ ព្រះអង្គទ្រង់ជានិមិត្តរូប នៃឯកភាពជាតិ និង និរន្តរភាពជាតិ ។ ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដី ។

***សំណួរ : ប្រសិនបើនាយករដ្ឋមន្ត្រីធ្វើសំណើទៅព្រះមហាក្សត្រ តើព្រះមហាក្សត្រមានសិទ្ធិបដិសេធទេ ? បើបដិសេធ មានន័យថា ព្រះមហាក្សត្រមានសិទ្ធិធំជាងនាយករដ្ឋមន្ត្រី ត្រូវទេ ?***

ចម្លើយ : ពុំមានមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ បញ្ញត្តិពីបញ្ហានេះទេ ប៉ុន្តែខ្ញុំអាចលើកជាឧទាហរណ៍មួយចំពោះករណីដែលធ្លាប់កើតមាននៅប្រទេសបែលហ្ស៊ិក។ ក្នុងករណីនេះ ព្រះមហាក្សត្របែលហ្ស៊ិកបានបដិសេធមិនព្រមឡាយព្រះហស្ថលេខាលើអត្ថបទច្បាប់ស្តីពីការរំលូតកូន ដោយសារតែព្រះអង្គជាអ្នកប្រកាន់ខ្ជាប់សាសនាគ្រិស្តកាតូលិកយ៉ាងហ្មត់ចត់ ។ ដូច្នេះហើយ គេបានបង្កើតនីតិវិធីមួយ តាមរយៈនេះគេតម្រូវឱ្យព្រះមហាក្សត្រនេះលាលែង ហើយឱ្យព្រះមហាក្សត្រថ្មីដែលត្រូវមកជំនួសឡាយព្រះហស្ថលេខាវិញ ។ ជាសរុបមក នៅប្រទេសកម្ពុជាយើងពុំដែលធ្លាប់ជួបករណីនេះនៅឡើយទេ ។

***សំណួរ : តើរដ្ឋធម្មនុញ្ញមានកំណត់ដែរឬទេ ថាព្រះជាយានៃព្រះមហាក្សត្រត្រូវតែជាព្រះរាជវង្ស ?***

ចម្លើយ : ព្រះមហាក្សត្រ ក៏មានសិទ្ធិសេរីភាពដូចជាប្រជាពលរដ្ឋដែរ ដូច្នេះព្រះអង្គមានសិទ្ធិក្នុងការជ្រើសរើសស្ត្រីណាដែលទ្រង់សព្វព្រះរាជហឫទ័យ ។

***សំណួរ : តើព្រះមហាក្សត្រអាចជាស្ត្រីដែរឬទេ ?***

ចម្លើយ : ជាគោលការណ៍ច្បាប់ តាមរដ្ឋធម្មនុញ្ញ បុរស និង ស្ត្រីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដូចជាករណីនៅប្រទេសអង់គ្លេស គឺមហាក្សត្រិយានី អេលីហ្សាបែត ។

***សំណួរ : ក្នុងករណីមានច្បាប់ផ្សេងអនុញ្ញាតឱ្យព្រះមហាក្សត្រអាចដាក់រាជសម្បត្តិ ឬ ចូលនិវត្តន៍ តើច្បាប់នោះមាន លក្ខណៈអធម្មនុញ្ញដែរឬ ?***

ចម្លើយ : ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៤ ហើយបានឆ្លងក្រុមប្រឹក្សាធម្មនុញ្ញរួចហើយ ។

***សំណួរ : សញ្ញាជាតិប្រើប្រាស់បាន និង មិនប្រើប្រាស់បាននៅកន្លែងណា?***

ចម្លើយ : សញ្ញាជាតិ ឬ ព្រះរាជសង្ហារ គឺត្រូវបានគេប្រើជាមួយនឹងកិច្ចការរបស់ព្រះមហាក្សត្រ ដូចជាលិខិតរបស់ក្រសួងព្រះបរមរាជវាំង ទង់ព្រះមហាក្សត្រ ព្រះរាជក្រឹត្យ ព្រះរាជក្រម លិខិតខាងការទូតជាដើម ហើយចំណែកឯនៅក្របសៀវភៅរដ្ឋធម្មនុញ្ញមានរូបព្រះរាជសង្ហារវិញ ដោយសាររដ្ឋធម្មនុញ្ញត្រូវបានគេចាត់ទុកជាច្បាប់កំពូលរបស់ប្រទេស ហើយព្រះរាជសង្ហារក៏ត្រូវបានគេយកមកប្រើដើម្បីជានិមិត្តរូបឱ្យជាតិដែរ ។

***សំណួរ : សូមបំភ្លឺ ព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ដោយលើកឧទាហរណ៍ ។***

ចម្លើយ : អំពីព្រះមហាក្សត្រ ក្នុងរដ្ឋធម្មនុញ្ញ មាត្រា៧ ចែងថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនមានអំណាចឡើយ ។ ដូច្នេះ ទ្រង់គ្មានអំណាចទេ គឺព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។ ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដី ។

***សំណួរ : មាត្រា ៧ ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។ តើហេតុអ្វីបានជាក្នុងមាត្រា ៨ ចំណុចទី ២ បានកំណត់ឱ្យព្រះមហាក្សត្រធានាបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ?***

ចម្លើយ : ដោយសារព្រះមហាក្សត្រមានព្រះរាជតួនាទី និង ភារកិច្ច យោងតាមមាត្រា ៨ នៃរដ្ឋធម្មនុញ្ញ " ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និង ការគោរពសន្ធិសញ្ញាអន្តរជាតិ ។" ទ្រង់មិនកាន់អំណាច ប៉ុន្តែទ្រង់មាន តួនាទីកំពូលមួយចំពោះបូរណភាពទឹកដី ។ មិនកាន់អំណាចផ្នែករដ្ឋបាល ប៉ុន្តែទ្រង់ជានិមិត្តរូបឯកភាពជាតិទាំងមូល ។

***សំណួរ : តើពាក្យ "ស្វេតឆត្រ" មានន័យយ៉ាងដូចម្តេច ?***

ចម្លើយ : ស្វេតឆត្រ ដែលមកពីពាក្យ ស្វេតៈ ពណ៌ស និង ពាក្យ ឆត្រ ។ ដូច្នេះ ជារួម មានន័យថា ឆត្រពណ៌ស ។ ជាក់ស្តែង គឺចង់សំដៅទៅឆត្រពណ៌ស៩ថ្នាក់ ដែលត្រូវបានគេប្រើបាំងឱ្យព្រះរាជបល្ល័ង្ករបស់ព្រះមហាក្សត្រ ។ តាមជំនឿរបស់ព្រះមហាក្សត្រខ្មែរ គឺមានទេវតានៅរក្សាព្រះមហាស្វេតឆត្រ ដូច្នេះ នៅពេលដែលព្រះមហាក្សត្រឡើងគ្រងរាជសម្បត្តិ ទ្រង់ត្រូវគង់នៅក្រោមព្រះស្វេតឆត្រនេះ ។

***សំណួរ : ព្រះជាយានៃព្រះមហាក្សត្រ មានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។ កន្លងមកព្រះមហាក្សត្រ ទ្រង់បានតែងតាំងជាសម្តេចព្រះរាជអគ្គមហេសី តើស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?***

ចម្លើយ : មិនមានអ្វីផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញទេ ពីព្រោះមួយគឺជាឋានៈ និងមួយទៀតគឺគ្រាន់តែជាគោរមងារដែលផ្តល់ជូនសម្តេចម៉ែ ក្រោយពីពេលដែលទ្រង់យាងចូលនិវត្តតាមរយៈច្បាប់មួយដែលបានអនុម័តកាលពីឆ្នាំ២០០៤ ស្តីពីការរៀបចំព្រះបរមងារ និង ព្រះរាជបុព្វសិទ្ធិថ្វាយសម្តេចឪ សម្តេចម៉ែ ។ ដូច្នេះហើយបានជាទ្រង់បានទទួលព្រះបរមងារជាសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និង បានទទួលបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ ដូចពេលដែលទ្រង់កំពុងគង់នៅក្នុងតំណែងដូច្នេះដែរ ។

***សំណួរ : យោងមាត្រា ២១ មិនមានចែងពីនគរបាលទេ មានចែងតែយោធា តើយ៉ាងដូចម្តេចដែរ ?***

ចម្លើយ : ព្រោះនគរបាលជាតិស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ពីដើមគឺចេញពីសាលាភូមិន្ទរដ្ឋបាល ឬសាលាជាតិរដ្ឋបាល ។

***សំណួរ : មាត្រា ២៨ថ្មី វាក្យខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ បានចែងពីប្រមុខរដ្ឋស្តីទីចុះហត្ថលេខាលើព្រះរាជក្រម និង ព្រះរាជក្រឹត្យ ដោយព្រះរាជសារប្រគល់សិទ្ធិ ។ ចំណែកមាត្រា ២១ តើប្រមុខរដ្ឋស្តីទីអាចចុះហត្ថលេខាលើ ព្រះរាជក្រឹត្យឯកត្តភូតនោះបានឬទេ ? ហេតុអ្វី ?***

ចម្លើយ : ការចុះហត្ថលេខាលើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យ ត្រូវធ្វើទៅតាមនីតិវិធី ជាពិសេសត្រូវមាន ការស្នើពីនាយករដ្ឋមន្ត្រីទាក់ទងនឹងព្រះរាជក្រឹត្យតែងតាំងបុគ្គលណាម្នាក់ ។

***សំណួរ : មាត្រា១៨ ហេតុអ្វីក៏ព្រឹទ្ធសភា រដ្ឋសភា មិនអាចយកព្រះរាជសារព្រះមហាក្សត្រមកជជែកពិភាក្សា?***

ចម្លើយ : បានជាព្រឹទ្ធសភា រដ្ឋសភា មិនអាចយកព្រះរាជសារព្រះមហាក្សត្រមកជជែកពិភាក្សា ព្រោះ រដ្ឋធម្មនុញ្ញហាម ។

***សំណួរ : សូមពន្យល់ឱ្យបានច្បាស់អំពីក្រោយពីច្បាប់ផ្សេងៗដែលបានអនុម័តដោយរដ្ឋសភារួចហើយ មុននឹងប្រកាសឱ្យប្រើតើត្រូវឆ្លងកាត់ស្ថាប័នណាខ្លះ ?***

ចម្លើយ : ក្រោយពីច្បាប់ណាមួយត្រូវបានរដ្ឋសភាអនុម័តរួចហើយ ប្រធានរដ្ឋសភាត្រូវបញ្ជូនអត្ថបទច្បាប់ នោះមកព្រឹទ្ធសភាដើម្បីពិនិត្យនិងឱ្យយោបល់ ។ ក្រោយពីពិនិត្យ និង ឱ្យយោបល់ដោយព្រឹទ្ធសភារួចមក ប្រធាន ព្រឹទ្ធសភាត្រូវបញ្ជូនអត្ថបទច្បាប់នោះត្រលប់ទៅរដ្ឋសភាវិញ ដើម្បីឱ្យរដ្ឋសភាបញ្ជូនទៅរាជរដ្ឋាភិបាល ប្រសិនបើ អត្ថបទច្បាប់នោះមិនមែនជាប្រភេទច្បាប់រៀបចំអង្គការ។ បន្ទាប់ពីនេះ រាជរដ្ឋាភិបាលធ្វើសេចក្តីព្រាងព្រះរាជក្រម ស្នើសុំព្រះមហាក្សត្រឡាយព្រះហស្តលេខាដើម្បីប្រកាសឱ្យប្រើច្បាប់នោះ ។ ប៉ុន្តែបើជាប្រភេទច្បាប់រៀបចំអង្គការ មានដូចជាច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ រដ្ឋធម្មនុញ្ញតម្រូវឱ្យបញ្ជូនអត្ថបទច្បាប់នោះ មកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីសុំពិនិត្យធម្មនុញ្ញភាពជាមុនសិនមុននឹង ប្រកាសឱ្យប្រើ ។ ចំពោះករណីសេចក្តីព្រាងច្បាប់ធម្មនុញ្ញ រាជរដ្ឋាភិបាល តាមរយៈព្រះមហាក្សត្រអាចស្នើសុំ ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ មុននឹងយកមកដាក់ឆ្លងរដ្ឋសភាដើម្បីអនុម័ត ពីព្រោះក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័ន ធានាការពារការគោរពរដ្ឋធម្មនុញ្ញ ។

***សំណួរ : ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ជាកូនរាស្ត្រ តើចាត់ទុកជាព្រះជាយាបានទេ ?***

ចម្លើយ : ព្រះរាជក្រឹត្យតែងតាំងហើយមិនបានយ៉ាងម៉េច ។ ទោះបីជាកូនរាស្ត្រក៏ដោយ ឱ្យតែមានស្វាមីជា ស្តេច គឺឡើងតួនាទីភ្លាមជាអ្នកម្នាង ហើយឋានៈបន្តបន្ទាប់ទៀត គឺឡើងតាមព្រះរាជក្រឹត្យតែងតាំង ។

# ពាក់ព័ន្ធនឹងជំពូកទី ៣
# អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

***សំណួរ : ត្រង់មាត្រា ៧៤ ជំពូកទី៦ នៃរដ្ឋធម្មនុញ្ញបានចែងថា រដ្ឋជួយឧបត្ថម្ភជនពិការ និង គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។ ចុះជនពិការដទៃទៀតដែលពិការដោយប្រការផ្សេងៗ ម្តេចមិនឃើញឧបត្ថម្ភផង?***

ចម្លើយ : ជាគោលការណ៍ រដ្ឋយកចិត្តទុកដាក់ចំពោះជនពិការគ្រប់ប្រភេទទាំងអស់ ដោយមិនមានការរើសអើងអ្វីទេ ប្រការដែលរដ្ឋធម្មនុញ្ញចែងយ៉ាងនេះ អាស្រ័យដោយច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាផ្តល់អាទិភាព ដល់ជនពិការ និង គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ តែប៉ុណ្ណោះ ។

***សំណួរ : ហេតុអ្វីសាសនាមានការទាក់ទងនឹងរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ប្រហែលសំណួរចង់សួរថា ហេតុអ្វីព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ? ធ្វើម៉េចនេះជាសាសនារបស់ដូនតាយើងទៅហើយ ខ្មែរភាគច្រើនគោរពបូជាព្រះពុទ្ធ ។ ការរស់រានមានជីវិត មានអារ្យធម៌ វប្បធម៌ អក្សរសាស្ត្រ ភាសាខ្លួនឯងជាដើម ក៏មានការចូលរួមចំណែកពីសាសនាដែរ ។ ប្រសិនបើប្រទេសមូស្លីម សាសនាកាន់តែមានឥទ្ធិពលនៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ នេះជារឿងធម្មតា ។ ច្បាប់វាមានទំនាក់ទំនងជាមួយវប្បធម៌ ទំនៀមទំលាប់ សាសនា ជៀសមិនផុតទេ ។

***សំណួរ: មាត្រា ៤៥ វាក្យខ័ណ្ឌទីពីរចែងថាការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ តែមានក្រុមហ៊ុនពលករដែលជ្រើសរើសស្ត្រីទៅបម្រើការងារនៅប្រទេសម៉ាឡេស៊ី ហើយការទៅធ្វើការនោះ គឺធ្វើការងារមេផ្ទះ ពេលដែលស្ត្រីនោះទៅដល់ប្រទេសម៉ាឡេស៊ី ក្រុមហ៊ុននៅម៉ាឡេស៊ីបានផ្ទេរលុយមកឱ្យក្រុមហ៊ុននៅស្រុកខ្មែរ តើនេះជាការធ្វើអាជីវកម្មលើការងារស្ត្រីដែរឬទេ ?***

ចម្លើយ : បើមានច្បាប់ចែងពីការងារនោះហើយ គឺមិនខុសអ្វីទេ តែបើបញ្ហាជួញដូរមនុស្សនោះ គឺជាការខុសហើយ ។ យើងមានក្រសួងដែលត្រួតពិនិត្យលើបញ្ហានោះ ដូចជាក្រសួងការងារជាដើម ។ សូមបញ្ជាក់ថា ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី គឺមានន័យថា ការយកនារីទៅលក់ ឬ ការយកនារីទៅធ្វើបាបផ្សេងៗ ដើម្បីប្រយោជន៍របស់ក្រុមហ៊ុន បើសិនណាជាការងារពលកម្មក៏ជាការងារដែរ បើមានកិច្ចសន្យា គឺត្រូវឱ្យស្របនឹងច្បាប់ការងារ និង ឱ្យស្របរដ្ឋធម្មនុញ្ញដែរ ។ បើមានការរំលោភកិច្ចសន្យាវាជាបញ្ហាផ្សេងមួយទៀត ។ ការបញ្ជូនពលករដើម្បីទៅធ្វើការងារនៅបរទេសជារឿងធម្មតាទេ ពិសេសការបញ្ជូនពីប្រទេសក្រីក្រ និង ប្រទេសកំពុងអភិវឌ្ឍន៍ នេះជាមធ្យោបាយរកការងារជូនប្រជាពលរដ្ឋផង និង ទទួលបាននូវបច្ចេកវិជ្ជា ព្រមទាំងជំនាញពីបរទេសមកវិញផងដែរ ។

***សំណួរ : ហេតុអ្វីបានជារដ្ឋធម្មនុញ្ញហាមមិនឱ្យមានទោសប្រហារជីវិត ?***

ចម្លើយ : ព្រោះនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសគេបានចងលក្ខខណ្ឌច្រើន ទាំងសិទ្ធិមនុស្ស ជំនឿ សាសនា ពិសេសរបបប្រជាធិបតេយ្យសេរី ភាគីទាំងអស់នៃកិច្ចព្រមព្រៀងបានយល់ព្រមថាបើធ្វើរដ្ឋធម្មនុញ្ញត្រូវលុបចោលទោសប្រហារជីវិតនេះ ដូច្នេះហើយទើបសភាធម្មនុញ្ញគោរពតាមកិច្ចព្រមព្រៀងនេះ ។ ដូច្នេះ រដ្ឋធម្មនុញ្ញយើង គឺជារដ្ឋធម្មនុញ្ញជឿនលឿនបើប្រៀបធៀបទៅនឹងរដ្ឋធម្មនុញ្ញនៃបណ្ដាប្រទេសមួយចំនួន ។ យើងហ៊ានសរសេរអំពីការគោរពសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញរបស់យើង ហើយការកាត់ទោសប្រហារជីវិតត្រូវលុបបំបាត់ចោល ដូច្នេះហើយទើបមិនអាចដាក់បានទេ ព្រោះប៉ះពាល់ដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីស ។

***សំណួរ : តាមខ្ញុំដឹង រាជរដ្ឋាភិបាលបានរៀបចំច្បាប់ថ្មីមួយ គឺច្បាប់ភូមិបាល (មិនទាន់ប្រកាសឱ្យប្រើ) ដែលច្បាប់ នោះ និយាយអំពីការផ្ដល់កម្មសិទ្ធិឱ្យជនបរទេស (ផ្ទះជាន់ទីពីរឡើង) ។ បើសិនជាច្បាប់នេះចេញ (ប្រកាសឱ្យប្រើ) តើវាមានបញ្ហាអធម្មនុញ្ញភាពឬទេ ? ផ្អែកតាមមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញ ។***

ចម្លើយ : មានតែពលរដ្ឋខ្មែរទេ ដែលមានសិទ្ធិលើកម្មសិទ្ធិដីធ្លី ដូច្នេះរង់ចាំមើលច្បាប់នេះចេញសិន ។

***សំណួរ: មាត្រា ៤៥ ឃ្លាទីពីរ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។ ខ្ញុំបាទចង់ដឹងថា អ្វីខ្លះជាការងាររបស់ស្ត្រី ?***

ចម្លើយ : ការងារដែលជាអាជីវកម្មលើស្ត្រីនោះ គឺជាការងារទាំងឡាយណាដែលមិនមានក្នុងកិច្ចសន្យា និង គ្មានចែងនៅក្នុងច្បាប់ ហើយអាចមានករណីផ្សេងៗទៀតដូចជាការជួញដូរផ្លូវភេទ ការប្រព្រឹត្តអំពើអនាចារជាដើម ។

***សំណួរ : មាត្រា ៤៦ នៃរដ្ឋធម្មនុញ្ញហេតុអ្វីបានជាមិនបានចែងពីភាពប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់បុរស តើមានភាពផ្ទុយគ្នានឹងឃ្លាទីបីនៃមាត្រា ៤៥ ដែរឬទេ ?***

ចម្លើយ : បើយើងមើលទៅក្នុងសង្គមខ្មែរ ក៏ដូចជាសង្គមភាគច្រើននៃបណ្ដាប្រទេសនៅអាស៊ី គឺគេឱ្យតម្លៃទៅលើស្ត្រីជាធំ ព្រោះស្ត្រីជាមាតា ជាគ្រូទីមួយក្នុងការអប់រំកូនៗ និងមានកត្តាជាច្រើនទៀតដែលយើងទាំងអស់គ្នាត្រូវលើកតម្លៃដល់ស្ត្រី ។

***សំណួរ : សូមពន្យល់បកស្រាយឱ្យបានច្បាស់លាស់នូវមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌដែលចែងថា "វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" តើចំណុចអ្វីខ្លះដែលចាត់ទុកជាវិមតិសង្ស័យ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ដូច្នេះគោលការណ៍នេះមិនអាចបដិសេធបានទេ ។ នៅតុលាការ បើសិនជាមានការសង្ស័យ និង គ្មានភស្ដុតាងគ្រប់គ្រាន់ នោះជនជាប់ចោទអាចរួចខ្លួន ទោះនៅក្នុងដំណាក់កាលស៊ើបអង្កេត ឬ ក្នុងដំណាក់កាលឃាត់ខ្លួន ចាប់ខ្លួន ឬ ក្នុងដំណាក់កាលជំនុំជម្រះក៏ដោយ ។ កាលណាមានមន្ទិលសង្ស័យនាំឱ្យមិនអាចជាប់គុកបានទេ ។

***សំណួរ : មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួន ។ ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។ ចុះបើនៅពេលជនល្មើសចាប់បានដោយប្រជាជន ហើយប្រជាជនធ្វើការប្រហារជីវិតជនល្មើសទាំងនោះមុនពេលសមត្ថកិច្ចទៅដល់ តើប្រជាជនទាំងនោះមានទោសដែរឬទេ? បើមានទោស តើជាទោសក៏រិតបែបណា ?***

ចម្លើយ : ទង្វើនេះ គឺជាការធ្វើមនុស្សឃាតក្រៅច្បាប់ ដែលជាទោសឧក្រិដ្ឋ ។

***សំណួរ : មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ដែលចែងពីសេរីភាពក្នុងការបញ្ចេញមតិ តើអាចមានន័យថាពលរដ្ឋម្នាក់ៗអាចផ្សព្វផ្សាយស្នាដៃបោះពុម្ពជាសៀវភៅ ដោយមិនចាំបាច់មានការត្រួតពិនិត្យពីស្ថាប័នជំនាញណាមួយឬយ៉ាងណា ?***

ចម្លើយ : ការផ្សព្វផ្សាយតាមសារព័ត៌មាន និង ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ត្រូវបានគ្រប់គ្រងយ៉ាង ច្បាស់លាស់ ហើយអាចមានច្បាប់ពិសេសណាមួយគ្រប់គ្រងទៅលើរាល់សកម្មភាពទាំងអស់នេះ ។ យោងទៅលើ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ដែលមានពីរឃ្លា ក្នុងនោះឃ្លាទី១ ចែងអំពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ និងឃ្លាទី២ ចែងកំណត់ពីព្រំដែននៃការអនុវត្តសិទ្ធិនោះថា "ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់មួយ។" ។ ដូច្នេះ រាល់ស្នាដៃទាំងឡាយដែលនឹងយកទៅផ្សព្វផ្សាយត្រូវគោរពតាមលក្ខខណ្ឌខាងលើនេះ។

***សំណួរ : មាត្រា ៤១ ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងបញ្ចេញមតិ ហេតុអ្វីបានជាអ្នកសារព័ត៌មានមួយចំនួនមានការចាប់ខ្លួនដាក់ពន្ធនាគារ ។***

ចម្លើយ : យើងមានសេរីភាពក្នុងការបញ្ចេញមតិមែន ប៉ុន្តែកុំឱ្យប៉ះពាល់សេរីភាពអ្នកដទៃ ។

***សំណួរ : សូមមេត្តាបកស្រាយអំពីឃ្លាថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ" នៅក្នុងជំពូកទី៣ មាត្រា ៣៩ ។***

ចម្លើយ : ពាក្យថា "ប្តឹងបរិហារ" មានន័យថា អ្នកប្តឹងគ្មានផលប្រយោជន៍ផ្ទាល់ខ្លួនឯងនៅក្នុងបណ្តឹងនោះទេ។

***សំណួរ : ជំពូកទី៣ មាត្រា ៤៦ ទំព័រ ១៥ ស្តីពីអំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និង អំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវបានហាមឃាត់។ ច្បាប់ហាមឃាត់អំពើនេះមានរួចហើយតែបច្ចុប្បន្នអ្នកប្រព្រឹត្តអំពើនេះនៅតែមាន តើច្បាប់មានវិធានការយ៉ាងណាបន្ថែម ?***

ចម្លើយ : អស់លោកហ្នឹងហើយដែលជាអ្នកមើល នគរបាលយុត្តិធម៌ ក្រុមប្រឹក្សាឃុំ មេឃុំ មិនត្រូវឱ្យមានរឿងហ្នឹងទៀតទេ ។ ការអនុវត្តន៍ច្បាប់ គឺវាពិបាកអ៊ីចឹង ឧទាហរណ៍ រឿងគ្រឿងញៀន ហាមមិនឱ្យជួញដូរនៅតែមាន ដូចសុភាសិតបារាំងមួយគេថា "ប្រាក់ គឺជាមធ្យោបាយដ៏ល្អ ប៉ុន្តែជាគ្រូដ៏អាក្រក់បំផុត" អ្នករកស៊ីបែបនេះ គឺយកប្រាក់ធ្វើគ្រូហើយ ។ ហើយវិធានការយ៉ាងណា គឺបង្ក្រាប និង ទប់ស្កាត់ ។

***សំណួរ៖ មាត្រា ៤៣ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ចុះហេតុអ្វីបានជាមិនប្រើពុទ្ធសករាជ ប្តូរជាទៅប្រើ គ្រិស្តសករាជទៅវិញ ?***

ចម្លើយ ៖ ទម្លាប់របស់យើងនៅក្នុងការប្រើប្រាស់អ៊ីចឹង គឺធ្វើទៅតាមសាកលភាវូបនីយកម្ម ។

***សំណួរ៖ មាត្រា ៤៥ "គោលការណ៍ស្វ័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ" តើអ្នកមានប្រពន្ធ ២ ឡើងទៅមានទោសឬទេ?***

ចម្លើយ ៖ អាពាហ៍ពិពាហ៍ គឺជាការព្រមព្រៀងរវាងប្តីមួយ និង ប្រពន្ធមួយ ដែលត្រូវបានធ្វើនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយបើគេសួរថា មានប្រពន្ធឬនៅ គឺមានន័យថា មានបានចុះអេតាស៊ីវិលហើយឬនៅ ។ ជាក្រឹត្យក្រមតាមច្បាប់ ការចុះអេតាស៊ីវិលអាពាហ៍ពិពាហ៍នេះ គឺអាចធ្វើបានតែមួយទេ ពីព្រោះច្បាប់ឯកពន្ធភាពទទួលស្គាល់គោលការណ៍ប្តីមួយ-ប្រពន្ធមួយ ។ ដូច្នេះ ការចុះអាពាហ៍ពិពាហ៍លើសពីមួយ គឺខុសនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ហើយ ។

# ពាក់ព័ន្ធនឹងជំពូកទី ៤
## អំពីរបបនយោបាយ

***សំណួរ*** ៖ *ហេតុអ្វីបានជារដ្ឋធម្មនុញ្ញប្រែប្រួលតាមរបបនយោបាយ ?*

ចម្លើយ ៖ រដ្ឋធម្មនុញ្ញត្រូវបានតាក់តែងឡើងដើម្បីតំណាងឱ្យរបបនយោបាយ ហើយនឹងបញ្ញត្តិពីរបបនយោបាយ និងទម្រង់នៃការគ្រប់គ្រងរដ្ឋមួយដែលគេចង់បាន ។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញក្នុងរបបមួយចែងថា អ្នកណានឹងកាន់កាប់អំណាចរបស់រដ្ឋ តួយ៉ាងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ អំណាចទាំងអស់ជារបស់ព្រះមហាក្សត្រ រីឯរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ អំណាចទាំងអស់ជារបស់ប្រជាជន ។

***សំណួរ*** ៖ *តើប្រៀបធៀបបានទេ របបនយោបាយក្នុងអាណត្តិទី៤នេះមានគោលនយោបាយដូចគោលនយោបាយប្រទេសខាងលិច ឬ ខាងកើត ?*

ចម្លើយ ៖ នយោបាយនៅកម្ពុជា គឺមានគោលនយោបាយបែបកម្ពុជា សម្រាប់សម្របសង្គមកម្ពុជា ដែលមិនស្ថិតក្រោមឥទ្ធិពលរបស់ប្លុកណាមួយទេ ។

***សំណួរ*** ៖ *ហេតុអ្វីបានជារបបនីមួយៗមានរដ្ឋធម្មនុញ្ញផ្សេងៗគ្នា? ហេតុអ្វីបានជារដ្ឋធម្មនុញ្ញនីមួយៗខ្លះជោគជ័យ ឯខ្លះទៀតបរាជ័យ? តើរដ្ឋធម្មនុញ្ញនៃរបបមួយអាចយកមកអនុវត្តលើរបបផ្សេងទៀតបានទេ ?*

ចម្លើយ ៖ របបនីមួយៗមានរដ្ឋធម្មនុញ្ញផ្សេងៗគ្នា ដោយសារតែរបបទាំងនោះមានឆន្ទៈនយោបាយផ្សេងគ្នា។ ការបរាជ័យរបស់ច្បាប់មួយអាស្រ័យដោយសារការអនុវត្តគ្មានប្រសិទ្ធភាព ។ រដ្ឋធម្មនុញ្ញនៃរបបមួយអាចមិនយកមកអនុវត្តលើរបបផ្សេងៗទៀតបានទេ ព្រោះរបបនីមួយៗតែងមានរដ្ឋធម្មនុញ្ញមួយ ។

***សំណួរ*** ៖ *មាត្រា ៥៥ "សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវលុបចោល"។ តើកិច្ចព្រមព្រៀងត្រូវធ្វើតាមរដ្ឋធម្មនុញ្ញ ប៉ុន្តែគេឃើញថាជួនកាលត្រូវបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឱ្យស្របតាមសន្ធិសញ្ញា។*

ចម្លើយ ៖ បើតាមខ្ញុំដឹង តាំងពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០០៨ មិនដែលឃើញមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសម្របទៅតាមសន្ធិសញ្ញាណាមួយទេ ពីព្រោះសន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងរវាងរដ្ឋ និង រដ្ឋ ជាទ្វេភាគី ឬ ជាពហុភាគី ។ ការធ្វើសន្ធិសញ្ញាត្រូវគិតទៅដល់រដ្ឋធម្មនុញ្ញ ឧទាហរណ៍ ទៅធ្វើសន្ធិសញ្ញាចូលបក្សសម្ព័ន្ធយោធាណាមួយ បើប៉ះពាល់ដល់រដ្ឋធម្មនុញ្ញមិនបានទេ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកសម្រេច ។

***សំណួរ : សូមពន្យល់មាត្រា ៥១ វាក្យខ័ណ្ឌទី២ ។ តើប្រជាពលរដ្ឋខ្មែរទាំងអស់ អាចជាម្ចាស់វាសនានៃប្រទេសជាតិបានឬទេ? ប្រសិនបើប្រជាពលរដ្ឋតាមជនបទស្ថិតក្នុងអនក្ខរភាពមិនយល់ដឹងច្បាប់នោះ?***

ចម្លើយ : បញ្ហានេះជាបញ្ហារបស់យើងទាំងអស់គ្នា យើងត្រូវទទួលស្គាល់អនក្ខរភាពក្នុងចំណោមប្រជា-ពលរដ្ឋយើង ប៉ុន្តែរាជរដ្ឋាភិបាលខិតខំណាស់តាំងពីឆ្នាំ១៩៧៩មក ក្នុងការលុបបំបាត់គ្រោះមិនចេះអក្សរ ។ ប៉ុន្តែពាក្យម្ចាស់វាសនានៃប្រទេសជាតិនេះ គឺគាត់ប្រើសិទ្ធិរបស់គាត់ក្នុងការជ្រើសរើសតំណាង ពោលគឺតំណាងរាស្ត្រនេះឯង។

***សំណួរ : សូមបកស្រាយអំពីសន្និសញ្ញា អនុសញ្ញា ស្ថិតនៅឋានានុក្រមណាជាមួយរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ច្បាប់ដែលខ្ពស់ជាងគេ គឺមានតែរដ្ឋធម្មនុញ្ញទេ ។

***សំណួរ : តើអ្វីជាគោលការណ៍សំខាន់បំផុតនៃការបែងចែកអំណាច? ហើយផ្តល់ប្រយោជន៍អ្វីខ្លះរវាងអំណាចទាំងបី?***

ចម្លើយ : នេះប្រហែលជាយោងមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ។ គេបែងចែកអំណាចយ៉ាងនេះ គឺដើម្បីកុំឱ្យអំណាចនីមួយៗរំលោភលើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។ មានន័យថា នីតិបញ្ញត្តិជាអ្នកធ្វើច្បាប់ ហើយនីតិប្រតិបត្តិជាអ្នកអនុវត្តច្បាប់ និង អំណាចតុលាការទាក់ទងនឹងយុត្តិធម៌ ការពារសិទ្ធិរបស់ពលរដ្ឋ ។

គោលការណ៍នៃការបែងចែកអំណាចជាបីដាច់ពីគ្នា ហើយអំណាចទាំងបីមានសមត្ថកិច្ចដោយឡែកៗពីគ្នា នេះជាគោលការណ៍សកល ផ្ទុយពីសង្គមដែលអំណាចទាំងអស់ចេញពីមនុស្សតែម្នាក់ ។ បើកាលណាអំណាចច្របូកច្របល់ វានាំឱ្យសង្គមច្របូកច្របល់ និង អាចឈានទៅរកអន្តរាយ ។

***សំណួរ : ខ្ញុំបាទសូមអនុញ្ញាតស្នើសុំការពន្យល់មាត្រា ៥១ ថ្មី ចំណុចត្រង់ថា ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី ។ តើប្រើអំណាចរបស់ខ្លួនតាមវិធីណា ?***

ចម្លើយ : ប្រទេសកម្ពុជាជាប្រទេសដែលកាន់របបប្រជាធិបតេយ្យដោយតំណាង មិនមែនប្រជាធិបតេយ្យដោយផ្ទាល់នោះទេ ។ ឧទាហរណ៍ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អ៊ីចឹងក្រុមប្រឹក្សាឃុំសង្កាត់នោះហើយជាតំណាងប្រជាពលរដ្ឋក្នុងឃុំនោះ ។ ប្រជាពលរដ្ឋអាចប្រើអំណាចរបស់ខ្លួនតាមរយៈឃុំ សង្កាត់ ហើយឥឡូវនេះយើងមាន ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួន ។ ជាងនេះទៅទៀត យើងមានតំណាងរាស្ត្រដែលជាតំណាងប្រជាពលរដ្ឋទូទាំងប្រទេស ។ រាជរដ្ឋាភិបាល តុលាការជាតំណាងប្រជាពលរដ្ឋ ដូច្នេះ រាជរដ្ឋាភិបាល តុលាការបំពេញសមត្ថកិច្ចក្នុងនាមតំណាងឱ្យប្រជាពលរដ្ឋ ។

***សំណួរ : តើអ្វីទៅហៅថា អព្យាក្រឹត និង មិនចូលបក្សសម្ព័ន្ធ ? តើរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានគោរពគោលការណ៍នេះដែរឬទេ?***

ចម្លើយ : តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានចែងថា ប្រទេសកម្ពុជាប្រកាន់ខ្ជាប់របបនយោបាយអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ។ ម្យ៉ាងវិញទៀត ទាក់ទងនឹងគោលជំហរនយោបាយអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធរបស់រាជរដ្ឋាភិបាល យើងអាចឃើញជាក់ស្តែងថា តើកម្ពុជាបានចូលបក្សសម្ព័ន្ធយោធាណាមួយហើយឬនៅ ។

***សំណួរ : មាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។ មូលហេតុអ្វីមជ្ឈដ្ឋាន និង ជនអគតិមួយចំនួននិយាយថា អំណាចតុលាការមិនឯករាជ្យ ហើយដោះស្រាយរាល់សំណុំរឿងភាគច្រើនមានការលម្អៀង ។***

ចម្លើយ : យើងកំពុងស្ថិតក្នុងដំណាក់កាលធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ច្បាប់ និង តុលាការ ។ ឥឡូវយើងបង្កើតបានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សម្រាប់បណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា ព្រោះយើងត្រូវការធនធានមនុស្ស ដោយសារយើងវិវឌ្ឍរហ័សពេក ។ រឿងដល់តុលាការវាតែងតែមានចាញ់មានឈ្នះហើយចៀសមិនរួចទេ ។ អ្នកឈ្នះគេថាយុត្តិធម៌ អ្នកចាញ់មិនដែលទទួលស្គាល់ថាយុត្តិធម៌ទេ ប្រទេសណាក៏ដូចប្រទេសណាដែរ ។

# ពាក់ព័ន្ធនឹងជំពូកទី ៥
# អំពីសេដ្ឋកិច្ច

***សំណួរ*** : *មាត្រា៥៣ ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សា ការរៀបចំនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់ ប៉ុន្តែនៅប៉ៃលិននេះមានការធ្វើអាជីវកម្មផ្តាច់មុខ ។ ឧទាហរណ៍ ជ្រូក គោ ច្បាប់កំណត់អ្នកដេញថ្លៃបានគ្រាន់តែជាម្ចាស់ទីសត្តឃាត អ្នកផ្សេងទៀតមានសិទ្ធិធ្វើអាជីវកម្មហើយបង់តម្លៃឱ្យម្ចាស់សត្តឃាត តាមការកំណត់ក្នុងសៀវភៅបន្ទុក ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច តែអភិបាលខេត្ត ប៉ៃលិននេះបែរជាឱ្យអ្នកមានលុយទិញសិទ្ធិផ្តាច់មុខ ហើយធ្វើអាជីវកម្មផ្តាច់មុខ ។ តើនេះជាការរំលោភលើរដ្ឋធម្មនុញ្ញដែរ ឬទេ ? មាត្រា ៦២ រដ្ឋយកចិត្តទុកដាក់ដោះស្រាយមធ្យោបាយផលិតផល ការពារថ្លៃផលិតផលជូនកសិករ និង ជួយរកទីផ្សារលក់ផលិតផល ។ ប៉ុន្តែនៅប៉ៃលិនផលិតផលកសិករធ្វើបាន មានឈ្មួញដែលទិញ និង នាំចេញទៅលក់នៅវៀតណាម ឬខាងថៃ តាមខាងណាដែលមានតម្លៃល្អជាង ពេលនាំចេញទៅថៃ ពេលឆ្លងដែនគាត់ត្រូវបង់ពន្ធតាមការកំណត់របស់ច្រកព្រំដែនហើយ ប៉ុន្តែអភិបាលខេត្តបែរជាអនុញ្ញាតបង្កើតផែស្ងួត ដែលតាមការពិតទៅគឺជាការដាក់របាំងយកលុយមួយជាន់ទៀតតែប៉ុណ្ណោះ ។ តើនេះជាការដាក់បន្ទុកធ្វើឱ្យតម្លៃផលិតផលចុះទាបដែរឬទេ? ហើយអាចជាការរំលោភរដ្ឋធម្មនុញ្ញមាត្រា ២៦ នេះដែរឬទេ?*

ចម្លើយ : បញ្ហានេះជាភារកិច្ចរបស់ថ្នាក់ដឹកនាំខេត្ត ដោយមានក្រសួងពាណិជ្ជកម្មសហការជាមួយផង ។ ដូច្នេះការងារនេះត្រូវរួមគ្នាដោះស្រាយ ព្រោះក្រុមប្រឹក្សាខេត្តកើតមានហើយ ។ ការនេះមិនទាន់ចាត់ចូលជាការរំលោភសិទ្ធិរបស់ពលរដ្ឋទេ ព្រោះយើងអនុវត្តរបបទីផ្សារសេរី ដូច្នេះវាត្រូវមានការប្រកួតប្រជែងគ្នាបែបនេះហើយ ។ ប៉ុន្តែទោះជាយ៉ាងណា ក៏រដ្ឋត្រូវធ្វើយ៉ាងណាឱ្យមានការប្រកួតប្រជែងមួយស្របច្បាប់ ហើយរដ្ឋយកចិត្តទុកដាក់ដោះស្រាយមធ្យោបាយផលិតផល ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និង ជួយរកទីផ្សារលក់ផលិតផល ។

***សំណួរ*** : *បកស្រាយមាត្រា ៥៩ ជាពិសេសពន្យល់ពាក្យភោគោត្តសាស្រ្ត និង ពាក្យភូគព្ភសាស្រ្ត ។*

ចម្លើយ : ពាក្យ "ភូគព្ភសាស្រ្ត" គឺជាវិទ្យាសាស្រ្តដែលសិក្សាពីវត្ថុធាតុនៅក្រោមដី មានរ៉ែជាដើម ពាក្យបារាំងថា Géologie អង់គ្លេសថា Geology ។

***សំណួរ*** : *តាមមាត្រា ៥៦ ព្រះរាជាណាចក្រកម្ពុជាអនុវត្តសេដ្ឋកិច្ចទីផ្សារ ។ ប៉ុន្តែនៅពេលថ្មីៗនេះ មានប្រកាសអន្តរក្រសួងមួយដែរបានកំណត់តម្លៃសេវាកម្មទូរស័ព្ទ តើហេតុអ្វីបានជាប្រកាសនេះអាចអនុវត្តបាន?*

ចម្លើយ : ការប្រកួតប្រជែងដោយសេរីត្រូវតែមាន ប៉ុន្តែវាមានសម្ងាប់គ្នាទៅវិញទៅមកដែរ ដូច្នេះរដ្ឋក៏ត្រូវធ្វើអន្តរាគមន៍ដែរ ឧទាហរណ៍ក្រុមហ៊ុនមួយវាបញ្ចុះថ្លៃទូរស័ព្ទច្រើនមែនទែន ប៉ុន្តែបើចង់ហៅចេញទៅក្រៅប្រព័ន្ធវាកាត់ចោលតែម្តង វាមិនភ្ជាប់ឱ្យ ដូច្នេះត្រូវមានអន្តរាគមន៍ខ្លះ ។

***សំណួរ*** *: ជំពូកទី៥ មាត្រា៥៦ ចែងថា "ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី" ។ មាត្រា ៣៦ ចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា" ។ សូមឯកឧត្តមមេត្តាជួយពន្យល់ពីអត្ថន័យនិងទំនាក់ទំនងរវាងមាត្រាទាំងពីរនេះ ។*

ចម្លើយ : អត្ថន័យនៃមាត្រាទាំងពីរនេះ គឺដាច់ពីគ្នា ពីព្រោះថាមាត្រាមួយនិយាយពីកម្ពុជាអនុវត្តរបបសេដ្ឋកិច្ចទីផ្សារសេរី និង មាត្រាមួយទៀតនិយាយពីសិទ្ធិក្នុងការទទួលបានប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ នៅបណ្ដាប្រទេសមួយចំនួន គេផ្ដល់ប្រាក់បំណាច់ចំពោះការងាររបស់បុរសច្រើនជាងការងាររបស់ស្ត្រី ប៉ុន្តែនៅកម្ពុជាយើងមានមាត្រានេះចងរួចជាស្រេច ។

***សំណួរ*** *: ពិនិត្យលើមាត្រា ៥៨ និង ៥៩ សូមលើកឡើងអំពី ថ្ម ព្រៃឈើ អនុផលព្រៃឈើ និង ពពួកសត្វព្រៃ ដែលពួកឈ្មួញ និង ពួកអ្នកមានអំណាចមួយចំនួនសមគំនិតបំផ្លាញ ទិញ-លក់ ធ្វើចរាចរតាមដងផ្លូវជាតិដោយសុវត្ថិភាពភាគច្រើន (មានរថយន្តគ្រប់ប្រភេទធំ/តូច និង ទំនើប) កន្លងមក តើកំហុសនេះធ្លាក់ទៅលើស្ថាប័នណាជាអ្នកទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល (ពីព្រោះមានស្ថាប័នជំនាញ កងកម្លាំងប្រដាប់អាវុធ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់) ។*

ចម្លើយ : នេះជាបាតុភាពដោយឡែកកើតនៅក្នុងសង្គម ។ អ្នកអនុវត្តច្បាប់ពិបាកណាស់ ហើយច្បាប់រត់តាមអ្នកខូច ។ មន្ត្រីរបស់យើងមានជំនាញ មានថ្នាក់ទទួលខុសត្រូវ និង មានការដោះស្រាយជាបន្តបន្ទាប់ ។

***សំណួរ*** *: មាត្រា ៥៧ ហេតុអ្វីបានជារាជរដ្ឋាភិបាលមិនធ្វើការបង់ពន្ធដីស្រែចំការពីប្រជាកសិករ ឬ ចាំដកហូតដីពីកសិករអស់សិនចាំធ្វើការបង់ពន្ធ ព្រោះបច្ចុប្បន្នរាជរដ្ឋាភិបាលធ្វើការផ្ទេរដីសម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុន ។ ធ្វើឱ្យផលប៉ះពាល់ដល់កសិករជាអ្នករងគ្រោះ ។*

ចម្លើយ : រឿងដីសម្បទានសេដ្ឋកិច្ច គឺជារឿងអភិវឌ្ឍប្រទេសជាតិ ដើម្បីឱ្យមានក្រុមហ៊ុនធំៗសម្រាប់អភិវឌ្ឍកសិឧស្សាហកម្ម ពីព្រោះកសិកម្មគ្រួសារ ពុំអាចរកផលិតផលនាំចេញបានទេ ដូច្នេះត្រូវរកអ្នកមានលុយឱ្យគេចូលមកធ្វើ ។ រឿងដីសម្បទានសេដ្ឋកិច្ច ខ្ញុំមើលប្រវត្តិស្រុកខ្មែរ ពេលបារាំងចូល គឺចាប់ផ្ដើមធ្វើដីសម្បទានសេដ្ឋកិច្ចពិបាកណាស់នៅលើដីក្រហមខេត្តកំពង់ចាម ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ពីព្រោះមានការតវ៉ាខ្លាំងក្លាជាងសព្វថ្ងៃ ទៅទៀតជាមួយនឹងបងប្អូនជនជាតិដើមដែលរស់នៅពឹងផ្អែកលើជ័រ លើវល្លិ លើប្រម៉ាញ់បន្តិចបន្តួចហ្នឹង ។ អ៊ីចឹងទេវិធីដើម្បីអភិវឌ្ឍកសិកម្មសេដ្ឋកិច្ច ពិសេសអភិវឌ្ឍកសិកម្ម អាចមានកសិផលនាំចេញដើម្បីយករូបិយប័ណ្ណចូល គឺមានតែធ្វើដីសម្បទានសេដ្ឋកិច្ចហ្នឹងទេ ។

***សំណួរ*** ៖ *សូមឯកឧត្តមមេត្តាជួយបំភ្លឺ ជំពូកទី៥ អំពីសេដ្ឋកិច្ច មាត្រា ៦០ ចែងថា ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ឬ ការយកភោគផល ឬ ទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេស ដែលមានច្បាប់អនុញ្ញាត ។*

ចម្លើយ ៖ ជាគោលការណ៍មានច្បាប់គោល ប៉ុន្តែមានបដិប្បញ្ញត្តិបន្តិច វៀរលែងតែក្នុងករណីពិសេស ដែលច្បាប់អនុញ្ញាត ពេលសង្គ្រាម ពេលបរទេសឈ្លានពាន ពេលត្រូវកំណែន ។

***សំណួរ*** ៖ *ក្នុងមាត្រា ៦២ រដ្ឋជួយរកទីផ្សារលក់ផលិតផល តើផលិតផលនោះចាប់គិតពីចំនួនប៉ុន្មានគីឡូ ឬ ប៉ុន្មាន តោនឡើងទៅ ?*

ចម្លើយ ៖ ឥឡូវនេះឱ្យតែមានកសិផល គឺឈ្មួញមកទិញដល់ទីកន្លែងតែម្តង ។

***សំណួរ*** ៖ *១-តើដីសម្បទានសេដ្ឋកិច្ចសម្រាប់ក្រុមហ៊ុនដែលរដ្ឋឱ្យបង់ពន្ធ ១ហិចតាប៉ុន្មាន ប៉ុន្តែដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋនេះ សម្រាប់បងប្អូនប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិដីស្រែចំការនេះ សុំបង់ពន្ធដូចក្រុមហ៊ុនដែរដោយមិនយល់ព្រមឱ្យក្រុមហ៊ុនដកយកដីធ្លីបានដែរឬទេ ?*

*២-តើដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋ ដែលរដ្ឋគិតឱ្យក្រុមហ៊ុនប៉ុន្មានស្មើនឹងប៉ុន្មានដុល្លារ ?*

ចម្លើយ ៖ ១-ច្បាប់វិនិយោគ ហើយនិងអនុក្រឹត្យដែលស្តីពីការប្រែក្លាយដីរដ្ឋពីដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋទៅជាកម្មសិទ្ធិឯកជនរបស់រដ្ឋបានអាចធ្វើអនុបយោគទៅជាដីសម្បទាន ប៉ុន្តែគោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះដីស្រែចំការរបស់កសិករដែលគាត់ដាំដុះ គឺអត់មានយកពន្ធមួយរៀលទេ លើកលែងតែដីជួលពីក្រសួងកសិកម្ម ដែលមានកុងត្រាត្រូវបង់ពន្ធ ។

២-ខ្ញុំមិនច្បាស់ដែរ ព្រោះវាទៅតាមកិច្ចសន្យាដែលបានចែង ។ តាមខ្ញុំដឹងអាត្រាមិនសូវស្មើគ្នាទេ ព្រោះមានការយោគយល់ ជាគោលនយោបាយបើកទ្វារទូលាយ ដើម្បីឱ្យអ្នកមានលុយគេយកលុយមកវិនិយោគក្នុងកសិកម្ម ពិសេសក្នុងកសិឧស្សាហកម្ម ។

***សំណួរ*** ៖ *១-ដីកម្មសិទ្ធិបុគ្គលកាប់រានព្រៃមុនឆ្នាំ២០០០ ប៉ុន្តែមិនបានធ្វើលិខិតស្នាមកាន់កាប់ តើរដ្ឋអាចដកវិញដែរឬទេ?*

*២-ដីដាំដំណាំហើយ ប៉ុន្តែមិនបានធ្វើលិខិតស្នាមកាន់កាប់ តើរដ្ឋអាចដកយកទៅឱ្យក្រុមហ៊ុនដាំដំណាំឧស្សាហកម្មដែរឬទេ ?*

ចម្លើយ ៖ ១-អាចដកបានព្រោះវាជារឿងខុសច្បាប់ ។ ប្រទេសយើងមានច្បាប់ ដូច្នេះធ្វើអ្វីក៏ដោយត្រូវធ្វើតាមច្បាប់ បើទៅកាប់រានដីរាប់ហិចតាអត់មានអ្នកទទួលស្គាល់ម៉េចកើត ។

២-ត្រូវសុំច្បាប់អាជ្ញាធរដែនដី ព្រោះខេត្តព្រះវិហារបានបែងចែកទៅភូមិ ឃុំ ក្រុង សង្កាត់រួចហើយ ។

***សំណួរ : ហេតុអ្វីបានជាចាំបាច់ច្បាប់ត្រូវយកពន្ធដារពីប្រជាពលរដ្ឋ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញថែង បើមិនអីចឹងទេ រដ្ឋបានលុយពីណាសម្រាប់បើកប្រាក់ខែឱ្យមន្ត្រីរាជការ សម្រាប់យកទៅកសាងនេះកសាងនោះ ប្រទេសណាក៏គេយកពន្ធដែរ ។ ពន្ធយើងជាពន្ធនៅក្នុងកម្រិតមួយទេ មិនទាន់ក្លាយទៅជាប្រព័ន្ធពន្ធដ៏តឹងរឹងទេ ។

***សំណួរ : សូមពន្យល់បន្ថែមមាត្រា ៥៩ ជំពូកទី ៥ អំពីសេដ្ឋកិច្ច ?***

ចម្លើយ : សេដ្ឋកិច្ចទីផ្សារ ខុសពីសេដ្ឋកិច្ចផែនការ យើងកំពុងអនុវត្តសេដ្ឋកិច្ចទីផ្សារ ដែលបើកឱ្យមានការប្រកួតប្រជែង ដើម្បីឱ្យតម្លៃវាចុះថោកទៅតាមក្រិត្យក្រមទីផ្សារ ។

***សំណួរ : តើ "ប្រទេសកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ" មានន័យដូចម្តេច? តើពាក្យ "សេដ្ឋកិច្ចទីផ្សារ" និង "សេដ្ឋកិច្ចទីផ្សារសេរី" ខុសគ្នាដូចម្តេច?***

ចម្លើយ : ពាក្យទាំងពីរនេះមានន័យដូចគ្នា គ្រាន់តែភាសាខ្មែរយើងគេតែងចូលចិត្តបន្ថែមពាក្យ "សេរី" ពីក្រោយទៀត ដើម្បីផ្តល់ភាពច្បាស់លាស់ ។ ពាក្យ "សេដ្ឋកិច្ចទីផ្សារសេរី" នេះ ចង់សំដៅទៅដល់ការប្រកួតប្រជែង មានន័យថាប្រកួតប្រជែងទាំងទិញចូល និង ប្រកួតប្រជែងទាំងលក់ចេញ ដោយមិនមានអន្តរាគមន៍របស់អ្នកទីបីដែលជារដ្ឋនោះទេ ។ ប៉ុន្តែមិនមែនសេរី ដោយមិនមានក្របខ័ណ្ឌនោះទេ ដូចជាករណីវិទ្ធ្វេទកម្មសេដ្ឋកិច្ច (**Sabotage économique**) ឬ ការលូកដៃរបស់រដ្ឋ ចំពោះប្រភេទទំនិញដែលជាអាយុជីវិតរបស់ប្រជាពលរដ្ឋ ដូចជាស្រូវ អង្ករ និង ប្រភេទទំនិញចាំបាច់មួយចំនួនទៀតសម្រាប់ជីវភាពប្រចាំថ្ងៃ ។ ដូច្នេះ សេដ្ឋកិច្ចសេរី មានន័យថា ការធានាឱ្យមានការប្រកួតប្រជែងដោយសេរី ក្នុងក្របខ័ណ្ឌនៃច្បាប់ ។

# ពាក់ព័ន្ធនឹងជំពូកទី ៦
## អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច

**សំណួរ :** *មាត្រា ៧៤ រដ្ឋជួយឧបត្ថម្ភជនពិការ និង គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រយោជន៍ជាតិ ។ ពិនិត្យឃើញថា តាមសាលារៀននានាមិនមានកន្លែងសម្រាប់សម្រួលដល់អ្នកពិការក្នុងការចូលរៀនសូត្រឡើយ ? អ្នកពិការជិះរទេះពុំអាចចូលរៀនសូត្របានច្រើនទេ ដោយសារសាលាខ្ពស់ៗពុំមានជាន់ក្រោមសម្រាប់អ្នកពិការសិក្សា ។ តើគោលការណ៍ដោះស្រាយរបស់ថ្នាក់ដឹកនាំកំពូលៗធ្វើយ៉ាងណា ដើម្បីឱ្យជនពិការមានលទ្ធភាពរៀនសូត្រដូចសិស្សនិស្សិតនានាបាន ?*

**ចម្លើយ :** ជាគោលការណ៍ សម្រាប់ជនពិការគេផ្តល់អាទិភាពឱ្យច្រើនណាស់ ។ ប្រទេសជឿនលឿនគេធ្វើបានរួចហើយ ប៉ុន្តែសម្រាប់ប្រទេសយើងគួរតែលើកសំណូមពរតាមរយៈតំណាងរបស់ខ្លួន ដូចជាតាមរយៈឃុំ សង្កាត់ ខេត្ត ក្រុង ស្រុក ខណ្ឌ ជាដើមជូនទៅរាជរដ្ឋាភិបាល ។ យើងត្រូវការពេលវេលាបន្តទៅទៀត ព្រោះនេះជាការងាររបស់ថ្នាក់ដឹកនាំក្នុងការកសាងជាតិ ។

**សំណួរ :** *មាត្រា ៧២ សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ ចុះហេតុអ្វីបានជានៅតាមមន្ទីរពេទ្យមួយចំនួនពេលឃើញរាស្ត្រក្រីក្រគ្មានលុយ គឺមិនព្យាបាល ?*

**ចម្លើយ :** ជាសីលធម៌ ជាវិន័យរបស់គ្រូពេទ្យ ជារឿងមួយផ្សេងទៀត និយាយរួម គឺជារឿងបុគ្គល ។

**សំណួរ :** *មាត្រា ៧២ ទំព័រ ២៤ តើស្ថាប័នណាដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងលើការពិនិត្យ សុខភាពដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ ? ហើយធ្វើយ៉ាងណាទើបដឹងថា បុគ្គលណាម្នាក់ស្ថិតក្នុងភាពក្រីក្រ ?*

**ចម្លើយ :** វាជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។ ចំពោះបញ្ហាបង់ថ្លៃ ឬ មិនបង់ថ្លៃ ត្រូវនៅរង់ចាំមានច្បាប់ពិសេសដោយឡែក ដើម្បីកំណត់ពីបញ្ហានេះទៀត ។

**សំណួរ :** *មាត្រា ៧២ នៃរដ្ឋធម្មនុញ្ញ ចែងថា ប្រជារាស្ត្រក្រីក្រត្រូវទទួលបានការពិនិត្យរោគដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋ ។ តើពាក្យ ពិនិត្យរោគ និង ព្យាបាលរោគទាក់ទងគ្នាទេ ?*

**ចម្លើយ :** ជាគោលការណ៍ ការពិនិត្យរោគ គឺជាការស្វែងរករោគសញ្ញា និង មូលហេតុដែលធ្វើឱ្យមានជម្ងឺ ហើយទើបធ្វើការព្យាបាល ដូចជាការពិនិត្យកំដៅ ចង្វាក់បេះដូង ពិនិត្យសំពាធឈាម ជាដើម ។

**សំណួរ :** *ជំពូកទី៦ មាត្រា៧១ បរិវេណបេតិកភណ្ឌជាតិ ក៏ដូចជាបេតិកភណ្ឌដែលបានបញ្ចូលជាបេតិកភណ្ឌពិភពលោក ត្រូវចាត់ចូលជាតំបន់អព្យាក្រឹតដែលមិនឱ្យមានសកម្មភាពយោធា ។ ដោយតំបន់បេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារដែលកំពុងមានសកម្មភាពយោធា ?*

**ចម្លើយ :** សូមបើកមើលមាត្រា ៥២ ដែលជាមាត្រាបដិប្បញ្ញត្តិទៅនឹងមាត្រា ៧១ "រាជរដ្ឋាភិបាលប្តេជ្ញាការពារឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា" អ៊ីចឹង រឿងប្រាសាទព្រះវិហារ

ជារឿងបូរណភាពទឹកដី បើកុំមានថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៨ តើយើងមានការចាំបាច់អីឱ្យមានសកម្មភាពយោធា ។ យើងបានអនុវត្តមាត្រានេះ ហេតុដូច្នេះហើយទើបយើងបានបង្កើនកម្លាំង ដើម្បីពង្រឹងបន្ទាត់ព្រំដែននៅតំបន់ប្រាសាទព្រះវិហារ ។

***សំណួរ : ជំពូកទី៦ ស្តីអំពីអប់រំ វប្បធម៌ និង សង្គមកិច្ច ។ មាត្រា ៦៨ ចែងអំពីប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ឆ្នាំ តើក្នុងករណីឪពុក-ម្តាយបង្ខំកូនឱ្យឈប់រៀនតិចជាង ៩ឆ្នាំ តើមានទោសយ៉ាងណា ?***

ចម្លើយ : ឪពុកម្តាយ បើមានកូនគ្រប់អាយុចូលរៀនហើយ មិនបញ្ជូនកូនឱ្យទៅរៀន ជាគោលការណ៍ គឺមានទោស ព្រោះនេះជាកាតព្វកិច្ចឪពុកម្តាយ ។ ប៉ុន្តែសួរថា ដាក់ទោសយ៉ាងម៉េច បើប្រជាកសិករយើងខ្លះក្រីក្រ ។ សូមមន្ទីរអប់រំថតចម្លងច្បាប់ស្តីពីការអប់រំចែកទៅមន្ទីរផ្សេងៗ និង ជួយផ្សព្វផ្សាយផង ។

# ពាក់ព័ន្ធនឹងជំពូកទី ៧

## អំពីរដ្ឋសភា

**សំណួរ :** *មាត្រា ៨៨ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ សម្រាប់ការអនុម័តទាំងឡាយដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីមានអ្វីខ្លះ ?*

ចម្លើយ : បច្ចុប្បន្ននេះនៅក្នុងសៀវភៅរដ្ឋធម្មនុញ្ញដែលចែងឱ្យរដ្ឋសភា ឬ ព្រឹទ្ធសភាប្រជុំអនុម័តយកសំឡេងភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ឬ ពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល មានពីរបីករណី ។ ទី១ ការកែប្រែរដ្ឋធម្មនុញ្ញ បើគ្មានសំឡេងពីរភាគបីទេ គឺកែប្រែមិនបានទេ ។ ទី២ ការដកអភ័យឯកសិទ្ធិតំណាងរាស្ត្រ ឬ ដកអភ័យឯកសិទ្ធិសមាជិកព្រឹទ្ធសភាក៏ទាមទារឱ្យមានសំឡេងពីរភាគបីដែរ ។ ប៉ុន្តែនៅមានសំឡេងមួយទៀត គឺសំឡេងបីភាគបួន គឺចំពោះសមាជិករដ្ឋសភា ឬ សមាជិកព្រឹទ្ធសភាណាដែលត្រូវបានតុលាការចោទប្រកាន់ កំពុងដំណើរការនីតិវិធី ហើយបើរដ្ឋសភា ឬ ព្រឹទ្ធសភាយល់ថា ការចោទប្រកាន់របស់តុលាការហ្នឹងខុស គឺរំលោភច្បាប់ រំលោភលើអភ័យឯកសិទ្ធិតំណាងរាស្ត្រ ឬ សមាជិកព្រឹទ្ធសភា រដ្ឋសភា ឬ ព្រឹទ្ធសភាអាចប្រជុំ ហើយបោះឆ្នោតបញ្ចប់នីតិវិធីរបស់តុលាការបានដោយសំឡេងបីភាគបួន ។

**សំណួរ:** *យោងមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងអំពីការបែងចែកអំណាចដាច់ពីគ្នា តែមាត្រា ៩១ថ្មី នៃរដ្ឋធម្មនុញ្ញ តុលាការមិនត្រូវបានច្បាប់អនុញ្ញាតឱ្យមានសិទ្ធិក្នុងការធ្វើច្បាប់ឡើយ តើមាត្រា ៩១ថ្មី នេះ ធានាសិទ្ធិស្មើភាពរវាងស្ថាប័នទាំងបីដែរឬទេ ?*

ចម្លើយ : តុលាការជាអ្នកអនុវត្តច្បាប់ ហើយរដ្ឋសភាជាអ្នកធ្វើច្បាប់ ដូច្នេះរាល់ច្បាប់ណាដែលពាក់ព័ន្ធនឹងតុលាការ ការធ្វើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះត្រូវបញ្ជូនទៅឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យជាមុនសិន ។ ចំពោះតុលាការឥតមានធ្វើច្បាប់ទេ មានតែរដ្ឋសភា និង ព្រឹទ្ធសភាទេ ចំណែកឯនាយករដ្ឋមន្ត្រីក៏មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ដែរ ព្រោះនាយករដ្ឋមន្ត្រីយកច្បាប់ទៅអនុវត្តក្នុងការគ្រប់គ្រងទាំងអស់ ហើយច្បាប់ភាគច្រើនកើតចេញពីរាជរដ្ឋាភិបាលជាអ្នកធ្វើសំណើឡើង ។

**សំណួរ:** *ហេតុអ្វីបានជាតំណាងរាស្ត្រមានសិទ្ធិធ្វើវិសោធនកម្មច្បាប់ ? ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬ បន្ថែមបន្ទុកលើប្រជាពលរដ្ឋ ?*

ចម្លើយ : រឿងសិទ្ធិផ្តើមគំនិតធ្វើច្បាប់ សិទ្ធិនេះមានចែងក្នុងរដ្ឋធម្មនុញ្ញ គឺតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា នាយករដ្ឋមន្ត្រី ។ ដូច្នេះរដ្ឋធម្មនុញ្ញកំណត់សិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ គំនិតធ្វើវិសោធនកម្ម ។ ត្រង់ថាមិនឱ្យធ្វើវិសោធកម្មសំដៅបន្ថយប្រាក់ចំណូលរបស់រដ្ឋ គឺកាលណាធ្វើទៅវាប្រតិឃាតខ្លាំងណាស់ ពីព្រោះចំណូល និង ចំណាយរបស់រដ្ឋកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

**សំណួរ:** *ហេតុអ្វីសមាជិករដ្ឋសភាមិនកំណត់អាយុបេក្ខភាពដូចសមាជិកព្រឹទ្ធសភា ?*

ចម្លើយ : ដើម្បីឈរឈ្មោះជាតំណាងរាស្ត្រ ត្រូវមានអាយុ ២៥ឆ្នាំយ៉ាងតិច សញ្ជាតិខ្មែរពីកំណើត ។ ចំពោះសមាជិកព្រឹទ្ធសភា អាយុ ៤០ឆ្នាំយ៉ាងតិច សញ្ជាតិខ្មែរពីកំណើតដូចគ្នា ។ សូមមើលមាត្រា ៣៤ថ្មី នៃរដ្ឋធម្មនុញ្ញ ។ សភាទាំងពីរមានថ្នាក់ខុសគ្នា ព្រឹទ្ធសភាជាអំណាចនីតិប្បញ្ញត្តិមួយដែលប្រកបដោយគតិបណ្ឌិត ឬ គេហៅថា ជាសភាដែលចាស់ទុំ ទើបមានការកម្រិតអាយុខ្ពស់ជាង ។

**សំណួរ:** *ខ្ញុំបាទមានភាពមិនច្បាស់លាស់អំពីបញ្ហាដែលនៅពេលប្រទេសជាតិមានភាពអាសន្ន ហេតុអ្វីបានជារដ្ឋសភាមិនអាចរំលាយបាន ?*

ចម្លើយ : ព្រោះស្ថានភាពប្រទេសជាតិនៅពេលនោះកើតកលិយុគ បះបោរពេញផ្ទៃប្រទេស ពេលនោះហើយអ្នកដែលជាតំណាងរបស់ប្រជារាស្ត្រមានតែរដ្ឋសភាទេ គឺពេលនោះរដ្ឋសភាប្រជុំរាល់ថ្ងៃ ដោះស្រាយនូវរាល់បញ្ហាធំៗរបស់ប្រទេសជាតិ ដើម្បីបញ្ចប់ភាពវឹកវរទាំងអស់នោះ ។

**សំណួរ:** *មាត្រា ៨១ នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា " រដ្ឋសភាមានថវិកាស្វយ័ត សម្រាប់ដំណើរការ " តើថវិកានោះបានមកពីណា ?*

ចម្លើយ : បានមកពីថវិការដ្ឋទាំងស្រុង។ បើមើលពីតារាងថវិកាជាតិ គឺក្រសួងព្រះបរមរាជវាំង លេខរៀងទី១ រដ្ឋសភាលេខរៀងទី២ ព្រឹទ្ធសភាលេខរៀងទី៣ និងក្រុមប្រឹក្សាធម្មនុញ្ញលេខរៀងទី៤ ។

**សំណួរ :** *មាត្រា ៨៨ថ្មី (ពីរ) តើពេលណាគេប្រើកូរ៉ុម សំឡេងដាច់ខាត និង ពេលណាគេប្រើកូរ៉ុមពីរភាគបី ឬ ច្រើនជាងនេះសម្រាប់ធ្វើការអនុម័ត ?*

ចម្លើយ : ការប្រើសំឡេងដាច់ខាត គឺលើសពីពាក់កណ្តាលនៃសមាជិកទាំងមូល ដល់ទៅកូរ៉ុមពីរភាគបី ឬ ច្រើនជាងនេះ ដូចជាការអនុម័តលើច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវការសម្លេង ពីរភាគបី ឬ ការលើកអភ័យឯកសិទ្ធិតំណាងរាស្ត្រណាមួយត្រូវការពីភាគបីដែរ ។

**សំណួរ :** *តើរដ្ឋសភាអាចធ្វើញត្តិបន្ទោសទម្លាក់រាជរដ្ឋាភិបាលបាននៅពេលណា ? មូលហេតុអ្វី ?*

ចម្លើយ : សូមមើលនីតិវិធីមាត្រា ៩៨ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា " *រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកយកមកពិភាក្សាបាន* "។

**សំណួរ :** *រាជរដ្ឋាភិបាលអាចទម្លាក់សភាបាននៅពេលណា ? មូលហេតុអ្វី ?*

ចម្លើយ : នៅពេលដែលរដ្ឋសភាខ្លួនឯងទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល១២ខែ ។ នៅពេលនោះរដ្ឋសភាត្រូវតែរំលាយខ្លួនឯងតែម្តង ។

***សំណួរ : សូមឯកឧត្តម មេត្តាជួយពន្យល់មាត្រា ៧៩ នៃរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : មាត្រា ៧៩ នៃរដ្ឋធម្មនុញ្ញបានចែងថា " *អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និង ជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា ។*" ។ ម្ចាស់សំណួរប្រហែលមានន័យថា ចង់ឱ្យពន្យល់វិសមិតភាពក្នុងមុខងាររបស់តំណាងរាស្ត្រ ។ សមាជិករដ្ឋសភាមិនអាចជាសមាជិកសកម្មនៃស្ថាប័នដទៃ ឧទាហរណ៍ ប្រធានអាជ្ញាធរសវនកម្ម ឬ ប្រធាន គ.ជ.ប ឬ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញនោះទេ ។ ចំពោះឃ្លាដែលថា "*សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុង គណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា* " គឺយើងអាចឃើញហើយ នាយករដ្ឋមន្ត្រី លោកមិនមានតួនាទីក្នុងគណៈកម្មការណាមួយក្នុងរដ្ឋសភានោះទេ គឺលោកជាសមាជិកសភាធម្មតា។ យើងអាចនិយាយបានថា សមាជិករដ្ឋសភាមិនអាចជាអ្នកធ្វើច្បាប់ផង ហើយអនុវត្តច្បាប់ផងនោះទេ ។ ពាក្យ វិសមិតភាព ជាពាក្យច្បាប់រដ្ឋធម្មនុញ្ញ គឺមានន័យថា ក្នុងពេលតែមួយសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា មិនអាចទៅបំពេញមុខងារដទៃទៀត ឬ យើងអាចថាធ្វើត្រួតគ្នាដែលច្បាប់បានហាមនោះទេ ប៉ុន្តែអាចដាក់ពាក្យសុំច្បាប់ឈប់ពិសេសណាមួយ ដើម្បីទៅធ្វើការងារផ្សេង ឬ លាឈប់ពីមុខតំណែងរបស់ខ្លួនជាមុនសិន ។ ឧទាហរណ៍ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតបេក្ខជនសមាជិករដ្ឋសភាត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសមួយខែមុន ទើបមានសិទ្ធិចុះទៅឃោសនាបោះឆ្នោត ។ ចំពោះបុគ្គលណាដែលមានក្របខ័ណ្ឌ ហើយបានជាប់ឈ្មោះជាតំណាងរាស្ត្រត្រូវព្យួរក្របខ័ណ្ឌដើមរបស់ខ្លួន នៅពេលចប់អាណត្តិតំណាងរាស្ត្រ បុគ្គលនោះអាចវិលមកចូលក្នុងក្របខ័ណ្ឌដើមវិញបាន ។

***សំណួរ : បើតំណាងរាស្ត្រម្នាក់ៗ រដ្ឋធម្មនុញ្ញមិនបានចែងពីកម្រិតសញ្ញាបត្រទេ តើគាត់មានសមត្ថភាពខាងធ្វើច្បាប់ដែរឬទេ ? នៅពេលដែលគាត់ចូលកាន់តំណែងជាតំណាងរាស្ត្រក្នុងរដ្ឋសភា ?***

ចម្លើយ : ពាក់ព័ន្ធនឹងរឿងតំណាងរាស្ត្រនេះ គឺជាសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ កាលណាលោកពេញចិត្តនឹងបុគ្គលណា លោកនឹងបោះឆ្នោតឱ្យ ដូច្នេះគេមិននិយាយអំពីសញ្ញាបត្រទេ ប៉ុន្តែពុំមែនមានន័យថា សញ្ញាបត្ររបស់តំណាងរាស្ត្រមិនសំខាន់នោះទេ កាលដែលមិនមានចែងអំពីសញ្ញាបត្រនេះ វាគឺជាស្មារតីរបស់ច្បាប់ ។ ម្យ៉ាងទៀតអ្នកតំណាងរាស្ត្រ គឺជាអ្នកនយោបាយ លោកមិនមែនស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការដែលចាំបាច់ត្រូវតែមានសញ្ញាបត្រដើម្បីប្រឡងយកក្របខ័ណ្ឌនោះទេ ។ ដូច្នេះចំណុចសំខាន់របស់អ្នកនយោបាយ គឺប្រជាប្រិយភាព សមត្ថភាព និងបទពិសោធន៍ ដែលអាចធ្វើឱ្យរាស្ត្រទុកចិត្តបាន ប៉ុន្តែបើលោកមានសញ្ញាបត្របន្ថែមទៀត វាកាន់តែធ្វើឱ្យអ្នកតំណាងរាស្ត្រនោះមានភាពលេចធ្លោ ។

***សំណួរ៖ រដ្ឋសភាអាចទម្លាក់គណៈរដ្ឋមន្ត្រី ឬ រាជរដ្ឋាភិបាលពីតំណែង ។ យោងតាមខ្លឹមសារនេះ តើសមាជិករដ្ឋសភាអាចអនុវត្តទៅបានដោយប្រសិទ្ធភាពដែរឬទេ បើសមាជិកភាគច្រើននៃរដ្ឋសភាកើតចេញពីគណបក្សកាន់អំណាច?***

ចម្លើយ ៖ ដើម្បីទម្លាក់គណៈរដ្ឋមន្ត្រីចេញពីតំណែងបាន យើងត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ។ វាផ្ដើមចេញពីការដាក់ជាសំណួរ-ចម្លើយ ការដាក់ញត្តិបន្ទោសដែលតម្រូវឱ្យមានតំណាងរាស្ត្រយ៉ាងតិច៣០នាក់ និង ការអនុម័តទទួល ឬ មិនទទួលញត្តិបន្ទោស ។

***សំណួរ៖ តើថវិកាស្វយ័តសម្រាប់ដំណើរការរដ្ឋសភាបានមកពីកញ្ចប់ថវិកាខ្ទង់ណា? ចំនួនប៉ុន្មានក្នុងមួយឆ្នាំ?***

ចម្លើយ ៖ ពាក្យ "ថវិកាស្វយ័ត" មានន័យថាប្រភពចំណូលបានមកពីថវិកាជាតិ ។ ប្រហែលជា ១៦ ពាន់លានរៀលក្នុងមួយឆ្នាំៗ (សូមមើលច្បាប់ថវិកាប្រចាំឆ្នាំ) ។

***សំណួរ៖ តើមានច្បាប់ចំនួនប៉ុន្មានហើយដែលរដ្ឋសភាបានអនុម័ត? អ្វីខ្លះ ?***

ចម្លើយ ៖ ខ្ញុំសូមជម្រាបតែអ្វីដែលខ្ញុំបានដឹងទេ ពីព្រោះនេះគឺជាសមត្ថកិច្ចរបស់រដ្ឋសភាទៅវិញទេ ។ ក្នុងអាណត្តិទី១ ឆ្នាំ១៩៩៣-១៩៩៨ រដ្ឋសភាបានអនុម័ត ៩០ច្បាប់ អាណត្តិទី២ ឆ្នាំ១៩៩៨-២០០៣ បានអនុម័ត ៨៨ច្បាប់ អាណត្តិទី៣ ឆ្នាំ២០០៣-២០០៨ បានអនុម័ត ១៤៥ច្បាប់ អាណត្តិទី៤ ឆ្នាំ២០០៨-២០១៣ ខ្ញុំពុំមានតួលេខនៅឡើយទេ ប៉ុន្តែរដ្ឋសភាបានអនុម័តច្បាប់សំខាន់ៗមួយចំនួន រួមមាន ក្រមរដ្ឋប្បវេណី ក្រមនីតិវិធី រដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ហើយយើងនៅមានច្បាប់ជាច្រើនទៀតដែលត្រូវអនុម័ត ជាពិសេសច្បាប់ទាក់ទងទៅនឹងវិស័យតុលាការសម្រាប់ចៅក្រម ព្រះរាជអាជ្ញា មានច្បាប់ស្តីពីរចនាសម្ព័ន្ធចាត់តាំងតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញាជាដើម ។

***សំណួរ៖ តើព្រឹទ្ធសភា និង រដ្ឋសភា ប្រើអំណាចនីតិប្បញ្ញត្តិដូចម្ដេច ?***

ចម្លើយ ៖ តាមរដ្ឋធម្មនុញ្ញ ស្ថាប័នទាំងពីរនេះមានអំណាចនីតិប្បញ្ញត្តិ មានន័យថាមានអំណាចធ្វើច្បាប់ ពិភាក្សា និង អនុម័តច្បាប់។ ក្រោយពីរដ្ឋសភាបានពិភាក្សា និង អនុម័តច្បាប់ហើយ ត្រូវបញ្ជូនអត្ថបទច្បាប់នោះមកឱ្យព្រឹទ្ធសភាដើម្បីពិនិត្យ និង ឱ្យយោបល់។ ភាពខុសគ្នារវាងស្ថាប័នទាំងពីរនេះនៅត្រង់ថា ព្រឹទ្ធសភាពុំមានសិទ្ធិក្នុងការផ្ដួចផ្ដើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដូចរដ្ឋសភាទេ។ នៅពេលណា ដែលរាជរដ្ឋាភិបាល និង រដ្ឋសភា មានបញ្ហាមិនចុះសម្រុងនឹងគ្នា នោះព្រឹទ្ធសភានៅមានអំណាចមួយទៀតក្នុងការសម្របសម្រួលស្ថាប័នទាំងពីរនេះ ។ ម្យ៉ាងវិញទៀត ខុសគ្នាត្រង់ថា ព្រឹទ្ធសភាពុំមានអំណាចក្នុងការបោះឆ្នោតជ្រើសតាំងរាជរដ្ឋាភិបាល ការត្រួតពិនិត្យរាជរដ្ឋាភិបាល ការធ្វើញត្តិបន្ទោស និង ការបោះឆ្នោតដកសេចក្ដីទុកចិត្តពរាជរដ្ឋាភិបាលដូចរដ្ឋសភាទេ ។

***សំណួរ : បច្ចុប្បន្នសៀមបានឈ្លានពានវត្តកែវសិក្ខាគិរីស្វារៈ (ហៅវត្តប្រាសាទ) និង ៤,៦$Km^2$ តំបន់ប្រាសាទព្រះវិហារ ថាទឹកដីរបស់ពួកវា ។ បើពិនិត្យទៅលើមាត្រា ១៥២ថ្មី និង មាត្រា ៨៦ ប្រទេសជាតិមិនស្ថិតក្នុងភាពអាសន្ន តើស្ថិតក្នុងភាពអ្វី ?***

ចម្លើយ : អត់ទាន់មានភាពអាសន្នទេ ដើម្បីប្រកាសភាពអាសន្នបានទាល់តែរដ្ឋសភា ព្រឹទ្ធសភាប្រជុំ ហើយព្រះមហាក្សត្រទ្រង់ជាអ្នកប្រកាស ។

***សំណួរ : មាត្រា ៧៦ បានបញ្ជាក់ថា ប្រជាពលរដ្ឋមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ លុះត្រាតែមានសញ្ជាតិជាខ្មែរពីកំណើត ។ ប៉ុន្តែពលរដ្ឋខ្លះមានសញ្ជាតិខ្មែរពីកំណើត តែបានទៅនៅបរទេស ហើយបានចូលសញ្ជាតិបរទេស តើពលរដ្ឋនោះអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្របានដែរឬទេ ?***

ចម្លើយ : ឱ្យតែគាត់កើតមកបានសញ្ជាតិខ្មែរ គឺគាត់អាចឈរឈ្មោះបាន អត់មានបែងចែកសញ្ជាតិពីរមិនអាចឈរបាននោះទេ ។

***សំណួរ : សូមជួយពន្យល់អំពីភាពខុសគ្នារវាងភារកិច្ចសភាធម្មនុញ្ញ និង សមាជិករដ្ឋសភា ?***

ចម្លើយ : សភាធម្មនុញ្ញ គឺមានភារកិច្ចសរសេរ តាក់តែង ពិភាក្សា និង អនុម័តរដ្ឋធម្មនុញ្ញ ។ សភាជាតិមានភារកិច្ចធ្វើច្បាប់ ។ ឋានានុក្រមនៃច្បាប់ខ្ពស់ជាងគេ គឺរដ្ឋធម្មនុញ្ញ ក្រោមរដ្ឋធម្មនុញ្ញ គឺច្បាប់ ក្រោមច្បាប់គឺអនុក្រឹត្យ ក្រោមអនុក្រឹត្យ គឺសេចក្តីសម្រេច ប្រកាស ដីកា ។ល។

***សំណួរ : មាត្រា ៧៦ មូលហេតុអ្វីបានជាតំណាងរាស្ត្រស្រុកខ្មែរច្រើនម្ល៉េះ បើប្រជាជនតិច ?***

ចម្លើយ : អត់ច្រើនទេ គណបក្សសិទ្ធិមនុស្ស គណបក្សសមរង្ស៊ី កំពុងទាមទារបង្កើនអាសនៈថែមទៀតព្រោះបើគិតជាអត្រាមធ្យម តំណាងរាស្ត្រម្នាក់ តំណាងឱ្យប្រជាពលរដ្ឋទាំងក្មេងទាំងចាស់ប្រហែលឡើងដប់ប្រាំម៉ឺននាក់ជាងហើយ ដូច្នេះ ១២៣រូប លើចំនួនប្រជាជនសរុបទាំងក្មេងទាំងចាស់ដប់បួនលាននាក់វាអត់ច្រើនទេ ។

## ពាក់ព័ន្ធនឹងជំពូកទី ៨ថ្មី
## អំពីព្រឹទ្ធសភា

***សំណួរ : តើថវិកាស្វយ័តរបស់ព្រឹទ្ធសភា រដ្ឋសភា និង ក្រុមប្រឹក្សាធម្មនុញ្ញជាថវិការបស់ជាតិ ឬជាថវិកាអ្វី? សូមជួយបំភ្លឺ ?***

ចម្លើយ : គឺជាថវិកាជាតិ ដែលមាននៅក្នុងតារាងចំណាយថវិកាជាតិប្រចាំឆ្នាំ ។ ពាក្យថា ស្វយ័តនេះខុសពីពាក្យស្វយ័តភិបាលហិរញ្ញវត្ថុ ? ស្វយ័តភិបាលហិរញ្ញវត្ថុ ? ស្ថាប័ននោះត្រូវរកចំណូលដោយខ្លួនឯងដោយស្របច្បាប់ និងធានាការចំណាយក្នុងស្ថាប័នទាំងឡាយដោយស្របច្បាប់ដែរ តែស្ថាប័នព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សា-ធម្មនុញ្ញ មិនមែនជាស្ថាប័នដែលរកចំណូលទេ ។ នៅក្នុងតារាងចំណាយថវិកាជាតិ ក្រសួងព្រះបរមរាជវាំងឋិតនៅលេខរៀងទី១ ព្រឹទ្ធសភាលេខរៀងទី២ រដ្ឋសភាលេខរៀងទី៣ ហើយក្រុមប្រឹក្សាធម្មនុញ្ញឋិតនៅលេខរៀងទី៤ ។

***សំណួរ : តើតួនាទី ភារកិច្ច របស់ព្រឹទ្ធសភាធ្វើអ្វីខ្លះ ?***

ចម្លើយ : សូមមើលក្នុងរដ្ឋធម្មនុញ្ញត្រង់ជំពូកទី៨ថ្មី អំពីព្រឹទ្ធសភា ។

***សំណួរ : ស្ថាប័នរដ្ឋសភា ព្រឹទ្ធសភា និង រាជរដ្ឋាភិបាល ជាស្ថាប័នកំពូលដូចគ្នារបស់រដ្ឋ តែមាត្រា ១១២ថ្មី នៃរដ្ឋធម្មនុញ្ញបែរជាលើកឡើងថា : ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និង រាជរដ្ឋាភិបាលទៅវិញ ។ សូមជួយបកស្រាយ ?***

ចម្លើយ : នេះគ្រាន់តែការសម្របសម្រួលមួយ ហើយប្រហែលជាមិនអាចកើតមាននោះទេ ព្រោះថារាជរដ្ឋាភិបាលកើតចេញពីរដ្ឋសភា ឬ កើតចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា ។ ដូច្នេះយើងអាចដឹងថា ទាំងរាជរដ្ឋាភិបាល ទាំងរដ្ឋសភា សមាជិកភាគច្រើនសុទ្ធតែកើតចេញតែពីសមាជិកគណបក្សតែមួយនេះគ្រាន់តែជាកិច្ចបង្ការតែប៉ុណ្ណោះ ព្រោះយើងមានបទពិសោធន៍មួយនៅឆ្នាំ១៩៩៧ គឺមានភាពមិនចុះសម្រុងនឹងគ្នាក្នុងគណបក្សតែមួយ ធ្វើឱ្យនយោបាយមានភាពច្របូកច្របល់ ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ប្រសិនបើគណបក្សនយោបាយមួយឈ្នះឆ្នោតហើយ បង្កើតរដ្ឋសភា បង្កើតរាជរដ្ឋាភិបាលហើយ បើគណបក្សនោះមិនចេះសាមគ្គីគ្នា ឯកភាពផ្ទៃក្នុងគណបក្សទេនោះ វាអាចនឹងធ្វើឱ្យមានភាពច្របូកច្របល់ ធ្វើឱ្យមានអស្ថេរភាពនយោបាយ ។

***សំណួរ : តើសមាជិកព្រឹទ្ធសភាមានចំនួនប៉ុន្មានរូប ? ដោយមាត្រា ៩៩ នៃរដ្ឋធម្មនុញ្ញ ជំពូកទី៨ ស្តីពីព្រឹទ្ធសភា ចែងថា សមាជិកព្រឹទ្ធសភាត្រូវស្មើនឹងពាក់កណ្តាលនៃសមាជិករដ្ឋសភាទាំងមូល ។ ហើយមាត្រា ១៥៧ នៃរដ្ឋធម្មនុញ្ញចែងថា សមាជិកចំនួន ៦១រូប សំរាប់នីតិកាលទី១នៃរដ្ឋសភា ។***

ចម្លើយ : តាមស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាជារួមត្រូវមានមិនលើសពីចំនួនពាក់កណ្តាលសមាជិករដ្ឋសភា ។ រដ្ឋសភានីតិកាលទី២ មានសមាជិក ១២២រូប

ដូច្នេះសមាជិកព្រឹទ្ធសភាត្រូវនឹង ៦១រូប ។ ក្នុងនោះ ០២រូបតែងតាំងដោយព្រះមហាក្សត្រ និង ០២រូប ជ្រើសតាំងដោយរដ្ឋសភា សល់ប៉ុន្មានត្រូវបោះឆ្នោតជាអសកល គឺដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលចងក្រងជាមណ្ឌល មណ្ឌលចងក្រងជាភូមិភាគ និងដោយតំណាងរាស្ត្រក្នុងភូមិភាគនោះ ។

***សំណួរ : ប្រសិនបើច្បាប់មួយ ដូចជាច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលច្បាប់បានអនុម័តដោយរដ្ឋសភាហើយ បន្ទាប់ពីព្រឹទ្ធសភាគ្មានពេលគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះ ហើយបញ្ជូនទៅព្រះមហាក្សត្រ ដើម្បីប្រកាសឱ្យប្រើ ។ តើច្បាប់ដែលព្រឹទ្ធសភាបានអះអាងដូច្នេះ អាចមានអានុភាពអនុវត្តឬទេ ?***

ចម្លើយ : ផ្អែកលើមាត្រានៃរដ្ឋធម្មនុញ្ញដែលចែងថា ច្បាប់ដែលរដ្ឋសភាបានអនុម័តចប់សព្វគ្រប់ហើយ ព្រឹទ្ធសភាលោកអាចថាមិនមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យច្បាប់នោះ ច្បាប់នោះនឹងអនុវត្តនីតិវិធីទៅព្រះមហាក្សត្រ ចំណុចនេះមិនមានបញ្ហាអ្វីទេ ។ ប្រសិនបើមានអធម្មនុញ្ញភាព ប្រធានព្រឹទ្ធសភា សមាជិកព្រឹទ្ធសភា ១/៤ អាចស្នើមកក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យជាក្រោយបាន ។

***សំណួរ : សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា មានន័យដូចម្តេច ?***

ចម្លើយ : អភ័យឯកសិទ្ធិសភា គឺជាសិទ្ធិពិសេសរបស់សភា ពុំមែនតែជារបស់តំណាងរាស្ត្រទេ ពោលគឺពុំមែនជាសិទ្ធិដាច់មុខរបស់សមាជិករដ្ឋសភាឡើយ ។ សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា មានន័យថា ច្បាប់បានផ្តល់ការការពារដល់សមាជិកព្រឹទ្ធសភា តាមរយៈអភ័យឯកសិទ្ធិមួយដូចគ្នានឹងតំណាងរាស្ត្រដែរ ។

***សំណួរ : តើព្រឹទ្ធសភា និង រដ្ឋសភា ប្រើអំណាចនីតិប្បញ្ញត្តិដូចម្តេច ?***

ចម្លើយ : តាមរដ្ឋធម្មនុញ្ញ ស្ថាប័នទាំងពីរនេះមានអំណាចនីតិប្បញ្ញត្តិ មានន័យថាមានអំណាចធ្វើច្បាប់ ពិភាក្សា និង អនុម័តច្បាប់។ ក្រោយពីរដ្ឋសភាបានពិភាក្សា និង អនុម័តច្បាប់ហើយ ត្រូវបញ្ជូនអត្ថបទច្បាប់នោះមកឱ្យព្រឹទ្ធសភាដើម្បីពិនិត្យ និង ឱ្យយោបល់។ ភាពខុសគ្នារវាងស្ថាប័នទាំងពីរនេះនៅត្រង់ថា ព្រឹទ្ធសភាពុំមានសិទ្ធិក្នុងការផ្តួចផ្តើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដូចរដ្ឋសភាទេ។ នៅពេលណា ដែលរាជរដ្ឋាភិបាល និង រដ្ឋសភា មានបញ្ហាមិនចុះសម្រុងនឹងគ្នា នោះព្រឹទ្ធសភានៅមានអំណាចមួយទៀតក្នុងការសម្របសម្រួលស្ថាប័នទាំងពីរនេះ ។ ម្យ៉ាងវិញទៀត ខុសគ្នាត្រង់ថា ព្រឹទ្ធសភាពុំមានអំណាចក្នុងការបោះឆ្នោតជ្រើសតាំងរាជរដ្ឋាភិបាល ការត្រួតពិនិត្យរាជរដ្ឋាភិបាល ការធ្វើញត្តិបន្ទោស និង ការបោះឆ្នោតដកសេចក្តីទុកចិត្តពរាជរដ្ឋាភិបាលដូចរដ្ឋសភាទេ ។

***សំណួរ : យោងមាត្រា ១១៣ថ្មី នៃជំពូកទី ៨ថ្មី យើងពិនិត្យឃើញ រដ្ឋសភាហាក់ដូចជាមានសិទ្ធិអំណាចជាងព្រឹទ្ធសភា តើស្ថាប័នមួយណាមានអំណាចគ្របដណ្តប់ ?***

ចម្លើយ : និយាយក្នុងរដ្ឋធម្មនុញ្ញ ដែលជាកិច្ចសន្យាអំណាច យើងពិបាកនិយាយថា ស្ថាប័នណាមានអំណាចជាងស្ថាប័នណាណាស់ ពីព្រោះអ្នកសរសេរគេថ្លឹងថ្លែងអំណាចឱ្យមានតុល្យភាពគ្នា ។ ប៉ុន្តែជាគោលការណ៍ យើងមើលនៅក្នុងក្រុមប្រឹក្សារាជសម្បត្តិ អ្នកណានៅពីលើគេ គឺប្រធានព្រឹទ្ធសភា ។ ពេលព្រះមហាក្សត្រអវត្តមាន ឬ

ពេលទ្រង់ប្រឈួនខ្លាំង មិនអាចបំពេញព្រះរាជភារកិច្ចបាន អ្នកណាធ្វើប្រមុខរដ្ឋស្តីទី ឬ រាជានុសិទ្ធិ គឺប្រធានព្រឹទ្ធសភា ។ ពេលរាជរដ្ឋាភិបាល និង រដ្ឋសភាឈ្លោះគ្នា អ្នកណាជាអ្នកសម្របសម្រួល គឺព្រឹទ្ធសភា ។ បើនិយាយពីខ្ពស់ ទាប ហើយជាគោលការណ៍ច្បាប់រដ្ឋធម្មនុញ្ញ ព្រឹទ្ធសភា គឺជាសភាជាន់ខ្ពស់ ។

***សំណួរ : រដ្ឋធម្មនុញ្ញខ្មែរគ្រប់របបនយោបាយខ្លះមានចែងពីព្រឹទ្ធសភា ប៉ុន្តែខ្លះមិនមានចែងទេ ។ ហេតុអ្វីត្រូវមានសមាជិកព្រឹទ្ធសភា ? និង ហេតុអ្វីមិនមាន ?***

ចម្លើយ : អាស្រ័យលើយើងប្រកាន់យក របបសភាមួយ ឬ របបសភាពីរ ។ សម័យសង្គមរាស្ត្រនិយម សភាមានពីរថ្នាក់ដែរ គ្រាន់តែមិនដាក់ឈ្មោះព្រឹទ្ធសភា កាលនោះគេដាក់ឈ្មោះថា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

# ពាក់ព័ន្ធនឹងជំពូកទី ១០ថ្មី
# អំពីរាជរដ្ឋាភិបាល

***សំណួរ : ហេតុអ្វីរដ្ឋធម្មនុញ្ញមិនចែងពីអាណត្តិនាយករដ្ឋមន្ត្រី ?***

ចម្លើយ : រដ្ឋធម្មនុញ្ញអត់មានចែងមែន ប៉ុន្តែមានលក្ខខណ្ឌច្រើនដើម្បីធ្វើនាយករដ្ឋមន្ត្រីបាន ទី១-ជាតំណាងរាស្ត្ររបស់គណបក្សឈ្នះឆ្នោត ។ បើអត់ចែងមានន័យថា បើកផ្លូវហើយ ឱ្យតែអ្នកនោះឯងមានប្រជាប្រិយឈ្នះឆ្នោត ហើយត្រូវបានគណបក្សខុទ្ទេសនាមឱ្យធ្វើជាបេក្ខជននាយករដ្ឋមន្ត្រី ព្រោះពាក្យថា បោះឆ្នោតនេះគណបក្សនីមួយៗសុទ្ធតែបញ្ចេញបេក្ខជននាយករដ្ឋមន្ត្រីហើយ ដូចជាយើងធ្លាប់ឃើញកន្លងមក បើបោះឆ្នោតឱ្យគណបក្ស ដូចបោះឆ្នោតឱ្យបេក្ខជននាយករដ្ឋមន្ត្រី បើស្រឡាញ់បេក្ខជននាយករដ្ឋមន្ត្រី ដូចបោះឱ្យគណបក្សដែរដូច្នេះវាទាក់ទងគ្នា ។ បើតាមខ្ញុំស្រាវជ្រាវទៅ គ្មានប្រទេសណាចែងថា នាយករដ្ឋមន្ត្រីមាន ២ អាណត្តិទេ គឺមានចែងតែពីអាណត្តិរបស់ប្រធានាធិបតីប៉ុណ្ណោះ ពីព្រោះប្រទេសប្រកាន់របបសភានិយម ជាទូទៅគេមិនមានចែងអំពីអាណត្តិរបស់នាយករដ្ឋមន្ត្រីទេ ។ នេះជារបបពីរផ្សេងគ្នា មួយជារបបប្រធានាធិបតីនិយម ឯមួយទៀតជារបបសភានិយម ។ ក្នុងរបបប្រធានាធិតីនិយម ប្រធានាធិបតីឥតរំលាយសភា ឬ សភាមិនទម្លាក់ប្រធានាធិបតីទេ ។ ចំណែករបបសភានិយម រដ្ឋាភិបាលត្រូវទទួលសេចក្តីទុកចិត្តពីរដ្ឋសភា នៅកម្ពុជាបើរាជរដ្ឋាភិបាលធ្លាក់ពីរដងក្នុង១២ខែនាំឱ្យរដ្ឋសភារលាយដែរ ។

***សំណួរ : បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ នោះត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយថ្មីក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនោះជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន ។***

ចម្លើយ : ប្រសិនណានាយករដ្ឋមន្ត្រីលោកទទួលមរណភាពទៅ ឬ ខ្ទាំងសត្រូវចាប់បាត់ទៅ នេះប្រៀបដូចជារំលាយរាជរដ្ឋាភិបាលហើយ ដូច្នេះគណបក្សដែលឈ្នះឆ្នោតត្រូវរៀបចំនីតិវិធីចាត់តាំងនាយករដ្ឋមន្ត្រីថ្មី ដោយស្នើឈ្មោះមករដ្ឋសភាដើម្បីសុំសេចក្តីទុកចិត្តពីរដ្ឋសភា ទាំងនេះគឺច្បាប់តម្រូវ ។ បើលោកអវត្តមានម្តងម្កាល ដើម្បីទៅមើល ជម្ងឺ ឬទៅធ្វើបេសកកម្មនៅក្រៅប្រទេសមួយរយៈនោះ លោកអាចចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូបជានាយករដ្ឋមន្ត្រីស្តីទី ប៉ុន្តែនាយករដ្ឋមន្ត្រីស្តីទីមានភារកិច្ចដឹកនាំតែការងារប្រចាំថ្ងៃទេ ឯការសម្រេចធំដុំត្រូវរង់ចាំនាយករដ្ឋមន្ត្រីត្រលប់មកវិញ ។ នេះហើយជារបបសភានិយម ។

***សំណួរ: នីតិបញ្ញត្តិ និង នីតិប្រតិបត្តិ បើនីតិទាំងពីរនៅដាច់ដោយឡែកពីគ្នា ហេតុដូចម្ដេចបានជានៅក្នុងអាណត្តិសភាមុនៗកត់សម្គាល់ឃើញថា មានឯកឧត្តមខ្លះគាត់ជាសមាជិករាជរដ្ឋាភិបាលផងនិងជាសមាជិកសភាផង ?***

ចម្លើយ : អំណាចចែកដាច់ពីគ្នា តែមនុស្សមិនបានចែកនោះទេ។ រដ្ឋធម្មនុញ្ញបានចែងដូច្នេះថាតំណាងរាស្ត្រអាចធ្វើជាសមាជិករាជរដ្ឋាភិបាលផង ហើយសមាជិករាជរដ្ឋាភិបាលក៏អាចធ្វើជាតំណាងរាស្ត្រផង ។ តែវិសមិតភាពមានឧទាហរណ៍ បើជាមន្ត្រីរាជការស៊ីវិល ជាយោធិន ជាចៅក្រម ឬ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គេមិនឱ្យទៅធ្វើការងារពីរបានទេ ។ ធ្វើជានាយករដ្ឋមន្ត្រីបានមានលក្ខខណ្ឌធំណាស់ គឺគាត់ត្រូវជាតំណាងរាស្ត្ររបស់គណបក្សដែលឈ្នះឆ្នោត ហើយធ្វើជាសមាជិករាជរដ្ឋាភិបាលបាន គាត់ត្រូវជាសមាជិកគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ។

***សំណួរ : តើអំណាចនីតិប្រតិបត្តិអាចចាប់បង្ខំឱ្យប្រជាពលរដ្ឋមានទោស នៅពេលដែលប្រជាពលរដ្ឋមិនទាន់យល់ពីច្បាប់?***

ចម្លើយ : តាមច្បាប់ គ្មានពលរដ្ឋណាម្នាក់អាចដោះសារថាខ្លួនមិនចេះច្បាប់ ហើយទៅប្រព្រឹត្តបទល្មើសតាមទំនើងចិត្តបានទេ ពីព្រោះច្បាប់មានវិសាលភាពគ្របដណ្ដប់ទៅលើគ្រប់ប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេស ។

***សំណួរ: តើបទបញ្ជា ឬ អនុសាសន៍របស់អំណាចនីតិប្រតិបត្តិមានអានុភាពដូចច្បាប់ដែរឬទេ?***

ចម្លើយ : បទបញ្ជា និង អនុសាសន៍របស់អំណាចនីតិប្រតិបត្តិចាប់ពីនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី អភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ គឺដើម្បីតម្រែតម្រង់ឱ្យអនុវត្តច្បាប់បានត្រឹមត្រូវតែប៉ុណ្ណោះ ហើយចំពោះសំណួរថា វាមានអានុភាពដូចច្បាប់ដែរឬទេនោះ គឺមិនដូចទេ ពីព្រោះវាមិនមែនជាច្បាប់ទេ ។

***សំណួរ : តើថ្នាក់ត្រឹមណាជាមន្ត្រីនយោបាយ ចុះក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់ តើត្រូវចាត់ចូលជាមន្ត្រីនយោបាយដែរ ឬទេ ?***

ចម្លើយ : ជាមន្ត្រីនយោបាយហើយ ពីព្រោះកើតដោយសារការបោះឆ្នោត ហើយមានការតែងតាំងពីគណបក្សនយោបាយ ហើយធ្វើការមិនកំណត់អាយុឡើយ ។

# ពាក់ព័ន្ធនឹងជំពូកទី ១១ថ្មី
## អំពីអំណាចតុលាការ

***សំណួរ : នៅពេលដែលតុលាការកំពូលចេញសាលដីកាសម្រេចហើយ អ្នកចាញ់ក្ដីមិនសុខចិត្ត តើអ្នកចាញ់ក្ដីនោះត្រូវប្ដឹងទៅស្ថាប័នណា? តាមរយៈអ្នកណា? តើស្ថាប័នណាដែលជាអ្នកត្រួតពិនិត្យនូវសកម្មភាពតុលាការ? ហើយនៅពេលតុលាការធ្វើខុស តើស្ថាប័នណាជាអ្នកដាក់ពិន័យស្ថាប័នតុលាការ? ដោយរបៀបណា?***

ចម្លើយ : មិនអាចប្ដឹងទៅណាទៀតទេ ពីព្រោះសេចក្ដីសម្រេចរបស់តុលាការកំពូលជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ប៉ុន្តែគេអាចប្ដឹងសើរើបាននៅតុលាការកំពូល ក្នុងករណីដែលគេរកឃើញភស្តុតាងថ្មី ក្រោយការចេញសាលដីកានោះ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកត្រួតពិនិត្យនូវសកម្មភាពតុលាការ ហើយនៅពេលដែលចៅក្រមធ្វើខុស ស្ថាប័ននេះជាអ្នកដាក់វិន័យចៅក្រម ។

***សំណួរ : អំណាចតុលាការជាអំណាចឯករាជ្យ ។ អំណាចទាំងបីបែងចែកដាច់ពីគ្នា ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាស្ថាប័នធានាឯករាជភាពរបស់អំណាចតុលាការដោយមានព្រះមហាក្សត្រជាប្រធាន ។ ហេតុអ្វីបានជាស្ថាប័ននេះមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាសមាជិក ? ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាសមាជិករាជរដ្ឋាភិបាលផងនោះ តើអំណាចតុលាការធានាឯករាជ្យបានដូចម្ដេចទៅ ?***

ចម្លើយ : រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចព្រះមហាក្សត្រដែរ ប៉ុន្តែព្រះមហាក្សត្រក្ដី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្ដី លោកមិនចូលប្រជុំក្នុងក្រុមប្រឹក្សាវិន័យនៃអង្គចៅក្រមទេ ដើម្បីធានាឯករាជភាព ។

***សំណួរ : ហេតុអ្វីបានជាព្រះរាជាណាចក្រកម្ពុជា ពុំបង្កើតឱ្យមានតុលាការដោះស្រាយវិវាទរដ្ឋបាល ។***

ចម្លើយ : ថ្ងៃនេះមិនទាន់មាន ថ្ងៃអនាគតយើងនឹងបង្កើតតុលាការរដ្ឋបាល តុលាការពាណិជ្ជកម្ម និង តុលាការការងារ ។

***សំណួរ : តើអំណាចទាំងបីបានចែងក្នុងរដ្ឋធម្មនុញ្ញ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ ហេតុអ្វីបានគេឱ្យអំណាចតុលាការឯករាជទៅវិញ ពីព្រោះថាស្ថាប័នតុលាការរស់ក្រោមរដ្ឋធម្មនុញ្ញដែរ ?***

ចម្លើយ : អំណាចតុលាការ គឺសម្រាប់រកយុត្តិធម៌ជូនរូបវន្តបុគ្គលក្ដី នីតិបុគ្គលក្ដី ដែលស្របនឹងលក្ខណៈអន្តរជាតិ ព្រោះតុលាការនៅស្រុកណាក៏ដោយត្រូវតែឯករាជ្យ និង អព្យាក្រឹត ។

***សំណួរ : ក្នុងករណីដែលប្រធានតុលាការកំពូលប្រព្រឹត្តខុសអ្វីមួយ តើនរណាជាអ្នកមានសមត្ថកិច្ច ដោយយើងដឹងហើយថា ប្រធានតុលាការកំពូលជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។***

ចម្លើយ : គឺក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ បើប្រធានតុលាការកំពូលធ្វើខុស ប្រធានតុលាការកំពូលអត់មានសិទ្ធិចូលប្រជុំក្នុងក្រុមប្រឹក្សាវិន័យទេ អ៊ីចឹងគឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកដាក់វិន័យលើប្រធានតុលាការកំពូល ។

***សំណួរ : យោងមាត្រា ១៣៣ថ្មី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យលើចៅក្រមដែលប្រព្រឹត្តខុស តើការដាក់វិន័យលើចៅក្រមដែលប្រព្រឹត្តខុសដូចម្តេចខ្លះ ? ព្រោះមាត្រានេះបាននិយាយថា ចៅក្រមមិនអាចត្រូវបានដកងារ ឡើយ ។***

ចម្លើយ : ក្នុងការដាក់វិន័យមានពីរយ៉ាង ទីមួយ ដាក់វិន័យចៅក្រម គឺប្រធានតុលាការកំពូលជាប្រធាននៃអង្គប្រជុំ ទីពីរ ដាក់វិន័យព្រះរាជអាជ្ញា គឺអគ្គព្រះរាជអាជ្ញាអមតុលាកាកំពូលជាប្រធានអង្គប្រជុំ ។ ដូច្នេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ព្រះមហាក្សត្រមិនលូកដៃចូលក្នុងរឿងដាក់វិន័យហ្នឹងទេ ។

***សំណួរៈ បើពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ត្រូវឆ្លងកាត់តាមរយៈតុលាការថ្នាក់ក្រោម និង ទទួលការពិនិត្យសម្រេចពីតុលាការកំពូល តើអាចប៉ះពាល់ឯករាជភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញឬទេ ?***

ចម្លើយ : គឺអត់មានទំនាក់ទំនងអ្វីទេ ។ អំណាចតុលាការ មានសិទ្ធិជំនុំជម្រះគ្រប់រឿងក្តីទាំងអស់ គិតទាំងរឿងក្តីរដ្ឋបាលផង ប៉ុន្តែរឿងក្តីទាក់ទងនឹងការបោះឆ្នោត គឺស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ គឺគ្មានប៉ះពាល់ដល់ឯករាជភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ហើយបើក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយរឿងក្តីដូចដែលបានលើកនោះ គឺវាជាការរំលោភលើសមត្ថកិច្ចរបស់តុលាការហើយ ។

***សំណួរៈ ពេលសវនាការ ចៅក្រមអនុវត្តខុសនីតិវិធី បណ្តាលឱ្យប្រជាពលរដ្ឋទទួលនូវភាពអយុត្តិធម៌ ហេតុអ្វីក៏ចៅក្រមមិនបានទទួលនូវទោសទណ្ឌដូចប្រជាពលរដ្ឋ ? មិននិយាយពេលលោកចៅក្រម ឬ ព្រះរាជអាជ្ញាអនុវត្តខុសពេលសវនាការទេ ។***

ចម្លើយ : នេះជាកិច្ចការមួយដែលយើងទាំងអស់គ្នា ពិសេសចៅក្រម មេធាវី អ្នកច្បាប់ ឬ ក៏ក្រុមប្រឹក្សាទាំងអស់ត្រូវខិតខំជួយពន្យល់បងប្អូនប្រជាពលរដ្ឋឱ្យបានយល់ដឹងពីច្បាប់ ចេះពីនីតិវិធីជាដើម កាលណាយើងចេះយល់ដឹងទាំងអស់គ្នាទៅ អំពើរំលោភច្បាប់ក៏ចេះតែកាត់បន្ថយទៅដែរ ។

***សំណួរ: ជំពូកទី១១ ថ្មី មាត្រា ១៣៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា : " ចៅក្រមមិនអាចគេដកពីមុខតំណែងបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យលើចៅក្រមប្រព្រឹត្តខុស " ។ សួរថា : ចុះបើចៅក្រមនោះប្រព្រឹត្តខុសធ្ងន់ធ្ងររហូតដល់ប្រព្រឹត្តបទឧក្រិដ្ឋ ឬ មជ្ឈិម តើការដាក់វិន័យទៅលើចៅក្រមនោះតាមរូបភាពណា ? ចុងក្រោយអាចដកចេញពីមុខតំណែងដែរឬទេ ?***

ចម្លើយ : សូមមើលមាត្រានេះឱ្យចប់ បើយកតែមួយឃ្លាមកមើលពិបាកបកស្រាយណាស់ ដូច្នេះបើមើល ច្បាប់ត្រូវមើលឱ្យអស់ន័យ ។ មាត្រា ១៣៣ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យលើចៅក្រមដែលប្រព្រឹត្តខុស ។ សូមជម្រាបថា ចៅក្រមក៏ជាពលរដ្ឋដែរ គឺត្រូវមានទោសដូចគ្នា បើបានប្រព្រឹត្តខុស ។ ឧទាហរណ៍ បើប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មិនថាជាចៅក្រម ឬ សមាជិកសភាទេ បើជាបទល្មើសជាក់ស្តែង គឺចាប់ឃុំខ្លួនតែម្តង អត់ចាំបាច់ស្នើសុំដកអភ័យឯកសិទ្ធិអ្វីទេ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេច និង លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការបួតងារចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់ ហើយក្រុមប្រឹក្សាវិន័យមានសិទ្ធិសម្រេចលើការដាក់វិន័យចំពោះចៅក្រម ឬ ព្រះរាជអាជ្ញាដែលប្រព្រឹត្តខុស ។

***សំណួរ: ការកាត់ទោសខ្មែរក្រហម តើមូលហេតុអ្វីបានជាចាំបាច់ត្រូវយកតុលាការអន្តរជាតិមកកាត់សេចក្តីវិញ? តើយកតុលាការខ្មែរយើងធ្វើដោយខ្លួនឯងបានដែរឬទេ ? ឬក៏តុលាការខ្មែរយើងគ្មានសមត្ថភាព ។***

ចម្លើយ : នេះជាឆន្ទៈរបស់ប្រជារាស្ត្រខ្មែរភាគច្រើន ដែលលោកប្រើអំណាចនេះតាមរយៈអំណាច នីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។ មុននឹងមានការកាត់ទោស មានការចរចាគ្នាជាច្រើនលើករវាងរាជរដ្ឋាភិបាលកម្ពុជា និង អន្តរជាតិ ដើម្បីបង្កើតតុលាការកូនកាត់នេះឡើង ។

***សំណួរ: យោងមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ បានចែងថា : "អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់" ។ បើសិនទៅថ្ងៃក្រោយយើងមានតុលាការពាណិជ្ជកម្ម តុលាការការងារ តុលាការរដ្ឋបាលហើយ យើងមានវិវាទកម្មជាមួយរដ្ឋធម្មនុញ្ញដែរឬទេ ?***

ចម្លើយ : អត់មានទេ ព្រោះវាស្ថិតនៅក្នុងការបង្កើតតុលាការជំនាញវិជ្ជាជីវៈនីមួយៗ ។

***សំណួរៈ*** *តាមមាត្រា ១២៨ ថ្មី " ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជាពលរដ្ឋខ្មែរ តាមនីតិវិធី និង ច្បាប់ជាធរមាន ។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និង ឱ្យអស់ពីដួងចិត្ត និង សម្បជញ្ញៈរបស់ខ្លួន ។ " ឱ្យអស់ពីដួងចិត្ត និង សម្បជញ្ញៈរបស់ខ្លួន " តើមានអ្វីវាស់វែងដឹង ?*

ចម្លើយ ៈ កាលណាមានរឿងក្តីដល់តុលាការហើយ ការកាត់ក្តីរបស់តុលាការ ត្រូវមាន អ្នកឈ្នះ និង អ្នកចាញ់ ទើបគេបង្កើតឱ្យមានតុលាការមានច្រើនថ្នាក់ ។ សាលាដំបូង ពិនិត្យទាំងអង្គហេតុ និង អង្គច្បាប់ បើមិនសុខចិត្តទេប្តឹងទៅសាលាឧទ្ធរណ៍ សាលាឧទ្ធរណ៍ពិនិត្យទាំងអង្គហេតុ និង អង្គច្បាប់ទៀត ។ បើមិនសុខចិត្តទៀតប្តឹងទៅតុលាការកំពូល តុលាការកំពូលពិនិត្យអង្គច្បាប់ បើពិនិត្យឃើញមានខ្វះចន្លោះណាមួយ តុលាការកំពូលបង្វិលរឿងឱ្យសាលាឧទ្ធរណ៍ពិនិត្យឡើងវិញ ទើបបញ្ជូនទៅតុលាការកំពូលម្តងទៀត ។ ការកាត់សេចក្តីរបស់តុលាការកំពូលជាការកាត់សេចក្តីចុងក្រោយបិទផ្លូវតវ៉ា នេះជានីតិវិធី ។ ការកាត់សេចក្តីរបស់តុលាការថា ឱ្យអ្នកនេះចាញ់ ឬ អ្នកនោះឈ្នះ មិនមានអ្វីមកវាស់ឱ្យដូចយកម៉ែត្រមកវាស់នោះទេ តែអ្នកច្បាប់អាចត្រិះរិះពិចារណារកហេតុរកផលមួយបាន ។

***សំណួរៈ*** *តើថ្នាក់ណាជាអ្នកតែងតាំងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម?*

ចម្លើយ ៈ បង្កើតដោយច្បាប់មួយ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ច្បាប់កំណត់ថា ៈ

| | |
|---|---|
| -ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| -រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| -ប្រធានតុលាការកំពូល | សមាជិក |
| -អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | សមាជិក |
| -ប្រធានសាលាឧទ្ធរណ៍ | សមាជិក |
| -អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | សមាជិក |
| -ចៅក្រម ៣រូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម | សមាជិក |

ច្បាប់នេះជាច្បាប់រៀបចំអង្គការ ។

***សំណួរ ៈ*** *តើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមត្ថកិច្ចធ្វើអ្វីខ្លះ ?*

ចម្លើយ ៈ សមត្ថកិច្ច ៈ

-ផ្តល់យោបល់លើសេចក្តីស្នើច្បាប់ ឬ សេចក្តីព្រាងច្បាប់ ដែលទាក់ទងដល់ការរៀបចំវិស័យតុលាការ

-សម្រេច និង លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាក់ពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការហូតងារចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់

-ឱ្យយោបល់ចំពោះការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ ឱ្យចៅក្រម និង ព្រះរាជអាជ្ញាទាំងអស់

-ដាក់ទោសវិន័យចំពោះចៅក្រម និង ព្រះរាជអាជ្ញា

**សំណួរ** : *ពេលមន្ត្រីតុលាការអនុវត្តខុសនីតិវិធីច្បាប់ តើស្ថាប័នណាជាអ្នកដាក់ទោស ?*

ចម្លើយ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកមានសមត្ថកិច្ចទៅលើរឿងនេះ ។

**សំណួរ** : *ហេតុអ្វីបានជាគេចែងថាតុលាការជាស្ថាប័នឯករាជ្យ?*

ចម្លើយ : រដ្ឋធម្មនុញ្ញ បានចែងថា តុលាការជាស្ថាប័នឯករាជ្យ ការចែងបែបនេះមានន័យថា អំណាចពីរទៀត ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ គឺអំណាចនីតិប្រតិបត្តិ និង អំណាចនីតិបញ្ញត្តិ មិនអាចបញ្ជាលើអំណាចតុលាការបានទេ ពោលគឺតុលាការធ្វើសេចក្តីសម្រេចដោយឯករាជ្យ ក្នុងនាមប្រជាពលរដ្ឋខ្មែរដើម្បីផ្តល់នូវយុត្តិធម៌ដល់រាស្ត្រ និង សង្គម ។ ចំពោះការប្រតិបត្តិជាក់ស្តែង យើងមិនបដិសេធពីការខ្វះខាតលើចំណុចនេះទេ ព្រោះពាក្យថាជំនុំជម្រះហើយតែងតែមានអ្នកឈ្នះ និង អ្នកចាញ់ ដូច្នេះការទិតៀន កើតមានដោយជៀសមិនរួច ។ និយាយដោយខ្លីថា ឯករាជ្យដើម្បីអ្វី? គឺដើម្បីយុត្តិធម៌ ។

**សំណួរ** : *តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិទទួលបានតុលាការដែលមានសមត្ថភាពឯករាជ្យ និង ឥតលំអៀងដែរឬទេ ? ម្យ៉ាងទៀត តើតុលាការនៅកម្ពុជាបច្ចុប្បន្នអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជារាស្ត្រដែរឬទេ ? សូមពិនិត្យមាត្រា ១២៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។*

ចម្លើយ : នៅក្នុងមាត្រានៃរដ្ឋធម្មនុញ្ញនេះ បានបញ្ញត្តិច្បាស់ណាស់ថា អំណាចតុលាការជាអំណាចឯករាជ្យ ហើយនៅក្នុងការអនុវត្តការងារជាក់ស្តែងត្រង់ឯករាជ្យ ឬមិនឯករាជ្យ គឺជាបញ្ហារបស់បុគ្គលខ្លួនឯងនោះទេ ប៉ុន្តែជារួមតុលាការ គឺឯករាជ្យ ។ ម្យ៉ាងវិញទៀត បើនិយាយអំពីសមត្ថភាពរបស់តុលាការនៅកម្ពុជាយើង ក៏យើងមានកំរិតរបស់យើងដែរ ជាពិសេសទាក់ទងនឹងជំនាញផ្នែកច្បាប់ និង ខាងភាសាបរទេស ។

**សំណួរ** : *មាត្រា ១៣១ថ្មី ( មាត្រា ១១២ចាស់) មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ ដើមបណ្តឹងយល់ឃើញថា ការសម្រេចរបស់តុលាការពុំទាន់បានសមស្រប ធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈរបស់រដ្ឋ ប៉ុន្តែព្រះរាជអាជ្ញាពុំបានធ្វើបណ្តឹងអាជ្ញាទេ ។ តើគួរមានវិធានការចំពោះព្រះរាជអាជ្ញារូបនោះយ៉ាងណា ? មានទោសដែរឬទេ ?*

ចម្លើយ : អត់រួចខ្លួនទេ ។ ត្រូវធ្វើពាក្យប្តឹងតាមលំដាប់លំដោយ ។

**សំណួរ** : *តើអំណាចតុលាការរក្សាអនាគតិដោយផ្អែកលើមូលដ្ឋានគតិយុត្ត ឬ លក្ខខណ្ឌអ្វីខ្លះ ?*

ចម្លើយ : យើងដឹងហើយពាក្យថា រក្សាអនាគតិ គឺមិនលម្អៀង ។ អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។ រឿងក្តីទាំងអស់ត្រូវប្តឹងចូលទៅតុលាការ ហើយតុលាការសម្រេចសេចក្តី

ដោយគោរពតាមផ្លូវបណ្ដឹងនៃតុលាការនីមួយៗ ។ ដូច្នេះត្រូវផ្អែកលើច្បាប់ លើនីតិវិធី មានហេតុផល មានភស្តុតាង មានសាក្សីគ្រប់គ្រាន់ កុំភ័យ កុំរំភើប កុំធ្លាក់ក្នុងការអួសទាញ ការទិញទឹកចិត្ត ។ល។

***សំណួរ : នៅក្នុងពេលបច្ចុប្បន្នដែលមានការរីកចំរើននូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តើអំណាចតុលាការមានមូលដ្ឋានលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលនាំឱ្យបែងចែកអំណាចតុលាការ ខុសពីអំណាចកាត់ក្ដីរបស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ?***

ចម្លើយ : ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសំខាន់ណាស់ ព្រោះការដោះស្រាយតាមផ្លូវតុលាការមានឈ្នះមានចាញ់ ដល់ដោះស្រាយក្រៅប្រព័ន្ធតុលាការមានការសម្របសម្រួល វិធីនេះគឺធ្វើតាមរយៈមជ្ឈត្តករ តាមរយៈអន្តរការី គេរកផ្លូវមួយគ្មានឈ្នះគ្មានចាញ់ ភាគីទាំងពីរស្រុះស្រួលយោគយល់គ្នា វិធីនេះល្អណាស់សម្រាប់ពួកឈ្មួញ ឬ ធុរជន ។

***សំណួរ : បញ្ហាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម កាលពីរដ្ឋធម្មនុញ្ញពីមុនមានវចនាសម្ព័ន្ធ សមាសភាពខុសគ្នាពីសព្វថ្ងៃឬទេ ឧទាហរណ៍ឆ្នាំ១៩៤៧ ? ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចមានវិសមិតភាពបានទេ ?***

ចម្លើយ : សមាសភាពអាចខុសគ្នា ព្រោះច្បាប់បង្កើតខុសពេលវេលាគ្នា ។ តាមច្បាប់លក្ខន្តិកៈចៅក្រម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានវិសមិតភាព ។

***សំណួរ : អំណាចតុលាការ ធានារក្សាអនាគតិ និង ការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។ ហេតុអ្វីបានជាចៅក្រមជម្រះក្ដីមិនយុត្តិធម៌ ហើយចៅក្រមមិនអាចត្រូវគេដកមុខងារបានដោយសារអ្វី ?***

ចម្លើយ : ចៅក្រមសម្រេចសេចក្ដីដោយមានហេតុផលភស្តុតាង និង ច្បាប់ជាសម្អាង ហើយអ្នកដែលការពារក្ដីគឺមានមេធាវី ហ្នឹងគឺដំណើរការតាមនីតិវិធីច្បាប់ ដល់ទៅចោទចៅក្រមថា អយុត្តិធម៌ តើអយុត្តិធម៌ត្រង់ណា? ខុសច្បាប់ចំណុចណា? ព្រោះម្នាក់ៗត្រូវមានសម្អាង ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកដាក់ពិន័យចៅក្រម ។

***សំណួរ : ប្រជារាស្ត្រចង់ប្ដឹងចៅក្រម ឬតុលាការណាម្នាក់ តើត្រូវដាក់ពាក្យបណ្ដឹងទៅកន្លែងណាទើបត្រឹមត្រូវ ?***

ចម្លើយ : ប្រសិនបើប្រជារាស្ត្រចង់ប្ដឹងចៅក្រម គឺត្រូវប្ដឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាអ្នកមានសមត្ថកិច្ចដាក់ទណ្ឌកម្មចៅក្រម។ ចំណែកឯតុលាការ គឺជាស្ថាប័នមួយ ដូច្នេះគេមិនអាចដាក់ទណ្ឌកម្មស្ថាប័នបានទេ ។

# ពាក់ព័ន្ធនឹងជំពូកទី ១២ថ្មី
# អំពីក្រុមប្រឹក្សាធម្មនុញ្ញ

**សំណួរ :** *តើវិវាទក្នុងការបោះឆ្នោត តែករណីនេះទាក់ទងនឹងផលប្រយោជន៍បុគ្គលមួយរូប ឬច្រើនរូប តើជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែរឬទេ ?*

**ចម្លើយ :** ក្រុមប្រឹក្សាធម្មនុញ្ញមិនដោះស្រាយរឿងទំនាស់បុគ្គលទេ ។

**សំណួរ :** *ចូរបញ្ជាក់បំភ្លឺយ៉ាងដូចម្ដេចហៅថា "ការបកស្រាយច្បាប់" និង "ការផ្សព្វផ្សាយច្បាប់" តើមានលក្ខណៈខុសគ្នាយ៉ាងណា ?*

**ចម្លើយ :** ការបកស្រាយច្បាប់ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ ដើម្បីបំភ្លឺទៅនឹងភាពស្រពិចស្រពិលលើបញ្ញត្តិច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិបកស្រាយច្បាប់។ ចំណែកឯការផ្សព្វផ្សាយច្បាប់វិញ គឺគ្រាន់តែជាការអប់រំ ឬជូនព័ត៌មាន ។

**សំណួរ :** *ការសម្រេចសេចក្ដីរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានផ្ដន្ទាទោសជាប់ពន្ធនាគារ និង ពិន័យជាប្រាក់ តើការដាក់ទោសទណ្ឌចំពោះក្រុមណា ?*

**ចម្លើយ :** ក្រុមប្រឹក្សាធម្មនុញ្ញមិនមែនជាស្ថាប័នដែលមានសមត្ថកិច្ចផ្ដន្ទាទោសដាក់ពន្ធនាគារដល់បុគ្គលណាដូចតុលាការទេ ប៉ុន្ដែច្បាប់បានកំណត់ពិន័យ និង ផ្ដន្ទាទោសដល់បុគ្គលទាំងឡាយណាដែលមិនគោរពសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**សំណួរ :** *តើបុគ្គលណាអាចសម្រេចថា ច្បាប់ធម្មនុញ្ញនេះត្រឹមត្រូវ?*

**ចម្លើយ :** គឺក្រុមប្រឹក្សាធម្មនុញ្ញ។ បើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថាស្របនឹងរដ្ឋធម្មនុញ្ញហើយ ទើបព្រះមហាក្សត្រឡាយព្រះហស្ដលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់នោះបាន។

**សំណួរ :** *ហេតុអ្វីបានជាច្បាប់មិនអនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សាធម្មនុញ្ញប្រកបមុខរបរផ្សេងៗ ?*

**ចម្លើយ :** ដោយសារការត្រួតមុខងារក្នុងពេលតំណាលគ្នានេះមានផលអាក្រក់មិនល្អ ។ ឧទាហរណ៍ ដូចជាឯកឧត្ដមឧត្ដមសេនីយ៍ណាមួយចង់ទៅធ្វើតំណាងរាស្ត្រ ឬ ចង់ទៅធ្វើសមាជិកព្រឹទ្ធសភា ទាល់តែព្យួរក្របខ័ណ្ឌឧត្ដមសេនីយ៍សិន ប៉ុន្ដែការតម្លើងថ្នាក់គេរក្សាទុកឱ្យ ។

**សំណួរ :** *ពេលប្រជាពលរដ្ឋមានបញ្ហាចំពោះសេចក្ដីសម្រេចរបស់តុលាការ គាត់ចង់ប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្ដែ បើតាមរយៈរដ្ឋសភា ឬ ផ្លូវតុលាការគ្មានលទ្ធភាព តើគាត់អាចមានវិធីណាទើបប្ដឹងទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញ ?*

**ចម្លើយ :** បើទាក់ទងនឹងសេចក្ដីសម្រេច ឬ សាលក្រម ឬ សាលដីការបស់តុលាការ ក្នុងនីតិរូប អ្នកដែលកើតទុក្ខមិនសុខចិត្ត ដូចជាមិនអាចប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញឱ្យកាត់សេចក្ដីថា តុលាការថ្នាក់នេះ ថ្នាក់នោះ ធ្វើខុស ឬ

ត្រូវបានទេ ព្រោះមិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ មិនមែនជាស្ថាប័នកំពូលលើតុលាការកំពូល ហើយក្រុមប្រឹក្សាធម្មនុញ្ញក៏មិនមែនជាស្ថាប័នមួយស្ថិតក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់តុលាការដែរ ។ បើសិនជាកំពុងដំណើរការនីតិវិធីតុលាការលេចចេញនូវបញ្ហាថា បទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពណាមួយ ម្ចាស់សំណើអាចលើកសំណើសុំឱ្យតុលាការពិនិត្យសំណើថា កន្លែងនេះខុសនឹងរដ្ឋធម្មនុញ្ញ អ៊ីចឹងតុលាការថ្នាក់នោះត្រូវស្នើមកតុលាការកំពូលដើម្បីពិនិត្យ បើតុលាការកំពូលពិនិត្យឃើញថាខុសមែន តុលាការកំពូលបញ្ជូនមកក្រុមប្រឹក្សាធម្មនុញ្ញ ។

**សំណួរ :** *រចនាសម្ព័ន្ធការងារក្រុមប្រឹក្សាធម្មនុញ្ញ អង្គភាព មន្ត្រី ។*

ចម្លើយ : មានអគ្គលេខាធិការដ្ឋានមួយ និង មានមន្ត្រីក្របខណ្ឌជាងចិតសិបនាក់ ។

**សំណួរ :** *អំពីប្រាក់បៀវត្សទ្រទ្រង់ជីវភាព បើមានវិសមិតភាពការងារ ។*

ចម្លើយ : រដ្ឋបានឧបត្ថម្ភប្រាក់បៀវត្សសមរម្យ ពីព្រោះច្បាប់ចែងថា ឋានៈ និងបុព្វសិទ្ធិប្រធានក្រុមប្រឹក្សា-ធម្មនុញ្ញស្មើនឹងប្រធានរដ្ឋសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា ប៉ុន្តែការរៀបចំជាក់ស្តែងយើងយោគយល់ទៅដល់ការលំបាករបស់រដ្ឋ ។

**សំណួរ :** *តើការបកស្រាយនិងវិនិច្ឆ័យរបស់ក្រុមប្រឹក្សាធម្មនុញ្ញលើអធម្មនុញ្ញភាព ធ្វើតាមការបកស្រាយតាមពាក្យពេចន៍ ឬ គំនិតដើមរបស់នីតិនិពន្ធ ?*

ចម្លើយ : គឺផ្អែកលើមូលដ្ឋានគតិយុត្ត មើលរដ្ឋធម្មនុញ្ញ មើលច្បាប់ មើលទាំងសន្ធិសញ្ញា កតិកាសញ្ញាទាំងឡាយ ក្រែងលោមានការពាក់ព័ន្ធ ។ ក្រុមប្រឹក្សាធម្មនុញ្ញថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ មើលគ្រប់អស់ហើយពេលខ្លះពិភាក្សាគ្នាសម្ងាត់នៅក្នុងបន្ទប់ពិភាក្សា គ្មានអ្នកណាចូលបានទេ សមាជិកក្មេងជាងគេជាលេខាធិការកត់ត្រា ពេលខ្លះជជែកគ្នាដាច់បាយរាប់ម៉ោង ។

**សំណួរៈ** *តើការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញមានផលប៉ះពាល់និងផលប្រយោជន៍អ្វីខ្លះចំពោះព្រះរាជាណាចក្រកម្ពុជា?*

ចម្លើយ : ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញបង្កើតឡើង ដើម្បីធានាការពារមិនឱ្យមានអំណាចណាមួយ បុគ្គលណាមួយរំលោភលើរដ្ឋធម្មនុញ្ញ ។ នៅប្រទេសបារាំងគេចាត់ទុកជានិយ័តករ ដើម្បីកុំឱ្យអំណាចទាំងបីជាន់ជើងគ្នា ឬ កក្ដូរកកាយផ្ទៃក្នុងពីកន្លែងមួយទៅកន្លែងមួយ គឺយកច្បាប់ជាមូលដ្ឋានគតិយុត្ត ។

**សំណួរ :** *មាត្រា ១៤២ថ្មី តើហេតុអ្វីចាំបាច់ឱ្យមានការសម្រេចបិទផ្លូវតវ៉ា របស់សេចក្តីសម្រេចនៃក្រុមប្រឹក្សាធម្មនុញ្ញ ?*

ចម្លើយ : រយៈពេលកន្លងជាង ១០ឆ្នាំ មកហើយ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានច្រើនដែលឯកឧត្តម លោក លោកស្រីបានដឹងហើយការសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចដោយមនសិការ មានភាពស្ងប់ គ្មានស្តាយក្រោយទេ ព្រោះទាមទារឱ្យមានភាពសុក្រឹត ហ្មត់ចត់ជានិច្ច។ សេចក្តីសម្រេច

របស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចបិទផ្លូវតវ៉ា គឺគ្មានប្តឹងឧទ្ធរណ៍ ឬ កំពូលទេ ហើយក៏មិនស្ថិតនៅក្នុងប្រព័ន្ធតុលាការដែរ និង ឯករាជ្យ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្ត ទៅលើគ្រប់អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ បិទផ្លូវតវ៉ាចំពោះសមត្ថកិច្ច ឧទាហរណ៍ បកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ ដោះស្រាយវិវាទបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពីព្រោះរដ្ឋធម្មនុញ្ញចែងអ៊ីចឹង ច្បាប់មេច្បាប់គោលចែងអ៊ីចឹង ច្បាប់រៀបចំអង្គការក៏ចែងអ៊ីចឹងដែរ។ ពាក្យថា បិទផ្លូវតវ៉ា គឺចប់ត្រឹមប៉ុណ្ណឹងឯង នៅស្រុកបារាំងក៏ធ្វើយ៉ាងនេះដែរ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃសាធារណរដ្ឋបារាំងក៏បិទផ្លូវតវ៉ាដែរ សេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញទាំងអស់ក៏បិទផ្លូវតវ៉ាដែរ។ ការបិទផ្លូវតវ៉ានេះ មិនមែនបិទមិនឱ្យគេដឹងគេឮនោះទេព្រោះរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចុះក្នុងរាជកិច្ចប្រកាសជាសាធារណៈ ។

**សំណួរ:** *យោងមាត្រា ១៣៦ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ ។ តើហេតុអ្វីមិនផ្តល់ឱ្យរដ្ឋសភា ឬ តុលាការ ក្នុងការធ្វើការបកស្រាយក៏ដូចជាការការពារការគោរព ។ តើគុណសម្បត្តិក៏ដូចជាគុណវិបត្តិយ៉ាងណាការផ្ទេរភារកិច្ចទៅឱ្យរដ្ឋសភា ឬ អំណាចតុលាការ ?*

ចម្លើយ : សូមបញ្ជាក់ថា រដ្ឋសភាមានសមត្ថកិច្ចធ្វើច្បាប់ តុលាការមានសមត្ថកិច្ចយកច្បាប់ទៅអនុវត្តដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ដូច្នេះការពិនិត្យធម្មនុញ្ញភាព ឬ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់នេះនៅក្នុងប្រទេសប្រជាធិបតេយ្យសេរី គេច្រើនបង្កើតឱ្យមានស្ថាប័នឯករាជ្យ តាមបែបបារាំងមានក្រុមប្រឹក្សាធម្មនុញ្ញ ឬ តុលាការធម្មនុញ្ញ បើប្រព័ន្ធច្បាប់អង់គ្លេសាក់សុង គេប្រគល់ទៅឱ្យតុលាការកំពូលមួយគត់ ។

**សំណួរ :** *ហេតុអ្វីបានជាច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភានិងព្រឹទ្ធសភាត្រូវតែពិនិត្យជាមុន ?*

ចម្លើយ : រដ្ឋធម្មនុញ្ញតម្រូវ ហេតុអ្វីបានជារដ្ឋធម្មនុញ្ញតម្រូវ? ពីព្រោះច្បាប់រៀបចំអង្គការកាលណាបង្កើតទៅអាចប៉ះពាល់ដល់ឯកភាពជាតិ ប៉ះពាល់ដល់អធិបតេយ្យជាតិ ឬ ប៉ះពាល់ដល់រដ្ឋធម្មនុញ្ញ ។ ចំពោះបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រឹទ្ធសភា អាងតែខ្លួនធ្វើបទបញ្ជាខ្លួនឯងចេះតែអនុម័តពង្រីកអំណាចទៅប៉ះពាល់អំណាចពីរទៀត អ៊ីចឹងហើយបានច្បាប់តម្រូវឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យជាមុន ។

**សំណួរ :** *តើនៅពេលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញប្រព្រឹត្តខុស តើនរណាមានសមត្ថកិច្ចដាក់វិន័យ ?*

ចម្លើយ : គឺក្រុមប្រឹក្សាធម្មនុញ្ញប្រជុំ ហើយប្រសិនបើកំហុសហ្នឹងមានភស្តុតាងគ្រប់គ្រាន់ ត្រូវអនុម័តបណ្តេញចេញដោយសំឡេង ២/៣ នៃសមាជិកទាំងមូល ។

**សំណួរ :** *ប្រសិនបើមានស្ថាប័នណាមួយមិនគោរពរដ្ឋធម្មនុញ្ញ តើក្រុមប្រឹក្សាធម្មនុញ្ញមានវិធានការយ៉ាងដូចម្តេច?*

ចម្លើយ : សូមជម្រាបថា ក្រុមប្រឹក្សាធម្មនុញ្ញ មិនមែនជាតុលាកាធម្មនុញ្ញទេ វាមានន័យខុសគ្នាបន្តិច ។ តុលាការធម្មនុញ្ញ កាត់សេចក្តីអំពីអំពើណាមួយដែលរំលោភលើរដ្ឋធម្មនុញ្ញ ចំណែកក្រុមប្រឹក្សាធម្មនុញ្ញយើង បានត្រឹមតែត្រួតពិនិត្យធម្មនុញ្ញភាពប៉ុណ្ណោះ ។

***សំណួរ*** : *ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ ។ ប្រសិនបើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនប្រកាន់អព្យាក្រឹតភាព តើមានវិធានណាមួយសម្រាប់ដាក់ទណ្ឌកម្ម ?*

ចម្លើយ : មាននៅក្នុងបទបញ្ជាផ្ទៃក្នុង ។ ក្នុងសមត្ថកិច្ច សមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ត្រូវប្រកាន់ឥរិយាបថធ្វើការងារជាអ្នកអព្យាក្រឹត ប៉ុន្តែមិនមែនមានន័យថា ក្រៅពីការងារអ្នកនោះឯងមិនធ្វើនយោបាយ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិនយោបាយដូចប្រជាពលរដ្ឋដទៃទៀតដែរ ។

***សំណួរ*** : *បើផ្អែកតាមជំពូក ១១ថ្មី ដែលបញ្ញត្តិស្តីអំពីអំណាចតុលាការ ហើយក្នុងនោះមានមាត្រាមួយចំនួនបានចែងថា "អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង" "មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី" ។ ប៉ុន្តែនៅក្នុងវិវាទបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺត្រូវប្រគល់ភារកិច្ច និង តួនាទីជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ តើការធ្វើរបៀបនេះប៉ះពាល់ដល់អំណាចតុលាការដែលជាស្ថាប័នឯករាជ្យដែរឬទេ?*

ចម្លើយ : សូមបញ្ជាក់ថា ទី១ រដ្ឋធម្មនុញ្ញតម្រូវ ( មាត្រា ១៣៦ថ្មី) ទី២ ច្បាប់បោះឆ្នោតតម្រូវ ប៉ុន្តែបានតែរឿងវិវាទបោះឆ្នោត មិនចូលក្នុងនីតិរូមទេ ប្រសិនបើរឿងនោះទាក់ទងនឹងនីតិរូម ឧទាហរណ៍ថាជាបទល្មើសដែលមានចែងដោយឡែក ហ្នឹងចូលសមត្ថកិច្ចតុលាការ ។

***សំណួរ*** : *បើផ្អែកតាមមាត្រា ១៣៧ថ្មី (មាត្រា១១៨ចាស់) បានបញ្ញត្តិថា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបីត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិក ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣រូប ជ្រើសតាំងដោយរដ្ឋសភា និង ៣រូបទៀត ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ តើមានភាពខុសគ្នាដូចម្តេចចំពោះការប្រើប្រាស់ពាក្យពេចន៍ តែងតាំង និង ជ្រើសតាំងក្នុងមាត្រានេះ ?*

ចម្លើយ : ពាក្យតែងតាំង គឺចុះហត្ថលេខាចង្អុល ។ ពាក្យជ្រើសតាំង គឺកើតចេញពីការបោះឆ្នោត ។

***សំណួរ*** : *តើមូលហេតុអ្វីដែលធ្វើឱ្យមានការយឺតយ៉ាវក្នុងការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញដល់ឆ្នាំ១៩៩៨ ?*

ចម្លើយ : មានកត្តាច្រើន ប៉ុន្តែការបង្កើតឱ្យមាននៅឆ្នាំ១៩៩៨ គឺដើម្បីឱ្យដោះស្រាយវិវាទបោះឆ្នោតជ្រើសតាំងរដ្ឋសភានីតិកាលទី២ ដែលជាភាពចាំបាច់របស់ប្រទេសជាតិ ។

***សំណួរ*** : *ក្នុងនាមជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ តើក្រុមប្រឹក្សាធម្មនុញ្ញមានតួនាទីអ្វីខ្លះនៅក្នុងតុលាការធម្មនុញ្ញអន្តរជាតិ ?*

ចម្លើយ : អត់មានតុលាការធម្មនុញ្ញអន្តរជាតិទេ មានតែសមាគមតុលាការធម្មនុញ្ញ ដូចជាសមាគមតុលាការធម្មនុញ្ញប្រើភាសាបារាំងជាដើម ។ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ជាសមាជិកពេញសិទ្ធិនៅក្នុងសមាគមនោះ ដែលអក្សរកាត់បារាំងហៅថា **ACCPUF** ។

***សំណួរ*** : *ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ ។ ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញមានកំហុស តើស្ថាប័នណាមាន សមត្ថកិច្ចត្រួតពិនិត្យ ។*

ចម្លើយ : បើនិយាយពីក្រុមប្រឹក្សាទាំងមូលគ្មានទេ បើបុគ្គលធ្វើខុសមាន ។ បើសមាជិកណាមួយធ្វើខុស គឺក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកដាក់ទណ្ឌកម្ម ។

***សំណួរ*** : *តើក្រុមប្រឹក្សាធម្មនុញ្ញបានពង្រឹងលទ្ធិប្រជាធិបតេយ្យអ្វីខ្លះសម្រាប់ប្រទេសកម្ពុជា ?*

ចម្លើយ : ព្រោះពាក្យថា ការពារការគោរពរដ្ឋធម្មនុញ្ញ មានន័យថា ការពាររបបប្រជាធិបតេយ្យសេរី ពហុបក្ស ការពារសិទ្ធិមនុស្ស ពិសេសការពារសិទ្ធិកុមារ និង សិទ្ធិស្ត្រី ។

***សំណួរ*** : *សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន ៣រូប ដែលជ្រើសតាំងដោយរដ្ឋសភានោះ តើជ្រើសចេញពីតំណាង ឬយ៉ាងណា ? បើមិនមែន ជ្រើសចេញពីណា ? បើមែន តើតំណាងរាស្ត្រជ្រើសចេញនោះមានតំណាងរាស្ត្រថ្មីមកជំនួសឬ?*

ចម្លើយ : អាស្រ័យទៅតាមស្ថាប័ននីមួយៗ អាចថាសមាជិកចេញពីរដ្ឋសភា អាចមិនមែនអ្នកនៅរដ្ឋសភា ប៉ុន្តែត្រូវបានសមាជិករដ្ឋសភា ១៣នាក់ ឧទ្ទេសនាមមកស្របទៅតាមលក្ខខណ្ឌកំណត់ ។ ផ្អែកលើច្បាប់បោះឆ្នោត សមាជិករដ្ឋសភារូប ណាម្នាក់ចេញ បេក្ខជនលេខរៀងបន្ទាប់ត្រូវមកជំនួស ។

***សំណួរ*** : *តើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានតម្លៃជាអ្វីបើប្រៀបទៅនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ ។*

ចម្លើយ : ច្បាប់អត់មានចែងទេ ប៉ុន្តែសូមជម្រាបថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺមានអានុភាពអនុវត្តទៅលើគ្រប់អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

***សំណួរ*** : *ចាប់តាំងពីក្រុមប្រឹក្សាធម្មនុញ្ញបានបង្កើតឡើង តើច្បាប់ណាខ្លះដែលអធម្មនុញ្ញភាព ហើយត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញត្រួតពិនិត្យ ?*

ចម្លើយ : គឺច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងកិច្ចការនារី ត្រង់មាត្រាមួយដែលចែងថា រដ្ឋមន្ត្រី ត្រូវតែជានារី ដែលផ្ទុយពីគោលការណ៍ស្មើភាពគ្នារវាងបុរស និង នារី ។

***សំណួរ*** : *ក្នុងការប្រជុំដោះស្រាយបញ្ហាអធម្មនុញ្ញភាព ឬ វិវាទបោះឆ្នោត បើមានអវត្តមាននៃសមាជិកណាមួយនៃក្រុមប្រឹក្សាធម្មនុញ្ញ តើនឹងមានចំណាត់ការបែបណា?*

ចម្លើយ : ការប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ កូរ៉ុមលើសពីពាក់កណ្តាល គឺស្មើនឹង ៥រូប អាចប្រជុំបានហើយ ។ ដូច្នេះ បើសមាជិកណាមួយអវត្តមានក៏មិនអីដែរ ឱ្យតែគ្រប់កូរ៉ុម។

***សំណួរ*** : *រាល់ការបង្កើតអ្វីមួយឡើង គេឃើញថាតែងតែមានគុណសម្បត្តិ និង គុណវិបត្តិកើតឡើង ។*

*-តើការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញមានគុណសម្បត្តិ និង គុណវិបត្តិដូចម្ដេចខ្លះ?*

*-តើការកែប្រែរដ្ឋធម្មនុញ្ញធ្វើឡើងដើម្បីកែប្រែរបបគ្រប់គ្រងប្រទេស ឬ តម្រូវតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល? ហេតុអ្វី?*

ចម្លើយ : ការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញស្របទៅតាមច្បាប់មិនមានគុណវិបត្តិអ្វីទេ គឺមានតែគុណសម្បត្តិ ។ រដ្ឋធម្មនុញ្ញហាម ៤ ប្រការមិនឱ្យកែទេ ប៉ុន្តែបើកែកន្លែងដទៃទៀតអាចកែបាន តែត្រូវរកសំឡេងឱ្យគ្រប់ ។

***សំណួរ*** : *ការត្រួតពិនិត្យជាអាទិកាលចែកចេញជា ២ គឺ ដាច់ខាត និង មិនដាច់ខាត។ តើដាច់ខាតត្រួតពិនិត្យ យ៉ាងដូចម្ដេច និង មិនដាច់ខាតត្រួតពិនិត្យយ៉ាងដូចម្ដេច? ហើយត្រួតពិនិត្យទៅលើអ្វីខ្លះ?*

ចម្លើយ : មិនមានការត្រួតពិនិត្យធម្មនុញ្ញភាពដោយដាច់ខាត និង មិនដាច់ខាតទេ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចលើកសំណើសុំត្រួតពិនិត្យធម្មនុញ្ញភាពដោយខ្លួនឯងបានទេ ។

***សំណួរ*** : *សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមាន ៩រូប ។ តើ ៣រូបដំបូងដែលប្ដូរក្នុងរយៈពេល ៣ឆ្នាំ មុនគេនោះ តើពួកគាត់អាចត្រឡប់ចូលក្នុងការជ្រើសរើសសមាជិកថ្មីបានទេ?*

ចម្លើយ : សមាជិក ៣ រូបដែលមានអាណត្តិ ៣ ឆ្នាំ នៅអាណត្តិដំបូង អាចបន្តឈរឈ្មោះម្ដងទៀតបាន។

***សំណួរ*** : *ប្រសិនបើមានករណីការបោះឆ្នោតមានភាពមិនត្រឹមត្រូវកើតឡើង តើក្រុមប្រឹក្សាធម្មនុញ្ញមានអានុភាពបញ្ឈប់មិនឱ្យសម្រេចពីការបោះឆ្នោតដែរទេ?*

ចម្លើយ : ការដោះស្រាយវិវាទបោះឆ្នោត បើការបោះឆ្នោតនោះមិនត្រឹមត្រូវទូទាំងប្រទេសតែម្ដង ឬមិនប្រក្រតីនៅមណ្ឌលណាមួយ ឬការិយាល័យណាមួយ គឺសមត្ថកិច្ចក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកសម្រេច ។

***សំណួរ*** : *ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ ។ តើចំណុចណាខ្លះដែលអាចបញ្ជាក់ថាជាស្ថាប័នឯករាជ្យ?*

ចម្លើយ : គឺចំណុចដែលយើងខ្ញុំអត់មានចំណុះឱ្យស្ថាប័នណាទេ ។ យើងធ្វើការងារទៅតាមរដ្ឋធម្មនុញ្ញ និង ច្បាប់កំណត់ ហើយក្នុងការសម្រេចឥតទៅរណបបុគ្គលណា ឬស្ថាប័នណាទេ ពោលគឺផ្អែកតែទៅលើរដ្ឋធម្មនុញ្ញ និង ច្បាប់បកស្រាយទៅគឺចប់ហើយ ។ នេះហើយគឺឯករាជ្យ ប៉ុន្តែមិនមែនឯករាជ្យក្នុងនគរមួយម្នាក់ឯងទេ មានទំនាក់ទំនងជាមួយអ្នកនេះអ្នកនោះ ដូចមកស្ថាប័ននេះអីចឹង ពេលមានបុណ្យទាន ឬពិធីផ្សេងៗក៏ចូលរួមដែរ កុំឱ្យតែមានប៉ះពាល់ដល់ស្ថាប័ន។

***សំណួរ*** : *តើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលកើតចេញពីការជ្រើសរើសដោយរដ្ឋសភា នៅពេលផ្លាស់ប្ដូរក្នុងរយៈពេល ៩ឆ្នាំម្ដង តើអាចឈរឈ្មោះឱ្យសមាជិករដ្ឋសភាបោះឆ្នោតធ្វើជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញម្ដងទៀតដែរឬទេ?*

ចម្លើយ : អត់ទេ។ បើចប់អាណត្តិ ៩ ឆ្នាំហើយ គឺចប់ហើយ ឥតមានមកឈរឈ្មោះម្ដងទៀតបានទេ ។

***សំណួរ : តើមានស្ថាប័នណាខ្លះដែលចំណុះឱ្យក្រុមប្រឹក្សាធម្មនុញ្ញដែរឬទេ?***

ចម្លើយ : អត់មានទេ ។ គ្មានខ្សែបណ្តោយ និង ខ្សែទទឹងទេ។ ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ ប៉ុន្តែថវិកាសម្រាប់ដំណើរការ គឺបានមកពីថវិការដ្ឋ ។

***សំណួរ : ប្រជាពលរដ្ឋដែលកើតទុក្ខមិនសុខចិត្តនឹងការជំនុំជម្រះរបស់តុលាការកំពូល អាចប្តឹងឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ជួយពិនិត្យរឿងក្តីនោះឡើងវិញបានឬទេ ?***

ចម្លើយ : មិនបានទេ ព្រោះច្បាប់មិនអនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើកិច្ចការនេះទេ វាចែកដាច់ពីគ្នា ។ គឺបញ្ហានីត្យានុកូលភាពជាសមត្ថកិច្ចរបស់តុលាការ ទុកឱ្យតុលាការជាអ្នកសម្រេច ។

***សំណួរ : ហេតុដូចម្តេចបានជាបណ្តឹងរបស់គណបក្សនយោបាយ ត្រូវបញ្ចប់នៅត្រឹមគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោតនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ?***

ចម្លើយ : ព្រោះច្បាប់បោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនផ្តល់សមត្ថកិច្ចឱ្យដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើរតួនាទីជាសាលាឧទ្ធរណ៍ និង បិទផ្លូវតវ៉ា។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ក៏ដូច្នោះដែរ ដូចឯកឧត្តម **សឹន សុវណ្ណី** បានលើកឡើងហើយថា ក្រុមប្រឹក្សាធម្មនុញ្ញមិនមានសមត្ថកិច្ចដោះស្រាយវិវាទកម្មនៃការបោះឆ្នោតថ្នាក់ក្រោមជាតិនោះទេ ប៉ុន្តែគឺនៅជំពាក់ការធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចដោះស្រាយវិវាទក្នុងករណីមានការតវ៉ានឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលសម្រេចលុបឈ្មោះ ឬ ក៏សម្រេចចុះឈ្មោះ ឬ មិនចុះឈ្មោះប្រជាពលរដ្ឋក្នុងពេលធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋអាចប្តឹងឡើងរហូតមកដល់ក្រុមប្រឹក្សាធម្មនុញ្ញបាន។ បច្ចុប្បន្នភាពបញ្ជីគេធ្វើរៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ។

***សំណួរ: តើសមត្ថកិច្ចបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតែមួយ ឬមានស្ថាប័នដទៃផ្សេងទៀតដែរ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានកំណត់ហើយ ថា ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នផ្តាច់មុខក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ និង បកស្រាយច្បាប់ ហើយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានអានុភាពអនុវត្តលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ បើមិនអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬរារាំងដល់កិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវមានទោសព្រហ្មទណ្ឌ ហើយអាចត្រូវពិន័យជាប្រាក់ថែមទៀត ។

***សំណួរ : តើពេលណាដែលប្រជាជនអាចមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ នៅពេលទទួលបានសាលក្រមពីតុលាការខេត្ត សាលាឧទ្ធរណ៍ ឬ ពីតុលាការកំពូល ?***

ចម្លើយ : គឺមិនមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទេ ។ ហើយបើមានការប្ដឹងទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញ យើងខ្ញុំធ្វើការប្រជុំគ្នា រួចធ្វើការជូនដំណឹងទៅវិញថា មិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។ សូមមើលក្នុងលិខិតផ្ដត់ ។

***សំណួរ : តើមានករណីលើកលែងដែរឬទេ ប្រសិនបើមានសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយរដ្ឋសភា ព្រឹទ្ធសភា មុខងារសាធារណៈ ប្រធាន ឬ អនុប្រធានគណបក្សនយោបាយ ប្រធាន ឬ អនុប្រធានសហជីព ឬ ចៅក្រមក្នុងតំណែងដូចមានចែងត្រង់មាត្រា ១៣៩ ថ្មី នៃរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : គ្មានការលើកលែងទេ ។ បើចូលធ្វើជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាល់តែលាលែងចេញពីមុខតំណែងទាំងអស់ដែលរដ្ឋធម្មនុញ្ញបានចែងពីវិសមិតភាព ប៉ុន្តែបើចប់អាណត្តិរបស់ខ្លួនអាចវិលត្រឡប់ទៅកន្លែងដើមវិញ ។

***សំណួរ: តើការតែងតាំងអាណត្តិនីមួយៗរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ខ្លះ ៣ឆ្នាំ ខ្លះ ៦ឆ្នាំ និង ខ្លះ ៩ឆ្នាំ ដោយរបៀបណា ?***

ចម្លើយ : សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិ ៩ឆ្នាំ សមាជិក ០៣រូប តែងតាំងដោយ ព្រះមហាក្សត្រ ០៣រូប ត្រូវជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយ ០៣រូប ត្រូវជ្រើសតាំង ដោយរដ្ឋសភា ។ អាណត្តិទី១ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានសមាជិក ០៣រូប តែងតាំង និង ជ្រើសតាំងសម្រាប់ រយៈពេល ៣ឆ្នាំ ៣រូប ត្រូវតែងតាំង និង ជ្រើសតាំងសម្រាប់រយៈពេល ៦ឆ្នាំ ០៣រូបទៀត ត្រូវតែងតាំង និង ជ្រើសតាំងសម្រាប់រយៈពេល ៩ឆ្នាំ គឺដើម្បីរក្សានិរន្តភាពស្ថាប័ន កុំឱ្យឈប់ ឈប់ទាំងអស់គ្នា ហើយចូលថ្មី ថ្មីទាំងអស់គ្នា ។ ក្នុងរយៈពេល ៣ឆ្នាំម្ដងៗ សមាជិកចំនួន ០៣រូប ត្រូវផ្លាស់ប្ដូរ និង តែងតាំងជាថ្មី គឺ ០១រូប តែងតាំងដោយព្រះមហាក្សត្រ ០១រូបជ្រើសតាំងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម និង ០១រូបទៀតជ្រើសតាំងដោយរដ្ឋសភា ។

***សំណួរ : តើរដ្ឋធម្មនុញ្ញ និង ក្រុមប្រឹក្សាធម្មនុញ្ញ ទាំងពីរនេះណាមួយធំជាង ? ចូរបកស្រាយ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញជាច្បាប់គោល ជាច្បាប់កំពូលលើគេបង្អស់ ហើយរាល់ការពិនិត្យធម្មនុញ្ញភាព បកស្រាយច្បាប់នានា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែគោរពតាមរដ្ឋធម្មនុញ្ញជាដាច់ខាត ។

***សំណួរ : តើជនណាខ្លះ ឬ ស្ថាប័នណាខ្លះមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ?***

ចម្លើយ : អ្នកដែលមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញមាន : ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ នាយករដ្ឋមន្ត្រី គណបក្ស

នយោបាយដែលក្រសួងមហាផ្ទៃបានបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។ គណបក្សនយោបាយ ប្តឹងផ្ទាល់ (បណ្តឹងនេះធ្វើបានតែក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន) ឬតាមបណ្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ក្នុងវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ បណ្តឹងរបស់ប្រជារាស្ត្រ គឺត្រូវធ្វើតាមរយៈតំណាងរបស់ខ្លួន ដូចជាប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញមានវិធានការដូចម្តេចដើម្បីកែលំអ ឬ លុបបំបាត់បាតុភាពនៅស្ថាប័នខ្លះដែលរៀបចំខ្លឹមសារលិខិតបទដ្ឋានគតិយុត្ត (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស...) ដែលស្របឯកសារយោង ឬ មិនស្របរដ្ឋធម្មនុញ្ញឱ្យមានប្រសិទ្ធភាព ឬ ក្លាយជាប្រទេសប្រកាន់នីតិរដ្ឋ ។***

ចម្លើយ : ប្រហែលមិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ព្រោះរដ្ឋធម្មនុញ្ញបានបញ្ជាក់ហើយ ថា អំណាចទាំងបីធ្វើអ្វីក៏ដោយត្រូវស្របរដ្ឋធម្មនុញ្ញ ហើយក្រុមប្រឹក្សាធម្មនុញ្ញមើល និង ឱ្យយោបល់ទៅលើការសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និង មានសមត្ថកិច្ចពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាមុនប្រកាសឱ្យប្រើ និង បកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់ហើយ ។

***សំណួរ : តាមប្រសាសន៍ឧទ្ទេសនាមរបស់លោកជំទាវ ស៊ុំ នីផា ថា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបុព្វសិទ្ធិស្មើប្រធានរដ្ឋសភា រីឯសមាជិកស្មើអនុប្រធានរដ្ឋសភា តើឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិប្រើរថយន្ត ស៊ីរ៉ែននាំមុខក្នុងការធ្វើដំណើរដែរឬទេ ? បើមានហេតុអ្វីឯកឧត្តមមិនប្រើ ?***

ចម្លើយ : មានសិទ្ធិប្រើឡានស៊ីរ៉ែនបើកផ្លូវហើយមិនប្រើ ព្រោះពិបាកធ្វើដំណើរ ។

***សំណួរ : តើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញម្នាក់ៗ មានអភ័យឯកសិទ្ធិដែរឬទេ ?***

ចម្លើយ : ជាគោលការណ៍ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនមានអភ័យឯកសិទ្ធិដូចសមាជិកសភាទេ តែនៅក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មានបទប្បញ្ញត្តិមួយចែងថា សមាជិកក្រុមប្រឹក្សា-ធម្មនុញ្ញមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬ បទរដ្ឋប្បវេណីណាមួយចំពោះការសម្រេចដែលបានធ្វើនៅពេលដែលបំពេញភារកិច្ចឡើយ ។ ករណីនេះមើលទៅហាក់ដូចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានអភ័យឯកសិទ្ធិខ្លះដែរដែលច្បាប់បានការពារ ។

***សំណួរ : តើប្រទេសប្រកាន់លទ្ធិកុម្មុយនិស្តមានក្រុមប្រឹក្សាធម្មនុញ្ញឬទេ ? បើមាននោះ មានសិទ្ធិ និង តួនាទីដូច ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ ឬ សេរីនិយមឬទេ ?***

ចម្លើយ : គ្មានទេ ។

*សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញអាចបកស្រាយពីលិខិតក្រោមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តនានាដែលពុំប្រក្រតីបានដែរឬទេ ?*

ចម្លើយ : មិនបានទេ ព្រោះគ្មានសមត្ថកិច្ច ។

*សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញអាចបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់នានា ដោយមានពាក្យបណ្តឹង ឬ ពិនិត្យ ដោយខ្លួនឯង តើពិតមែនឬទេ ?*

ចម្លើយ : បើគ្មានបណ្តឹងត្រឹមត្រូវតាមនីតិវិធីដែលមានកំណត់ក្នុងច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចពិនិត្យបានទេ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចធ្វើស្វ័យបណ្តឹងដោយខ្លួនឯងបានទេ ។

*សំណួរ : តើប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសរើសដោយរបៀបណា ?*

ចម្លើយ : ដោយសមាជិករបស់ខ្លួន ០៨រូបទៀត និង ដោយការបោះឆ្នោតជាសម្ងាត់ ។

*សំណួរ : តើស្ថាប័នណាខ្លះជាស្ថាប័នរដ្ឋ ? ហើយក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នរដ្ឋដែរឬទេ ?*

ចម្លើយ : ស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជាស្ថាប័នរដ្ឋទាំងអស់ ។ ប្រសិនបើរាជរដ្ឋាភិបាលចង់បង្កើតគណៈកម្មាធិការ ឬ អាជ្ញាធរណាមួយជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលជាអ្នកបង្កើតដោយអនុក្រឹត្យ ។

*សំណួរ : បើសិនជាក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមិនតាមរដ្ឋធម្មនុញ្ញ តើយ៉ាងណាទៅវិញ ?*

ចម្លើយ : ក្រុមប្រឹក្សាធម្មនុញ្ញអនុវត្តទៅតាមសមត្ថកិច្ចដែលច្បាប់បានកំណត់ឱ្យ ពិសេសធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ។

*សំណួរ : តើការផ្សព្វផ្សាយច្បាប់ ការពន្យល់ខ្លឹមសារមាត្រាច្បាប់ និង ការបកស្រាយច្បាប់ (ដែលមានតែក្រុមប្រឹក្សាធម្មនុញ្ញទើបមានសមត្ថកិច្ច) ខុសគ្នាដូចម្តេច ?*

ចម្លើយ : ខ្ញុំសូមបញ្ជាក់ពាក្យមួយឃ្លាថា ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ ពាក្យនេះជាពាក្យច្បាប់ ហើយច្បាប់រដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចបកស្រាយ រដ្ឋធម្មនុញ្ញ និង បកស្រាយច្បាប់ ។ ចំណែកការផ្សព្វផ្សាយច្បាប់ ការពន្យល់ខ្លឹមសារច្បាប់ នរណាក៏មានសិទ្ធិពន្យល់ និង ផ្សព្វផ្សាយដែរ ព្រោះវាជាការបង្រៀនពីអ្នកចេះច្បាប់ទៅអ្នកមិនទាន់យល់ដឹងពីច្បាប់ ។

*សំណួរ : ហេតុអ្វីបានជាក្រុមប្រឹក្សាធម្មនុញ្ញគ្មានអនុប្រធានដូចព្រឹទ្ធសភា និង រដ្ឋសភា ?*

ចម្លើយ : ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងយ៉ាងច្បាស់ណាស់ គឺមានតែប្រធាន មិនមានអនុប្រធាននោះទេ ហើយប្រធានត្រូវនៅជាប្រចាំជាមួយស្ថាប័នផ្ទាល់ ដោយមិនអាចអវត្តមានយូរនោះទេ ទោះបីជាត្រូវបំពេញបេសកកម្មនៅឯបរទេស ក៏ត្រូវមានទំនាក់ទំនងជាប់ជានិច្ចមកស្ថាប័នដែរ ។

**សំណួរ** : *សូមឯកឧត្តម ជួយពន្យល់បន្ថែម :*

*-រដ្ឋធម្មនុញ្ញជាលក្ខន្តិកៈនៃអំណាច ?*

*-ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកការពាររដ្ឋធម្មនុញ្ញ ?*

ចម្លើយ : -រដ្ឋធម្មនុញ្ញជាលក្ខន្តិកៈនៃអំណាច : គឺមានន័យថា អ្នកដែលមានអំណាចត្រូវគ្រប់គ្រងប្រជាពលរដ្ឋទៅតាមអ្វីដែលរដ្ឋធម្មនុញ្ញបានសរសេរ អីចឹង គឺមានន័យថា មិនមែនបាត់សិទ្ធិអ្នកដែលមានអំណាចនោះទេ គឺគាត់ត្រូវគោរពតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ លិខិតបទដ្ឋានទាំងឡាយដើម្បីគ្រប់គ្រងដឹកនាំប្រទេស ។ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវតែគោរពតាមលក្ខន្តិកៈនេះជាដាច់ខាត ។ លក្ខន្តិកៈនេះជា តំណាងឱ្យឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ដែលជាលក្ខណៈប្រជាធិបតេយ្យបែបទំនើបមួយក្នុងយុគសម័យថ្មីនេះ ។

-ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកការពាររដ្ឋធម្មនុញ្ញ គឺមានន័យថា ក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាឆ្មាំឃ្លាំមើលការអនុវត្តរដ្ឋធម្មនុញ្ញ ដើម្បីកុំឱ្យមានការអនុវត្តប្រាសចាកពីរដ្ឋធម្មនុញ្ញ តែបើឋិតក្នុងកាលៈទេសៈពិសេសណាមួយដូចជា ពេលមានសង្គ្រាម ឬ រដ្ឋប្រហារអ្វីមួយ គឺក្រុមប្រឹក្សាធម្មនុញ្ញមិនអាចជាអ្នកការពាររដ្ឋធម្មនុញ្ញបន្តទៀតនោះទេ ព្រោះទាំងអស់គ្នាលែងគោរពរដ្ឋធម្មនុញ្ញទៀតហើយ គេប្រើច្បាប់អាជ្ញាសឹក ។

**សំណួរ** : *តើសភាធម្មនុញ្ញ និង ក្រុមប្រឹក្សាធម្មនុញ្ញខុសគ្នាដូចម្តេច ?*

ចម្លើយ : សភាធម្មនុញ្ញ និង ក្រុមប្រឹក្សាធម្មនុញ្ញ មានលក្ខណៈខុសគ្នាស្រឡះ គឺសភាធម្មនុញ្ញមានតួនាទីក្នុងការតាក់តែង ពិភាក្សា និង អនុម័តរដ្ឋធម្មនុញ្ញ ។ ចំណែកឯក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចក្នុងការធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់ហើយ ។

**សំណួរ** : *តើក្រុមប្រឹក្សាធម្មនុញ្ញកាត់ក្តីតែទៅលើទំនាស់ផ្នែកនយោបាយ ឬ ក៏ដោះស្រាយទៅលើទំនាស់ព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីដែរ ?*

ចម្លើយ : ក្រុមប្រឹក្សាធម្មនុញ្ញពុំមានអំណាចក្នុងការកាត់ក្តីលើទំនាស់នយោបាយ ឬ ក៏ដោះស្រាយទំនាស់ព្រហ្មទណ្ឌ និង រដ្ឋប្បវេណីទេ ។ យោងតាមច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទកម្មពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ជ្រើសតាំងសមាជិកព្រឹទ្ធសភា ហើយទទួលសំណើក្នុងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់តែប៉ុណ្ណោះ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញពុំមានសមត្ថកិច្ចដោះស្រាយទំនាស់នយោបាយទេ ។

***សំណួរ: តើឯករាជភាពនៅត្រង់ណា បើកន្លងមកស្ថាប័ននេះត្រូវបានរំលោភនៅពេលមានវិបត្តិនយោបាយនៅក្នុងប្រទេស ?***

ចម្លើយ : តាមពិតប្រទេសយើងមិនដែលមានវិបត្តិនយោបាយទេ ។ និយាយដោយស្មោះត្រង់ភាពជាប់គាំងខាងនយោបាយមាន វិបត្តិនយោបាយមិនទាន់មានទេ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនដែលមានស្ថាប័នណារំលោភបំពានទេ ហើយក៏គ្មានស្ថាប័នណាបង្គាប់ឱ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើបែបនេះធ្វើបែបនោះដែរ ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចអ្វីខ្លះទាក់ទងព្រឹទ្ធសភា និង រដ្ឋសភា ?***

ចម្លើយ : បើនិយាយពីចំណងទាក់ទងគ្នាខ្សែទទឹងបណ្តោយអត់មានទេ ព្រោះក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នមួយដោយឡែក មានសមត្ថកិច្ចខុសគ្នា ។ លោកជំទាវបានឧទ្ទេសនាមរួចហើយ រដ្ឋសភា ព្រឹទ្ធសភា ជាអ្នកធ្វើច្បាប់ ឯក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកធានាការពារការគោរពរដ្ឋធម្មនុញ្ញ គឺចាប់បង្ខំឱ្យគេគោរព ហើយយើងបានដឹងហើយ ការសម្រេចទាំងឡាយណារបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យជាតិ អធិបតេយ្យ បូរណ-ភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា បើមិនគោរពមានទោសព្រហ្មទណ្ឌជាប់ពន្ធនាគារ ឬ អាចត្រូវពិន័យថែមទៀត ។

***សំណួរ : ក្រុមប្រឹក្សាធម្មនុញ្ញយករូបព្រះនារាយណ៍ធ្វើជានិមិត្តសញ្ញា តើរូបភាពនេះមានអត្ថន័យតំណាងឱ្យដូចម្តេចខ្លះ ?***

ចម្លើយ : មិនមែនព្រះនារាយណ៍ទេ គឺព្រះព្រហ្ម ព្រះព្រហ្មមុខ ៤ ជាអាទិទេពមួយអង្គ ព្រះព្រហ្មជាកំពូលអាទិទេព ជាអាទិទេពបង្កើតលោកក្នុងសាសនាព្រាហ្មណ៍ ។ និមិត្តសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ មានរូបព្រះព្រហ្មមានព្រះភ័ក្ត្រ ៤ និង ព្រះហស្ត ៤ កាន់កេតនភណ្ឌ គង់លើបល្ល័ង្ក ។ ព្រះព្រហ្មជានិមិត្តរូបនៃអ្នកបង្កើតលោក ។ ព្រះភ័ក្ត្រព្រះព្រហ្មតំណាងឱ្យព្រហ្មវិហារធម៌ទាំងបួនគឺ : **មេត្តា ករុណា មុទិតា និង ឧបេក្ខា** ។

- ព្រះហស្តឆ្វេងខាងលើកាន់ផ្កាឈូក : តំណាងការកកើត
- ព្រះហស្តឆ្វេងខាងក្រោមកាន់សាស្ត្រា : តំណាងគម្ពីរ ក្បួន ច្បាប់
- ព្រះហស្តស្តាំខាងលើកាន់ផ្គាំ : តំណាងឱ្យការរំងាប់អារម្មណ៍ ការឧទ្ទិសកុសល ការចំរើនភាវនា រកអំពើល្អ ផ្លូវធម៌ ផ្លូវលោក
- ព្រះហស្តខាងស្តាំខាងក្រោមកាន់ពួចទឹក : តំណាងទឹកអម្រឹតប្រោះព្រំ ឱ្យសុខសប្បាយត្រជាក់ត្រជុំឱ្យរស់

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិចូលដោះស្រាយវិវាទផ្នែកយោធាដែរឬទេ ? តើក្រុមប្រឹក្សាធម្មនុញ្ញមានការពាក់ព័ន្ធជាមួយយោធាដែរឬទេ ? បើសិនជាមានពាក់ព័ន្ធ តើយ៉ាងដូចម្តេច ?***

ចម្លើយ : មិនមានទេ ។

***សំណួរ : ក្រោយពេលបោះឆ្នោតជាតិ ខែ កក្កដា ឆ្នាំ២០០៨ មានគណបក្សនយោបាយមួយដែលត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើការផាកពិន័យជាប្រាក់លើការរំលោភច្បាប់បោះឆ្នោត ។ ប៉ុន្តែប្រធានគណបក្សនោះហាក់ដូចជាពុំគោរពតាមសិទ្ធិសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយអំពាវនាវឱ្យព្រះមហាក្សត្រប្រើព្រះរាជសិទ្ធិលើកលែងឱ្យខ្លួន ។ តើបញ្ហានេះក្រុមប្រឹក្សាធម្មនុញ្ញ ចាត់វិធានផ្លូវច្បាប់យ៉ាងណា ដើម្បីការពារច្បាប់និងការកម្រិតសិទ្ធិនៃគណបក្សនយោបាយនោះ ។***

ចម្លើយ : អ្នកដាក់សំណួរ គឺជាអ្នកតាមដានព្រឹត្តិការណ៍ម្នាក់ រឿងនេះពាក់ព័ន្ធទៅនឹងមាត្រា ៣៦ នៃច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិននៅស្ងៀមទេ គាត់ឃើញបុគ្គលនោះមិនគោរព គាត់ប្តឹងភ្លាមទៅព្រះរាជអាជ្ញាអមតុលាការសាលាដំបូងរាជធានីភ្នំពេញ ។ ការប្តឹងនោះមានទម្ងន់ខ្លាំង គឺទី១ ប្តឹងពីការមិនគោរពសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទី២ បើកឱ្យមានការចោទប្រកាន់ ព្រោះមិនងាយចោទបានទេ ដោយអ្នកត្រូវគេប្តឹងជាតំណាងរាស្ត្រ ត្រូវសុំលើកអភ័យឯកសិទ្ធិជាមុន ព្រះរាជអាជ្ញាសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ស្នើទៅប្រធានរដ្ឋសភា ដោយយល់ថា ស្ថិតក្នុងអំឡុងពេលដែលរដ្ឋសភាវិស្សមកាល គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបើកកិច្ចប្រជុំដកអភ័យឯកសិទ្ធិពេលព្រឹកដល់ពេលល្ងាចសាមីខ្លួនក៏យក ១០.០០០.០០០រ០០ ទៅបង់នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ នៅពេលព្រឹកថ្ងៃបន្ទាប់ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ធ្វើលិខិតដកពាក្យបណ្តឹងវិញ រឿងនោះក៏ចប់ទៅ ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញមានទំនាក់ទំនងអ្វីជាមួយរដ្ឋសភា ព្រឹទ្ធសភា និង ជាមួយព្រះមហាក្សត្រ ?***

ចម្លើយ : បានបញ្ជាក់រួចហើយក្នុងបទឧទ្ទេសនាមរបស់លោកជំទាវ ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញបង្កើតក្នុងបំណងអ្វីនៅក្នុងរាជរដ្ឋាភិបាល ឬ នៅក្នុងសង្គមមួយ ។ មូលហេតុអ្វីបានជាបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ? តើសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាអ្វី ? តើរដ្ឋធម្មនុញ្ញមានគោលបំណងអ្វីក្នុងព្រះរាជាណាចក្រកម្ពុជា និង ក្រុមប្រឹក្សាធម្មនុញ្ញបង្កើតឡើងដើម្បីអ្វីក្នុងរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ដូចឯកឧត្តម ប៉ែន ថុល ជម្រាបជូនហើយ គឺរដ្ឋធម្មនុញ្ញមានតួនាទីសំខាន់ណាស់នៅក្នុងរដ្ឋមួយ វាមានតួនាទីសម្រាប់គ្រប់គ្រងរដ្ឋ ជាច្បាប់គោលដែលកំណត់អំពីរបបនយោបាយ និង ការបែងចែកអំណាចនយោបាយ ។ ប្រសិនបើគ្មានរដ្ឋធម្មនុញ្ញទេ ប្រៀបបាននឹងប្រទេសគ្មានច្បាប់ ពីព្រោះរដ្ឋធម្មនុញ្ញជាច្បាប់មេសម្រាប់បង្កើតច្បាប់ផ្សេងៗទៀត ប៉ុន្តែនៅអាស៊ីអាគ្នេយ៍យើងមានប្រទេសប៊្រុយណេ ជាប្រទេសគ្មានរដ្ឋធម្មនុញ្ញ ប៉ុន្តែគេរស់នៅបានសុខដែរ ។ ជាទូទៅ គឺប្រទេសទាំងឡាយតែងតែមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូល ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចបកស្រាយរដ្ឋធម្មនុញ្ញ ច្បាប់ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដោះស្រាយវិវាទទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ គោលបំណងនៃការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ គឺពង្រឹងនីតិរដ្ឋ ។

***សំណួរ : ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិស្មើរដ្ឋសភា ឬ ព្រឹទ្ធសភាដែរឬទេ ?***

ចម្លើយ : មិនដឹងពន្យល់យ៉ាងម៉េចទេ បើនិយាយពីសិទ្ធិស្ថាប័ន និង ស្ថាប័ន ដូចពិបាកនិយាយ បើសិទ្ធិពលរដ្ឋដូចស្រួលនិយាយជាង។ បើនិយាយពីសមត្ថកិច្ចអាចនិយាយបាន សមត្ថកិច្ចមិនដូចគ្នាទេ រដ្ឋសភាធ្វើច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញធានាការពារការគោរពរដ្ឋធម្មនុញ្ញ ដោះស្រាយវិវាទទាក់ទងនិងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញមានបទបញ្ជាផ្ទៃក្នុងដើម្បីដឹកនាំការងារដែរឬទេ ? បើមាន តើបទបញ្ជាផ្ទៃក្នុង នោះមានប្រយោជន៍អ្វីខ្លះ ?***

ចម្លើយ : មាន ។ បទបញ្ជាផ្ទៃក្នុង គឺជាវិធានដែលសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ និង មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់ត្រូវគោរព មិនខុសគ្នាពីបទបញ្ជាយើងប្រើក្នុងតុលាការ ឬ ប្រើនៅក្នុងអង្គភាព ឬ សាលានានានោះដែរទេ ។ មានបទបញ្ជាផ្ទៃក្នុងពីរ ទី១ បទបញ្ជាផ្ទៃក្នុងសម្រាប់ការត្រួតវិន័យ ទី២ បទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ។ ឯកសារនេះនឹងមានជូននាយកសាលាដើម្បីតម្កល់ទុកក្នុងបណ្ណាល័យ ។

***សំណួរ : ហេតុអ្វីបានជាស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៅក្រៅអំណាចទាំងបី ?***

ចម្លើយ : រដ្ឋធម្មនុញ្ញចែងយ៉ាងដូច្នេះ ច្បាប់ក៏ចែងអ៊ីចឹង នៅដោយឡែកមែន ជាស្ថាប័នទោលស្ថិតក្នុងបរិវេណព្រឹទ្ធសភា គ្មានខ្សែទទឹង ខ្សែបណ្ដោយទេ តែទំនាក់ទំនងមាន បើមិនមានទំនាក់ទំនងបានប្រាក់មកពីណាចាយព្រោះដំណើរការត្រូវការថវិកា ។

***សំណួរ : សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបិទផ្លូវតវ៉ា តើមុននឹងសម្រេចយើងអាចតវ៉ាបានដែរឬទេ? បើមានការតវ៉ាបានមុនសម្រេច តើដំណើរការតវ៉ានោះមានរបៀបរបបបែបណាខ្លះ ?***

ចម្លើយ : ប្រយ័ត្នប្រយែងណាស់មុននឹងសម្រេច ផ្អែកលើមូលដ្ឋានគតិយុត្ត មើលរដ្ឋធម្មនុញ្ញ មើលច្បាប់ មើលទាំងកតិការសញ្ញាទាំងឡាយក្រែងលោមានការពាក់ព័ន្ធ ។ ក្រុមប្រឹក្សាធម្មនុញ្ញថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយមើលគ្រប់អស់ហើយ ពេលខ្លះពិភាក្សាគ្នាសម្ងាត់នៅក្នុងបន្ទប់ពិភាក្សា គ្មានអ្នកណាចូលបានទេ សមាជិកក្មេងជាងគេជាលេខាធិការកត់ត្រា ពេលខ្លះជជែកគ្នាដាច់បាយរាប់ម៉ោង ។ ធម្មតាទេ អ្នកឈ្នះសប្បាយចិត្ត អ្នកចាញ់មិនសប្បាយចិត្ត មានប្រតិកម្មអីចេះអីចុះ ។

**សំណួរ ៖ តើក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិប៉ុន្មានឆ្នាំ? ហើយសមាជិកទាំងនោះមានការចូលនិវត្តន៍ឬទេ? មានការចូលនិវត្តន៍ចាប់ពីអាយុប៉ុន្មាន ?**

ចម្លើយ ៖ ក្រុមប្រឹក្សាធម្មនុញ្ញមាន ៩រូប ៣រូបតែងតាំងពីព្រះមហាក្សត្រ ៣រូបជ្រើសតាំងដោយរដ្ឋសភា ៣រូបទៀតជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ជាធម្មតាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិ ៩ឆ្នាំ លើកលែងតែអាណត្តិទីមួយ សមាជិក ៣រូបមានអាណត្តិ ៣ឆ្នាំ ៣រូបមានអាណត្តិ ៦ឆ្នាំ ៣រូបមានអាណត្តិ ០៩ឆ្នាំ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទទួលប្រាក់សោធននិវត្តន៍នៅពេលចប់អាណត្តិរបស់ខ្លួន ។ គឺមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មានន័យថារបបសោធននិវត្តន៍ដែលអនុវត្តចំពោះតំណាងរាស្ត្រនឹងយកមកអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែរ ។ អាយុចូលនិវត្តន៍គិតពីអាយុ ៦០ឆ្នាំ ឡើងទៅ អាចសុំចូលនិវត្តន៍ដោយទទួលរបបសោធននិវត្តន៍ ។ ថវិកានេះជាថវិកាជាតិ ដែលបញ្ចូលទៅក្នុងថវិកាក្រុមប្រឹក្សាធម្មនុញ្ញប្រចាំឆ្នាំ ហើយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវទៅបើកប្រាក់សោធននិវត្តន៍នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

**សំណួរ ៖ តើក្រុមប្រឹក្សាធម្មនុញ្ញអាចពិនិត្យធម្មនុញ្ញភាពសន្ធិសញ្ញាអន្តរជាតិដែរឬទេ ?**

ចម្លើយ ៖ ធម្មតាសន្ធិសញ្ញាត្រូវបញ្ជូនទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រួចបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់មកដាក់ឆ្លងសុំរដ្ឋសភាឱ្យសច្ចាប័ន ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចពិនិត្យធម្មនុញ្ញភាពសន្ធិសញ្ញាអន្តរជាតិបានទេ ។

**សំណួរ ៖ តើមានច្បាប់ណាខ្លះដែលឆ្លងកាត់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាពដាច់ខាត? ហេតុអ្វី?**

ចម្លើយ ៖ ច្បាប់ដែលឆ្លងកាត់ក្រុមប្រឹក្សាធម្មនុញ្ញត្រូតពិនិត្យធម្មនុញ្ញភាពមុនប្រកាសឱ្យប្រើ គឺច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាផងដែរ ដែលត្រូវយកមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ គឺដោយមានចែងក្នុងច្បាប់ ច្បាប់តម្រូវយ៉ាងនេះ ។

**សំណួរ ៖ ប្រសាសន៍របស់ឯកឧត្តម ព្រហ្ម ញាណវិចិត្រ បានលើកឡើងថា ច្បាប់ គឺជាទម្រង់បទបញ្ញត្តិទូទៅ និងខ្លឹមសារលម្អិតពិបាកយល់ ។ សុភាសិតបារាំងមួយលើកឡើងថា ពលរដ្ឋបារាំងគ្មាននរណាម្នាក់មិនចេះច្បាប់ ។ ឥឡូវយើងងាកមើលប្រជាពលរដ្ឋកម្ពុជាវិញ មានប្រជាពលរដ្ឋជាច្រើនដែលមិនបានរៀនជ្រៅជ្រះ ។ ចំពោះប្រសាសន៍នេះ តើឯកឧត្តមយល់យ៉ាងណាដែរចំពោះលទ្ធភាពនៃការយល់ដឹងរបស់ពលរដ្ឋកម្ពុជាទៅលើផ្នែកច្បាប់?**

ចម្លើយ ៖ នេះមិនមែនជាបញ្ហាពិបាកទេ វាជាសុភាសិតបារាំងមួយដែលមានប្រភពពីប្រទេសបារាំង ។ ចំពោះការអនុវត្តន៍ក្នុងសម័យទំនើបនេះ ច្បាប់មាននីតិវិធីនៃការផ្សព្វផ្សាយ ។ ឧទាហរណ៍ ក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានការផ្តួចផ្តើមពីឯកឧត្តមប្រធាន ឱ្យមានការផ្សព្វផ្សាយនៅតាមមូលដ្ឋានផ្សេងៗ ហើយអ្នកដែលមកចូលរួមអាចធ្វើការផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយបន្ថែម ។ ខ្ញុំសូមឆ្លើយដោយខ្លីប៉ុណ្ណេះ ។

***សំណួរ : តើមានមូលហេតុអ្វីដែលបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ?***

ចម្លើយ : ដូចដែលឯកឧត្តម លោកជំទាវ បានលើកឡើងហើយ ការបង្កើតស្ថាប័នមួយនេះ គឺជាការរួមចំណែកពង្រឹងនីតិរដ្ឋក្នុងរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស សេដ្ឋកិច្ចទីផ្សារសេរី។ កន្លងមកក្នុងរបបសាធារណរដ្ឋ-ខ្មែរគេបង្កើតតុលាការធម្មនុញ្ញ ហើយក្នុងរបបរដ្ឋកម្ពុជាទាក់ទងនឹងការបកស្រាយច្បាប់ បកស្រាយរដ្ឋធម្មនុញ្ញ មានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងមានក្រុមប្រឹក្សារដ្ឋ ។ តាមការវិវឌ្ឍន៍ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នេះ បង្កើតក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីបំពេញសមត្ថកិច្ចរបស់ខ្លួនដែលចែងក្នុងរដ្ឋធម្មនុញ្ញ ជំពូកទី១២ថ្មី ថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចក្នុងការធានាការពារការគោរពរដ្ឋធម្មនុញ្ញ និងបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ និងដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា។ នេះជាការវិវឌ្ឍន៍មួយ។ ហេតុអ្វីមិនទុកឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាធ្វើទៅ ? តាមបទពិសោធន៍ ការទុកឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាធ្វើក៏បានដែរ ការលំបាកត្រង់ថា គាត់ជាអ្នកធ្វើច្បាប់រួចទៅហើយ ដល់មានការមិនច្បាស់ទុកឱ្យគាត់បកស្រាយវាមានការពិបាក ហើយបើតុលាការបកស្រាយរដ្ឋធម្មនុញ្ញក៏មានការពិបាកដែរ។ ដូច្នេះ ត្រូវឱ្យមានស្ថាប័នផ្សេងមួយជាអ្នកបកស្រាយ ។

***សំណួរ : ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និង សម្រេចពីករណីវិវាទកម្មទាក់ទងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភា ។ ចំពោះខ្លឹមសារនេះ តើវិវាទកម្មនេះត្រូវឆ្លងកាត់ប្រព័ន្ធតុលាការដែរឬទេ? ក្នុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង មានចែងក្នុងច្បាប់បោះឆ្នោតទាំងពីរ ហើយច្បាប់បោះឆ្នោតកំណត់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាធម្មនុញ្ញ គ.ជ.ប និង ខ្សែរយៈ គ.ជ.ប បកស្រាយឬកំណត់ដោយអ្វី ?***

ចម្លើយ : វិវាទកម្មទាក់ទងការបោះឆ្នោតជាសមត្ថកិច្ចរបស់ គ.ជ.ប និង ក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកសម្រេចហើយក្រុមប្រឹក្សាធម្មនុញ្ញអាចជាសាលាកាត់សេចក្តីចុងក្រោយ តែបើទាក់ទងបទល្មើសថ្មីទៀតជាសមត្ថកិច្ចរបស់តុលាការ ។ ឧទាហរណ៍ ការចុះបញ្ជីបោះឆ្នោត វិវាទកម្មជុំវិញការឃោសនាបោះឆ្នោត ភាពមិនប្រក្រតីនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ជាសមត្ថកិច្ចរបស់ គ.ជ.ប ក្នុងរចនាសម្ព័ន្ធរបស់ គ.ជ.ប ពីក្រោម ដល់ថ្នាក់កណ្តាល គ.ជ.ប ហើយចុងក្រោយគេគឺក្រុមប្រឹក្សាធម្មនុញ្ញ។ បើក្រុមប្រឹក្សាធម្មនុញ្ញកាត់សេចក្តីចប់ហើយមិនអាចប្តឹងទៅណាទៀតបានទេ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនមែនស្ថិតក្នុងរចនាសម្ព័ន្ធតុលាការនោះទេ តែជាស្ថាប័នមួយដោយឡែកមានតែមួយទោល គ្មានខ្សែបណ្តោយ ចុះក្រោម គ្មានខ្សែទទឹង ។ ត្រង់នេះខ្ញុំសូមភ្ជាប់សំណួរថា តើមានទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលឬទេ ? គឺពិតជាមាន ឯករាជ្យនៅពេលនេះ គឺឯករាជ្យតែក្នុងសមត្ថកិច្ចរបស់ខ្លួន តែទំនាក់ទំនងរដ្ឋបាល និង ហិរញ្ញវត្ថុ គឺទាក់ទងគ្នារហូត ។

***សំណួរ : ប្រសិនបើប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ឬ កំពុងមានសង្គ្រាម តើក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចធ្វើអ្វីខ្លះ ? ឬប្រទេសជាតិមានជម្លោះផ្ទៃក្នុងអាចបង្កឡើងដោយមានផ្ទុះអាវុធខ្លាំងក្លាបែងចែកទឹកដី តើក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចធ្វើអ្វីខ្លះ ?***

ចម្លើយ : បើប្រទេសស្ថិតក្នុងភាពអាសន្ន រដ្ឋសភាត្រូវប្រជុំរាល់ថ្ងៃ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃ ក្រុមប្រឹក្សា-ធម្មនុញ្ញ មិនទាន់មានបទបញ្ញត្តិចែងពីករណីនេះទេ តែប្រហែលជាប្រជុំរាល់ថ្ងៃហើយ ដើម្បីតាមដានមើលក្នុងឋានៈខ្លួនជាអ្នកការពារការគោរពរដ្ឋធម្មនុញ្ញ ធ្វើយ៉ាងម៉េចដើម្បីកុំឱ្យគេរំលោភលើរដ្ឋធម្មនុញ្ញ ។ ប្រសិនបើមានរដ្ឋប្រហារហើយ គឺក្រុមប្រឹក្សាធម្មនុញ្ញមិនមានអ្វីទៀតទេ ព្រោះគេលែងគោរពរដ្ឋធម្មនុញ្ញហើយ ។ តែប្រើច្បាប់យោធា គឺចប់ហើយ ។

***សំណួរ : ប្រសិនបើគណបក្សនយោបាយណាឈ្នះឆ្នោត ហើយគណបក្សនោះមានអំណាចទាំងស្រុងក្នុងការគ្រប់គ្រងប្រទេស ហើយបានផ្លាស់ប្តូររដ្ឋធម្មនុញ្ញទាំងស្រុង ។ តើក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចធ្វើអ្វីខ្លះ ?***

ចម្លើយ : ចំណុចនេះជាសំណួរដែលឆ្លើយបានខ្លះហើយ ។ ចង់បន្ថែមបន្តិចថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និងបន្តមក គឺប្តូរភ្លេងជាតិ ប្តូរទង់ជាតិ មិនមែនជាការងាយទេ ។ ក្រុមប្រឹក្សាធម្មនុញ្ញ ប្រហែលជាមិនឱ្យគេផ្លាស់ប្តូររដ្ឋធម្មនុញ្ញទេ បើគណបក្សណាឈ្នះឆ្នោត លោកចង់ធ្វើវិសោធនកម្ម ឬ កែប្រែមាត្រាណាខ្លះដែលរដ្ឋធម្មនុញ្ញបានកំណត់កែបាន តែត្រូវគោរពតាមករណីហាមឃាត់មួយចំនួនដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដូចជា :

-ប្រទេសស្ថិតក្នុងភាពអាសន្ន

-ប៉ះពាល់ដល់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

-ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ តែមិនកាន់អំណាច

-និងមិនឱ្យកែប្រែទេត្រង់ចំណុចដែលថា ប្រទេសកម្ពុជាប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស

ចំណុចខាងលើនេះប្រសិនបើមកដល់ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញនឹងបដិសេធចោល និង បិទផ្លូវតែម្តង ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ អព្យាក្រឹត ដែរឬទេ ? សូមបង្ហាញអំណះអំណាង ?***

ចម្លើយ : អំណះអំណាង គឺសេចក្តីសម្រេចទាំងឡាយដែលបានធ្វើរយៈពេល១១ឆ្នាំកន្លងមកនេះ គឺជាការបញ្ជាក់ពីគោលការណ៍ឯករាជ្យ អព្យាក្រឹត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**សំណួរ** : *បើមិនមានការសុំពិនិត្យធម្មនុញ្ញភាពពីព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា១/៤ និង តំណាងរាស្ត្រ១/១០ ឬតុលាការ តើក្រុមប្រឹក្សាធម្មនុញ្ញអាចមានវិធីសាស្ត្រណាខ្លះ បើខ្លួនដឹងថាមានអធម្មនុញ្ញភាពនៃច្បាប់ណាមួយដូចជាក្រុមប្រឹក្សាធម្មនុញ្ញធ្វើការជូនដំណឹងទៅអ្នកដែលមានសិទ្ធិ ធ្វើការសុំពិនិត្យធម្មនុញ្ញភាព ដើម្បីឱ្យអ្នកទាំងនោះធ្វើការសុំពិនិត្យធម្មនុញ្ញភាពទៅក្រុមប្រឹក្សាធម្មនុញ្ញវិញ ?*

ចម្លើយ : លោកជំទាវ បានលើកឡើងហើយថា ក្រុមប្រឹក្សាធម្មនុញ្ញគ្មានសិទ្ធិធ្វើស្វ័យបណ្តឹងដោយខ្លួនឯងទេ។ អ្នកដែលមានសិទ្ធិធ្វើបណ្តឹង ប្រសិនបើឃើញគេធ្វើបណ្តឹងមក ។ ឧទាហរណ៍ មានអង្គការសង្គមស៊ីវិលមួយចំនួនប្តឹងទាក់ទងនឹងសិទ្ធិកុមារក្នុងច្បាប់ស្តីពីស្ថានទម្ងន់ទោស ដល់កតិកាសញ្ញាស្តីពីសិទ្ធិកុមារដែលកម្ពុជាជាភាគី សង្គមស៊ីវិលមានជាងដប់អង្គការធ្វើសំណើថ្វាយព្រះមហាក្សត្រ ព្រះមហាក្សត្រទ្រង់ឈ្វេងយល់ បានធ្វើព្រះរាជសារមួយដល់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ ។ ដូច្នេះមិនអាចនៅស្ងៀមបានទេ នៅពេលដែលឃើញរឿងនោះទាក់ទងដល់សិទ្ធិពលរដ្ឋធ្ងន់ធ្ងរ គឺយូរឬឆាប់ក្រុមប្រឹក្សាធម្មនុញ្ញនឹងបានទទួលបណ្តឹង ។

**សំណួរ** : *ក្នុងករណីមានសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាម្នាក់លាលែង ឬ ទទួលមរណភាព តើក្រុមប្រឹក្សាធម្មនុញ្ញ នឹងជ្រើសរើសបុគ្គលណាមកទទួលតំណែងបន្ត ?*

ចម្លើយ : នៅក្នុងច្បាប់បានកំណត់ ឧទាហរណ៍ ករណីឯកឧត្តម **ចាន់ សុខ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញលោកទទួលមរណភាពក្នុងអាណត្តិ អ៊ីចឹងក្រុមប្រឹក្សាធម្មនុញ្ញធ្វើសំណើទៅស្ថាប័នដែលជាម្ចាស់ជ្រើសតាំង ឬ តែងតាំង គឺទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរៀបចំជ្រើសតាំងសមាជិកមួយរូបមកជំនួស ។ ឧទាហរណ៍ បើសមាជិកនោះតែងតាំងដោយព្រះមហាក្សត្រ ក្រុមប្រឹក្សាធម្មនុញ្ញធ្វើចុតហ្មាយថ្វាយព្រះមហាក្សត្រ ព្រះមហាក្សត្រលោកនឹងរៀបចំបញ្ជូនបេក្ខជនថ្មីមកវិញ នេះជានីតិវិធីដែលមានចែងក្នុងច្បាប់ ។

**សំណួរ** : *តើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងអស់មានសិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយឬទេ ?*

ចម្លើយ : ក្នុងពេលម៉ោងធ្វើការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺហាមផ្តាច់មិនឱ្យសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាម្នាក់ទៅធ្វើនយោបាយទេ តែបើចង់ធ្វើនយោបាយ គឺត្រូវបំពេញតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ឧទាហរណ៍ ករណីឯកឧត្តម **ស៊ឹន ស៊ុំប៊ឿ** ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃអាណត្តិទី៤ ។ ឯកឧត្តមជាបេក្ខជនតំណាងរាស្ត្រលេខរៀងទី១ នៃគណបក្សសិទ្ធិមនុស្ស នៅមណ្ឌលខេត្តបន្ទាយមានជ័យ ពេលនោះឯកឧត្តមត្រូវធ្វើពាក្យសុំច្បាប់ពិសេសគឺមានរយៈពេលច្រើនខែ ។ ពេលនោះ ឯកឧត្តមចង់ចូលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញក៏មិនបានដែរ គឺទាល់តែក្រោយលទ្ធផលស្ថាពរនៃការបោះឆ្នោត ទើបឯកឧត្តមអាចត្រលប់ចូលប្រជុំវិញបាន។ នេះគឺដើម្បីកុំឱ្យធ្វើជាអាជ្ញាកណ្តាលផង ធ្វើជាអ្នកទាត់បាល់ផង។ លោកអាចធ្វើបាននៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ នេះជាសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងសិទ្ធិ

នយោបាយ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពជាមួយមុខងារមួយចំនួនដូចជា ប្រធាន អនុប្រធានគណបក្សនយោបាយ ចៅក្រមក្នុងមុខតំណែង ឬ មានមុខរបរផ្សេងទៀតដូចជាមិនអាចបើកភោជនីយដ្ឋានបានទេ។

***សំណួរ : ផ្អែកតាមប្រសាសន៍ឯកឧត្តមប្រធាន ឯក សំអុល ថាក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយតែវិវាទនៃការបោះឆ្នោតតំណាងរាស្ត្រ និង ការបោះឆ្នោតព្រឹទ្ធសភា ។ តើវិវាទក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយឬអត់ ? បើអត់ដោះស្រាយ មូលហេតុអ្វី ? ហើយបើដោះស្រាយមូលហេតុអ្វី ?***

ចម្លើយ : រដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានកំណត់ច្បាស់ហើយថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចដោះស្រាយតែវិវាទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាធម្មនុញ្ញពុំមានសមត្ថកិច្ចដោះស្រាយវិវាទទេ ដោយមូលហេតុថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំបានចែងផ្តល់សមត្ថកិច្ចដល់ក្រុមប្រឹក្សាធម្មនុញ្ញទេ ប៉ុន្តែជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងស្រុង ។ ដោយឡែក ក្រុមប្រឹក្សាធម្មនុញ្ញនៅជាប់ជំពាក់ជាមួយនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តែក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោតប៉ុណ្ណោះ ដោយសារច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានបញ្ញត្តិឱ្យ គ.ជ.ប ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតជារៀងរាល់ឆ្នាំ ហើយដែលនៅពេលនោះតែងមានការប្តឹងកើតមានឡើង ។ ដូច្នេះ បណ្តឹងតវ៉ា ឬ បដិសេធនឹងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលក្រោយពីបានធ្វើនៅចំពោះមុខគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការរាជធានី-ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរួចមក អាចនឹងប្តឹងបន្តមកក្រុមប្រឹក្សាធម្មនុញ្ញដែលជាស្ថាប័នមានសមត្ថកិច្ចចុងក្រោយក្នុងបញ្ហានេះ ។

***សំណួរ : បើសាលាជម្រះក្តីកាត់ក្តីអ្វីមួយ ហើយអ្នកចាញ់ក្តីមិនសុខចិត្ត តើអាចប្តឹងនូវចំណុចណាមួយដែលពួកគាត់មិនសុខចិត្តទៅក្រុមប្រឹក្សាធម្មនុញ្ញបានទេ ឬ ពឹងទៅខាងណាវិញ ?***

ចម្លើយ : ប្រសិនបើករណីនោះទាក់ទងនឹងការរំលោភសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ គេអាចធ្វើសំណើមួយមកក្រុមប្រឹក្សាធម្មនុញ្ញបានតាមរយៈនីតិវិធីសម្រាប់បញ្ហាបន្ទាន់បង្ខំ ដែលលោកជំទាវបានលើកឡើងពីខាងដើមរួចមកហើយ ។ ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញមិនមែនជាកំពូលនៅលើតុលាការកំពូលនោះទេ ដូច្នេះប្រសិនបើសាលក្រមសាលាដំបូងណាមួយអស់រយៈពេលប្តឹងទាស់ ឬ សាលដីការបស់តុលាការកំពូលចេញមកហើយ ត្រូវតែយកមកអនុវត្តហើយ ពីព្រោះតុលាការក៏ជាស្ថាប័នឯករាជ្យដូចក្រុមប្រឹក្សាធម្មនុញ្ញដែរ ។

***សំណួរ : តើឥស្សរជនរូបណា ជាអ្នកនឹកឃើញបង្កើតក្រុមប្រឹក្សាធម្មនុញ្ញនេះមុនគេនៅស្រុកខ្មែរ ?***

ចម្លើយ : បើយើងរាប់ចាប់ពីឆ្នាំ ១៩៩៣ យើងអាចឆ្លើយបានថា គឺសមាជិកសភាធម្មនុញ្ញ ទាំង ១២០រូប ក្នុងនោះមតិភាគច្រើនថាគួរណាតែបង្កើតស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនេះឡើង ពីព្រោះស្រុកសេរី ហើយសេដ្ឋកិច្ចទីផ្សារហើយ ។ គោលបំណងនៃការបង្កើតស្ថាប័ននេះ គឺជាការបង្កើតឱ្យមានឆ្នាំ ឬ និយតកររដ្ឋធម្មនុញ្ញ មានន័យថាជាអ្នកធានាឱ្យមានការអនុវត្តន៍រដ្ឋធម្មនុញ្ញកាន់តែរលូននៅពេលអនាគត ។ ដូច្នេះ យើងអាចនិយាយបានថា ជាសមិទ្ធិផលដែលចេញពីការសរសេររដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយគណបក្សចំនួន ០៤ រួមគ្នា មានគណបក្សហ្វ៊ុនស៊ិនប៉ិច ៥៨រូប គណបក្សប្រជាជនកម្ពុជា ៥១រូប គណបក្សសេរីនិយមព្រះពុទ្ធសាសនា ១០រូប និង គណបក្សម៉ូលីណាកា ០១រូប ។

***សំណួរ : តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្ដឹងផ្ទាល់ទៅក្រុមប្រឹក្សាធម្មនុញ្ញដែរឬទេ នៅពេលដែលតុលាការកាត់ក្ដី ដោយអយុត្តិធម៌ ?***

ចម្លើយ : រឿងបញ្ហាការកាត់ក្ដីដោយអយុត្តិធម៌របស់តុលាការ មិនមែនជាសមត្ថកិច្ចដែលក្រុមប្រឹក្សាធម្មនុញ្ញត្រូវដោះស្រាយទេ តែភាគីនៃរឿងក្ដីអាចប្ដឹងអំពីអធម្មនុញ្ញភាពនៃច្បាប់នៅក្នុងករណីបន្ទាន់បង្ខំ ។ ការប្ដឹងពីបញ្ហាបន្ទាន់បង្ខំនេះត្រូវធ្វើតាមរយៈតុលាការកំពូល ។

***សំណួរ : តើការបកស្រាយក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពធ្វើតាមនីតិវិធីរបៀបណា? អធម្មនុញ្ញភាព ធ្វើតាមនីតិវិធីរបៀបណា ?***

ចម្លើយ : ការបកស្រាយច្បាប់ គឺធ្វើនៅក្រោយការប្រកាសឱ្យប្រើ ។ អ្នកដែលមានសិទ្ធិស្នើសុំរួមមានព្រះមហាក្សត្រ ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា តំណាងរាស្ត្រចំនួនមួយភាគដប់ សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន នាយករដ្ឋមន្ត្រី និង តុលាការ ។

**-នីតិវិធី** : កាលណាទទួលបានសំណើសុំបកស្រាយច្បាប់ណាមួយ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចចាត់តាំងសមាជិកមួយរូបក្នុងក្រុមណាមួយជាសមាជិករាយការណ៍ឱ្យធ្វើការសិក្សា ។ សិក្សារួចទើបប្រជុំក្រុម ហើយធ្វើសេចក្ដីរាយការណ៍មួយ ដើម្បីសុំកោះប្រជុំបឋម រួចមកទើបកោះប្រជុំពេញអង្គ ។ ប្រជុំពេញអង្គ គឺចេញសេចក្ដីសម្រេចជាផ្លូវការហើយ ។

**-របៀបស្រាវជ្រាវ** : ឧទាហរណ៍ សំណើសុំបកស្រាយមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ របស់នាយករដ្ឋមន្ត្រីមកដល់ ។ យើងខ្ញុំចាប់ផ្ដើមសិក្សា ដូចជាត្រូវមើលសេចក្ដីព្រាងដើម សេចក្ដីថ្លែងហេតុ កំណត់ហេតុពិស្ដារនៃកិច្ចប្រជុំរបស់រដ្ឋសភា និងឯកសារផ្សេងៗទៀត ។ នេះជាការស្រាវជ្រាវតាមបែបបណ្ឌិតសភា ។

ដូច្នេះយន្តការ គឺសមាជិករាយការណ៍សិក្សាស្រាវជ្រាវ ហើយធ្វើរបាយការណ៍ដាក់ក្នុងរបៀបវារៈប្រជុំក្រុម ក្រុមត្រូវធ្វើរបាយការណ៍មួយទៀត ទើបកោះប្រជុំបឋម រួចមកទើបកោះប្រជុំពេញអង្គ ។ ប្រជុំពេញអង្គរួច គឺចេញសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញបានដោះស្រាយវិវាទកម្មទាក់ទងនឹងការបោះឆ្នោតបានប៉ុន្មានដង ? ចូរពន្យល់ ។***

ចម្លើយ : តាំងឆ្នាំ១៩៩៨ មកដល់បោះឆ្នោតឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេច ចំនួន ៤៦ បណ្តឹង ក្នុងនោះឆ្នាំ១៩៩៨ មានចំនួន ១៧ បណ្តឹង ឆ្នាំ២០០៣ មានចំនួន១១ បណ្តឹង និងឆ្នាំ២០០៨ មានចំនួន ០៩ បណ្តឹង ដែលសុទ្ធសឹងជាបណ្តឹងដែលត្រូវបានយកមកបើកសវនាការជាសាធារណៈ ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចបកស្រាយលិខិតបទដ្ឋានរបស់អង្គនីតិប្រតិបត្តិឬទេ ?***

ចម្លើយ : ផ្អែកតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លិខិតបទដ្ឋានក្រោមច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញមិនពិនិត្យទេ ។ ប្រសិនបើបញ្ហានេះកើតមានឡើងនៅក្នុងពេលកំពុងដំណើរការនីតិវិធីតុលាការ ហើយចុងចោទ ឬ ដើមចម្លើយយល់ឃើញថា សេចក្តីសម្រេចណាមួយមានអធម្មនុញ្ញភាព គេអាចប្តឹងពីបញ្ហានេះបាន ។

***សំណួរ : ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធំធេងណាស់ខាងផ្នែកច្បាប់ ។ មាត្រា ១៣៨ថ្មី ចែងពីសមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ តើថ្ងៃក្រោយអាចមានសមាជិកក្រុមប្រឹក្សាធម្មនុញ្ញគ្មានសញ្ញាបត្រផ្នែក ច្បាប់ឬទេ បើមាត្រានេះមិនចែងពីប្រភពនៃសញ្ញាបត្រឱ្យបានច្បាស់លាស់? តើមានយន្តការអ្វីដើម្បីឱ្យមានសមាសភាពនេះពីគ្រប់សញ្ញាបត្រ?***

ចម្លើយ : សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានតែងតាំង និងជ្រើសតាំងមកពីស្ថាប័នផ្សេងៗគ្នា។ ដូច្នេះយើងត្រូវគោរពសេចក្តីស្នើ ឬ សេចក្តីសម្រេចចិត្តរបស់ស្ថាប័នទាំងនោះ ពីព្រោះស្ថាប័នទាំងនោះក៏ជាស្ថាប័នអធិបតេយ្យដែរ។ ម្យ៉ាងវិញទៀត វាក៏ជាការលំបាកដែរដែលត្រូវយកលក្ខខណ្ឌទាំងនោះទៅឱ្យស្ថាប័ននីមួយៗគោរព ។

***សំណួរ : តើក្រុមប្រឹក្សាធម្មនុញ្ញនឹងធ្វើអន្តរាគមន៍យ៉ាងដូចម្តេច ប្រសិនបើស្ថាប័នកំពូលរបស់ប្រទេសធ្វើផ្ទុយពីគោលការណ៍សំខាន់ៗក្នុងរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ក្រុមប្រឹក្សាធម្មនុញ្ញ មិនមែនជានគរបាលយុត្តិធម៌ទេ ហើយក្រុមប្រឹក្សាធម្មនុញ្ញក៏មិនអាចធ្វើស្វ័យបណ្តឹងដោយខ្លួនឯងបានទេ ។ ម្យ៉ាងវិញទៀត បើមានបណ្តឹងហើយក្រុមប្រឹក្សាធម្មនុញ្ញយកមកពិនិត្យបានលុះត្រាតែបណ្តឹងនោះស្ថិតនៅក្នុងសមត្ថកិច្ចទៀត ។ តាំងពីចាប់ផ្តើមដំណើរការបំពេញការងាររបស់ខ្លួនមករហូតមកដល់ឆ្នាំ២០០៩ ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលបណ្តឹងដែលមិនចូលសមត្ថកិច្ច សរុបចំនួន ៤០ ។

***សំណួរ : ហេតុអ្វីបានជាក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិរយៈពេលវែងរហូតដល់ ៩ឆ្នាំ ?***

ចម្លើយ : ពីព្រោះរដ្ឋធម្មនុញ្ញបានកំណត់យ៉ាងដូច្នេះ ។ ម្យ៉ាងវិញទៀត ដោយសារតែកម្ពុជាបានទទួលមរតកពីប្រព័ន្ធច្បាប់បារាំង ដូច្នេះយើងអនុវត្តតាមច្បាប់បារាំងដែរ ។ កាលពីសរសេររដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ អ្នកសរសេររដ្ឋធម្មនុញ្ញក៏បានអានរដ្ឋធម្មនុញ្ញបារាំង និងបានស្រង់យកយន្តការដែលមានប្រើស្រាប់ជាមួយនឹងក្រុមប្រឹក្សាធម្មនុញ្ញបារាំងដែរ ។ ប៉ុន្តែដោយសារតែរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ កាលនោះមិនបានចែងពីស្ថាប័នព្រឹទ្ធសភានៅឡើយនោះ ហេតុដូច្នេះហើយបានជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន បីរូប មិនបានមកពីស្ថាប័នព្រឹទ្ធសភា ដូចជាករណីនៅប្រទេសបារាំងទេ ហើយយើងផ្តល់សិទ្ធិនេះទៅឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមវិញជាអ្នកឧទ្ទេសនាមសមាជិកចំនួន ០៣រូបនេះ ។ ទាក់ទងនឹងអាណត្តិរបស់សមាជិកនេះ គឺមិនមានការខុសគ្នាទេ រវាងអាណត្តិសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបារាំង និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺ ៩ឆ្នាំដូចគ្នា ។ កន្លែងខុសគ្នាគឺនៅត្រង់ថា ចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញបារាំង គឺមិនមែនមានតែ ០៩រូប ដូចយើងនោះទេ ពីព្រោះប្រធានាធិបតីបារាំង ក្រោយពេលចប់អាណត្តិរបស់ខ្លួន ត្រូវក្លាយទៅជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាស្វ័យប្រវត្តិ ។

***សំណួរ : កន្លងមក តើមានបទប្បញ្ញត្តិក្នុងមាត្រាណា ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ និងមិនអាចយកទៅប្រកាសឱ្យប្រើទេ ?***

ចម្លើយ : មាន ដូចជាច្បាប់ស្តីពីការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ សម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវខ្ពស់បំផុតបានកំណត់ដាក់ទោសប្រហារជីវិត ដែលរដ្ឋធម្មនុញ្ញបានកំណត់មិនឱ្យមានទោសប្រហារជីវិត ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារីដែលចែងថារដ្ឋមន្ត្រីក្រសួងកិច្ចការនារីត្រូវតែជានារី ដែលតាមរដ្ឋធម្មនុញ្ញ បុរស និង នារី មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។

***សំណួរ : តើនៅថ្នាក់ណាដែលមានសិទ្ធិបកស្រាយច្បាប់?***

ចម្លើយ : បើនិយាយពីបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់ជាផ្លូវការ គឺស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្តែបើអ្នកស្នើឱ្យបកស្រាយ គឺមានច្រើន សូមពិនិត្យមើលរដ្ឋធម្មនុញ្ញ ។ ដូច្នេះ បើក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយហើយគឺចប់បិទផ្លូវតវ៉ា ។ ចំណែកឯការធ្វើអត្ថាធិប្បាយ (ដែលភាសាបារាំងថា Commentaire) អ្នកណាក៏អាចធ្វើបានដែរ ដូចជាចៅក្រម ព្រះរាជអាជ្ញា សមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាឃុំ-សង្កាត់ជាដើម ប៉ុន្តែនៅពេលដែលមានភាពមិនច្បាស់លាស់ក្នុងចំណោមស្ថាប័នទាំងអស់នោះ គឺមានតែការបកស្រាយរបស់ក្រុមប្រឹក្សា-ធម្មនុញ្ញទេ ដែលជាការបកស្រាយអាចយកមកអនុវត្តជាផ្លូវការបាន ។ ឧទាហរណ៍ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានកំណត់ឱ្យអភិបាល អភិបាលរងខេត្ត ស្រុក ខណ្ឌ ត្រូវសុំលាឈប់ពីមុខងារប៉ុន្មានខែមុន ដើម្បីអាចចូលរួមឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន ។ ដោយយល់ឃើញពីការប៉ះពាល់ដល់ផលប្រយោជន៍របស់មន្ត្រីរាជការក្នុងក្របខណ្ឌបែបនេះ រាជរដ្ឋាភិបាលស្នើសុំឱ្យក្រុមប្រឹក្សា-

ធម្មនុញ្ញបកស្រាយមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ ។ ជាលទ្ធផល ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយឱ្យត្រឹមតែព្យួរមុខងារតែក្នុងមួយរយៈពេលនៃការធ្វើយុទ្ធនាការនៃការបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលតែប៉ុណ្ណោះទេ ទើបគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការកែសម្រួលបទបញ្ជា និង នីតិវិធីនោះជាថ្មី ហើយជូនដំណឹងទៅក្រសួងមហាផ្ទៃ ដើម្បីធ្វើការផ្សព្វផ្សាយ ។

**សំណួរ :** *ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិបញ្ជាតាមដានសកម្មភាពស្ថាប័នកំពូលរដ្ឋសភា ព្រឹទ្ធសភាដែរឬទេ?*

**ចម្លើយ :** ក្រុមប្រឹក្សាធម្មនុញ្ញឥតមានសមត្ថកិច្ចទៅត្រួតពិនិត្យលើរដ្ឋសភា និងព្រឹទ្ធសភាទេ ។ ក្រុមប្រឹក្សា-ធម្មនុញ្ញ មិនមែនស្ថាប័នកំពូលលើកំពូលទេ ដូច្នេះអត់មានសិទ្ធិទេ។ គ្មានខ្សែបណ្ដោយ និងខ្សែទទឹងទេ។ ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ ប៉ុន្តែថវិកាសម្រាប់ដំណើរការ គឺបានមកពីថវិការដ្ឋ ។

**សំណួរ :** *ក្រុមប្រឹក្សាធម្មនុញ្ញ និង រដ្ឋសភា តើមានទំនាក់ទំនងការងាររបៀបណា ?*

**ចម្លើយ :** បើនិយាយពីការងារ គឺទាក់ទងគ្នាចាប់តាំងពីបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមក។ បន្ទាប់មក គឺមានទំនាក់ទំនងគ្នាក្នុងក្របខណ្ឌនៃការធ្វើច្បាប់ ជាពិសេសច្បាប់រៀបចំអង្គការ មុននឹងយកទៅប្រកាសឱ្យប្រើ និងបន្ទាប់ពីព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ចប់សព្វគ្រប់ហើយ រដ្ឋសភាត្រូវបញ្ជូនច្បាប់នោះឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់នោះជាមុន ។ ឧទាហរណ៍ ច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី ដែលបានកំណត់ថា រដ្ឋមន្ត្រីក្រសួងកិច្ចការនារីត្រូវតែជានារី ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា អធម្មនុញ្ញភាព និងមិនអាចយកទៅប្រកាសឱ្យប្រើបានឡើយ ។ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាធម្មនុញ្ញ និងរដ្ឋសភាមានទំនាក់ទំនងគ្នាដើម្បីផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។ ឧទាហរណ៍ ដូចជាថវិការបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាថវិកាក្នុងកញ្ចប់ថវិកាជាតិ ដែលត្រូវអនុម័តដោយរដ្ឋសភា ។

**សំណួរ :** *តើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចកិច្ចការអ្វីខ្លះ? ការសម្រេចនោះមានប៉ះពាល់លើរាជរដ្ឋាភិបាលដែរឬទេ?*

**ចម្លើយ :** ទីមួយ សម្រេចទៅលើវិវាទនៃការបោះឆ្នោត ទីពីរ បកស្រាយរដ្ឋធម្មនុញ្ញ ឬ បកស្រាយច្បាប់ពិនិត្យធម្មនុញ្ញភាពលើច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ការសម្រេចនេះបើស្របនឹងរដ្ឋធម្មនុញ្ញថា ស្រប បើមិនស្របនឹងរដ្ឋធម្មនុញ្ញថា មិនស្រប ឧទាហរណ៍ រាជរដ្ឋាភិបាលធ្វើសេចក្ដីព្រាងច្បាប់មួយបង្កើតក្រសួងកិច្ចការនារី ក្នុងច្បាប់នោះដាក់ថា ក្រសួងកិច្ចការនារីត្រូវតែដឹកនាំដោយរដ្ឋមន្ត្រីជានារី។ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចថា ច្បាប់ហ្នឹងមានការរើសអើងហើយ ពីព្រោះបុរស និង ស្ត្រីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។

***សំណួរ : ក្រុមប្រឹក្សាធម្មនុញ្ញបានជួយអ្វីខ្លះដល់ប្រជាពលរដ្ឋកម្ពុជា ហើយបានជួយធ្វើអ្វីខ្លះដល់រាជរដ្ឋាភិបាល ហើយបានជួយការពារអ្វីខ្លះដល់ព្រះមហាក្សត្រ ?***

ចម្លើយ : ក្រុមប្រឹក្សាធម្មនុញ្ញធ្វើបានច្រើនណាស់តាំងពីកកើតក្នុងឆ្នាំ១៩៩៨មក ពិសេសភារកិច្ចការពារការគោរពរដ្ឋធម្មនុញ្ញ ជួយព្រះមហាក្សត្រក្នុងការថ្វាយយោបល់ផ្សេងៗ គឺជួយក្នុងផ្លូវច្បាប់ ។

***សំណួរ : សម័យមុនឆ្នាំ១៩៧០ មានស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញឬទេ ?***

ចម្លើយ : អត់មានទេ ពីព្រោះរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ អត់មានចែង ។

***សំណួរ : ពេលក្រុមប្រឹក្សាធម្មនុញ្ញសម្រេចហើយ សេចក្ដីសម្រេចនោះយកទៅណា អនុវត្តរបៀបដូចម្ដេច (ខ្ញុំមិនដែលឃើញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ)***

ចម្លើយ : ជាសំណួរល្អ ពីព្រោះគេមិនដែលផ្ញើឱ្យប្រជារាស្ត្រ ហើយវិទ្យុ ទូរទស្សន៍ក៏មិនផ្សាយទាំងស្រុងដែរ ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជូនថ្វាយព្រះមហាក្សត្រតាមរយៈសម្ដេចចៅហ្វាវាំង ផ្ញើជូនប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ប្រធានតុលាការកំពូល និងចុះក្នុងរាជកិច្ច ។

ឥឡូវខ្ញុំមិនដឹងគេធ្វើដូចម្ដេចទេ ពីដើមមេឃុំ ចៅសង្កាត់ត្រូវទទួលបានសៀវភៅរាជកិច្ចយ៉ាងទៀងទាត់ រួចហើយត្រូវយកទៅផ្សព្វផ្សាយជូនប្រជារាស្ត្រ ។

បើចង់ដឹងសូមទៅទាក់ទងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ឬក៏បើកអ៊ីនធឺណេតមើលគេហទំព័ររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

***សំណួរ : តើយកសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ យកទៅអនុវត្តរបៀបម្ដេច? ដូចការអនុវត្តច្បាប់ផ្សេងៗ ឬទេ ?***

ចម្លើយ : ប្រធានព្រឹទ្ធសភាត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដល់សមាជិកព្រឹទ្ធសភាទាំងអស់ ប្រធានរដ្ឋសភាត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដល់សមាជិករដ្ឋសភាទាំងអស់ នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដល់សមាជិករាជរដ្ឋាភិបាលទាំងអស់ ប្រធានតុលាការកំពូលត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដល់តុលាការសាមី ។ សេចក្ដីសម្រេចនេះត្រូវយកទៅអនុវត្តចំពោះប្រធានបទណាដែលទាក់ទងនឹងវិស័យរបស់ខ្លួនជំនាញរបស់ខ្លួន ។ ចំពោះវិវាទទាក់ទងនឹងការបោះឆ្នោត គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយកទៅអនុវត្ត ។

# ពាក់ព័ន្ធនឹងជំពូកទី ១៣ថ្មី

# អំពីការគ្រប់គ្រងរដ្ឋបាល

**សំណួរ :** *មាត្រា ១៨៦ ហេតុអ្វីក៏មិនដាក់ភូមិនៅក្នុងអង្គការផង បើឃុំកើតឡើងដោយសារភូមិដែរ ?*

ចម្លើយ : ភូមិមិនស្ថិតក្នុងរចនាសម្ព័ន្ធរដ្ឋបាលទេ ប៉ុន្តែយើងមានអនុក្រឹត្យដើម្បីកំណត់ការរៀបចំភូមិ ។

**សំណួរ :** *យោងតាមមាត្រា ១៨៥ថ្មី នៃរដ្ឋធម្មនុញ្ញ តើក្រសួងអភិវឌ្ឍន៍ជនបទបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ភូមិត្រឹមត្រូវឬទេ ? តើផ្ទុយមាត្រានេះដែរឬទេ ?*

ចម្លើយ : តាមចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី គឺមិនឱ្យធ្វើការបោះឆ្នោតរើសប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ភូមិ ពីព្រោះវាជាន់ទៅលើសមត្ថកិច្ចរបស់មេភូមិ ។

# ពាក់ព័ន្ធនឹងជំពូកទី ១៤ថ្មី
# អំពីសមាជជាតិ

***សំណួរ : អំពីសមាជជាតិ តើមានភាពខុសគ្នានិងសិក្ខាសាលា សន្និបាត សន្និសីទយ៉ាងណា? មានគោលដៅសំណូមពរយ៉ាងណា ? តើយើងបានធ្វើហើយឬនៅ ? មូលហេតុអ្វី ? តើមានកំហុសមិនទទួលខុសត្រូវអនុវត្តច្បាប់រដ្ឋធម្មនុញ្ញ ដែរឬទេ ?***

ចម្លើយ : និយាយអំពីប្ញសគល់របស់សមាជជាតិ គឺមានប្រវត្តិនៅក្នុងអារ្យធម៌ក្រិចបុរាណ ស.វទី៦ មុនគ.ស ធ្វើនៅក្នុងបូរីអាតែន ហើយគំនិតដែលធ្វើសមាជបុរាណនោះ គឺក្រោយពេលដែលលោក សូឡុក (៥៩៤ឆ្នាំមុនគ.ស) និងលោក គ្រិស្តតែន (៥០៨ឆ្នាំមុនគ.ស) បានធ្វើការកែទម្រង់រដ្ឋបាលគ្រប់គ្រងបូរីអាតែន ។ ប្រទេសក្រិចបុរាណគេប្រារព្ធធ្វើសមាជនៅទីលានអាហ្គូរ៉ា ក្បែរវិមានអាគ្រូប៉ូល និង វិមានប៉ាតេណុកនៃបូរីអាតែន ។ អ្នកគ្រប់គ្រងបូរីចង់សម្រេចច្បាប់នីមួយៗ ក៏ដូចជាការតែងតាំងមន្ត្រីជាន់ខ្ពស់ តែងតាំងចៅក្រម គេត្រូវប្រជុំពលរដ្ឋភេទប្រុស ដែលកូរ៉ុមចាប់ពី ១/៦ ឡើងទៅ គឺអាចសម្រេចបាន ។ អ្នកច្បាប់គេពន្យល់ថា សមាជពលរដ្ឋនេះ គឺជាទម្រង់នៃការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ ។ ពាក្យថា ប្រជាធិបតេយ្យដោយផ្ទាល់ បដិបក្ខទាំងស្រុងទៅនឹងប្រជាធិបតេយ្យដោយតំណាង ។ រដ្ឋធម្មនុញ្ញយើងអនុវត្តប្រជាធិបតេយ្យដោយតំណាង ប្រជារាស្ត្រប្រើអំណាចរបស់គាត់តាមរយៈព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និង តុលាការ ។ ចំណែកសមាជជាតិ កើតចេញពីសមាជចលនាសង្គមរាស្ត្រនិយម ដែលបង្កើតឡើងនៅដើមឆ្នាំ១៩៥៥ ក្រោយពីប្រទេសយើងបានឯករាជ្យ ព្រោះថា តាមកិច្ចព្រមព្រៀងទីក្រុងសឺណែវ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ១៩៥៤ គឺជាការបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន ។ តាមកិច្ចព្រមព្រៀងនេះ បណ្តាប្រទេសនៅឥណ្ឌូចិនទាំងអស់ត្រូវធ្វើការបោះឆ្នោត ។ ដោយឡែកប្រទេសកម្ពុជាយើងបានទទួលឯករាជ្យនៅថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ១៩៥៣ គឺ ៨ខែ មុនកិច្ចព្រមព្រៀងទីក្រុងសឺណែវ (Genève) ហើយយើងរៀបចំធ្វើការបោះឆ្នោតនៅឆ្នាំ១៩៥៥ ។ ព្រះបាទនរោត្តម សីហនុ ព្រះអង្គបានដាក់រាជ្យនៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ១៩៥៥ ថ្វាយរាជសម្បត្តិដល់ព្រះបិតា គឺព្រះបាទនរោត្តម សុរាម្រិត និង ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន លោកឡើងសោយរាជ្យនៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ១៩៥៥ ។ ក្រោយពីព្រះបិតាឡើងសោយរាជ្យ ព្រះបាទ នរោត្តម សីហនុ បានបង្កើតចលនាមួយហៅថា ចលនាសង្គមរាស្ត្រនិយម នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៥៥ ។ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៥៥ សម្តេចឪបានកោះសមាជសង្គមរាស្ត្រនិយមលើកដំបូងធ្វើនៅក្នុងបរិវេណព្រះបរមរាជវាំង រៀបចំកម្មវិធីនយោបាយ ទិសដៅដើម្បីធ្វើការបោះឆ្នោត។ នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ១៩៥៥ ក្នុងការបោះឆ្នោតសកលរើសតំណាងរាស្ត្រ គណបក្សសង្គមរាស្ត្រនិយមដណ្តើមបានកៅអីទាំងអស់ក្នុងរដ្ឋសភា គណបក្សប្រជាធិបតេយ្យចាញ់ គណបក្សប្រជាជនក៏ចាញ់ ព្រោះមាន ៣ គណបក្សឈរឈ្មោះកាលហ្នឹង ។ សមាជលើកទី១ និង លើកទី២ ធ្វើនៅព្រះបរមរាជវាំង ដល់សមាជលើកក្រោយៗ

មកទៀតធ្វើនៅរាលព្រះមេរុ ។ នៅឆ្នាំ១៩៥៨ មានការកែប្រែរដ្ឋធម្មនុញ្ញ រដ្ឋសភាបានប្រែក្លាយសមាជសង្គមរាស្ត្រនិយម នេះទៅជាសមាជជាតិ ។ ដូច្នេះ សមាជជាតិដែលមានក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺកើតចេញពីពេលហ្នឹងមក ហើយ សមាជជាតិកាលហ្នឹងអាចធ្វើបាន ព្រោះសង្គមរាស្ត្រនិយមតែមួយ ជារបបឯកបក្សដឹកនាំលើគ្រប់វិស័យក្នុងប្រទេស កម្ពុជាពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០ ។ ឥឡូវនេះយើងសួរថា តើអាចធ្វើបានទេ បើសម័យពហុបក្សអ៊ីចឹង ? នេះហើយ ដែលជាបញ្ហា អ៊ីចឹងហើយបានជាសមាជនៅជាប់គាំងរហូតដល់សព្វថ្ងៃ ។ សមាជអាចធ្វើបានទាល់តែបង្កើតច្បាប់ រៀបចំសមាជមួយ ហើយប្រសិនបើមានភាពចាំបាច់ រាជរដ្ឋាភិបាលអាចផ្តួចផ្តើមគំនិតធ្វើបាន ប៉ុន្តែមើលទៅ ពិបាកបន្តិចត្រង់យើងប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស ដែលមានគណបក្សនយោបាយច្រើនចូលរួម លើកគ្នាមកពេញសមាជ គឺគ្រប់គ្រងមិនកើតទេ សូម្បីតែសមាជគណបក្សនយោបាយខ្លះ ពេលសួរដេញដោលគ្នា កើតជាជម្លោះរហូតធ្វើឱ្យមានការបែកបាក់សាមគ្គីគ្នា ចុះទម្រាំបើមានគណបក្សច្រើនចូលរួមនោះ គឺប្រាកដជាមាន ការលំបាកច្រើន ហើយសួរថាខុសនឹងរដ្ឋធម្មនុញ្ញទេ គឺអត់ខុសទេ ។

# ពាក់ព័ន្ធនឹងជំពូកទី ១៥ថ្មី
## អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ

***សំណួរ : រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេស ហេតុអ្វីបានជាធ្វើវិសោធនកម្មតម្រូវចំណង់អ្នកគ្រប់គ្រងប្រទេសទៅវិញ ?***

ចម្លើយ : ទស្សនទានក្នុងការធ្វើច្បាប់បានកំណត់ថា ភាពចាំបាច់តម្រូវឱ្យមានច្បាប់ ដែលភាសាបារាំងថា " Nécessité fait loi " ។ ដូច្នេះ វាមិនមែនជារឿងតម្រូវចិត្តអ្នកគ្រង់គ្រងប្រទេសទេ តែជាការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រទេសជាតិ ។ ឧទាហរណ៍ ដោយសារតម្រូវការជាក់ស្តែង ជាពិសេសសភាពការណ៍របស់ប្រទេសជាតិតម្រូវ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានយកមកធ្វើវិសោធនកម្មបន្តបន្ទាប់នៅឆ្នាំ១៩៩៤ ឆ្នាំ១៩៩៩ ជាដើម ។

***សំណួរ : ពីឆ្នាំ១៩៩៣ ដល់ បច្ចុប្បន្ន តើការធ្វើវិសោធនកម្មមានប៉ុន្មានដង ? ពេលណាខ្លះ?***

ចម្លើយ : ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញធំៗ មានចំនួន ៦ លើក ដូចមានសរសេរនៅក្នុងសៀវភៅរដ្ឋធម្មនុញ្ញដែលបានចែកជូនស្រាប់ ។

***សំណួរ : ហេតុអ្វីបានជាគេចាត់ទុករដ្ឋធម្មនុញ្ញជាច្បាប់កំពូល ?***

ចម្លើយ : ព្រោះជាច្បាប់មេនៃច្បាប់ដទៃទៀត ជាលក្ខន្តិកៈនៃអំណាចសម្រាប់គ្រប់គ្រងប្រទេសមួយ ។

***សំណួរ : តើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ មាននីតិវិធីដូចម្តេចខ្លះ ?***

ចម្លើយ : អ្នកដែលអាចស្នើធ្វើវិសោធនកម្មបានមាន ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និង ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រ ១/៤ ។ ព្រះមហាក្សត្រ ពេលទទួលសំណើហើយ ទើបពិគ្រោះមតិជាមួយក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញថ្វាយមតិទៅព្រះមហាក្សត្រ បើធ្វើបានព្រះមហាក្សត្រទ្រង់ផ្តល់ចម្លើយទៅនាយករដ្ឋមន្ត្រី ឬ ទៅប្រធានរដ្ឋសភា ហើយអនុវត្តនីតិវិធីព្រាងច្បាប់ធម្មនុញ្ញ ធ្វើសេចក្តីថ្លែងហេតុ និងធ្វើសំណើ។ ប៉ុន្តែក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ រដ្ឋសភាត្រូវអនុម័តដោយសំឡេង ២/៣ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ព្រឹទ្ធសភាក៏ត្រូវអនុម័តដោយសំឡេង ២/៣ នៃចំនួនសមាជិកព្រឹទ្ធសភាទាំមូលដែរ។ នេះជាសំឡេងអនុម័តដែលមាន លក្ខណៈជាស្តង់ដារនៅក្នុងរដ្ឋធម្មនុញ្ញទាំងអស់នៅលើពិភពលោក ។

***សំណួរ : តើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមានគុណសម្បត្តិ និង គុណវិបត្តិយ៉ាងដូចម្តេច?***

ចម្លើយ : សំណើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល បើប្រៀបធៀបទៅនឹងបណ្តាប្រទេសដែលគេមានវ័យចំណាស់ខាងប្រជាធិបតេយ្យសេរី ប្រទេសណាក៏គេកែដែរ ហេតុអ្វីបានគេធ្វើ ? ពីព្រោះផ្អែកទៅលើឆន្ទៈរបស់ប្រជារាស្ត្រ និងភាពចាំបាច់នៃការគ្រប់គ្រងប្រទេស ប៉ុន្តែមានលក្ខខណ្ឌ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានលក្ខខណ្ឌ

៤ ហាមមិនឱ្យធ្វើការកែប្រែ ឬ សើរើរដ្ឋធម្មនុញ្ញ ទី១-កាលណាប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ទី២-កាលណាប៉ះពាល់ដល់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ទី៣-ព្រះមហាក្សត្រគ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាច និង ទី៤-នៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ។ ដោយផ្អែកលើភាពចាំបាច់របស់ប្រទេសជាតិ និងឆន្ទៈរបស់ប្រជារាស្ត្រភាគច្រើន ដែលមានតំណាងនៅក្នុងរដ្ឋសភា និង ព្រឹទ្ធសភា ពេលនោះហើយដែលគេអាចដំណើរការធ្វើវិសោធនកម្មបាន ។ អ៊ីចឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ គឺជាគុណសម្បត្តិ ជាការសម្របសម្រួលជាតម្រូវការចាំបាច់របស់ប្រទេសជាតិ ដើម្បីធានាឱ្យមានដំណើរការប្រក្រតីនៃអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ដូច្នេះគុណវិបត្តិ គឺមិនមានទេ ។

***សំណួរ : ការផ្តើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ។ តើត្រូវតែមានការផ្តើមគំនិតពីស្ថាប័នទាំងបីនេះ ទើបអាចធ្វើវិសោធនកម្មបាន ឬ មួយក្នុងចំណោមទាំងបីក៏អាចធ្វើវិសោធនកម្មបានដែរ ?***

ចម្លើយ : សូមជម្រាបថាមិនចាំបាច់ស្នើមកទាំងបីព្រមគ្នានោះទេ ជួនកាលព្រះមហាក្សត្រតែមួយអង្គឯងក៏អាចស្នើឱ្យធ្វើវិសោធនកម្មបានដែរ ។ នីតិវិធីមានការលំបាកបន្តិច ព្រោះថាការផ្តើមគំនិតត្រូវលើកហេតុផល និងធ្វើសេចក្តីព្រាងថ្វាយព្រះមហាក្សត្រ ។ ព្រះអង្គធ្វើរាជសារមួយមកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីផ្តល់មតិ ។ ក្រុមប្រឹក្សា-ធម្មនុញ្ញប្រជុំគ្នាពិនិត្យមើលថា តើសំណើនោះត្រឹមត្រូវគ្រប់លក្ខខណ្ឌទេ បើគ្រប់គ្រាន់ហើយ ក្រុមប្រឹក្សាធម្មនុញ្ញធ្វើចុតហ្មាយថ្វាយព្រះមហាក្សត្រ ព្រះមហាក្សត្រប្រាប់ទៅម្ចាស់សំណើវិញតាមចុតហ្មាយដែលបានថ្វាយទ្រង់។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ជាការពិបាកដែរ ព្រោះត្រូវយកសំឡេងអនុម័តពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ហើយការយកសំឡេងពីរភាគបីនេះ ជាគោលការណ៍សាកល គ្រប់ប្រទេសទាំងអស់បើចង់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ គឺទាល់តែមានសំឡេងអនុម័តពីរភាគបីទើបអាចកែបាន ។

***សំណួរ : ក្នុងបទឧទ្ទេសនាមរបស់ឯកឧត្តម សឹន ស៊ុំម៉ឺ ការសើរើធ្វើវិសោធនកម្មត្រូវហាមឃាត់មិនឱ្យធ្វើនៅពេលណាប្រទេសជាតិឋិតក្នុងភាពអាសន្ន ។ តើស្ថានភាពអាសន្ននោះក្នុងកម្រិតណា? បើស្ថានភាពអាសន្នពិតមែន បើយើងមិនធ្វើវិសោធនកម្មវាអាចធ្វើឱ្យប្រទេសជាតិជាប់គាំងធ្ងន់ធ្ងរ តើគួរធ្វើយ៉ាងណា ?***

ចម្លើយ : ចំណុចនេះមិនមានចែងច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញទេ តែយើងអាចដឹងថា ពាក្យថាភាពអាសន្ននេះមានន័យថា ប្រទេសស្ថិតនៅក្នុងសង្គ្រាម ឬ សង្គ្រាមជាមួយប្រទេសដទៃទៀត ឬ អាចថាប្រទេសមានវិបត្តិធំៗ ។

***សំណួរ : គ្រប់ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ត្រូវតែស្របរដ្ឋធម្មនុញ្ញ តើយោងលើមូលដ្ឋានអ្វីខ្លះដើម្បីកំណត់ថា ច្បាប់ លិខិតបទដ្ឋានគតិយុត្តណាមួយមិនស្របរដ្ឋធម្មនុញ្ញ? (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស...) មាត្រា ១៥០ថ្មី នៃរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ខ្ញុំយល់ថារដ្ឋធម្មនុញ្ញជាប្រដាប់វាស់មួយដើម្បីឱ្យដឹងថាច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តណាមួយមិនស្របរដ្ឋធម្មនុញ្ញ ហើយអ្នកដែលមានសមត្ថកិច្ចត្រួតពិនិត្យថាត្រឹមត្រូវ ឬ មិនត្រឹមត្រូវ គឺទាល់តែមានបណ្ដឹងទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញ ព្រោះក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចប្រកាសថា ច្បាប់ណាមួយមិនស្របរដ្ឋធម្មនុញ្ញ ប៉ុន្តែមិនត្រួតពិនិត្យធម្មនុញ្ញភាពដល់ទៅព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាសឡើយ ។

***សំណួរ : ទម្រង់នៃការរៀបចំលិខិតបទដ្ឋានទីមួយៗ (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស...) ចាំបាច់ត្រូវមាន ឯកសារយោងរួមមានរដ្ឋធម្មនុញ្ញ ច្បាប់ដែលពាក់ព័ន្ធ តើឯកសារយោងទាំងនោះមានឥទ្ធិពល ឬសារៈសំខាន់អ្វីខ្លះ ក្នុងការវាយតម្លៃខ្លឹមសារលិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំនេះថា ស្រប ឬ មិនស្របរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : អ្នកសួរចង់យោងទៅដល់មូលបទ ព្រោះមូលបទគេដាក់យោងរដ្ឋធម្មនុញ្ញ យោងព្រះរាជក្រមយោងច្បាប់បន្តបន្ទាប់ ។ ការដែលយោងហ្នឹងហើយ ដើម្បីឱ្យខ្លឹមសារខាងក្រោមរលូនដូចអ្វីដែលមានយោងខាងលើ ព្រោះអ្នកដែលបានសរសេរលិខិតបទដ្ឋាន គឺគោរពទៅតាមខ្លឹមសារដែលមានយោងខាងលើ គឺធ្វើឱ្យរលូនទៅតាមរដ្ឋធម្មនុញ្ញ ហើយមូលបទដែលខ្ពស់ជាងគេ គឺរដ្ឋធម្មនុញ្ញ បន្ទាប់មកច្បាប់ បន្តមកក្រោមៗទៀតតាមឋានានុក្រមគ្នាចុះមក ។

***សំណួរ : មាត្រា ១៥០ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា ច្បាប់ និង សេចក្ដីសម្រេចរបស់ស្ថាប័នរដ្ឋត្រូវតែស្របរដ្ឋធម្មនុញ្ញដាច់ខាត ។ តើច្បាប់ និង សេចក្ដីជូនដំណឹងមួយណាធំជាង ? ពីព្រោះកន្លងមកឱ្យតែមានរឿងកើតឡើងស្ថាប័នតុលាការដែលជាស្ថាប័នឯករាជ្យដូចជាមិនហ៊ានអនុវត្តនីតិវិធីនោះទេ ?***

ចម្លើយ : គឺច្បាប់ខ្ពស់ជាងសេចក្ដីជូនដំណឹង។ បើតាមឋានានុក្រម គឺច្បាប់ បន្ទាប់មកព្រះរាជក្រឹត្យ អនុក្រឹត្យ បន្ទាប់មកបានសេចក្ដីជូនដំណឹង ។

***សំណួរ : តើរដ្ឋធម្មនុញ្ញយើងជារដ្ឋធម្មនុញ្ញរឹង ឬ ទន់ ? បើរឹងមូលហេតុអ្វី ? បើទន់មូលហេតុអ្វី ?***

ចម្លើយ : រដ្ឋធម្មនុញ្ញរបស់យើងគឺអាចនិយាយបានថា ជារដ្ឋធម្មនុញ្ញរឹងផង និង ទន់ផង ។ ប្រការដែលថា រឹង គឺគេចែងចំណុចណាដែលគេហាមក្នុងការធ្វើវិសោធនកម្ម ឬ សើរើតាមចិត្ត ដូច្នេះអ្នកដែលមានអំណាចបញ្ញត្តិរដ្ឋធម្មនុញ្ញគេគិតពីចំណុចដែលនឹងហាមប្រាម ចំណុចដែលហាមមិនឱ្យកែប្រែ គឺទី១-ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្សទី២-របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ទី៣-ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ទី៤-ក្នុងកាលៈទេសៈប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ។ ចំពោះមាត្រាណាដែលគេអាចធ្វើការ

កែប្រែបាន គឺជារដ្ឋធម្មនុញ្ញទន់ ហើយរដ្ឋធម្មនុញ្ញរបស់យើងក៏មានការធ្វើវិសោធនកម្មច្រើនមាត្រាហើយដែរ ។ រដ្ឋធម្មនុញ្ញរបស់យើងសព្វថ្ងៃនេះ គឺជាសមិទ្ធផលនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលតម្រូវឱ្យខ្មែរគ្រប់ភាគីរួមគ្នាបង្កើតរដ្ឋធម្មនុញ្ញមួយ ។ កាលនោះ យើងបង្កើតសភាធម្មនុញ្ញដើម្បីរៀបចំតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញមួយ ដែលក្រោយមកសភាធម្មនុញ្ញបានក្លាយជារដ្ឋសភា ។

***សំណួរ : តើរាល់ការកែប្រែច្បាប់រដ្ឋធម្មនុញ្ញ ត្រូវឆ្លងកាត់ការប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ ឬត្រូវឆ្លងកាត់ព្រះមហាក្សត្រ ឬនាយករដ្ឋមន្ត្រី ?***

ចម្លើយ : សូមមើលគំនូសតាងដែលលោកជំទាវឧទ្ទេសនាម អ្នកដែលមានសិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមានតែ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និង ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ ១/៤ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ អ្នកផ្តួចផ្តើមរៀបចំនីតិវិធីរួចហើយ ថ្វាយទៅព្រះមហាក្សត្រ ព្រះមហាក្សត្រមិនឆ្លើយអ្វីទេ ទ្រង់បញ្ជូនមកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញថ្វាយមតិ បានចម្លើយនេះហើយ ទ្រង់ធ្វើត្រឡប់ទៅអ្នកស្នើវិញ ។

***សំណួរ : ច្បាប់ណាមួយដែលចែងប្រាសចាកពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តើអាចយកមកអនុវត្តបានដែរឬទេ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញតម្រូវឱ្យច្បាប់ទាំងអស់ និង អត្ថបទក្រោមច្បាប់ទាំងអស់ត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញ។

***សំណួរ : តើរដ្ឋធម្មនុញ្ញមានមុខងារយ៉ាងដូចម្តេចខ្លះ ?***

ចម្លើយ : ជាច្បាប់រួម ច្បាប់មេ ហើយក្នុងឋានានុក្រមនៃច្បាប់ រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ចុះមកច្បាប់រៀបចំអង្គការ ច្បាប់ធម្មតា ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី បន្ទាប់មកអនុក្រឹត្យ សេចក្តីសម្រេច ។ល។ តែត្រូវចងចាំឱ្យច្បាស់ថា ច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញ ។

***សំណួរ : មាត្រា១៥២ថ្មី នៃរដ្ឋធម្មនុញ្ញ មានពាក្យ "ច្បាប់" និង "សេចក្តីសម្រេច" តើពាក្យ "ច្បាប់" នេះសំដៅទៅដល់ច្បាប់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ឬ អនុក្រឹត្យ ឬ ប្រកាសដែរឬទេ ?***

ចម្លើយ : មាត្រា ១៥០ថ្មី នៃរដ្ឋធម្មនុញ្ញ ច្បាប់និងសេចក្តីសម្រេចទាំងឡាយរបស់ស្ថាប័ននានារបស់រដ្ឋត្រូវស្របទៅនឹងរដ្ឋធម្មនុញ្ញ ។ ដូច្នេះទាំងច្បាប់ ទាំងព្រះរាជក្រឹត្យ ទាំងអនុក្រឹត្យ និង ទាំងសេចក្តីសម្រេចនានាត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

***សំណួរ : តើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្សមានន័យយ៉ាងដូចម្តេចមាត្រា ១៥៣ថ្មី?***

ចម្លើយ : ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស មានន័យថា យើងមានសិទ្ធិសេរីភាពពេញទី ទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ ។ ម្យ៉ាងវិញទៀត ត្រង់មាត្រានេះ គេបានធ្វើការហាមឃាត់មិនឱ្យមានការកែប្រែ

ទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់របបប្រជាធិបតេយ្យសេរីពហុបក្សនេះ ដូចជាការកែប្រែពីរបបពហុបក្ស មកជាឯកបក្សជាដើម ដែលធ្វើឱ្យប៉ះពាល់ដល់ស្មារតីរបស់កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩៣ ។

***សំណួរ : ក្នុងមួយអាណត្តិនៃរាជរដ្ឋាភិបាល តើបានកំណត់ចំនួនដងនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែរឬទេ ? បើកំណត់តើប៉ុន្មានដង ? បើមិនកំណត់តើដូចម្ដេច ?***

ចម្លើយ : អត់មានទេ ពីព្រោះថាគេធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ទាល់តែមានការចាំបាច់ជាទីបំផុត ។ ឧទាហរណ៍ចុងក្រោយ ដូចជានៅខែ កុម្ភៈ ឆ្នាំ២០០៨ មុនការធ្វើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យើងបានធ្វើវិសោធនកម្មម្ដង ដោយសារតែយើងចង់ធ្វើការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលដែនដីចាស់ ពីព្រោះថារចនាសម្ព័ន្ធចាស់មិនឆ្លើយតបទៅនឹងការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យមានការបែងចែកដែនដីជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ ដូច្នេះ ក្រោយពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក្រុងមួយចំនួនត្រូវបានប្រែខ្លួនទៅជាខេត្ត ដូចជាក្រុងប៉ៃលិន ក្រុងព្រះសីហនុ ក្រុងកែប ហើយមានទីប្រជុំជនខ្លះដែលមានមនុស្សច្រើនកុះករអាចប្រែខ្លួនក្លាយទៅជាក្រុងបានដូចជាក្រុងប៉ោយប៉ែត ក្រុងបាវិត ក្រុងសួង ។ល។ ចំណែកឯអ្នកមានសិទ្ធិផ្ដួចផ្ដើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាន ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភាតាមសំណើរបស់តំណាងរាស្ត្រ ១/៤ ហើយព្រឹទ្ធសភាមិនមានសិទ្ធិផ្ដួចផ្ដើមធ្វើវិសោធនកម្មទេ ។ បើនាយករដ្ឋមន្ត្រីចង់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញវិញនោះ នាយករដ្ឋមន្ត្រីត្រូវធ្វើសំណើថ្វាយព្រះមហាក្សត្រ ហើយព្រះមហាក្សត្រទ្រង់ធ្វើព្រះរាជសារសុំពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យមើលចំណុចមួយចំនួនដែលរដ្ឋធម្មនុញ្ញហាមឃាត់ ក្នុងនោះមានរបបប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមជាដើម ។

***សំណួរ : រដ្ឋធម្មនុញ្ញជាច្បាប់កំពូល តើស្ថាប័នណាជាអ្នកតាក់តែង វិសោធនកម្ម និង និរាករណ៍ ?***

ចម្លើយ : តាមប្រវត្តិសាស្ត្រកម្ពុជា ដើម្បីបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧បាន ពេលនោះព្រះមហាក្សត្រទ្រង់បានរៀបចំឱ្យមានការបោះឆ្នោតមួយ ដើម្បីបង្កើតសភាធម្មនុញ្ញដែលជាស្ថាប័នទទួលភារកិច្ចសរសេររដ្ឋធម្មនុញ្ញ និងអនុម័តរដ្ឋធម្មនុញ្ញ។ នៅសម័យសាធារណរដ្ឋខ្មែរ របៀបបង្កើតរដ្ឋធម្មនុញ្ញនៅសម័យនោះ គឺគេបង្កើតគណៈកម្មការមួយទទួលបន្ទុករៀបចំតាក់តែងរដ្ឋធម្មនុញ្ញ និង យកទៅដាក់ឱ្យអនុម័តដោយប្រជាមតិ ។ ចំណែកឯនៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺសរសេរហើយជាស្រេច ដោយគ្រាន់តែយកទៅឆ្លងសន្និបាតកម្មាភិបាលទូទាំងប្រទេស ។ ចំណែកឯរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣វិញ តាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩៣ គឺគេបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របង្កើតសភាធម្មនុញ្ញឡើង ដើម្បីសរសេររដ្ឋធម្មនុញ្ញ ហើយក្រោយរដ្ឋធម្មនុញ្ញចូលជាធរមាន សភាធម្មនុញ្ញក្លាយទៅជារដ្ឋសភាតែម្ដង ។

មានតែព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រចំនួនមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើបអាចផ្តួចផ្តើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញបាន ។ បើពិនិត្យទៅលើរដ្ឋធម្មនុញ្ញត្រង់ជំពូកព្រឹទ្ធសភា គឺប្រធានព្រឹទ្ធសភាគ្មានសិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទេ ពីព្រោះជំពូកព្រឹទ្ធសភានេះជាជំពូកដែលកើតចេញពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញកាល ឆ្នាំ១៩៩៩ ។ ជំពូកនេះជាកូនកើតចេញពីដំណោះស្រាយនយោបាយឆ្នាំ១៩៩៨ពិសេសគណបក្សធំៗពីរក្នុងរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិច ។ ជំពូកនេះផ្តើមគំនិតយកចេញពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដែលគេនិយាយពីក្រុមប្រឹក្សា-ព្រះរាជអាណាចក្រជាមូលដ្ឋានយកមកសរសេរដោយប្តូរពាក្យពេចន៍ខ្លះ អាស្រ័យហេតុនេះហើយបានជាប្រធានព្រឹទ្ធសភាអត់មានសិទ្ធិផ្តួចផ្តើមសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញទេ។ ព្រឹទ្ធសភាជាសភាមួយសម្រាប់ត្រិះរិះពិចារណាតែប៉ុណ្ណោះ ។

ព្រះមហាក្សត្រពេលទទួលសំណើហើយ ទើបពិគ្រោះមតិជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញថ្វាយមតិទៅព្រះមហាក្សត្រ បើធ្វើបានព្រះមហាក្សត្រ ទ្រង់ផ្តល់ចម្លើយទៅនាយករដ្ឋមន្ត្រី ឬ ទៅប្រធាន រដ្ឋសភា ហើយអនុវត្តនីតិវិធីព្រាងច្បាប់ធម្មនុញ្ញ ធ្វើសេចក្តីថ្លែងហេតុ និងធ្វើសំណើ ប៉ុន្តែការធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញ រដ្ឋសភាត្រូវអនុម័តដោយសំឡេង ២/៣ នៃចំនួនសមាជិករដ្ឋសភាទាំមូល ហើយព្រឹទ្ធសភាក៏ត្រូវអនុម័តដោយសំឡេង ២/៣ នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលដែរ នេះជាសំឡេងអនុម័តដែលមានលក្ខណៈជាស្តង់ដារនៅក្នុងរដ្ឋធម្មនុញ្ញទាំងអស់នៅលើពិភពលោក ។ ចំណែកឯនិរាករណ៍វិញ គឺមិនមានចំពោះករណីរដ្ឋធម្មនុញ្ញទេ ប៉ុន្តែគេប្រើបានជាមួយច្បាប់ទៅវិញ ។

***សំណួរ :នៅពេលណាទើបមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ? តើការធ្វើវិសោធនកម្មច្បាប់ប្រព្រឹត្តទៅយ៉ាងដូចម្តេច?***

ចម្លើយ : មិនមានពេលវេលាកំណត់ទេ ពេលគឺទៅតាមភាពចាំបាច់របស់ប្រទេសជាតិ ពីព្រោះថា បើយើងមិនកែរដ្ឋធម្មនុញ្ញ គឺប្រទេសជាតិទៅមុខមិនរួច ដោយសារតែប្រទេសជាតិជួបប្រទះនឹងភាពជាប់គាំងខាងនយោបាយ។ ឆ្នាំ១៩៩៣ យើងមានរដ្ឋធម្មនុញ្ញហើយ ហើយនៅឆ្នាំ១៩៩៤ យើងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញបានចំនួន ០១ដង ពីព្រោះថាពេលនោះ បើព្រះមហាក្សត្រទ្រង់ត្រូវយាងទៅព្យាបាលព្រះរោគនៅទីក្រុងប៉េកាំង គឺគ្មាននរណាអាចចុះព្រះហស្តលេខាជំនួសព្រះអង្គក្នុងនាមព្រះប្រមុខរដ្ឋបាននោះទេ បើតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ ក្រោយបោះឆ្នោតឆ្នាំ១៩៩៨ កម្ពុជាជួបភាពជាប់គាំងខាងនយោបាយដែលជាហេតុធ្វើឱ្យគណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិច ចរចាគ្នាសម្រេចឱ្យកែរដ្ឋធម្មនុញ្ញ ដើម្បីទម្លាយភាពជាប់គាំងនោះ ។ ដូច្នេះហើយយើងបានជំពូកថ្មីមួយទៀតស្តីពីព្រឹទ្ធសភា ។ នៅឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៣ រដ្ឋសភាជួបបញ្ហាលំបាកដោយសារតែខ្វះចំនួនកូរ៉ុមរដ្ឋសភា និង សំឡេងដើម្បីអនុម័ត ដូចជានៅពេលប្រជុំរដ្ឋសភា បើមានការមិនពេញចិត្តពីសំណាក់តំណាងរាស្ត្រ

របស់គណបក្សនយោបាយមួយនោះ ពួកគេក៏នាំគ្នាចេញពីរដ្ឋសភាទាំងពេលកំពុងប្រជុំ ដែលជាហេតុធ្វើឱ្យរដ្ឋសភាមិនអាចអនុម័តអ្វីកើតពីព្រោះមិនអាចរកចំនួនកូរ៉ុម ៧/១០ និង សំឡេងភាគច្រើន ២/៣ បាន ។ លុះក្រោយពីការបោះឆ្នោតឆ្នាំ២០០៣ហើយ យើងនៅជាប់គាំងនយោបាយ ១ឆ្នាំទៀត រហូតដល់មានកិច្ចព្រមព្រៀងស្រុះស្រួលគ្នារវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សហ្វ៊ុនស៊ិនប៉ិច នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៤ ។ ប៉ុន្តែការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់របបប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញទេ ។ ចំណែកឯអ្នកមានសិទ្ធិផ្តួចផ្តើមស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរួមមាន ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភាតាមសំណើរបស់តំណាងរាស្ត្រចំនួន ១/៤ ហើយប្រធានព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ពុំមានសិទ្ធិនេះទេ ។ គ្រប់សំណើទាក់ទងនឹងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រទ្រង់ត្រូវពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យមើលថាសំណើនោះ មិនបានធ្វើឱ្យប៉ះពាល់ទៅនឹងការហាមឃាត់របស់រដ្ឋធម្មនុញ្ញ ជាពិសេសរបបប្រជាធិបតេយ្យសេរីពហុបក្ស និង របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ចំពោះឯកសារវិញ ម្ចាស់សំណើត្រូវធ្វើសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីការធ្វើវិសោធនកម្មមាត្រានៃរដ្ឋធម្មនុញ្ញណាមួយ សេចក្តីថ្លែងហេតុ និង ត្រូវមានហត្ថលេខាច្បាស់លាស់ភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរដ្ឋសភាអនុម័ត និង ព្រឹទ្ធសភាពិនិត្យ និង ឱ្យយោបល់ ។

***សំណួរ : តើប្រធានព្រឹទ្ធសភា មានសិទ្ធិផ្តើមគំនិតសើរើ ឬ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឬទេ ?***

ចម្លើយ : ប្រធានព្រឹទ្ធសភា គ្មានសិទ្ធិផ្តើមគំនិតសើរើ ឬ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទេ ។ មានតែព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រចំនួនមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូលទើបអាចធ្វើបាន ។ បើពិនិត្យទៅលើរដ្ឋធម្មនុញ្ញ ត្រង់ជំពូកព្រឹទ្ធសភា គឺប្រធានព្រឹទ្ធសភាគ្មានសិទ្ធិផ្តល់គំនិតសើរើ ឬ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទេ ព្រោះជំពូកព្រឹទ្ធសភានេះជាជំពូកដែលធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩។ ជំពូកនេះជាកូនកើតចេញពីដំណោះស្រាយនយោបាយឆ្នាំ១៩៩៨ ពិសេសគណបក្សធំពីរក្នុងរដ្ឋសភាគឺគណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិច ជំពូកនេះផ្តើមគំនិតយកចេញពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដែលគេនិយាយពីក្រុមប្រឹក្សាព្រះរាជអាណាចក្រជាមូលដ្ឋានយកមកសរសេរដោយប្តូរពាក្យពេជន៍ខ្លះ អាស្រ័យហេតុនេះហើយបានជាប្រធានព្រឹទ្ធសភាអត់មានសិទ្ធិផ្តួចផ្តើមសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញទេ ។ ព្រឹទ្ធសភាជាសភាមួយសម្រាប់ត្រិះរិះពិចារណាតែប៉ុណ្ណោះ ។

***សំណួរ : ហេតុអ្វីបានជាច្បាប់រដ្ឋធម្មនុញ្ញមាត្រា ១៥១ថ្មី ឥតមានអនុញ្ញាតឱ្យប្រធានព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាធ្វើការសើរើ ឬ វិសោធនកម្មរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ខ្ញុំជាអ្នកសរសេររដ្ឋធម្មនុញ្ញមួយរូបដែរ គឺមានបទពិសោធន៍ពីប្រទេសដទៃ ដែលគេមានដូច្នេះដែរ។ អាចមានចម្លើយផ្សេងទៀត គឺសមាជិកព្រឹទ្ធសភាកើតចេញពីការបោះឆ្នោតអសកល ។

# ពាក់ព័ន្ធនឹងជំពូកទី ១៦ថ្មី
# អំពីអន្តរប្បញ្ញត្តិ

***សំណួរ : មាត្រា ១៥៥ថ្មី ចូរពន្យល់ការខុសគ្នារវាងសភាធម្មនុញ្ញ និង ក្រុមប្រឹក្សាធម្មនុញ្ញ ?***

ចម្លើយ : -សភាធម្មនុញ្ញ : គឺជារដ្ឋសភាមួយកើតចេញពីការបោះឆ្នោតសកល ហើយមានភារកិច្ចកំណត់យ៉ាងច្បាស់ថា ត្រូវរៀបរៀងតាក់តែងរដ្ឋធម្មនុញ្ញ ពិភាក្សា និង អនុម័តរដ្ឋធម្មនុញ្ញ។ ដោយឡែកតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ជាគោលការណ៍ច្បាប់ គឺបោះឆ្នោតរើសសភាធម្មនុញ្ញ ពេលរដ្ឋធម្មនុញ្ញចូលជាធរមានហើយ ត្រូវបោះឆ្នោតម្តងទៀតរើសរដ្ឋសភា ប៉ុន្តែដោយសារពាក់ព័ន្ធនឹងថវិកា និង ពេលវេលា យើងបោះឆ្នោតតែមួយលើកទេ គឺពេលរដ្ឋធម្មនុញ្ញចូលជាធរមានហើយ សភាធម្មនុញ្ញក្លាយទៅជារដ្ឋសភាដោយស្វ័យប្រវត្តិ ។

-ក្រុមប្រឹក្សាធម្មនុញ្ញ : ជាស្ថាប័នមួយកើតចេញពីរដ្ឋធម្មនុញ្ញ មានតួនាទីពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ ដោះស្រាយវិវាទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភា ។

# ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ

***សំណួរ : តើពាក្យ "អាណត្តិអាជ្ញាបញ្ញា" និង ពាក្យ "អាណត្តិតំណាង" ពាក្យទាំងពីរនេះមានន័យដូចម្តេច ?***

ចម្លើយ : -អាណត្តិអាជ្ញាបញ្ញា គឺជាអាណត្តិនយោបាយ (ចេញពីការបោះឆ្នោត) ដែលអ្នកជាប់ឆ្នោតជាតំណាងរបស់ប្រជាជន ទទួលអាណត្តិពីប្រជាជនក្នុងមណ្ឌលរបស់ខ្លួន ត្រូវគោរពតាមសេចក្តីណែនាំរបស់ប្រជាជន ហើយអាចត្រូវប្រជាជនដកហូតតំណែងបាន ។ ទាំងនេះគឺដោយសារគេអនុវត្តតាមបែបអធិបតេយ្យប្រជាជន (**Souveraineté populaire**) ដែលគេច្រើនអនុវត្តនៅក្នុងរបបប្រជាធិបតេយ្យដោយផ្ទាល់ ដូចដែលមានសព្វថ្ងៃនៅតំបន់ខ្លះនៃប្រទេសស្វីស ។

-អាណត្តិតំណាង គឺជាអាណត្តិនយោបាយ ដែលអ្នកជាប់ឆ្នោតទទួលអាណត្តិពីប្រជាជាតិ នៅក្នុងការអនុវត្តន៍តាមបែបបទអធិបតេយ្យប្រជាជាតិ (**Souveraineté nationale**) ។ ឧទាហរណ៏ តំណាងរាស្ត្រដែលជាប់ឆ្នោតនៅក្នុងមណ្ឌលរបស់ខ្លួន មិនមែនតំណាងឱ្យតែប្រជាជនក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួនទេ តែតំណាងឱ្យប្រជាជនទូទាំងប្រទេស តំណាងឱ្យប្រជាជាតិទាំងមូល ។ អ្នកតំណាងដែលជាប់ឆ្នោតអនុវត្តការងារដោយឯករាជ្យពីអ្នកបោះឆ្នោតឱ្យគេ គេអាចមិនទទួលសំណូមពរ ឬសេចក្តីណែនាំរបស់អ្នកបោះឆ្នោត ហើយក៏មិនអាចត្រូវដកតំណែងដោយអ្នកបោះឆ្នោតឱ្យគេដែរ ។

***សំណួរ : តើពាក្យ "អវសានប្បញ្ញត្តិ" និង ពាក្យ "អន្តរប្បញ្ញត្តិ" ខុសគ្នាដូចម្តេច ?***

ចម្លើយ : -អវសានប្បញ្ញត្តិ គឺជាបទប្បញ្ញត្តិចុងក្រោយ ដែលមានពីរ ឬ បីមាត្រា ។

-អន្តរប្បញ្ញត្តិ គឺជាបទប្បញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬចែងនៅក្នុងច្បាប់សម្រាប់អនុវត្តក្នុងអន្តរកាលណាមួយ ការឆ្លងកាត់ណាមួយ ការផ្ទេរពីអ្វីមួយទៅអ្វីមួយទៀត ។ មានន័យថា ជារយៈពេលមួយដែលស្ថិតនៅចន្លោះរយៈពេលនៃច្បាប់មួយដែលមានហើយ ឆ្លងទៅច្បាប់ថ្មីមួយទៀត ដែលនឹងត្រូវគេយកមកជំនួសច្បាប់ចាស់នោះនៅពេលខាងមុខ ក្នុងគោលបំណងធានានូវនិរន្តរភាពនៃច្បាប់ ។ ឧទាហរណ៏ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ជាដើម មានចែងអំពីអន្តរប្បញ្ញត្តិ ។ ទាក់ទងនឹងអន្តរប្បញ្ញត្តិដែលមាននៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ សភាធម្មនុញ្ញធ្លាប់បានធ្វើការពិភាក្សាគ្នាថា តើពងមាន់កើតមុនមេមាន់ ឬ មេមាន់កើតមុនពងមាន់ ។ សភាធម្មនុញ្ញបានបើកសម័យប្រជុំលើកទី១ នាថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៩៣ ដើម្បីធ្វើការអនុម័តលើសេចក្តីសម្រេចចិត្តមួយក្នុងការថ្វាយអំណាចជូនសម្តេច នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋនៃកម្ពុជា ហើយត្រូវបានចុះហត្ថលេខាដោយសម្តេច បវរសេដ្ឋា សឺន សាន នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣។ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញត្រូវបានប្រកាសឱ្យប្រើដោយ សម្តេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ហើយព្រះអង្គទ្រង់ប្រកាសផងដែរថា សភាធម្មនុញ្ញក្លាយទៅជារដ្ឋសភា នីតិកាលទី១ ។

**សំណួរ :** *តើការធ្វើវិសោធនកម្មច្បាប់ផ្សេងៗ ដូចជាច្បាប់ព្រហ្មទណ្ឌ... អាចហៅថាវិសោធនកម្មរដ្ឋធម្មនុញ្ញឬទេ?*

**ចម្លើយ :** ច្បាប់ព្រហ្មទណ្ឌ គឺជាច្បាប់នៅក្រោមរដ្ឋធម្មនុញ្ញ ច្បាប់ពីរនេះមិនអាចច្រឡំគ្នាបានទេ។ ឋានានុក្រមនៃច្បាប់ គឺរដ្ឋធម្មនុញ្ញនៅខ្ពស់ជាងគេហើយ បន្ទាប់មកមានច្បាប់ មានព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង សេចក្តីសម្រេច។

**សំណួរ :** *ចំពោះពាក្យខាងក្រោមមានន័យដូចម្តេច ?*

*-ពាក្យថា បរិការណ៍*

*-ពាក្យថា អាទិកាល*

*-ពាក្យថា បច្ឆាកាល*

**ចម្លើយ :** -បរិការណ៍ : ក្នុងលក្ខខណ្ឌនៃសង្គមបរិយាកាស ឬ ស្ថានភាពបច្ចុប្បន្នណាមួយ ដែលវាអាចមានកត្តារួមផ្សំដទៃទៀតច្រើនទៀត (**contexte**) ។

-អាទិកាល : ពេលមុន (**a priori**) ។

-បច្ឆាកាល : ពេលក្រោយ (**a posteriori**) ។

**សំណួរ :** *សូមជួយបកស្រាយអ្វីទៅជាបទល្មើសពាក់ព័ន្ធនឹងកិច្ចការឃោធា (បទល្មើសឃោធា) ?*

**ចម្លើយ :** មិនមានពាក់ព័ន្ធនឹងក្រុមប្រឹក្សាធម្មនុញ្ញទេ ប៉ុន្តែប្រសិនបើមានសំណើសុំឱ្យបកស្រាយច្បាប់ ប្រហែលជាក្រមព្រហ្មទណ្ឌថ្មីអាចមាន ហ្នឹងចាំយើងខ្ញុំបកស្រាយ ។

**សំណួរ :** *សូមអនុញ្ញាតពន្យល់សំរាយខ្លឹមសារ និង វិសាលភាពសេចក្តីប្រកាសជាសកល កិច្ចព្រមព្រៀង សន្ធិសញ្ញា។*

**ចម្លើយ :** -សេចក្តីប្រកាសជាសកល : មានតែមួយទេ គឺសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ក្រោយសង្គ្រាមលោកលើកទី២ គឺនៅឆ្នាំ១៩៤៨ ។

-កិច្ចព្រមព្រៀង : ជាការព្រមព្រៀងគ្នាទ្វេភាគី ត្រីភាគី ចតុភាគី រវាងបុគ្គលនិងបុគ្គល ឬ នីតិបុគ្គលនិងនីតិបុគ្គល ឬ រដ្ឋនិងរដ្ឋ ។

-សន្ធិសញ្ញា : មានវិសាលភាពខ្ពស់ ច្រើនតែជាសន្ធិសញ្ញាអន្តរជាតិ ឬ ជាសន្ធិសញ្ញារវាងរដ្ឋមួយ និងរដ្ឋមួយ ។

**សំណួរ :** *សូមពន្យល់ពាក្យ អញ្ញត្រកម្ម ។*

**ចម្លើយ :** អញ្ញត្រកម្ម : មានន័យថា ដោយឡែក លើកលែង ករណីពិសេស ។

***សំណួរ : សុំមេត្តាជួយពន្យល់ន័យនៃពាក្យ :***

***១-យុត្តិការ***

***២-យុត្តាធិការ***

ចម្លើយ : គ្មានពាក្យយុត្តិការទេ។ យុត្តាធិការ : ទាក់ទងទៅនឹងការសម្រេចសេចក្តីរកយុត្តិធម៌របស់តុលាការ។

***សំណួរ : សាធារណរដ្ឋ តើប្រមុខរដ្ឋត្រូវរៀបចំឡើងដូចម្តេច? ចូរពន្យល់?***

ចម្លើយ : ឱ្យតែពាក្យសាធារណរដ្ឋ គឺមានប្រធានាធិបតីហើយដែលជាប្រមុខរដ្ឋ។ ចំណែកព្រះរាជាណាចក្រ គឺមានព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ។ ការជ្រើសរើសយ៉ាងម៉េចអាស្រ័យទៅលើរបប បើរបបប្រធានាធិបតីនិយម គឺត្រូវបោះឆ្នោតជ្រើសរើសប្រធានាធិបតីដោយផ្ទាល់ ប៉ុន្តែមានប្រទេសខ្លះជាសាធារណរដ្ឋដែរ តែប្រកាន់របបសភានិយម ប្រធានាធិបតីបោះឆ្នោតដោយរដ្ឋសភា ហៅថាអសាកល ។

***សំណួរ : តាមនីតិរដ្ឋធម្មនុញ្ញ និង នីតិអន្តរជាតិសាធារណៈ គេឱ្យនិយមន័យរដ្ឋដូចម្តេច?***

ចម្លើយ : សូមបើកវចនានុក្រមមើលទៅនៅបណ្ណាល័យ ឬ បើកអ៊ិនធឺណែតមើលទៅជាភាសាបារាំង និង ភាសាអង់គ្លេស ។ ហើយនិយមន័យមិនដូចគ្នាទេ យើងអ្នករៀនក៏អាចឱ្យនិយមន័យរដ្ឋបានដែរ តែត្រូវមានមូលដ្ឋានច្បាស់លាស់ ។

***សំណួរ : តើច្បាប់អនុវត្តទៅបានទេ ប្រសិនបើច្បាប់បង្កើតមកដោយមនុស្សមួយក្រុម តែបែរជាមិនសូវបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ?***

ចម្លើយ : សូមជម្រាបថាច្បាប់មានវិសាលភាពទូទាំងប្រទេស ទូទាំងប្រជាពលរដ្ឋទាំងអស់ មិនមែនច្បាប់ធ្វើសម្រាប់តែក្រុមណានោះទេ ។ ជាគោលការណ៍ ច្បាប់មានវិសាលភាពទូទៅ ។

***សំណួរ : តើមាត្រាណា ឬសេចក្តីសម្រេចណាមួយស្តីអំពីអំណាច និងឋានៈនៃសន្ធិសញ្ញាក្នុងនីតិឋានានុក្រមខ្មែរដែរឬទេ?***

ចម្លើយ : សន្ធិសញ្ញាដែលកម្ពុជាជាភាគី គឺជាអត្ថបទច្បាប់នៅក្រោមរដ្ឋធម្មនុញ្ញ និង ច្បាប់ខ្មែរហើយ។

***សំណួរ : សូមគោរពឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តមមានប្រសាសន៍ថា ការតាក់តែងការសរសេរច្បាប់វាពិបាក ហើយយកមកអនុវត្តកាន់តែពិបាកទៅទៀត តើមូលហេតុអ្វី ?***

ចម្លើយ : ឯកឧត្តម អស់លោក លោកស្រី ដែលអញ្ជើញមកនេះសុទ្ធតែជាអ្នកអនុវត្តច្បាប់ តើពិបាកទេ? គឺពិបាក ដូច្នេះវាទាមទារឱ្យអ្នកអនុវត្តច្បាប់ហ្នឹងចេះច្បាប់ឱ្យអស់ ។ យើងជាអ្នកគ្រប់គ្រងប្រជារាស្ត្រ ប៉ុន្តែតាមពាក្យសម័យសកលភាវូបនីយកម្ម យើងជាអ្នកផ្តល់សេវាជូនប្រជារាស្ត្រ ។ ឧទាហរណ៍ នគរបាល គឺសេវាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយ គ្រូបង្រៀន គឺសេវាអប់រំ សេវាបង្រៀនសិស្ស អីចឹងម្នាក់ៗសុទ្ធតែមានភារកិច្ច សួរថាស្រួល ឬ ពិបាក ? ដូច្នេះ ទាមទារត្រូវពន្យល់ ត្រូវប្រើវិធីអប់រំ ធ្វើម៉េចឱ្យគេយល់ ។

***សំណួរ : ព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រម ខ្លឹមសារទាំងពីរនេះមួយណាធំជាងគេ និង សុំការបំភ្លឺបន្ថែមអំពីអត្ថន័យ "ព្រះរាជក្រម" ។***

ចម្លើយ : ព្រះរាជក្រម គឺជាឯកសារគតិយុត្តមួយសម្រាប់ប្រកាសឱ្យប្រើច្បាប់ ហើយដែលមានឋានានុក្រមនៅលើច្បាប់ ។

***សំណួរ : ១-សូមមេត្តាពន្យល់ពាក្យ "ធម្មនុញ្ញ" ឱ្យងាយស្តាប់ ។***

***២-ពាក់ព័ន្ធនឹងជំពូកទី ៧ ជាអនុសាសន៍ បេក្ខជនតំណាងរាស្ត្រ គួរតែឆ្លងកាត់ការបោះឆ្នោតផ្ទៃក្នុងមុននឹងឈរឈ្មោះបោះឆ្នោតជាសកល ។***

ចម្លើយ : ១-កាលណាគេប្រើត្រឹម "ធម្មនុញ្ញ" ហ្នឹងវាជាគុណនាមប្រើសម្រាប់ភ្ជាប់នឹងពាក្យមួយទៀត ឧទាហរណ៍ សភាធម្មនុញ្ញ ច្បាប់ធម្មនុញ្ញ ។

២-ខ្ញុំមិនដឹងថា នៅព្រះវិហារគេធ្វើយ៉ាងម៉េចទេ ប៉ុន្តែគណបក្សប្រជាជននៅព្រៃវែង ស្វាយរៀង និង ខេត្តមួយចំនួនទៀត បោះឆ្នោតរកបេក្ខជនផ្ទៃក្នុងបក្ស បេក្ខជនណានៅលើគេបានឈរទី១ ។ តំណាងសមាជិកគណបក្សឡើងពីមូលដ្ឋានភូមិ ឃុំ បោះឆ្នោតថា តើមន្ត្រីរបស់គណបក្សក្នុងខេត្តហ្នឹងបានការគាំទ្រពីមូលដ្ឋានប៉ុន្មានរួចហើយ ទើបគណបក្សឧទ្ទេសនាមបេក្ខជន អ្នកណាឈរលេខ១ អ្នកណាឈរលេខ២ ឬ ឈរលេខ៣ ឧទាហរណ៍ ខេត្តព្រះវិហារ មាន០១កៅអី បេក្ខជនពេញសិទ្ធិ ០១ បេក្ខជនបំរុងអាចដាក់ ០៣ ។

***សំណួរ : សូមឯកឧត្តមជួយពន្យល់ពាក្យឆន្ទានុសិទ្ធិ និង បុព្វសិទ្ធិ ។***

ចម្លើយ : ពាក្យបុព្វសិទ្ធិ (**Prérogative**) ចង់និយាយថា សិទ្ធិផ្សេងៗ មានរបបបេសកកម្មអី ។ ចំណែកពាក្យឆន្ទានុសិទ្ធិ ជាសិទ្ធិរបស់ចៅក្រម ។

***សំណួរ : ក្នុងការបញ្ជាក់ពីការស្រេបនៃរដ្ឋធម្មនុញ្ញរបស់ច្បាប់មួយ គេតែងឃើញមាន "បានទ្រង់យល់រដ្ឋធម្មនុញ្ញ" ចុះចំណែកក្រឹត្យច្បាប់លេខ ៣៨ ដែលយើងកំពុងប្រើសព្វថ្ងៃ?***

ចម្លើយ : គេប្រើក្រឹត្យនៅសម័យរដ្ឋកម្ពុជា កាលណាក្រមនីតិវិធីថ្មីចូលជាធរមាន នោះក្រឹត្យ-ច្បាប់ លេខ ៣៨ នឹងនិរាករណ៍ដោយឯកឯង ឥតមានអានុភាពអនុវត្តទៀតទេ។

***សំណួរ : តើច្បាប់រៀបចំអង្គការមាត្រា ១៤០ មានអត្ថន័យដូចម្តេច ? តើច្បាប់មួយមានលក្ខណៈអ្វីខ្លះ ទើបអាចហៅថា ច្បាប់រៀបចំអង្គការ ?***

ចម្លើយ : គឺជាច្បាប់ដែលបង្កើតក្រសួង ស្ថាប័ន ឬ ច្បាប់បង្កើតអង្គការចាត់តាំង ។

***សំណួរ: ហេតុអ្វីបានជាអនុញ្ញាតឱ្យសួរមិនចេញឈ្មោះមិនចេញមុខ ?***

ចម្លើយ : ដើម្បីផ្តល់សេចក្តីក្លាហាន និង ផ្តល់ភាពងាយស្រួលដល់អ្នកសួរ ។

***សំណួរ: អ្វីទៅហៅថា អាវុធជីវសាស្ត្រ?***

ចម្លើយ : ជាអាវុធដែលអាចនាំឱ្យកើតជាមេរោគផ្សេងៗ ដូចជាជម្ងឺមហារីក ឃ្លង់ ជាដើម ។

***សំណួរ: សូមពន្យល់ពាក្យ "សន្តិសហវិជ្ជមាន" ។***

ចម្លើយ : មានន័យថាកិច្ចសហការដោយសន្តិភាព និងផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ។

***សំណួរ : តើពាក្យ "ប្រយោជន៍សាធារណៈ" មានន័យយ៉ាងដូចម្តេច ? មានលក្ខណៈអ្វីខ្លះ ?***

ចម្លើយ : មានន័យថាសាធារណជនទាំងអស់ ពលរដ្ឋទាំងអស់ ដោយមិនប្រកាន់ភេទ ប្រកាន់ពណ៌សម្បុរ ប្រកាន់សាសនា អាចទៅចូលរួមអាស្រ័យផលនៅកន្លែងនោះបាន ដូចជាស្ពាន ផ្លូវ ជាដើម ។ ផ្ទុយពីប្រយោជន៍ឯកជន បើសិនជាចង់ឆ្លងស្ពានឯកជនត្រូវបង់ថ្លៃសេវាឱ្យគេ ។

***សំណួរ : ខ្ញុំបាទឆ្ងល់ថា ហេតុអ្វីបានជា ខ្នាតផែនទី ១/១០០.០០០ របស់ប្រទេសយើងបង្កើតបញ្ហា ? តើការពិតតម្រូវឱ្យមានជំនួយពីអង្គការសហប្រជាជាតិដែរឬទេ ?***

ចម្លើយ : ខ្នាតផែនទីនៃព្រះរាជាណាចក្រកម្ពុជា គឺមានចែងនៅមាត្រា២ នៃរដ្ឋធម្មនុញ្ញ។ ដូច្នេះ ខ្នាតផែនទីនេះ គឺជាខ្នាតត្រឹមត្រូវតាមច្បាប់ ។ បញ្ហាដែលកើតមានជាមួយខ្នាតផែនទីនេះ គឺកើតចេញពីមនុស្សទេ ដែលជាអ្នកបង្កបញ្ហា ដូចជាបញ្ហាព្រំដែននៅភាគខាងលិចសព្វថ្ងៃ គឺកើតចេញពីអ្នកដឹកនាំនៅទីក្រុងបាងកកទេ ដែលបានលួចគូសផែនទីឯកតោភាគី ដោយសារតែមហិច្ឆតាចង់បានទឹកដី ។ ចំពោះសំណួរថា តើត្រូវការជំនួយពីអង្គការសហប្រជាជាតិឬយ៉ាងណានោះ យើងត្រូវចាំមើលសិន ពីព្រោះជាបឋមយើងត្រូវដោះស្រាយបញ្ហាដោយទ្វេភាគីសិន។

***សំណួរ : តើបក្សសម្ព័ន្ធសំដៅលើអង្គការចាត់តាំងអ្វី ? ឧទាហរណ៍ បក្សសម្ព័ន្ធយោធា បក្សសម្ព័ន្ធក្នុងមនោគមវិជ្ជាសង្គមនិយម ឬ សេរីនិយម ?***

ចម្លើយ : ពាក្យនេះកើតឡើងនៅក្នុងសម័យសង្គ្រាមត្រជាក់ ដូចជានៅអាស៊ីអាគ្នេយ៍ មានបក្សសម្ព័ន្ធមួយហៅថា បក្សសម្ព័ន្ធសេអាតូ ជាបក្សសម្ព័ន្ធយោធាមួយដែលសហរដ្ឋអាមេរិចបង្កើត ហើយនៅអឺរ៉ុបខាងជើង គឺអូតង់។ ចំណែកឯនៅខាងប្លុកសូវៀត មានបក្សសម្ព័ន្ធវ៉ាសូវី ដែលបានរំលាយខ្លួនហើយក្រោយពីការបញ្ចប់សង្គ្រាមត្រជាក់។

***សំណួរ : ខ្ញុំឆ្ងល់ថា ហេតុអ្វីបានឈ្មួញលក់ដូរទំនិញគ្រប់បែបយ៉ាងតាមចិត្ត បានន័យថា ហាងឆេងនៅលើមាត់ចុះហេតុអ្វីបានជារដ្ឋព្រងើយកន្តើយមិនកំណត់តម្លៃឱ្យបានច្បាស់លាស់ទៅលើមុខទំនិញនីមួយៗ ? តើចំណុចណាមួយដែលចែងថា រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ?***

ចម្លើយ : ការលូកដៃចូលរបស់រដ្ឋក្នុងការកំណត់តម្លៃលើទំនិញធ្វើឱ្យសេដ្ឋកិច្ចនោះលែងជាសេដ្ឋកិច្ចទីផ្សារហើយ ។ ការធ្វើបែបនេះហៅថា សេដ្ឋកិច្ចប្រមូលផ្តុំ ឬ សេដ្ឋកិច្ចសង្គមនិយម ។

*សំណួរ : ករណីលិខិតបទដ្ឋាន សារាចរ ប្រកាសនានាមានបដិវាទកម្ម ឬ បដិបញ្ញត្តិនឹងច្បាប់មានឋានានុក្រមធំជាង តើករណីនេះទាក់ទងនឹងសមត្ថកិច្ចណា?*

ចម្លើយ : បើក្នុងអំណាចនីតិប្រតិបត្តិ គឺរាជរដ្ឋាភិបាលដោះស្រាយនៅក្នុងគណៈរដ្ឋមន្ត្រី ។

*សំណួរ : ចំពោះក្រមរដ្ឋប្បវេណីថ្មី និង ក្រមព្រហ្មទណ្ឌថ្មី ហេតុអ្វីរង់ចាំរយៈពេល ១ឆ្នាំ ទើបអនុវត្ត ?*

ចម្លើយ : ហ្នឹងគេហៅថាសម័យអន្តរកាល ពីការអនុវត្តច្បាប់ដែលកំពុងចូលជាធរមាន ទៅទទួលយកក្រមរដ្ឋប្បវេណីថ្មី និង ក្រមព្រហ្មទណ្ឌថ្មី មកអនុវត្ត ត្រូវមានរយៈកាលមួយដើម្បីអប់រំដល់មន្ត្រីយុត្តិធម៌ ចៅក្រមព្រះរាជអាជ្ញា ប្រជាជន និង មន្ត្រី មុននឹងអនុវត្ត ។

*សំណួរ : តើក្រុមប្រឹក្សាខេត្តមានសិទ្ធិចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋដែរឬទេ? តើក្រុមប្រឹក្សាស្រុកមានសិទ្ធិចុះសួរសុខទុក្ខប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែរឬទេ?*

ចម្លើយ : ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានច្បាប់ស្តីពីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យបានម្នាក់មួយៗព្រោះយើងជាថ្នាក់ដឹកនាំគេ ។ មាត្រា ១៩ នៃច្បាប់នេះចែងថា ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និង សកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន គឺគ្មានច្បាប់ណាមួយដែលហាមមិនឱ្យចុះសួរសុខទុក្ខប្រជាពលរដ្ឋនោះទេ ។

*សំណួរ : តើសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិមានខ្លឹមសារខុសគ្នាដូចម្តេច ?*

ចម្លើយ : ជាសំណួរមួយស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ ។ សន្ធិសញ្ញា អនុសញ្ញា ជាទម្រង់មួយមានខ្លឹមសារប្លែកៗរវាងភាគីរដ្ឋមួយ និង រដ្ឋមួយ ជួនកាលពហុភាគីរវាងរដ្ឋច្រើន ។ បើនិយាយពីឋានានុក្រមសន្ធិសញ្ញាខ្ពស់ជាងអនុសញ្ញា ហើយកាលណាបានសន្ធិសញ្ញាទ្វេភាគី ពហុភាគីហើយ ទាល់តែរដ្ឋសភាឱ្យសច្ចាប័នសិនទើបប្រើប្រាស់បាន នីតិវិធីដូចជាការអនុម័តច្បាប់មួយអ៊ីចឹង គឺយករដ្ឋយើងបញ្ចូលទៅក្នុងសន្ធិសញ្ញា ឬ អនុសញ្ញា បើចូលហើយយើងមានភារកិច្ចអនុវត្ត ។

*សំណួរ : ហេតុអ្វីបានជាអំពើលួចចាប់ពី ០២ នាក់ ឡើងទៅចាត់ទុកជាអំពើប្លន់ ?*

ចម្លើយ : ព្រោះច្បាប់បានសរសេរច្បាស់ហើយក្នុងនីតិវិធីព្រហ្មទណ្ឌ បើចោរលួចខ្លាចម្ចាស់ បើចោរប្លន់អត់ខ្លាចម្ចាស់ទេ ព្រោះមានអាវុធ ។

*សំណួរ : សូមឯកឧត្តមជួយបកស្រាយនូវពាក្យចំនួនបី គឺធម្មានុរូបភាព សមាគតរដ្ឋ និង ធម្មនុញ្ញភាព ?*

ចម្លើយ : -ពាក្យ **ធម្មានុរូបភាព** គឺជាពាក្យច្បាប់ដែលមានប្រើនៅក្នុងនីតិរដ្ឋធម្មនុញ្ញផង និង នីតិស៊ីវិលផង មានន័យថា ជាគុណភាពនៃអំណាចមួយ ដែលស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជន។ ដូច្នេះវាមានធម្មានុរូបភាពតាមលក្ខណៈប្រជាធិបតេយ្យ ធម្មានុរូបភាពតាមលក្ខណៈរាជាធិបតេយ្យ ។ល។ និង ។ល។ ឱ្យតែស្របតាមបំណងប្រាថ្នារបស់ប្រជាជន ដែលភាសាបារាំងគេហៅថា **Légitimité** ។

-ពាក្យ **សមាគតរដ្ឋ** ពាក្យសរសេរក្នុងច្បាប់រដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៤៧ ដែលមានន័យថា ជារដ្ឋមួយដែលស្ថិតនៅក្នុងសមាគម ភាសាបារាំងហៅថា **Etat associé** ។ ពេលនោះរដ្ឋធម្មនុញ្ញបានចែងថា កម្ពុជាជាសមាគតរដ្ឋ មានន័យថា ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ។ ប្រទេសទាំងអស់នោះត្រូវគ្រប់គ្រងដោយបារាំង ដែលមានឈ្មោះថា សហភាពបារាំង ដែលមានប្រទេសប្រាំ គឺកម្ពុជា ឡាវ តុងកឹងខាងជើង អាណាម និង កូសាំងស៊ីន ។

-ពាក្យ ធម្មនុញ្ញភាព មានន័យថា ភាពដែលស្របរដ្ឋធម្មនុញ្ញ ដែលភាសាអង់គ្លេសហៅថា **Constitutionality** បារាំងហៅថា **Constitutionnalité** ។ រាល់បទដ្ឋានគតិយុត្តទាំងអស់ត្រូវគោរព និង ស្របតាមរដ្ឋធម្មនុញ្ញទាំងអស់ ។

***សំណួរ*** *: តើមានទោសឬទេ? ចំពោះករណីដែលកើតមានទៅក្នុងអំឡុងការចុះឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និង ការបោះឆ្នោតនោះ គឺតំណាងគណបក្សនយោបាយ អង្គការសង្គមស៊ីវិលបានដាក់ពាក្យបណ្តឹង ឬ បានលើកយកទៅផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាទាំងក្នុង និង ក្រៅប្រទេស តែក្រោយការស្រាវជ្រាវអង្កេតហេតុការណ៍នោះ គឺមិនពិតទៅវិញ ។ ដូច្នេះចំពោះអ្នកប្តឹង និង អ្នកផ្សព្វផ្សាយគប្បីមានរូបភាព ឬ ទម្ងន់ទោសណាមួយ ព្រោះបច្ចុប្បន្នពុំទាន់មានទោសកំណត់សំរាប់អ្នកប្តឹង និង អ្នកផ្សាយខុស ។ តែចំពោះការពិតអ្នកប្រព្រឹត្តតែងទទួលការពិន័យ ។ បើពុំនោះទេអ្នកមានបំណងមិនល្អអាចបង្កការរំខានដល់សមត្ថកិច្ចគ្រប់ថ្នាក់ ។*

ចម្លើយ : ចំពោះករណីនេះយើងឃើញថាមានច្រើន ហើយភាគច្រើនត្រូវបានសម្របសម្រួលនៅថ្នាក់មូលដ្ឋាន តែមានករណីមួយចំនួនតូចបានកើតឡើងដូចខាងលើ ។ ក្នុងករណីនេះយើងត្រូវកាត់សេចក្តីទៅតាមអ្វីដែលមានចែងក្នុងច្បាប់ ក្នុងនេះមានច្បាប់ស្តីពីការបោះឆ្នោតជាដើម ។ បើមិនមានច្បាប់ចែងទេយើងមិនអាចថាខុសឬត្រូវបានទេ ។

***សំណួរ*** *: តើអ្វីជាច្បាប់ Civil Law និង Common Law ? តើច្បាប់ទាំងពីរនេះមានអត្ថន័យខុសគ្នាបែបណាដែរ?*

ចម្លើយ : -ច្បាប់ **Civil Law** គេអាចហៅម្យ៉ាងទៀតថា **Romano-germanique** គឺជាប្រព័ន្ធច្បាប់រ៉ូម៉ាំងអាល្លឺម៉ង់ ដែលមានប្រវត្តិតាំងពីសម័យចក្រភពរ៉ូម៉ាំងមកម្ល៉េះ ។ ការធ្វើច្បាប់នេះនៅក្នុងសម័យបូរាណក៏ដូចជាក្នុងសម័យបច្ចុប្បន្ន គឺគេពឹងផ្អែកទៅលើស្ថាប័នមួយដែលមានអំណាចបញ្ញត្តិច្បាប់ ដើម្បីតាក់តែងជាក្រម ឬ ហៅថាច្បាប់សរសេរ ។

-ច្បាប់ **Common Law** ឬ ហៅម្យ៉ាងទៀតថា ជាប្រព័ន្ធនៃនីតិរួម គឺជាច្បាប់ទំនៀមទម្លាប់ ដែលចេញមកពីមូលដ្ឋានទំនៀមទម្លាប់ ពោលគឺយកយុត្តាធិការមកធ្វើជាមូលដ្ឋាន ដោយពុំមានជាក្រមទេ ។ សេចក្តីសម្រេចរបស់តុលាការនៅក្នុងប្រព័ន្ធ **Common Law** វានឹងក្លាយទៅជាច្បាប់ដែលយើងហៅថាយុត្តិសាស្ត្រ

(**Jurisprudence** )នោះឯង ។ ច្បាប់ទំនៀមទម្លាប់នេះ គឺខ្មែរយើងក៏មានដែរ ដែលបារាំងហៅថា **droit coutumier** ឬ អង់គ្លេសហៅថា **Customary law** ។

ច្បាប់ទាំងពីរនេះមានអត្ថន័យខុសគ្នាដូចបានបកស្រាយខាងលើ គឺ **Civil Law** ជាច្បាប់សរសេរ ចំណែកឯ **Common Law** ជាច្បាប់ទំនៀមទម្លាប់ នេះបើនិយាយឱ្យស្រួលស្តាប់ ។

***សំណួរ :*** *ការរំលោភបូរណភាពពីពួកសៀមនៅតាមខ្សែបន្ទាត់ព្រំដែនខ្មែរ តើស្ថាប័នកំពូលដែលមានឧបនិស្ស័យក្នុងការការពារការគោរពច្បាប់ ត្រូវប្រកាសអំពីភាពរំលោភទាំងនោះជាសាធារណៈដល់ពលរដ្ឋកម្ពុជាដែរឬទេ ?*

ចម្លើយ : ស្ថាប័នកំពូលដែលមានឧបនិស្ស័យក្នុងការការពារការគោរពច្បាប់ មិនដឹងចង់សួរពីអ្វីទេ បញ្ហានេះជាបញ្ហាបច្ចុប្បន្នភាព យើងចាំស្តាប់មេ មេដោះស្រាយតាមរបៀបណា តាមវិធីសាស្ត្រដោយសន្តិវិធី ។ ដោះស្រាយតាមកម្លាំងអាវុធមិនស្រួលប៉ុន្មានទេ ព្រោះសាកល្បងគ្នាពីរប្រាវរួចហើយ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០០៨ ម្តង ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០០៩ ម្តង មិនស្រួលប៉ុន្មានទេ ប៉ុន្តែស្មារតីប្រុងប្រយ័ត្នការពារឯករាជ្យ ទឹកដី យើងមិនធ្វេសប្រហែសឡើយ ។

***សំណួរ :*** *តើមានវិសមភាពដែរឬទេ ក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៅក្នុងរដ្ឋ ឬ ប្រទេសមួយដែលអង្គការអំណាចកំពូលទាំង ៣ ត្រូវបានកាន់កាប់ដោយបេក្ខជនដែលប្រសូត្រចេញពីគណបក្សតែមួយ ?*

ចម្លើយ : សំណួរនយោបាយហើយ អង្គការកំពូលទាំងបី ជាគោលការណ៍ច្បាប់បែងចែកដាច់ពីគ្នា មិនឱ្យអំណាចណារំលោភអំណាចណាបានទេ បើរំលោភលើគ្នានាំឱ្យច្របូកច្របល់ ។

***សំណួរ :*** *ក្នុងនាមប្រជារាស្ត្រធម្មតា បើសិនមានភាពខុសពីធម្មតាចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនោះ តើយើងគួរដាក់ពាក្យបណ្តឹងតាមវិធីណា? កន្លែងណា? ដើម្បីទទួលនូវភាពយុត្តិធម៌ចំពោះការបោះឆ្នោតដែលមានភាពសុក្រឹត?*

ចម្លើយ : បើមានអ្នកមិនសុខចិត្ត និង សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺត្រូវប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកកាត់ក្តីរឿងបោះឆ្នោត ប៉ុន្តែបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើខុស គឺមានរដ្ឋសភាជាអាណាព្យាបាល បើឃើញមានភាពមិនប្រក្រតីចំពោះបុគ្គល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្តឹងទៅរដ្ឋសភា ព្រោះរដ្ឋសភាអាចបោះឆ្នោតដកសេចក្តីទុកចិត្តចំពោះប្រធាន ឬ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាន ។

***សំណួរ : នៅក្នុងអង្គភាពមួយ តើយោធាអាចមានការជ្រើសរើសតែងតាំងជាសមាជិក ឬ ឃោសនានយោបាយដែរឬទេ ?***

ចម្លើយ : ច្បាប់ស្តីពីគណបក្សនយោបាយ ហាមមិនឱ្យកងកម្លាំងប្រដាប់អាវុធមានរចនាសម្ព័ន្ធបក្សនៅក្នុងអង្គភាពឡើយ តុលាការក៏ដូច្នេះដែរ ។

***សំណួរ : សូមឯកឧត្តមជួយបកស្រាយ ភាពដាច់ដោយឡែកពីគ្នារវាងអំណាចកំពូលទាំងបី ។***

ចម្លើយ : គោលការណ៍នៃការបែងចែកអំណាចជាបីដាច់ពីគ្នា អំណាចទាំងបីនោះ គឺអំណាចនីតិប្បញ្ញត្តិ ជាអ្នកធ្វើច្បាប់ នីតិប្រតិបត្តិជាអ្នកអនុវត្តច្បាប់ និងអំណាចតុលាការទាក់ទងនឹងយុត្តិធម៌ ការពារសិទ្ធិរបស់ពលរដ្ឋ នេះគឺជាគោលការណ៍សកល ផ្ទុយពីសង្គមដែលអំណាចទាំងអស់ចេញពីមនុស្សតែម្នាក់ ។ បើកាលណាអំណាចច្របូកច្របល់ វានាំឱ្យសង្គមច្របូកច្របល់ និងអាចឈានទៅរកអន្តរាយ ។

***សំណួរ : តើនៅពីមុខពាក្យ "មាត្រា" អាចប្រើពាក្យ "ទី " បានឬទេ? បើមិនបានព្រោះអ្វី?***

ចម្លើយ : នេះជាបញ្ហាអក្សរសាស្ត្រហើយ ឥឡូវយើងឃើញច្បាប់សរសេរយ៉ាងម៉េចប្រើយ៉ាងនោះទៅ កុំបន្ថែមឬបន្ថយអី ។

***សំណួរ : ហេតុអ្វីច្បាប់នៅក្នុងតុលាការប្រទេសកម្ពុជាពុំសូវមានប្រសិទ្ធភាព ?***

ចម្លើយ : នេះជារឿងលើការអនុវត្តទេ រឿងមនុស្សយកទៅអនុវត្ត ដូច្នេះយើងនឹងខិតខំផ្សព្វផ្សាយ អប់រំហើយរាជរដ្ឋាភិបាលតាំងពីអាណត្តិទី១ រហូតពេលនេះ មានទិសដៅយុទ្ធសាស្ត្ររួចហើយ គឺធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ។ ដំណើរការកំណែទម្រង់មិនមែនជាការងាយស្រួលទេ គឺត្រូវធ្វើជាជំហាន១ៗ យើងបានផ្លែផ្កាជាបណ្តើរ១ៗ ហើយដូចជាយើងមានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដែលមានសាលាចៅក្រម សាលាមេធាវី សាលាសារការី សាលាក្រឡាបញ្ជី ។ ដើម្បីឱ្យអំណាចមានដំណើរការល្អ អនុវត្តមានប្រសិទ្ធភាពទាល់តែមានធនធានមនុស្ស ។

***សំណួរ : នៅសម័យមុនមានបណ្ឌិតតែ ១៨ អង្គ ប៉ុន្តែអាចធ្វើឱ្យប្រទេសជាតិត្រចះត្រចង់បានតាមច្បាប់គំនិត ។ ចុះហេតុអ្វីបច្ចុប្បន្នផ្ទុយស្រឡះ ហើយតែបែរជាមិនអាច ?***

ចម្លើយ : គឺវាអាច នេះជាសម័យទំនើប មនុស្សរៀនតាមប្រព័ន្ធអ៊ីនធឺណេតហើយ តែយើងត្រូវធ្វើពីមួយជំហានទៅមួយជំហាន ។

***សំណួរ : តើច្បាប់ធ្វើឡើងដើម្បីប្រយោជន៍អ្វី ? ដើម្បីឱ្យនរណាអនុវត្ត និង ប្រើប្រាស់ ?***

ចម្លើយ :សំណួរនេះអ្នកច្បាប់ឬយ៉ាងណាទេដែលសួរនេះ តែចង់បញ្ជាក់ថាមាន សុភាសិតបារាំងមួយថា "ភាពចាំបាច់តម្រូវឱ្យធ្វើច្បាប់ **La nécessité fait loi** " ។ ក្នុងការគ្រប់គ្រងវិស័យនីមួយៗ គឺមានតម្រូវការទៅតាមពេលវេលា ទៅតាមការវិវឌ្ឍ បើមិនធ្វើច្បាប់ទេ គឺមិនកើតទេ ដើម្បីកុំឱ្យអំណាចទាំងអស់ចេញពីបុគ្គលមួយរូប ។

ដើម្បីឱ្យនរណាអនុវត្ត? គឺប្រជាពលរដ្ឋទាំងពីរភេទក្នុងប្រទេស ទាំងអស់គ្នាស្មើភាពគ្នាចំពោះ មុខច្បាប់ ហើយគ្មាននរណានៅពីលើច្បាប់ទេ ។

***សំណួរ : តើច្បាប់មានឥទ្ធិពលដែរឬទេ ដើម្បីឱ្យមេឃនិងដីដែលទើបតែឆ្លងកាត់ភាពអន្ធកាល អាចទទួលសមភាពនៃពន្លឺព្រះអាទិត្យ ?***

ចម្លើយ : ច្បាប់កាលណាចូលជាធរមានហើយ ចាប់បង្ខំហើយ ទោះមេឃយ៉ាងម៉េចក៏ដោយ រញ្ជួយដីក៏ដោយ គឺពលរដ្ឋត្រូវតែគោរព ។ នេះប្រហែលជាចង់និយាយពីប្រសិទ្ធភាពនៃច្បាប់ ។ អ្នករៀនច្បាប់ប្រហែលជាយល់ហើយ ការរៀនទ្រឹស្តីជាការពិបាកមួយ ហើយនៅពេលអនុវត្តជាការពិបាកមួយទៀត គឺត្រូវការដោះស្រាយ ត្រូវការពន្យល់ ។ ប្រទេសមានអារ្យធម៌ខ្ពង់ខ្ពស់យ៉ាងម៉េចក៏ដោយ គឺនៅតែមានការរំលោភដដែល ។ យើងអាចឃើញហើយ ប្រទេសណាមួយមិនមានគុក គ្មានប្រទេសណាមិនមានតុលាការ នគរបាលយុត្តិធម៌ទេ គឺដើម្បីអ្វី ? គឺដើម្បីការពារផលប្រយោជន៍បុគ្គលផង ផលប្រយោជន៍សង្គមផង ។

***សំណួរ : នៅក្នុងច្បាប់បោះឆ្នោតបានចែងថា នៅក្នុងយុទ្ធនាការឃោសនាម្តងៗ មិនត្រូវឱ្យគណបក្សនីមួយៗ ជេរ្យមដាម ជេរប្រមាថ មើលងាយគ្នាទេ ក៏ប៉ុន្តែតាមការសង្កេតរបស់យើងខ្ញុំ ឃើញថា ពេលយុទ្ធនាការម្តងៗ នៅតែមានមិនដែលខាន ។ ដូច្នេះនៅក្នុងទោសបញ្ញត្តិនៃច្បាប់ តើត្រូវវិសោធនកម្មត្រង់មាត្រាទោសបញ្ញត្តិឱ្យខ្លាំងជាងហ្នឹងបានទេ ?***

ចម្លើយ : ទោសបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាននៅក្នុងជំពូកទី ១១ ចាប់ពីមាត្រា ១២២ថ្មី ទៅដល់មាត្រា ១៣៣ ដូច្នេះសរុបមកមានចំនួន ១១ មាត្រា ។ បើយើងពិនិត្យមើលទៅ យើងពិបាកនឹងថាទោសទាំងនេះស្រាលណាស់ ពីព្រោះទោសនេះមិនទាន់បានគិតជាមួយនឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀតទេ ដែលជាសមត្ថកិច្ចរបស់តុលាការ ។ ឧទាហរណ៍ថា ការបង្កការខូចខាតដល់ទ្រព្យសម្បត្តិឯកជន ឬ ទ្រព្យសម្បត្តិសាធារណៈក្នុងពេលឃោសនាបោះឆ្នោត ឬក៏ការយកអាវុធយុទ្ធភ័ណ្ឌទៅគំរាមនៅក្នុងការិយាល័យបោះឆ្នោត។ ចំពោះការស្នើសុំឱ្យធ្វើវិសោធនកម្មច្បាប់ គឺជាសិទ្ធិរបស់តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា ឬរាជរដ្ឋាភិបាល ក្នុងការផ្តួចផ្តើមនោះ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។ ប៉ុន្តែដោយសារច្បាប់បោះឆ្នោត គឺជាច្បាប់រៀបចំអង្គការ ដូច្នេះក្រោយពីរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវតែបញ្ជូនមកក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាពនៃច្បាប់នោះ ។

***សំណួរ : សូមឯកឧត្តមមេត្តាជួយពន្យល់ពាក្យ " បកស្រាយច្បាប់ " និងពាក្យ "ផ្សព្វផ្សាយច្បាប់ " ។***

ចម្លើយ : ការបកស្រាយច្បាប់ គឺជាការយកកថាខ័ណ្ឌនៃមាត្រាណាមួយ ឬ មាត្រាណាមួយនៃច្បាប់ ប៉ុន្តែមិនមែនច្បាប់ទាំងមូលនោះទេ មកសិក្សាលម្អិត និង ស៊ីជម្រៅដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមរយៈសំណើពីប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី តំណាងរាស្ត្រ ១/១០ និង សមាជិកព្រឹទ្ធសភា ១/៤ ក្នុងគោលបំណង

ពិនិត្យឱ្យឃើញថា តើខ្លឹមសាររបស់កថាខ័ណ្ឌនៃមាត្រាណាមួយ ឬ បទបញ្ញត្តិនៃមាត្រារបស់ច្បាប់ណាមួយស្របទៅនឹងរដ្ឋធម្មនុញ្ញឬទេ ។ ឧទាហរណ៍ មុនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្តេចនាយករដ្ឋមន្ត្រីបានស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីព្រោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើសពីអ្វីដែលមាននៅក្នុងខ្លឹមសារដើមរបស់ច្បាប់ ។ តាមរយៈប្រការនៃបទបញ្ជានោះបានបញ្ញត្តិថា *"ប្រសិនបើបេក្ខជនឈរឈ្មោះក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នជា អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើពាក្យលាលែងពីមុខតំណែងឱ្យបានមួយសប្តាហ៍មុនថ្ងៃឃោសនាបោះឆ្នោត "* ប៉ុន្តែបើពិនិត្យមើលនៅក្នុងច្បាប់វិញ មាត្រា ១៧ និង មាត្រា ១៨ ចែងត្រឹមតែថា *" បើបេក្ខជនឈរឈ្មោះនោះ គឺជាមន្ត្រីរាជការ ឬអភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដាក់ពាក្យឈប់ពិសេស "*។ ចំណែកឯការផ្សព្វផ្សាយច្បាប់វិញ គឺគ្រាន់តែជាការណែនាំ និង ផ្តល់ជាព័ត៌មានអំពីខ្លឹមសារនៃច្បាប់ណាមួយ ជាពិសេសច្បាប់ថ្មីដែលទើបតែនឹងចូលជាធរមាន ក្នុងគោលបំណងចង់ឱ្យប្រជាពលរដ្ឋចេះច្បាប់ និង កុំឱ្យប្រព្រឹត្តបទល្មើសណាមួយ ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ពលរដ្ឋ ឬ សង្គម ។

***សំណួរ : តើមាននីតិវិធីយ៉ាងណា អំពីការប្រមាថរវាងគណបក្សនយោបាយ និង គណបក្សនយោបាយ ដើម្បីកុំឱ្យយុវជនជិតដាមការមើលងាយគ្នារវាងខ្មែរ និង ខ្មែរ?***

**ចម្លើយ** : កាលណាគណបក្សជេរគ្នា គឺវានាំឱ្យមានការប៉ះពាល់ដល់សង្គម ដូច្នេះហើយបានជាតាមគោលការណ៍នៃច្បាប់បោះឆ្នោត គេតម្រូវឱ្យគណបក្សនយោបាយទាំងអស់គោរពគ្នាទៅវិញទៅមក ឧទាហរណ៍ មាត្រា ៧០ នៃច្បាប់នេះបានចែងពីការឃោសនាបោះឆ្នោត គឺឱ្យយកកម្មវិធីនយោបាយមកឃោសនាដើម្បីឱ្យប្រជាពលរដ្ឋបានជ្រួតជ្រាប ច្បាប់ហាមមិនឱ្យគណបក្សនយោបាយជេរប្រមាថគ្នាទេ ។ នៅក្នុងក្រមសីលធម៌របស់គណបក្សនយោបាយក៏មានចែងពីការហាមជេរប្រមាថគ្នារវាងគណបក្សនិងគណបក្សដែរ ហើយសមាជិកគាំទ្រគណបក្សនយោបាយទាំងអស់ត្រូវគោរពតាមវិធានដែលមានចែងខាងលើនេះ ។ ដូច្នេះដើម្បីជៀសវាងការជះឥទ្ធិពលអាក្រក់ទៅលើយុវជន ដែលបង្កឡើងដោយសារការជេរប្រមាថរវាងគណបក្សនិងគណបក្ស យើងត្រូវគោរពតាមគោលការណ៍ពីរយ៉ាង :

១-គណបក្សនយោបាយទាំងអស់ត្រូវគោរពច្បាប់ និង បទដ្ឋានក្រោមច្បាប់ទាំងអស់ : កុមារ និង យុវជនទាំងឡាយ គឺជាគោលដៅដែលយើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់ ព្រោះជាវ័យដែលងាយ និង ទទួលយកឥទ្ធិពលពីខាងក្រៅ ដូច្នេះកាលណាគណបក្សនយោបាយអនុវត្តទៅតាមវិធានច្បាប់ គឺមិនមានជះឥទ្ធិពល

អាក្រក់ទៅលើយុវជនទេ ហើយបញ្ហារើសអើងគណបក្សនយោបាយក៏នឹងមិនកើតមាននៅក្នុងស្រទាប់យុវជនរបស់យើងដែរ ។

២-ការអប់រំ : វាជាកាតព្វកិច្ចរួមគ្នា ទាំងឪពុកម្តាយ ក៏ដូចជាគណបក្សនយោបាយទាំងអស់ ធ្វើយ៉ាងណាអប់រំយុវជនរបស់យើងឱ្យយល់ពីបញ្ហាសីលធម៌សង្គម និងសីលធម៌នយោបាយ ព្រោះខ្មែរយើងជាអ្នកគោរព និងប្រតិបត្តិព្រះពុទ្ធសាសនា តោងយើងដែលជាចាស់ និងជាអ្នកអប់រំគេ ធ្វើយ៉ាងណាកុំឱ្យកើតមានពហុជម្លោះនៅក្នុងសង្គមជាតិរបស់យើង ព្រោះយើងឆ្លងកាត់ជម្លោះនេះមកជាច្រើនហើយ ទីបំផុតនៅសល់តែសោកនាដកម្មតែប៉ុណ្ណោះ ។

***សំណួរ : តើពាក្យ "នីត្យានុកូលភាព" "បច្ឆាកាល" និង "អាទិកាល" មានន័យដូចម្តេច ?***

ចម្លើយ : -នីត្យានុកូលភាព ដែលភាសាបារាំងថា **Légalité** មានន័យថាលក្ខណៈដែលស្របច្បាប់ កំណត់ដោយច្បាប់ ហើយចំណែកឯធម្មានុរូបភាព ដែលភាសាបារាំងថា **Légitimité** មានន័យថា គុណភាពនៃអំណាចមួយដែលស្របតាមបំណងប្រាថ្នារបស់ប្រជាជន ប៉ុន្តែនីត្យានុកូលភាព និងធម្មានុរូបភាព មិនអាចកាត់ផ្តាច់ចេញពីគ្នាបានទេ។

-បច្ឆាកាល : ពេលក្រោយ ។

-អាទិកាលៈ ពេលមុន ។

***សំណួរ : សូមពន្យល់ពាក្យ "យុត្តាធិការ" ។***

ចម្លើយ : យុត្តាធិការ គឺទាក់ទងទៅនឹងការសម្រេចសេចក្តីរកយុត្តិធម៌របស់តុលាការ ។

***សំណួរ : តើរយៈពេលប៉ុន្មានឆ្នាំដែលអាចធ្វើវិសោធនកម្មនៃច្បាប់បានក្នុងមាត្រានីមួយៗ ?***

ចម្លើយ : គ្មានកំណត់រយៈពេលប៉ុន្មានឆ្នាំទើបអាចធ្វើវិសោធនកម្មច្បាប់ដែលនៅជាធរមាននោះទេ តែវាអាស្រ័យទៅលើថាមានការចាំបាច់ ឬ ពុំមានការចាំបាច់ ជាពិសេសសម្រាប់នីតិប្រតិបត្តិពេលយកច្បាប់ទៅអនុវត្ត។ នៅពេលដែលអនុវត្តទៅឃើញថានៅមានចន្លោះខ្វះខាតផ្សេងៗ ពេលនោះរាជរដ្ឋាភិបាលអាចផ្តើមគំនិតឱ្យធ្វើវិសោធនកម្មច្បាប់នោះបានហើយ ។

***សំណួរ : សូមពន្យល់ពាក្យ "អាសារសូន្យ" ។***

ចម្លើយ : មានន័យថា ទុកជាសូន្យ ទុកជាមិនបានការ ទុកជានិរាករណ៍ចោល លុបចោល។

***សំណួរ : ពាក្យខុសគ្នារវាងព្រះរាជក្រម និង ព្រះរាជក្រឹត្យ សូមពន្យល់ ។***

ចម្លើយ : ព្រះរាជក្រម គឺជាឯកសារគតិយុត្តមួយសម្រាប់ប្រកាសឱ្យប្រើច្បាប់ ចំណែកឯព្រះរាជក្រឹត្យវិញ គឺសម្រាប់តែងតាំងមន្ត្រីជាន់ខ្ពស់ ឬ បង្កើតអង្គការចាត់តាំងណាមួយ ប៉ុន្តែព្រះរាជក្រឹត្យមានឋានានុក្រមនៅក្រោមច្បាប់ ចំណែកឯព្រះរាជក្រមមានឋានានុក្រមនៅលើច្បាប់។

**សំណួរ ៖ ពន្យល់ពាក្យ វិសមិតភាព ។**

ចម្លើយ ៖ វិសមិតភាព មានន័យថាជាការត្រួតមុខងារក្នុងពេលតំណាលគ្នា។ ឧទាហរណ៍ ដូចជាឯកឧត្តម ឧត្តមសេនីយ៍ណាមួយចង់ទៅធ្វើតំណាងរាស្ត្រ ឬចង់ទៅធ្វើសមាជិកព្រឹទ្ធសភា ទាល់តែព្យួរក្របខ័ណ្ឌឧត្តមសេនីយ៍សិន ប៉ុន្តែការតម្លើងថ្នាក់គេរក្សាទុកឱ្យ ។

**សំណួរ ៖ តើពាក្យថា បរិការណ៍ ភោគោត្តសាស្ត្រ មានន័យដូចម្តេច ?**

ចម្លើយ ៖ -បរិការណ៍ មានន័យថាក្នុងលក្ខខ័ណ្ឌនៃសង្គមបរិយាកាស ឬ ស្ថានភាពបច្ចុប្បន្នណាមួយដែលវាអាចមានកត្តារួមផ្សំដទៃទៀតច្រើនទៀត ។

-ភោគោត្តសាស្ត្រ គឺជាវិទ្យាសាស្ត្រមួយ ដែលសម្រាប់សិក្សាអំពីរចនាសម្ព័ន្ធវត្ថុធាតុនៅក្រោមដីតើមានអ្វីខ្លះ ដែលពាក្យជាភាសាបារាំងថា **Géologie** ។

**សំណួរ ៖ បទភ្លេងជាតិ ឬ បទគោរពទង់ជាតិនៃកម្ពុជាយើង នៅពេលគោរពទង់ជាតិ ហេតុអ្វីបានជាច្រៀងតែមួយវគ្គខាងលើ ?**

ចម្លើយ ៖ បទភ្លេងជាតិនគររាជនេះ ជាស្នាព្រះរាជនិពន្ធរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** នៅ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៤១ ដែលមានទាំងអស់ចំនួន បីវគ្គ ប៉ុន្តែតាមព្រះរាជបន្ទូលរបស់សម្តេចឪ អតីតព្រះមហាក្សត្រ **នរោត្តម សីហនុ** និង តាមទម្លាប់ដែលយើងប្រកាន់យករហូតមក គឺគេច្រៀងតែមួយវគ្គខាងដើមតែប៉ុណ្ណោះ ។ ក្រោយពីឡើងគ្រងរាជ្យ សម្តេចឪ **នរោត្តម សីហនុ** បានឡាយព្រះហស្តលេខាលើព្រះរាជក្រមលេខ ១ ប៉េអ៊ែរ (អក្សរកាត់ភាសាបារាំងដែលមានន័យថា Palais Royal) ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ១៩៤១ ប្រកាសឱ្យប្រើបទភ្លេងជាតិ នគររាជ ។

**សំណួរ ៖ ដូចម្តេចហៅថា លិខិតគតិយុត្ត និង លិខិតរដ្ឋបាល ?**

ចម្លើយ ៖ លិខិតគតិយុត្ត ភាសាបារាំងថា **Acte juridique** គឺជាបណ្តាលិខិតទាំងឡាយណាដែលមានលក្ខណៈជាច្បាប់ ហើយលិខិតរដ្ឋបាល ភាសាបារាំងថា **Acte administratif** គឺជាលិខិតទាំងឡាយ ដែលចេញដោយអាជ្ញាធរគ្រប់គ្រងរដ្ឋបាល ដូចជាការចេញជាវិញ្ញាបនបត្ររដ្ឋបាល លិខិតទាក់ទងគ្នារវាងស្ថាប័ន លិខិតជូនដំណឹងពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិជាដើម ។

**សំណួរ ៖ ធម្មនុញ្ញភាព មានន័យដូចម្តេច?**

ចម្លើយ ៖ មានន័យថាភាពស្របនឹងរដ្ឋធម្មនុញ្ញ ហើយមានតែក្រុមប្រឹក្សាធម្មនុញ្ញទេដែលមានសមត្ថកិច្ចក្នុងការសម្រេចថាច្បាប់នោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ។

***សំណួរ៖ : សូមឯកឧត្តមប្រធាន មេត្តារៀបរាប់ពីឋានានុក្រមច្បាប់ពីថ្នាក់ខ្ពស់រហូតមកដល់ថ្នាក់ទាបបំផុត ។***

ចម្លើយ : ឋានានុក្រមច្បាប់ពីខ្ពស់មកទាបមាន រដ្ឋធម្មនុញ្ញ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេចរបស់រដ្ឋបាលមូលដ្ឋានក្រោមជាតិដទៃទៀត ។

***សំណួរ៖ : ចូរឱ្យនិយមន័យពាក្យ និយតករ ។***

ចម្លើយ : ពាក្យ "និយតករ" (**Régulateur**) នេះ មកពីពាក្យ "និយតភាព" (**Régulation**)។ និយតករ មានន័យថា ជាអ្នកសម្របសម្រួល និងធ្វើឱ្យក្លាយទៅជាប្រក្រតីវិញ។ និយតករនៅក្នុងសង្គមខ្មែរ គឺមេបាហ្នឹងហើយ ។

***សំណួរ៖ : តើពលរដ្ឋខ្មែររស់នៅបរទេស មានសិទ្ធិបោះឆ្នោតដែរឬទេ ? បើមានសិទ្ធិ តើគេត្រូវបោះនៅទីណា?***

ចម្លើយ : បញ្ហានេះ គឺត្រូវបានជជែកគ្នាដែរក្នុងអាណត្តិរបស់រដ្ឋសភា សម្រាប់នីតិកាលទី១ ឆ្នាំ១៩៩៣-១៩៩៨ ពេលធ្វើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនៅពេលនោះ មានមតិតំណាងរាស្ត្រខ្លះបានលើក ប៉ុន្តែបញ្ហានៅត្រង់ថា តើកម្ពុជាធ្វើបាន ឬ មិនបានប៉ុណ្ណោះ ។ ប្រជាពលរដ្ឋខ្មែរដែលរស់នៅឯបរទេសអាចបោះឆ្នោតបានលុះត្រាតែមានចែងក្នុងច្បាប់។ ចំណែកឯនៅស្រុកគេវិញ គេធ្វើបានតាមរយៈការបង្កើតការិយាល័យបោះឆ្នោតរបស់ស្ថានទូតនៅឯបរទេស ឧទាហរណ៍ ដូចជាការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាម៉េរិក ប្រធានាធិបតីបារាំងជាដើម ។ ប៉ុន្តែដោយសារតែប្រជាជនបណ្តាប្រទេសទាំងនោះ ជាប់កាតព្វកិច្ចចំពោះរដ្ឋដែរ ដូចជាការបង់ពន្ធជូនរដ្ឋតាមរយៈការកាត់ប្រាក់ខែ នៅពេលដែលខ្លួនធ្វើការនៅបរទេស ឬ ប្រាក់ចំណូលរបស់ក្រុមហ៊ុនប្រតិបត្តិការនៅបរទេសជាដើម ។

***សំណួរ៖ : អំណាចសាធារណៈ មានន័យយ៉ាងដូចម្តេច ?***

ចម្លើយ : ជាទូទៅ គឺសំដៅទៅអាជ្ញាធរសាធារណៈទាំងអស់ ដូចជាសមាជិកក្រុមប្រឹក្សាខេត្ត ជាដើម ដែលត្រូវទទួលប្រាក់បៀវត្ស ប្រាក់សោធននិវត្តន៍ និង ប្រាក់បំណាច់ផ្សេងៗពីរដ្ឋទាំងអស់។

***សំណួរ៖ : សូមពន្យល់ពាក្យ "កតិកាសញ្ញា" ។***

ចម្លើយ : កតិកាសញ្ញា មានន័យថាជាកិច្ចព្រមព្រៀងក្នុងករិតមួយខ្ពស់រវាងរដ្ឋ និង រដ្ឋ ។

***សំណួរ៖ : តើអ្វីទៅជាប្រេសិតវិសាមញ្ញ ?***

ចម្លើយ : ជាឥស្សរជនពិសេសដែលត្រូវបានរដ្ឋចាត់តាំងឱ្យទៅបំពេញកិច្ចការអ្វីមួយ ដែលភាគច្រើនប្រើនៅក្នុងច្បាប់អន្តរជាតិ ហើយភាសាបារាំងថា **Envoyé extraordinaire** ។

***សំណួរ : រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេសនីមួយៗ ចុះនៅសម័យរបបកម្ពុជាប្រជាធិបតេយ្យមានច្បាប់រដ្ឋធម្មនុញ្ញដូចបណ្តាប្រទេសនានានៅលើសកលលោកដែរ ហេតុអ្វីនៅសម័យនោះគេមិនយកច្បាប់មកអនុវត្តផ្ទុយទៅវិញគេយកទ្រឹស្តីអង្គការមកអនុវត្ត តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញដែរ ឬទេ ? បើមានសូមជួយបកស្រាយ ? បើគ្មានសូមជួយបកស្រាយ ?***

ចម្លើយ : រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមាន ១៦ជំពូក និង ២១មាត្រា ។ រដ្ឋធម្មនុញ្ញរបស់ខ្មែរក្រហមមានតែមួយទេនៅលើពិភពលោក ។ ប្រទេសសហភាពសូវៀត ចិន វៀតណាម ឡាវ បណ្តាប្រទេសអឺរ៉ុបខាងកើតដែលជាប្រទេសសង្គមនិយមដែរ ប៉ុន្តែរដ្ឋធម្មនុញ្ញគេមានច្រើនមាត្រា ហើយបន្ទាប់ពីរដ្ឋធម្មនុញ្ញ ប្រទេសកុម្មុយនីស្តទាំងនោះមានបង្កើតច្បាប់ជាបន្តបន្ទាប់ដើម្បីគ្រប់គ្រងប្រទេសដូចជា ច្បាប់ព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី ច្បាប់ពន្ធដារ ច្បាប់គយ ច្បាប់ទីផ្សារ ។ល។ ប៉ុន្តែកម្ពុជាប្រជាធិបតេយ្យ តាមខ្ញុំស្រាវជ្រាវ រដ្ឋសភាប្រជុំបានតែម្តងគត់ គឺអនុម័តរដ្ឋធម្មនុញ្ញហើយចប់ គ្មានដែលប្រជុំពិភាក្សាធ្វើច្បាប់អ្វីទេ ។ ខ្មែរក្រហមគេធ្វើរដ្ឋធម្មនុញ្ញនេះ គ្រាន់តែសម្រាប់បង្គ្រប់ល័ក្ខខ័ណ្ឌឱ្យអង្គការសហប្រជាជាតិទទួលស្គាល់ប៉ុណ្ណោះ ។

***សំណួរ : បើច្បាប់ព្រហ្មទណ្ឌផ្ទុយនឹងរដ្ឋធម្មនុញ្ញ តើត្រូវផ្លាស់ប្តូរយ៉ាងណា ?***

ចម្លើយ : គឺត្រូវមានសំណើទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញតាមនីតិវិធី ។ ឧទាហរណ៍ មានមាត្រាណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញត្រូវធ្វើសំណើទៅក្រុមប្រឹក្សាធម្មនុញ្ញធ្វើការបកស្រាយ ហើយបើក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចយ៉ាងណា គឺបិទផ្លូវតវ៉ា ។

***សំណួរ : តើរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដូច ឬ ក៏ខុសពីច្បាប់អន្តរជាតិ ?***

ចម្លើយ : ពាក្យថា ច្បាប់អន្តរជាតិ មានន័យទូលាយណាស់ ប៉ុន្តែច្បាប់អន្តរជាតិកំពូល គឺសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ បន្ទាប់មកទៀតមានអនុសញ្ញា កតិកាសញ្ញាផ្សេងៗរបស់អង្គការសហប្រជាជាតិ ហើយអ្វីដែលប្រទេសយើងទទួលស្គាល់ គឺយើងបានសរសេរសង្ខេបចូលក្នុងរដ្ឋធម្មនុញ្ញយើងទាំងអស់ ។ ក្នុងប្រទេសប្រជាធិបតេយ្យនៅលើពិភពលោកប្រហែលជាមានតែប្រទេសកម្ពុជាយើងទេ ដែលក្លាហានសរសេរចូលក្នុងច្បាប់កំពូលរបស់ខ្លួន អំពីសិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជនពិការ សិទ្ធិជនជាតិភាគតិច សិទ្ធិក្នុងវប្បធម៌ សិទ្ធិក្នុងជំនឿសាសនា គឺសរសេរទាំងអស់ នេះដោយសារឆន្ទៈរបស់ប្រជារាស្ត្រខ្មែរតាមរយៈសភាធម្មនុញ្ញឆ្នាំ១៩៩៣ ។ ឆ្លងកាត់ពីឆ្នាំ១៩៧០ មកដល់ឆ្នាំ១៩៩១ មានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ខ្មែរស្គាល់រសជាតិទាំងអស់ អ៊ីចឹងហើយបានជាយើងសរសេរដាក់ក្នុងហ្នឹង ។ ខ្ញុំហ៊ានថា គ្មានមាត្រាណាមួយ ឃ្លាណាមួយក្នុងច្បាប់ខ្មែរ ដែលផ្ទុយពីគោលការណ៍រួមនៃច្បាប់អន្តរជាតិទេ ។

***សំណួរ : ហេតុអ្វីក៏រដ្ឋធម្មនុញ្ញយើងមិនបញ្ចូលសញ្ញាសាសនារបស់ព្រះពុទ្ធក្នុងរដ្ឋធម្មនុញ្ញ តើសញ្ញានេះកំណត់ដូចម្ដេច?***

ចម្លើយ : ពុទ្ធសាសនាយើងមានទង់ព្រះពុទ្ធសាសនា ដែលជាទង់មានលក្ខណៈអន្តរជាតិ ហើយបានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ អ៊ីចឹងមិនចាំបាច់មាននិមិត្តសញ្ញាទេ ។

***សំណួរ : តើអាចមានករណីណាមួយទេដែលរដ្ឋធម្មនុញ្ញត្រូវធ្វើការផ្លាស់ប្ដូររបបទាំងស្រុង លើកលែងករណីផ្លាស់ប្ដូររបប?***

ចម្លើយ : បើមានរដ្ឋប្រហារហើយ អ្វីៗគឺព្យួរអស់ហើយ គ្មាននរណាការពារទេ ។

***សំណួរ : តើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈល្អឥតខ្ចោះហើយឬនៅ? បើនៅមិនទាន់ល្អឥតខ្ចោះ តើមានកង្វះខាតត្រង់ចំណុចណាខ្លះ?***

ចម្លើយ : ក្នុងនាមក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋធម្មនុញ្ញដែលមាននៅក្នុងដៃអស់លោក លោកស្រីនេះ ខ្ញុំយល់ថាប៉ុណ្ណឹងវាគ្រប់គ្រាន់ហើយ ការពារប៉ុណ្ណឹងទៅសុខហើយ រីកចម្រើនហើយ ។ លុះត្រាតែវាវិវឌ្ឍទៅរកដំណាក់កាលមួយចាំបាច់ត្រូវធ្វើវិសោធនកម្ម យើងអាចធ្វើទៀត ប៉ុន្តែគោរពទៅតាមនីតិវិធីនៃការធ្វើវិសោធនកម្ម ហើយអ្វីដែលរដ្ឋធម្មនុញ្ញហាមកុំប៉ះពាល់ឱ្យសោះ ។

***សំណួរ : តើការប្រើពាក្យ "ថ្មី (មួយ)" មានន័យដូចម្ដេច? តើន័យខុសគ្នានឹង "ថ្មី" ឬ "ថ្មី (ពីរ)" យ៉ាងដូចម្ដេច?***

ចម្លើយ : សូមជម្រាបថា បញ្ហានេះគឺពិបាកណាស់ ។ របៀបដាក់លេខរៀងមាត្រានេះ គឺយករដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ជាគោល ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មកដល់ឆ្នាំ១៩៧០ មានធ្វើវិសោធនកម្មចំនួន ១២លើក ។ បើកាលណាឃើញមាត្រា ហើយមានពាក្យថ្មីនៅបន្ត ឧទាហរណ៍មាត្រា ២០ថ្មី នេះមានន័យថាមាត្រានេះបានកែលើកទីមួយហើយ ។ ប្រសិនបើគេដាក់ពាក្យមាត្រាថ្មី (មួយ) គឺមានន័យថាមាត្រានោះបានធ្វើការកែប្រែពីរដងហើយ ។ ប៉ុន្តែបើគេដាក់មាត្រាថ្មី ហើយបើករង្វង់ក្រចកយោងលើមាត្រាចាស់ អាហ្នឹងគឺមាត្រាចាស់ទាំងស្រុងតាំងពីឆ្នាំ១៩៩៣ ប្ដូរតែលេខទេ ពីព្រោះយើងបង្កើតជំពូកព្រឹទ្ធសភាមួយកាលពីឆ្នាំ១៩៩៩ ធ្វើឱ្យប្ដូរលេខរៀងមាត្រាទាំងអស់ ។ ប៉ុន្តែបើគេដាក់មាត្រាថ្មី (ពីរ) គឺមានន័យថាមាត្រានោះបានធ្វើការកែប្រែយ៉ាងតិចពី ២ ទៅ ៣ ដង ។ ដូច្នេះត្រូវមើលទៅឧបសម្ព័ន្ធខាងក្រោយគេ នេះគឺជាវិធីសាស្ត្រក្នុងការដាក់លេខរៀងរដ្ឋធម្មនុញ្ញ ។

***សំណួរ : ការប្រើប្រាស់ពាក្យថ្មីនៅតាមមាត្រាដែលបានធ្វើវិសោធនកម្ម ការដាក់ពាក្យនេះហាក់ដូចជាបង្កឱ្យមានភាពច្របូកច្របល់ក្នុងការយោង ហើយនឹងនាំឱ្យមានកំហុសឆ្គង។ ប្រសិនបើមានការភ្លេចភ្លាំងនៅក្នុងការដាក់ពាក្យថ្មី តើក្រុមប្រឹក្សាធម្មនុញ្ញមានវិធីសាស្ត្រអ្វី ដើម្បីធ្វើឱ្យមានឯកភាពនៃមាត្រាដែលបានរៀបរាប់ក្នុងរដ្ឋធម្មនុញ្ញដែរឬទេ?***

ចម្លើយ : ច្បាប់ក៏ដោយ រដ្ឋធម្មនុញ្ញក៏ដោយ កាលណាធ្វើវិសោធនកម្ម វានឹងបណ្ដាលឱ្យមានការដាក់ពាក្យថា "ថ្មី" ហើយ ។ ម្យ៉ាងវិញទៀត ពាក្យថា "ថ្មី" នេះសំដៅទៅដល់ការកែលើកទី១ ហើយបើកែលើកទី២ គេដាក់ថា "ថ្មី(មួយ)" និងកែលើកទី៣ គេដាក់ថា "ថ្មី(ពីរ)" ។ នេះគឺជារបៀបរៀបលំដាប់មាត្រាដែលត្រូវបានគេធ្វើវិសោធនកម្ម ។ ប៉ុន្តែបញ្ហាលំបាកនឹងកើតមាននៅពេលដែលគេបង្កើតជំពូក និងមាត្រាថ្មី តួយ៉ាងដូចការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយបង្កើតឱ្យមានជំពូកថ្មីមួយស្ដីពីព្រឹទ្ធសភា និងជំពូកថ្មីមួយទៀតស្ដីពីសមាជរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីដោះស្រាយភាពជាប់គាំងខាងនយោបាយកាលពីឆ្នាំ១៩៩៨ ។ ដូច្នេះ ការដាក់លេខរៀងមាត្រានៃរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងវិញ ដោយផ្អែកតាមគោលការណ៍ណាមួយ ។ ទាក់ទងបញ្ហានេះ យើងបានដកស្រង់បទពិសោធន៍ដែលមានស្រាប់ជាមួយនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដែលត្រូវបានគេធ្វើវិសោធនកម្មចំនួន ១២ លើកនោះ ។ ម្យ៉ាងវិញទៀត បើទោះបីជាមានការខុសឆ្គងទៅនឹងការដាក់ពាក្យ "ថ្មី(មួយ)" ឬ "ថ្មី(ពីរ)" ក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញគ្មានសមត្ថកិច្ចទៅធ្វើការកែសម្រួលទេ ពីព្រោះការកែប្រែផ្នែកណាមួយ ឬ មាត្រាណាមួយនៃរដ្ឋធម្មនុញ្ញត្រូវឆ្លងកាត់នីតិវិធីច្បាប់ត្រឹមត្រូវដូចជាត្រូវអនុម័តច្បាប់ធម្មនុញ្ញមួយដើម្បីធ្វើកែប្រែពាក្យ "ថ្មី" នេះ ។

***សំណួរ : ហេតុអ្វីបានជាមានមាត្រា "ថ្មី" និង មាត្រាអត់មាន "ថ្មី" ?***

ចម្លើយ : មាត្រាដើមនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ អត់មានថ្មីទេ ដូចជាមាត្រា១ មាត្រា២ មាត្រា៣ ជាដើម ហើយចាប់ពីមាត្រា ១១ មានដាក់ពាក្យថា "ថ្មី" នៅពីក្រោយមាត្រានីមួយៗ ដោយសារតែមានការធ្វើវិសោធនកម្មបណ្ដាមាត្រាទាំងនោះ ហើយក៏ជាវិធីសាស្ត្រក្នុងការដាក់សម្គាល់ពីចំនួនដងនៃការធ្វើវិសោធនកម្មដែរ ។

***សំណួរ : មុននឹងបង្កើតរដ្ឋធម្មនុញ្ញ តើគេត្រូវយកចិត្តទុកដាក់ទៅលើកត្តាអ្វីខ្លះ? ដើម្បីកុំឱ្យរដ្ឋធម្មនុញ្ញបង្កើតហើយត្រូវឆ្លងកាត់ការធ្វើវិសោនកម្មច្រើនលើកច្រើនសារ ?***

ចម្លើយ : សូមជម្រាបជូនថា នៅក្នុងគណៈធិបតីនេះមានវត្តមានអតីតសមាជិកសភាធម្មនុញ្ញ ៣រូប គឺ ឯកឧត្តម **សឺន ស៊ូប៊ែរ្ដ៏** ឯកឧត្តម **ប៉ែន ថុល** ឯកឧត្តម **ឯក សំអុល** និងឯកឧត្តមម្នាក់ទៀតអវត្តមាន គឺឯកឧត្តម **ឈួរ លាងហួត**។ នៅឆ្នាំ១៩៩៣ សមាជិកសភាធម្មនុញ្ញ ១២០រូប មានពេលវេលាតែ ៣ខែគត់ ក្នុងការសរសេររដ្ឋធម្មនុញ្ញ ។ ដូច្នេះទទួលស្គាល់ថា ការសរសេរនេះមិនគ្រប់ជ្រុងជ្រោយទេ ព្រោះស្ថានការណ៍ និងតម្រូវការរបស់ជាតិ ប្រជាជនវិវឌ្ឍទៅមុខជានិច្ច ។ កត្តានេះហើយដែលតម្រូវឱ្យមានការកែប្រែ ។

***សំណួរ : រដ្ឋធម្មនុញ្ញក្នុងរបបខ្មែរក្រហម ជនណា ឬ ក្រុមណាអ្នកបង្កើត និង សម្រេចបម្រើនយោបាយឱ្យជននោះអនុវត្តទៅលើជនណា ព្រោះរបបនេះមានរដ្ឋធម្មនុញ្ញឃោរឃៅណាស់ ?***

ចម្លើយ : យើងអាចចោទជាសំណួរទៅថ្នាក់ដឹកនាំសម័យនោះដែលមានលោក នួន ជា លោក អៀង សារី ជាដើម ដែលជាមនុស្សសកម្មក្នុងការបង្កើតរដ្ឋធម្មនុញ្ញសម័យនោះ តែយើងអាចនិយាយលេងបានថា ការគ្រប់គ្រងប្រទេសជាតិនាសម័យនោះជារបបមួយដែលអាចចាត់ទុកថាជារបបឆ្វេងផុតលេខ ព្រោះមុនរបប ប៉ុល ពត គឺរបបកុម្មុយនីស្តមានជាយូរមកហើយ ហើយអ្នកគ្រប់គ្រងសម័យនោះក៏ជាមនុស្សមិនធម្មតាដែរ គឺជាបញ្ញាជនដែលមកពីបរទេសទៀតផង ។

***សំណួរ : តើរដ្ឋធម្មនុញ្ញថ្មីចេញដោយអ្នកណាខ្លះ ?***

ចម្លើយ : សំណួរនេះប្រហែលជាសំដៅទៅលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ហើយ ។ សូមជម្រាបថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នេះចេញមកពីការបោះឆ្នោតជាសកល ដែលរៀបចំឡើងដោយអ៊ុនតាក់ ក្រោយពេលដែលសភាធម្មនុញ្ញបានអនុម័តរដ្ឋធម្មនុញ្ញនេះរួចមក ។ នៅពេលដែលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញបានក្លាយជារដ្ឋសភានៃអាណត្តិទី១ ឆ្នាំ១៩៩៣-១៩៩៨ ។

***សំណួរ : ហេតុអ្វីបានជាប្រទេសនីមួយៗចាំបាច់ត្រូវបង្កើតឱ្យមានរដ្ឋធម្មនុញ្ញ ?***

ចម្លើយ : ដូចឯកឧត្តម **ម៉ែន ថុល** ជម្រាបជូនហើយ គឺរដ្ឋធម្មនុញ្ញមានតួនាទីសំខាន់ណាស់នៅក្នុងរដ្ឋមួយ ។ វាមានតួនាទីសម្រាប់គ្រប់គ្រងរដ្ឋ ជាច្បាប់គោលដែលកំណត់អំពីរបបនយោបាយ និងការបែងចែកអំណាចនយោបាយ ។ ប្រសិនបើគ្មានរដ្ឋធម្មនុញ្ញទេ ប្រៀបបាននឹងប្រទេសគ្មានច្បាប់ ពីព្រោះរដ្ឋធម្មនុញ្ញជាច្បាប់មេសម្រាប់បង្កើតច្បាប់ផ្សេងៗទៀត ប៉ុន្តែនៅអាស៊ីអាគ្នេយ៍យើងមានប្រទេសប្រ៊ុយណេជាប្រទេសគ្មានរដ្ឋធម្មនុញ្ញ ប៉ុន្តែគេរស់នៅបានសុខដែរ ។ ជាទូទៅ គឺប្រទេសទាំងឡាយតែងតែមានរដ្ឋធម្មនុញ្ញជាច្បាប់កំពូល ។

***សំណួរ : តើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីច្បាប់ស្តីពីអំពើពុករលួយដែរឬទេ ? ហើយកាត់ទោសដូចម្តេចចំពោះអ្នកប្រព្រឹត្ត ?***

ចម្លើយ : ក្នុងរដ្ឋធម្មនុញ្ញឥតមានចែងទេ ប៉ុន្តែមានចែងក្នុងច្បាប់ដោយឡែកមួយ ស្តីពីការបង្ការនិងប្រឆាំងអំពើពុករលួយ ។ យើងបានដឹងគ្រប់គ្នាហើយថា រាជរដ្ឋាភិបាលបានសន្យាថានឹងធ្វើបន្ទាប់ពីក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើ ។

***សំណួរ : តើនៅមុនឆ្នាំ១៩៤៧ កម្ពុជាមានច្បាប់កំពូល ឬ ប្រព័ន្ធច្បាប់របស់ខ្លួនដែរឬទេ? បើមានតើអ្វីខ្លះ?***

ចម្លើយ : នៅស្រុកណាក៏គេមានច្បាប់របស់ខ្លួនដែរ ហើយសូម្បីតែប្រពៃណីទំនៀមទម្លាប់ក៏ជាច្បាប់ដែរ ។ នៅក្រោមការដឹកនាំរបស់ព្រះបាទជ័យវរ្ម័នទី៧ លោកបានរៀបចំឱ្យមានជាក្បួនច្បាប់ជាច្រើនដែលយើងអាចឃើញស្រាប់នៅតាមជញ្ជាំងប្រាសាទនានា ហើយលុះមកដល់ឆ្នាំ១៨២០ ក្នុងរាជ្យស្តេចជ័យជេដ្ឋា ទ្រង់បានរៀបចំច្បាប់ដឹកនាំ

ស្រុកទេសជាថ្មី ដែលគេហៅថា ក្រមស្រុក ឬ ច្បាប់ស្រុក ប៉ុន្តែគេមិនហៅថា រដ្ឋធម្មនុញ្ញនោះទេ ។ ក្រោយពីបារាំងចូលស្រុក នៅឆ្នាំ១៩១២ នៅក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ យើងមានក្រមព្រហ្មទណ្ឌដំបូង ហើយក្រោយមកទៀតយើងមានក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីនៅឆ្នាំ១៩២០ ពោលគឺមុនមានរដ្ឋធម្មនុញ្ញទៅទៀត ។ ប្រព័ន្ធតុលាការសម្រាប់ដោះស្រាយវិវាទមានពីរ ក្នុងនោះមួយសម្រាប់ដោះស្រាយវិវាទរវាងខ្មែរនិងខ្មែរ និង មួយទៀតសម្រាប់ដោះស្រាយវិវាទរវាងខ្មែរនិងបារាំង ហើយកាលនោះយើងមានតែសាលាដំបូងទេ ចំណែកឯសាលាឧទ្ធរណ៍គឺនៅព្រៃនគរឯណោះ ។ ដូច្នេះ បើយើងនិយាយពីរដ្ឋធម្មនុញ្ញ គឺយើងទើបមានចាប់ពីឆ្នាំ១៩៤៧ នោះទេ ។ យើងអាចមើលព្រឹត្តិការណ៍ឡើងវិញថា យើងបានទទួលឯករាជ្យឆ្នាំ១៩៥៣ មុនឆ្នាំនេះយើងមានស្តេចសោយរាជ្យ ។ ខ្ញុំសូមលើកយកព្រះមហាក្សត្រ **នរោត្តម សីហនុ** ដែលលោកសោយរាជ្យពីឆ្នាំ១៩៤១មក គឺយើងបានអនុម័តរួចហើយហៅថា ព្រះរាជបញ្ញត្តិរបស់ព្រះមហាក្សត្រជាលាយលក្ខណ៍អក្សរ ។ បើយើងមើលទៅមុននេះទៀត យើងអាចមើលឃើញច្បាប់ក្រមង៉ុយ ច្បាប់ទំនៀមទំលាប់ផ្សេងៗ ។ បើតាមឯកសារយើងអាចដឹងទៀតថា ច្បាប់មានតាំងពីជំនាន់ **ព្រះបាទជ័យវរ្ម័នទី២** មានលើសិលាចារឹក ដែលយើងចាត់ទុកជាព្រះរាជបញ្ញត្តិ ។

**សំណួរ** : *តើច្បាប់រដ្ឋធម្មនុញ្ញ និង រដ្ឋធម្មនុញ្ញខុសគ្នាដូចម្តេច ?*

ចម្លើយ : ច្បាប់រដ្ឋធម្មនុញ្ញប្រហែលជាចង់និយាយច្បាប់ធម្មនុញ្ញទេមើលទៅ ហើយរដ្ឋធម្មនុញ្ញខុសគ្នាដូចម្តេច? ខ្ញុំសូមឆ្លើយត្រួសៗ ច្បាប់ធម្មនុញ្ញកាលណាមិនទាន់ប្រកាសឱ្យប្រើទេ គឺមិនទាន់ជារដ្ឋធម្មនុញ្ញទេ នៅជាច្បាប់ធម្មនុញ្ញ ។ សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះគេស្នើធ្វើវិសោធនកម្ម ឬ ធ្វើបន្ថែម ហើយនៅពេលឆ្លងកាត់រដ្ឋសភាព្រឹទ្ធសភាចប់ហើយ ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ នៅពេលនោះហើយដែលច្បាប់ធម្មនុញ្ញនឹងក្លាយជារដ្ឋធម្មនុញ្ញ ។

**សំណួរ** : *តើលក្ខណៈជាសារវ័ន្តនៃរដ្ឋធម្មនុញ្ញមានន័យដូចម្តេច ?*

ចម្លើយ : យើងមើលគ្រោងធំៗនៃរដ្ឋធម្មនុញ្ញ ។ ដើម្បីគ្រប់គ្រងរដ្ឋ គ្រប់គ្រងប្រទេស គឺមានស្ថាប័នព្រះមហាក្សត្រ ចំពោះព្រះរាជាណាចក្រ ស្ថាប័នប្រធានាធិបតី ចំពោះរបបសាធារណរដ្ឋ ។ អំណាចប្រធានាធិបតីអំណាចព្រះមហាក្សត្រ ហើយការកំណត់សិទ្ធិ ជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ កំណត់ពីសមត្ថកិច្ចនៃអំណាចទាំងបីគឺនីតិបញ្ញត្តិ នីតិប្រតិបត្តិ និង អំណាចតុលាការ ។ ទន្ទឹមនឹងនោះមានកំណត់ពីនិយ័តករ ឬ អ្នកធានាការពារការគោរពរដ្ឋធម្មនុញ្ញ ។ ក្នុងរបបប្រជាធិបតេយ្យសេរីដូចយើង ជាទូទៅ គឺមានស្ថាប័នហៅថា ក្រុមប្រឹក្សាធម្មនុញ្ញ តុលាការធម្មនុញ្ញ ឬ តុលាការកំពូល និង អាចមានស្ថាប័នឈ្មោះប្លែកពីនេះ ។

**សំណួរ** : *តើការបង្កើតរដ្ឋធម្មនុញ្ញធ្វើដោយរបៀបណា ?*

ចម្លើយ : តាមប្រវត្តិសាស្ត្រកម្ពុជា ដើម្បីបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧បាន នៅក្នុងឆ្នាំ១៩៤៦ ព្រះមហាក្សត្រទ្រង់បានរៀបចំឱ្យមានការបោះឆ្នោតមួយ ដើម្បីបង្កើតសភាធម្មនុញ្ញ ដែលជាស្ថាប័នទទួលភារកិច្ចសរសេររដ្ឋធម្មនុញ្ញ

និង អនុម័តរដ្ឋធម្មនុញ្ញ។ នៅសម័យសាធារណរដ្ឋខ្មែរ របៀបបង្កើតរដ្ឋធម្មនុញ្ញនៅសម័យនោះ គឺគេបង្កើតគណៈកម្មការ តាក់តែង និង អនុម័តដោយប្រជាមតិ ចំណែកឯនៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺសរសេរហើយស្រេច ដោយគ្រាន់តែយកទៅឆ្លងសន្និបាតកម្មាភិបាលទូទាំងប្រទេស ។

ករណីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩៣ គឺគេបោះឆ្នោត ដើម្បីរើសតែសភាធម្មនុញ្ញទេ ដើម្បីសរសេរដ្ឋធម្មនុញ្ញ ហើយក្រោយរដ្ឋធម្មនុញ្ញចូលជាធរមាន សភាធម្មនុញ្ញក្លាយទៅជារដ្ឋសភា ។

*សំណួរ : តើរដ្ឋធម្មនុញ្ញបានរៀបរៀងដោយឈរលើគោលការណ៍ចំណុចប៉ុន្មានយ៉ាង?*

ចម្លើយ : រដ្ឋធម្មនុញ្ញត្រូវបានរៀបរៀងឡើងដោយឈរលើគោលការណ៍ច្រើន ក្នុងនោះមានការកំណត់អំណាច (អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ) ការកំណត់អំពីប្រមុខរដ្ឋ (តើអ្នកណាដែលត្រូវធ្វើជាប្រមុខរដ្ឋ ជាប្រធានាធិបតី ឬក៏ជាព្រះមហាក្សត្រ? ហើយមានអំណាចយ៉ាងដូចម្តេច?) ជាដើម ។

*សំណួរ : យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ យើងមិនឃើញមានមាត្រាណាមួយបញ្ជាក់ឱ្យច្បាស់ពីពាក្យ "សេវាសាធារណៈ" ឡើយ ហេតុអ្វី? សូមអនុញ្ញាតពន្យល់ពាក្យនេះដោយអធ្យាស្រ័យ ។*

ចម្លើយ : រដ្ឋធម្មនុញ្ញ ពុំមានប្រើពាក្យ "សេវាសាធារណៈ" នេះមែន ប៉ុន្តែអត្ថបទច្បាប់ ឋានានុក្រមលំដាប់ទី២ មានចែងពីពាក្យនេះ ។

*សំណួរ : តើហេតុអ្វីបានជាមានការធ្វើវិសោធនកម្មជាច្រើនដងលើរដ្ឋធម្មនុញ្ញខ្មែរ? អាចនាំឱ្យមានផលអវិជ្ជមានដល់ប្រទេសដែរឬទេ?*

ចម្លើយ : វាកើតចេញពីការចាំបាច់ និង ភាពទាល់ច្រកខាងនយោបាយ ដូច្នេះពុំមាននាំមកនូវផលអវិជ្ជមានដល់ប្រទេសជាតិទេ ពីព្រោះក្រោយពីវិសោធនកម្មរដ្ឋធម្មនុញ្ញហើយ យើងអាចយកមកដោះស្រាយបញ្ហាដោយជោគជ័យ។

*សំណួរ : តើពាក្យថា "វាក្យខ័ណ្ឌ" និង "កថាខ័ណ្ឌ" នៅក្នុងច្បាប់ មានន័យដូចគ្នា ឬខុសគ្នា ?*

ចម្លើយ : ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មានប្រើពាក្យវាក្យខ័ណ្ឌខ្លះ និងកថាខ័ណ្ឌខ្លះ ដូច្នេះនៅមិនទាន់ច្បាស់ ។ ចំណែករដ្ឋធម្មនុញ្ញសម័យ លន់ នល់ ក៏នៅមិនទាន់ច្បាស់នៅឡើយដែរ ។ សៀវភៅដែលបោះពុម្ពដោយលោក អេង សុត ឆ្នាំ១៩៦៤ មានពន្យល់ពីពាក្យ វាក្យខ័ណ្ឌ និង កថាខ័ណ្ឌច្បាស់ ។ ការប្រើប្រាស់ពាក្យនេះក្នុងរដ្ឋធម្មនុញ្ញសព្វថ្ងៃ គឺច្បាស់លាស់ហើយ ដោយកថាខ័ណ្ឌ មានទម្រង់ធំជាង ក្នុងនោះមានចែកជាវាក្យខ័ណ្ឌ ហើយចែកជាផ្នែក។

*សំណួរ : ហេតុអ្វីបានជាក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាយើង ឬ ប្រទេសខ្លះមានរដ្ឋសភា និង ព្រឹទ្ធសភា ?*

ចម្លើយ : ករណីនេះ គឺអាស្រ័យទៅលើរដ្ឋធម្មនុញ្ញ ថាតើគួរជ្រើសយករបបសភាមួយ ឬ របបសភាពីរ។ បណ្តាប្រទេសសង្គមនិយមទាំងអស់មានសភាតែមួយទេ ចំណែកឯនៅក្នុងតំបន់យើងវិញ មានតែប្រទេសសិង្ហបុរីទេដែលមានសភាតែមួយ គឺរដ្ឋសភានេះឯង ។ ចំណែកឯកម្ពុជាវិញ ក្រោយពីឈានដល់ព្រមព្រៀងបញ្ចប់វិបត្តិ

នយោបាយឆ្នាំ១៩៩៨មក នៅឆ្នាំ១៩៩៩ បណ្តាគណបក្សក្នុងរាជរដ្ឋាភិបាលចំរុះបានឯកភាពគ្នាបង្កើតឱ្យមាន ព្រឹទ្ធសភាមួយទៀត ដែលធ្វើឱ្យយើងទទួលយករបបសភាពីរថ្នាក់នេះ ។ យើងក៏មានប្រវត្តិសាស្ត្ររបស់យើង ពីព្រោះ តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ យើងមាន "ក្រុមប្រឹក្សាព្រះរាជអាណាចក្រ" រួចទៅហើយ ។

*សំណួរ : សូមបំភ្លឺការចុច "." នៅក្រោយមាត្រានីមួយៗ ។ សូមពន្យល់មាត្រា ៧១ ?*

ចម្លើយ : ការចុចនេះ គឺយើងយកតាមរចនាបថពីមុនៗមក ជាពិសេសសូមពិនិត្យមើលរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ។

*សំណួរ : តើច្បាប់ធម្មនុញ្ញបង្កើតនេះ យកតាមប្រព័ន្ធច្បាប់ណានៅលើពិភពលោក?*

ចម្លើយ : ប្រទេសយើងធ្លាប់ធ្វើខ្ញុំបារាំងតាំងពីឆ្នាំ១៨៦៣មក ដូច្នេះយើងយកតាមប្រព័ន្ធច្បាប់បារាំង ។ តាម រយៈការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ប្រព័ន្ធច្បាប់របស់យើងយកតាមប្រព័ន្ធច្បាប់បារាំង ឬប្រព័ន្ធច្បាប់ រ៉ូម៉ាណូហ្សែកម៉ានិក ដែលសំដៅទៅលើប្រព័ន្ធច្បាប់ចំរុះរវាងច្បាប់បារាំង និង ច្បាប់អាឡឺម៉ង់ ។

*សំណួរ : រដ្ឋធម្មនុញ្ញត្រូវបានបង្កើតដោយសភាធម្មនុញ្ញ ឬ តាមរយៈប្រជាមតិ ចំពោះរដ្ឋធម្មនុញ្ញសរសេរ ។ តើហេតុអ្វីបានជារដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ ត្រូវបានគេចាត់ទុកជាការបង្កើតរដ្ឋធម្មនុញ្ញថ្មី បើពុំមានសភាធម្មនុញ្ញ ឬ ប្រជាមតិផងនោះ ?*

ចម្លើយ : ជាសម័យកាលនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាមាន រដ្ឋសភារបស់ខ្លួន ហើយចាប់ផ្តើមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ គឺអនុវត្តទៅតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិត កម្ពុជា ។

*សំណួរ : ការរៀបចំខ្លឹមសារមាត្រាបង្កើតរដ្ឋធម្មនុញ្ញឆ្លងកាត់ច្រើនរបបគ្រប់គ្រងក្នុងប្រទេសកម្ពុជា តើមានការកែសម្រួលដកស្រង់ខ្លឹមសារតាមគ្នាធ្វើដោយខ្សែក ឬចងក្រងដោយវិធីណា ? ក្រុមប្រឹក្សាធម្មនុញ្ញ អាចពិនិត្យធម្មនុញ្ញភាពសន្ធិសញ្ញាអន្តរជាតិដែរឬទេ ?*

ចម្លើយ : ការរៀបចំសរសេររដ្ឋធម្មនុញ្ញ ជារួម គឺអ្នកច្បាប់ និងអ្នកច្បាប់ដែលជំនាញខាងច្បាប់រដ្ឋធម្មនុញ្ញ ។ ដូច្នេះ ការយល់ដឹង និងបទពិសោធន៍ក្នុងការសរសេរ មិនអាចយកមនុស្សគ្មានចំណេះដឹង ឬគ្មានសញ្ញាណខាងផ្នែក ច្បាប់មកសរសេរបានទេ ហើយការសរសេរនេះត្រូវមានការសម្រេចចិត្តខាងនយោបាយឱ្យបានច្បាស់លាស់រួចជា ស្រេច ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនមានសមត្ថកិច្ចពិនិត្យធម្មនុញ្ញភាពសន្ធិសញ្ញាអន្តរជាតិទេ ។

*សំណួរ : នៅក្នុងរដ្ឋសភាមានគណបក្សរាជរដ្ឋាភិបាល និង គណបក្សប្រឆាំង ពាក្យថា គណបក្សប្រឆាំង គឺតស៊ូស្លាប់រស់ដើម្បីឱ្យទទួលបានជោគជ័យ ហេតុនេះពាក្យនេះធ្វើឱ្យមានភាពតានតឹងដល់សភាពការណ៍នយោបាយ សុំស្នើប្តូរមកជាគណបក្សជំទាស់បានដែរឬទេ ?*

ចម្លើយ : ពាក្យនេះជាពាក្យរបស់អ្នកនយោបាយ ឬប្រជាជនប្រើ ដូច្នេះពិបាកឆ្លើយណាស់ ចង់ហៅអ្វីក៏បានដែរ ប៉ុន្តែគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យមិនមែនដល់ថ្នាក់តស៊ូស្លាប់រស់ទេ ។

***សំណួរ : ច្បាប់អស្សាមិករណ៍ តាមការសែតប្រែថា (ការរឹបអូសអចលនទ្រព្យ) នេះគឺជាពាក្យមួយដែលបង្កើតនូវការភ័យព្រួយរបស់ប្រជាពលរដ្ឋបំផុត សុំបកស្រាយថាតើគោលដៅសំណួមពរនៃច្បាប់នេះយ៉ាងណា ?***

ចម្លើយ : រដ្ឋត្រូវការចាំបាច់ដកហូតអចលនទ្រព្យមួយចំនួនសម្រាប់សំណង់សាធារណៈ ពីព្រោះការងារខាងមុខយើងត្រូវធ្វើផ្លូវថ្នល់ ផ្លូវរទេះភ្លើង ។ល។ អ៊ីចឹងហើយអាចមានការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាជន ប៉ុន្តែរដ្ឋធម្មនុញ្ញបានចែងថាទាល់តែមានសំណងសមស្រប ។

***សំណួរ : ប្រសិនបើរាជរដ្ឋាភិបាលបានធ្វើរំលោភលើរដ្ឋធម្មនុញ្ញ តើគួរឱ្យយោធាប្រើកម្លាំងទ័ពដើម្បីដោះស្រាយក្នុងករណីច្បាប់ត្រូវបានស្ថិតនៅក្រោមអំណាចរាជរដ្ឋាភិបាល?***

ចម្លើយ : សូមជម្រាបថា យោធាពុំមានអំណាចផ្ទាល់ខ្លួនក្នុងការដោះស្រាយនៅពេលដែលរាជរដ្ឋាភិបាលរំលោភទៅលើរដ្ឋធម្មនុញ្ញទេ ពីព្រោះកាតព្វកិច្ចការពារជាតិរបស់យោធាត្រូវធ្វើឡើងតាមច្បាប់កំណត់ហើយព្រះមហាក្សត្រ ទ្រង់គង់ជាអគ្គមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ដូច្នេះបើគ្មានបញ្ជាពីព្រះមហាក្សត្រទេ យោធាមិនអាចប្រើកម្លាំងដោះស្រាយវិបត្តិណាមួយបានឡើយ ។

***សំណួរ : សូមឯកឧត្តមពន្យល់អំពីជម្លោះព្រំដែននៅខេត្តព្រះវិហារដែលកើតមានកន្លងមក ហេតុអ្វីដូចជាមិនឃើញមានការប្រជុំដេញដោលពីសភាទាំងពីរថ្នាក់ រួមទាំងមិនឃើញមានអាជ្ញាបញ្ជាពីព្រះមហាក្សត្រផងដែរ ឃើញតែសកម្មភាពរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ ដែលខុសពីភាគីថៃ ។ តើជម្លោះនេះ រាជរដ្ឋាភិបាលចាត់ទុកថាជាសង្គ្រាមដែរឬទេ ? តើជម្លោះដល់កម្រិតណាទើបសភាទាំងពីរថ្នាក់ធ្វើការប្រជុំអនុម័ត ?***

ចម្លើយ : ចំពោះសំណួរដែលសួរថា តើជម្លោះនេះរាជរដ្ឋាភិបាលចាត់ទុកថាជាសង្គ្រាមដែរឬទេ ? សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** លោកបានប្រកាសហើយកាលពីពេលថ្មីៗនេះ គឺមានការដកកំលាំងទ័ពមកវិញជាបណ្តើរៗហើយ នេះមិនមែនជាសង្គ្រាមទេ វាគ្រាន់តែជាការប៉ះទង្គិចគ្នាដោយអាវុធ ។ កន្លងមកមានបាតុភាពបុគ្គលនឹងបុគ្គលនៅតាមព្រំដែនទេ ដោយឡែករដ្ឋ និង រដ្ឋមិនទាន់ឈានដល់ការប្រកាសធ្វើសង្គ្រាមទេ ។ យើងនៅតែប្រកាន់យកការដោះស្រាយដោយសន្តិវិធី ឥឡូវយើងបានផលជាវិជ្ជមានបណ្តើរៗហើយ ហើយក៏មិនទាន់ដល់ថ្នាក់សភាទាំងពីរប្រជុំប្រកាសសង្គ្រាមដែរ ។ ប្រទេសយើងជួបប្រទះនូវសង្គ្រាមច្រើនហើយ យើងចង់បានសុខសន្តិភាពជូនជាតិជូនប្រជាពលរដ្ឋ ។

***សំណួរ : រូបសញ្ញាជាតិ ពិនិត្យមើលទៅហាក់បីដូចខុសៗគ្នាមូលហេតុអ្វី ?***

ចម្លើយ : ជារឿងអ្នកសិល្បៈគេគូរ គេរចនា អ៊ីចឹងហើយវាល្អៀងគ្នាបន្តិចបន្តួច ប៉ុន្តែន័យនៅតែដដែលទេ។

**សំណួរ** : *រដ្ឋធម្មនុញ្ញ ១៩៧៥-១៩៧៦ ជារបស់កម្ពុជាប្រជាធិបតេយ្យហៅ ខ្មែរក្រហមបើមានច្បាប់រដ្ឋធម្មនុញ្ញ បែបនេះហើយចុះហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សគ្រប់ជាតិសាសន៍ ។*

ចម្លើយ : រឿងទាក់ទងនឹងខ្មែរក្រហមនេះ ទុកចាំឱ្យតុលាការជាអ្នកសួរថា ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្សគ្រប់ជាតិសាសន៍ ? ហ្នឹងទាល់តែមេខ្មែរក្រហមឆ្លើយ ។

**សំណួរ** : *តើហេតុអ្វីបានជាប្រទេសកម្ពុជារបស់យើងមិនបានថែរក្សាទុករដ្ឋធម្មនុញ្ញពីជំនាន់មុនមកទល់សព្វថ្ងៃហើយបោះពុម្ពជូនប្រជាពលរដ្ឋបានដឹងផង ?*

ចម្លើយ : ប្រជាជនដឹងតែច្បាប់ណានៅជាធរមានបានហើយ ។

**សំណួរ** : *ហេតុអ្វីបានជាព្រះហស្តលេខា និង ព្រះរាជលញ្ជករ នរោត្តម សីហមុនី គ្មានស៊ីញ៉េ ?*

ចម្លើយ : មាន ។

**សំណួរ** : *តើព្រះរាជបច្ឆាញាតិព្រះបាទអង្គឌួងមាននៅសេសសល់ដែរឬទេ ?*

ចម្លើយ : មាននៅសល់ម្នាក់រស់នៅប្រទេសបារាំង ។

**សំណួរ** : *១-សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ។*

*២-សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមមហាក្សត្រ ខេមរាជនាសមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ។*

*តើមានន័យដូចម្តេច ?*

ចម្លើយ : ព្រះបរមងារពិបាកពន្យល់ណាស់ ទាល់តែអាចារ្យព្រះបរមរាជវាំង ។

**សំណួរ** : *ឧត្តមសេនីយ៍ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៧០ តើជាការខុសច្បាប់ដែរឬទេ ?*

ចម្លើយ : ជាការខុសច្បាប់ ។ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៩៣ សភា-ធម្មនុញ្ញបានធ្វើសេចក្តីសម្រេចចិត្តមួយប្រកាសបដិសេធរដ្ឋប្រហាររបស់ លន់ នល់ ថាជាការខុសច្បាប់ ហើយបានរៀបចំថ្វាយព្រះរាជតំណែងដល់សម្តេចឪវិញ ជាព្រះប្រមុខរដ្ឋនៃកម្ពុជាជាផ្លូវច្បាប់ ។ នេះជាឆន្ទៈរបស់ប្រជារាស្ត្រខ្មែរ ។

**សំណួរ** : *១-ទង់ជាតិខ្មែរតំណាងជាតិ តើពណ៌នីមួយៗមានន័យដូចម្តេចខ្លះ ?*

*២-គ្រួសារមួយរស់នៅជាមួយគ្នាមិនបាន តើស្ត្រីជាប្រពន្ធមានសិទ្ធិសុំលែងលះបានឬទេ ? តើទ្រព្យសម្បត្តិកើតក្រោយអាពាហ៍ពិពាហ៍មានសិទ្ធិទទួលបានប៉ុន្មានភាគរយ ?*

ចម្លើយ : ១-ទង់ជាតិយើងចាប់ផ្តើមប្រើនៅក្នុងឆ្នាំ១៩៤៨ សម័យអាណានិគម មុនឆ្នាំ១៩៤៨ ពណ៌មានប៉ុណ្ណឹងដែរ តែរឹមខៀវព័ទ្ធជុំវិញ ។ ពណ៌ក្រហម តំណាងសេចក្តីអង់អាចក្លាហាន ពណ៌ខៀវតំណាងឱ្យទឹកដី ពណ៌ស

តំណាងឱ្យភាពបរិសុទ្ធ ។ ចំណែកឯបទភ្លេងនគររាជ និពន្ធដោយសម្តេចព្រះសង្ឃរាជ ជួន ណាត នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៤១ ហើយពេលដែលព្រះបាទនរោត្តម សីហនុ ឡើងគ្រងរាជជាព្រះមហាក្សត្រ គឺព្រះអង្គទៅក្រាបបង្គំទូលសម្តេចព្រះសង្ឃរាជឱ្យតែងបទនេះ ។ បទនគររាជ ជាបទចំរៀងស្នេហាជាតិ កើតឡើងនៅឆ្នាំ១៩៤១ កាលនោះពិបាកណាស់ព្រះមហាក្សត្រឡើងគ្រងរាជសម្បត្តិ ប៉ុន្តែនៅក្រោមនឹមអាណានិគមបារាំង ហើយព្រះបាទនរោត្តម សីហនុ បានចេញព្រះរាជក្រមដំបូងលេខ ១ PR ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ១៩៤១ ឱ្យប្រើបទភ្លេងជាតិនគររាជទូទាំងប្រទេស ។

២-លែងបាន ព្រោះវាជាកិច្ចសន្យា ប៉ុន្តែកាលចុះ៧ជាមួយមេឃុំ ដល់ទៅសុំលុបវិញត្រូវលុបនៅតុលាការ ។ គេសាកល្បងផ្សះផ្សាសម្របសម្រួល ព្រោះកាលណាបាក់មែកបាក់ធាងវាមិនជារឿងល្អទេ ពិសេសអ្នកដែលទទួលខ្លាំងជាងគេ គឺអារម្មណ៍របស់កូន ។ ទ្រព្យសម្បត្តិកើតក្រោយអាពាហ៍ពិពាហ៍ គឺជាទ្រព្យរួម មានសិទ្ធិទទួលបានប៉ុន្មានទុកឱ្យតុលាការជាអ្នកកាត់សេចក្តី ។

***សំណួរ : ១-តើការបោះបង្គោលព្រំដែនរវាងភាគីកម្ពុជា និង វៀតណាម មានអ្នកជំនាញអន្តរជាតិចូលរួមធ្វើជាសាក្សីផង ឬ ក៏ធ្វើតែទ្វេភាគី ប្រសិនបើពុំត្រឹមត្រូវតាមមាត្រដ្ឋានផែនទីឆ្នាំ៦៣-៦៩ តើត្រូវធ្វើដូចម្តេច ?***

ចម្លើយ : ការបោះបង្គោលព្រំដែនរវាងប្រទេសនិងប្រទេស រវាងរដ្ឋនិងរដ្ឋ គឺជាការព្រមព្រៀងរវាងរដ្ឋាភិបាលទាំងពីរប្រទេស មិនចាំបាច់មានអ្នកទីបីទេ ព្រោះជារដ្ឋឯករាជ្យ អធិបតេយ្យ ។

***សំណួរ : ខ្ញុំមានដីស្រែ ឬដីចំការប្រមាណជា ១០ហិចតា ធ្វើជារៀងរាល់ឆ្នាំតាំងពីដូនតាមក ប៉ុន្តែក្រោយមករាជរដ្ឋាភិបាលបានប្រគល់ដីទៅឱ្យក្រុមហ៊ុនមួយដែលមានទីតាំងក្នុងប្លុកដីស្រែចំការរបស់ខ្ញុំបាទ នៅក្នុងក្រុមហ៊ុននោះសម្រាប់អភិវឌ្ឍដំណាំឧស្សាហកម្ម តើក្រុមហ៊ុនត្រូវចេញសំណងថ្លៃដីឱ្យខ្ញុំបាទដោយរបៀបណា ?***

ចម្លើយ : តើមានឯកសារត្រឹមត្រូវតាមផ្លូវច្បាប់ថាដីហ្នឹងជាដីរបស់យើងទេ បើមានជារឿងមួយ បើគ្មានជារឿងមួយទៀត ខ្ញុំនិយាយអីចឹងព្រោះសំណួរនេះជារឿងជាក់ស្តែងក្នុងមូលដ្ឋាន ។

***សំណួរ : ១-តើសង្គ្រាមលោកលើកទី១ ប្រទេសណាជាមួយប្រទេសណា នៅឆ្នាំណា ?***

***២-តើសង្គ្រាមលោកលើកទី២ ប្រទេសណាជាមួយប្រទេសណា នៅឆ្នាំណា ?***

***៣-តើសង្គ្រាមលោកទាំងពីរលើកមានផលប៉ះពាល់ដល់កម្ពុជាអ្វីខ្លះ ?***

ចម្លើយ : ១-ឆ្នាំ១៩១៤-១៩១៨ កើតនៅអឺរ៉ុបខាងលិច ។ តាមអ្នកវិទ្យាសាស្ត្រនយោបាយ គេនិយាយថាជាសង្គ្រាមរវាងចក្រពត្តិ និង ចក្រពត្តិ ដើម្បីចែកដីអាណានិគមគ្នាឡើងវិញ ។

២-ឆ្នាំ១៩៣៩-១៩៤៥ ដូចគ្នានឹងសង្គ្រាមលោកលើកទី១ដែរ ដើម្បីផលប្រយោជន៍ និង ដណ្តើមដីអាណានិគមគ្នា ។

៣-សង្គ្រាមលោកលើកទី១ កងទ័ពឥណ្ឌូចិនក្នុងនោះមានខ្មែរដែរ ទៅជួយច្បាំងដល់ប្រទេសបារាំង ។ សង្គ្រាមលោកលើកទី២ ក៏មានទាហានខ្មែរទៅជួយច្បាំងបារាំងដែរ ។ ខ្មែរយើងវេទនាណាស់ក្នុងសង្គ្រាមលោកលើកទី២ អត់សាប៊ូដុស អត់ក្រណាត់ស្លៀក ខ្លះស្លៀកបាវឆ្នូតខៀវ អេះចេញចៃពីស្បែក ។ល។

***សំណួរ : សូមពន្យល់ពាក្យ "វាក្យខណ្ឌ" ?***

ចម្លើយ : វាក្យខណ្ឌ ជាចន្លោះដែលលាតសន្ធឹងពីចំណុចបញ្ចប់ឃ្លាមួយ រហូតដល់ដើមបន្ទាត់ និង ចន្លោះប្រវែងដែលគេកំណត់រឿងនៅដើមបន្ទាត់បន្ទាប់ទៀត ។

***សំណួរ : តើច្បាប់ប្រឆាំងអំពើពុករលួយចេញនៅពេលណា ? ព្រោះសព្វថ្ងៃក្នុងអង្គភាពកងទ័ព នគរបាល PM មេកាត់លុយក្នុង១ខែ ២ម៉ឺនទៅ៣ម៉ឺនរៀល ។***

ចម្លើយ : ចូលជាធរមានរួចហើយៗបង្កើតបានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយរួចហើយដែរ ។

***សំណួរ : តើច្បាប់រដ្ឋធម្មនុញ្ញមានលក្ខណៈគ្រប់គ្រាន់ពេញលេញក្នុងការគ្រប់គ្រងរដ្ឋឬទេ ? ព្រោះអ្វី ? បើមិនគ្រប់គ្រាន់គេត្រូវធ្វើអ្វីបន្ថែមទៀត ?***

ចម្លើយ : រដ្ឋធម្មនុញ្ញ គ្រាន់តែជាច្បាប់គោលរបស់ប្រទេស ក្នុងការកំណត់អំពីរបបនយោបាយ អំណាច ការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារ ជំនឿ ។ល។ សួរថាគ្រប់គ្រាន់ទេ? គ្រប់គ្រាន់នៅក្នុងកាលៈទេសៈណាមួយដែលកកើត គឺគ្រប់គ្រាន់ ប៉ុន្តែយើងត្រូវដឹងថា សង្គមមានការវិវឌ្ឍរីកចម្រើនទៅតាមការវិវឌ្ឍរីកចម្រើនរបស់ពិភពលោកដែរ ។ ប្រទេសនីមួយៗមានទំនាក់ទំនងគ្នា ស្ថិតនៅក្នុងសហគមន៍អន្តរជាតិ ពិសេសចាប់ពីពេលមានអង្គការសហប្រជាជាតិ យើងអាចនិយាយថា ប្រទេសណាក៏ជាសមាជិកអង្គការសហប្រជាជាតិដែរ ។ ដូច្នេះ កាលណាពិភពលោកវិវឌ្ឍរីកចម្រើន ប្រទេសជាតិរីកចម្រើន ពេលនោះហើយបើកាលណាមានភាពចាំបាច់ត្រូវដោះស្រាយអ្វីមួយឱ្យស្របនឹងការរីកចម្រើន គេចាំបាច់ត្រូវរៀបចំធ្វើការកែប្រែ ឬបន្ថែម។ ដោយសារការវិវឌ្ឍនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដល់កម្រិតដែលត្រូវធ្វើការកែប្រែហើយត្រូវតែធ្វើការកែប្រែ ដូចជាការកែប្រែពីប្រព័ន្ធអនុម័តបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា បោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល ឬទម្លាក់រាជរដ្ឋាភិបាលកាលពីឆ្នាំ១៩៩៣ សរសេរសុទ្ធតែ ២/៣ ទាំងអស់ ពីព្រោះពេលនោះទាមទារឱ្យខ្មែររួបរួមគ្នាស្រុះស្រួលគ្នា។ ដោយសារមានការវិវឌ្ឍន៍ នៅឆ្នាំ២០០៦ ទាមទារឱ្យមានការកែប្រែពីសំឡេងអនុម័តបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា ឬបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល ប្តូរពីសំឡេង ២/៣ មកសំឡេងភាគច្រើនដាច់ខាត ។

***សំណួរ : ១-តើស្របនឹងរដ្ឋធម្មនុញ្ញមានន័យដូចម្តេច ?***

***២-តើអធម្មនុញ្ញភាព ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មានន័យដូចម្តេច ?***

ចម្លើយ : ១-ពាក្យថា ស្របនឹងរដ្ឋធម្មនុញ្ញ គឺស្របទាំងអក្ខរាវិរុទ្ធ ស្របទាំងអត្ថន័យ ។ អក្ខរាវិរុទ្ធ និងអត្ថន័យនៅក្នុងសៀវភៅរដ្ឋធម្មនុញ្ញសរសេរយ៉ាងម៉េច សុំឱ្យសរសេរតាម។ ឧទាហរណ៍ ក្នុងអំណាចនីតិប្បញ្ញត្តិ មានរដ្ឋសភា

និងព្រឹទ្ធសភា ហើយបើអ្នកណាប្ដូរឈ្មោះរដ្ឋសភាទៅជាសភាជាតិ ហ្នឹងគឺមិនស្របនឹងរដ្ឋធម្មនុញ្ញហើយ។ រដ្ឋសភាគឺរដ្ឋសភា មានអ្នកខ្លះថាសភាជាតិ ហ្នឹងផ្ទុយពីរដ្ឋធម្មនុញ្ញហើយ ដូច្នេះយើងដែលជាអ្នកគោរពរដ្ឋធម្មនុញ្ញ ទាំងភាសានិយាយ ទាំងភាសាសរសេរ គឺសរសេរឱ្យដូចពាក្យច្បាប់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ដូចជាពាក្យ រាជរដ្ឋាភិបាលគណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដល់ពេលយើងសរសេរដាក់ថា រដ្ឋាភិបាលកម្ពុជា ហ្នឹងផ្ទុយនឹងរដ្ឋធម្មនុញ្ញហើយ ។

២-អធម្មនុញ្ញភាព ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ មានន័យថា ឱ្យតែខុសពីអ្វីដែលមាននៅក្នុងសៀវភៅរដ្ឋធម្មនុញ្ញ គឺមិនស្របហើយ ។ ពាក្យថា ត្រួតពិនិត្យធម្មនុញ្ញភាព គឺត្រួតពិនិត្យតាំងពីអក្ខរាវិរុទ្ធ ច្បាប់ និង ខ្លឹមសារ ។